# ត្រពាំងបិសាច
# ព្រះសង្ឃនៅភ្នំកូយ៉ា

របស់និពន្ធ អ៊ីស៊ូមី គ្យោកា

បកប្រែសំរួលដោយ ប៉ែន សេដ្ឋារិន



夜叉ヶ池 & 高野聖　泉鏡花 作　ペン・セタリン 訳

# រឿង ត្រពាំងបិសាច YASHAGA IKÉ

របស់អ្នកនិពន្ធជប៉ុន អ៊ីស៊ុមី គ្យោកា (IZUMI KYOKA)

បកប្រែដោយ ឃ៊ីន សេដ្ឋារិន

ដោយមានជំនួយពី ម៉ាជិជិម៉ា តូមីអ៊ុជិ

ជូនស្នាដៃនេះ ជាពិសេសចំពោះសាស្ត្រាចារ្យ នួន កន

ដែលស្រឡាញ់ ល្ខោន និង សិល្បៈ ស្មើជីវិតលោក ។

ប.ស

## កំណត់អ្នកបកប្រែ

ខ្ញុំបានសាកល្បងបកប្រែរឿងដ៏ប្រកបទៅដោយទេពកោសល្យនេះ ដើម្បីជូនជាពិសេសចំពោះលោកសាស្ត្រាចារ្យ នួន កន នៅពេលដែលដឹងថា លោកមានជំងឺ.ដើម្បីលើកទឹកចិត្តលោកដែលកំពុងតែប្រយុទ្ធនឹងជំងឺ ។ ផ្ទុយទៅវិញនៅពេលដែលលោកបានអានសំណៅរឿងនេះ លោកបានផ្ដល់យោបល់ឱ្យខ្ញុំរៀបចំការបោះពុម្ព ដើម្បីជូនបងប្អូនរួមជាតិយើង បានក្រេបជញ្ជក់នូវសោភ័ណភាពអក្សរសិល្ប៍នៃអ្នកនិពន្ធជប៉ុន ដែលប្រកបទៅដោយទេពកោសល្យ ដ៏ខ្ពស់ស្ទើរតែពុំអាចស្មានបាននេះ ហើយលោកព្រមទាំងចំណាយពេលនៅពេលដែលលោកកំពុងតែមានការលំបាកទាំងគ្រប់. សរសេរអារម្ភកថាសំរាប់រឿងទាំងពីរដើម្បីឱ្យជនជាតិខ្មែររួមជាតិអាចចាប់អត្ថន័យនិងអត្ថរសបានស្រួលផង ។ ចំពោះរឿងត្រពាំងបិសាច.ខ្ញុំជឿថាបងប្អូនខ្មែរយើងអាចស្វែងយល់ចាប់នូវអត្ថន័យបានឆាប់ជាងរឿងព្រះសង្ឃនៅភ្នំកូយ៉ា នៅពេលបានអានអារម្ភកថាបន្ថែមផងដែរ ។ប្រធានបទនៃរឿងត្រពាំងបិសាចគឺ "កិច្ចសន្យា" ។ ឯរឿងព្រះសង្ឃនៅភ្នំកូយ៉ាវិញគឺសេចក្ដីណែនាំអំពីជីវិតសុទ្ធសាធ ។

លោកសាស្ត្រាចារ្យ នួន កន បានពន្យល់នៅក្នុងអារម្ភកថានៃរឿងព្រះសង្ឃនៅភ្នំកូយ៉ាថា.ភារៈរក្សាខ្លួនអោយនៅជាសង្ឃពេញលក្ខណៈមួយអង្គជាផ្លូវមួយតឹងតែងយូរយារ ហើយប្រកបដោយឧបសគ្គរាប់មិនអស់ទេ ។ គេត្រូវការសេចក្ដីអំណត់ អត់ធ្មត់ តស៊ូនៅមុខបាតុភូតធម្មជាតិ និង បដិហារសព្វបែបយ៉ាងទាំងអស់ផងដែរ ។

ចំពោះរូបខ្ញុំដែលជាអ្នកបកប្រែ ខ្ញុំយល់ថារឿងនេះមិនចង់បង្ហាញតែចំពោះព្រះសង្ឃទេ. ប៉ុន្តែចង់បង្ហាញដល់មនុស្សជាតិគ្រប់រូប អំពីវិធីជំនះនឹងខ្លួនឯង.ដើម្បីនឹងធ្វើខ្លួនឱ្យទៅជាមនុស្សពេញលក្ខណៈមួយរូប។ ម្យ៉ាងទៀត អ្នកនិពន្ធចង់បង្ហាញថា បដិហារនានាដែលធ្វើអោយអារម្មណ៍មានអមង្គលស្រួលជំនះជាងបដិហារដែលធ្វើអោយអារម្មណ៍មានសេចក្ដីសុខ មានមង្គល។

រឿងទាំងពីរដែលខ្ញុំលើកមកបកប្រែលើកនេះ គឺជារឿងដែលបង្ហាញពីទម្ងន់នៃកិច្ចសន្យាផង ពីការជម្នះនឹងខ្លួនឯងផង ជូនកាលធ្វើអោយយើងមានសេចក្ដីអៀនខ្មាសក្នុងនាមជាមនុស្ស ដោយមនុស្សយើងឆាប់ភ្លេច. ហើយបែរជា "បិសាច "ឯនោះទៅវិញទេដែលខំគោរពខសន្យា។ (ពាក្យយាយមេដោះអាយុមួយម៉ឺនទៅរកម្ចាស់ក្សត្រីយ៍ដែលជាម្ចាស់របស់គាត់ : ព្រះនាងទ្រង់មិនអាចធ្វើដូច្នោះបានទេ។ ជួងនោះបើវាជាជួងធម្មតា ពុំមានបង្កប់នូវអត្ថន័យអ្វី ខ្ញុំម្ចាស់មិនបាច់ចាំព្រះរាជបញ្ជាទេ ខ្ញុំម្ចាស់នឹងចាប់ភើចវាជាមួយនឹងដៃដ៏សំគមរបស់ខ្ញុំម្ចាស់. នឹងម្រាមដៃខ្ញុំម្ចាស់។ កុំសូម្បីតែជួងនោះទម្ងន់ត្រឹមតែ ២០០គីឡូ. ទោះជាប៉ុន្មានតោន. ក៏ខ្ញុំម្ចាស់កំទេចដែរ។ "ប៉ុន្តែទម្ងន់នោះជាទម្ងន់នៃពាក្យសន្យា" ។

ម្យ៉ាងទៀត អ្វីដែលខ្ញុំស្រឡាញ់ជាពិសេសចំពោះអក្សរសិល្បិ៍របស់អ៊ីស៊ីមីគ្យោកា គឺពាក្យពេចន៍ដ៏ថ្លៃថ្នូរ ពិរោះសឹងតែធ្វើអោយយើងដែលជាអ្នកអានស្រវឹងហើយចងចាំទុកក្នុងដួងចិត្តរហូត។ (តួយ៉ាងពាក្យសម្ដីរបស់ង៉ាតឹអិនទៅរកអ្នកភូមិដែលមកបង្ខំចាប់នាងយូរីយកទៅបូជាយញ្ញសុំទឹកភ្លៀងៈ "អើថា

ភ្លៀងនឹងធ្លាក់មកទៅចុះ.ពពកខ្មៅនឹងផុសចេញមកទៅចុះ. ប៉ុន្តែនៅពេលដែលឃើញសំណែនបូជាយញ្ញដ៏គួរឱ្យអាណិតហួសហេតុនៅលើខ្នងគោខ្មៅ. លោកច្បាស់ជាមិនអាចទ្រាំមើលបានទេ. ព្រះច្បាស់ជាសំរក់ទឹកភ្នែកយំមិនខាន ។ ព្រះច័ន្ទច្បាស់ជានឹងលាក់មុខលោកពីក្រោយពពក ។.... ត្រូវហើយស្រូវច្បាស់ជានឹងរស់. ប៉ុន្តែមនុស្សនៅតែអត់ឃ្លានអញ្ចឹង.ទឹកមានមែន.ប៉ុន្តែមនុស្សនៅតែស្រេកអញ្ចឹង") ។ បន្ទាប់មកយើងអាចប្រទះឃើញសោភ័ណភាពនៃឃ្លាប្រយោគរបស់គេ្យាកានៅសឹងតែគ្រប់ទីកន្លែងនៃអក្សរសិល្ប៍របស់លោក ។

សូមឧទ្ទិសប្រលោមលោកដ៏ពិសិដ្ឋនេះជូនអ្នកស្នេហាអក្សរសិល្ប៍ទាំងអស់ និងវិញ្ញាណខ័ន្ធសាស្ត្រាចារ្យ នួនកនដែលបានទទួលមរណភាពកាលពីថ្ងៃទី៣១ ខែមីនាឆ្នាំ២០០២ សូមអោយលោកបានដល់ព្រះនិព្វានកុំបីអាក់ខានឡើយ ។

សូមអរគុណលោកម៉ាជិជិម៉ាដែលបានពន្យល់ពាក្យពិបាកៗចាស់ៗបូរាណរបស់ជប៉ុន ក្នុងការបកប្រែនេះ និងក្រុមសូយ៉ា (SOYA)ដែលបានផ្តល់ឳកាសសំរាប់បោះពុម្ពផ្សាយសៀវភៅនេះ ។

តូក្យូ. ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០២

ប៉ែន សេដ្ឋារិន

អនុបណ្ឌិត គរុវិជ្ជា និង ចិត្តសាស្ត្រ

សាស្ត្រាចារ្យសាកលវិទ្យាល័យអូបិរីន (តូក្យូ)

# អារម្ភកថា

## ចំណាប់អារម្មណ៍របស់សាស្ត្រាចារ្យ នួន ភន
## ទៅលើរឿង ត្រពាំងបិសាច

នេះគឺជាលើកទីមួយហើយ ដែលខ្ញុំបានមកភពប្រសព្វ និងបានអាន ល្ខោននាដកម្មបុរាណជប៉ុន រឿង " ត្រពាំងបិសាច " របស់លោក Izumi Kyoka បកប្រែជាភាសាខ្មែរ ដោយនាង ប៉ែន សេដ្ឋារិន ។

ជាធម្មតា អារម្មណ៍ដំបូងដែលមាន គឺភាព "ចម្លែក" នៃរបៀបចងក្រងដំណើររឿង ។ តែលុះគេចូលដល់ជំរៅអក្សរសិល្ប៍បន្តិចទៅ គេឃើញថាការសន្ទនារបស់តួមានលំនាំប្រក្រតី ធម្មតា ដូចគេលឺរាល់ថ្ងៃឥតបង្ខំ ឥតជ្រើសរើស ទៅតាមដំណើរធម្មជាតិ ។ ខ្ញុំមិនអាចនិយាយថា ជាការសន្ទនាទៅតាមបែបបទធម្មជាតិនិយម (Naturalisme) នោះទេ ពីព្រោះថា គេរកគ្រឿះសោភ័ណភាពមកជួយយោងផង ។ ហើយលុះដល់យើងលំអិតរឿងបន្តិចទៅទៀតភ្លាមឡើង គេឃើញជួងដែលមានវត្តមានប្រចាំក្នុងភ្នែក.ក្នុងចិត្តគំនិតរបស់យើង។ បើតាមរឿងនិទានដែលគេនិយាយតៗគ្នាមកថា: "កាលពីព្រេងនាយមនុស្សបានច្បាំងជាមួយនឹងទឹក ។ នៅពេលដែលទឹកជំនេះ ហៀបនឹងវិនាសអន្តរធាន. លោកតាធុត្តង្គម្នាក់ឈ្មោះ**តៃឌៅ**ដែលជាម្ចាស់ស្រុកបានប្រើមហិទ្ធិរិទ្ធរបស់លោកចាប់ឃុំឃាំងពស់នាគរាជខ្ទប់ក្នុងបាតត្រពាំងបិសាច។

នាគរាជនិយាយថា គេសុខចិត្តរស់ក្នុងទីឃុំឃាំងចុះ អោយតែមនុស្ស សត្វបាន សុខសប្បាយ ចៀសផុតពីការលិចលង់ ការស្រុតព្រះធរណី ។ ប៉ុន្តែជាថ្នូរត្រូវ ធ្វើជួងមួយ ពាក់នៅនឹងចង្កេះភ្នំ ហើយត្រូវវាយមួយថ្ងៃបីដង ដើម្បីពញ្ញាក់គេ កុំអោយភ្លេចកិច្ចសន្យារបស់គេ ....។ ចំពោះគេជានាគ ជីវិតមនុស្សសត្វដែល រស់នៅលើលោកនេះ គ្មានតំលៃសំខាន់ទាល់តែសោះ ។ ប៉ុន្តែគេនឹងគោរពពាក្យ សន្យារបស់គេ មិនបំពានសម្បថរបស់គេទេ ។ តែសូមជួយធ្វើម៉េចកុំអោយ គេបំភ្លេចពាក្យសន្យា និងបំពានពាក្យសម្បថរបស់គេសោះឡើយ ពោលគឺមិន ត្រូវខ្ជីខ្ជា ក្នុងការវាយជួងជាដាច់ខាត ។ បើគេភ្លេចវាយម្តង មុខជាមាន ភ្លៀងធំ រន្ទះធំ ខ្យល់ព្យុះ ..... បន្ទាប់មក ទឹកត្រពាំងបិសាចនឹងពោរព្រៀប លិចលង់ភូមិស្រុក ហើយស្តេចនាគនឹងហក់ហោះស្លេវពាសវាលពាសកាលមួយ រំពេច...." ។

ហេតុដូច្នេះហើយបានជាជួងនេះ គេត្រូវតែវាយបីដងក្នុងមួយថ្ងៃខាន មិនបាន នៅម៉ោង៦ព្រឹកម្តង ម៉ោង៦ល្ងាចម្តង និង ម៉ោង២អាធាត្រម្តង ហើយ ហាមផ្តាច់មិនអោយនរណាគោះលេងផ្តេសផ្តាសទេ ។ ឃើញទេ ជួងនេះ ក្រៅពីអោយសញ្ញាម៉ោងពេល ជាជួង "សញ្ញាកិច្ចសន្យា" រវាងមនុស្សជាតិនៃ លោកនេះ ជាមួយនឹងសភាវៈផ្សេងមួយនាលោកឯនាយ ។

តាយ៉ាតាបេអ្នកវាយជួងអាយុ៧៩ឆ្នាំ។ គាត់នៅវាយជួងនេះ៥០ឆ្នាំ កន្លងមក គាត់មានជំនឿនេះស៊ប់សួន ទើបគាត់វាយជួងនេះមិនដែលខានមួយ ថ្ងៃណាឡើយ។

នៅពេលគាត់ឈឺជិតស្លាប់ គាត់គិតដល់រឿងមហន្តរាយដែលនឹងកើតដល់មនុស្សជាតិ កាលណាអត់ពីគាត់ទៅគ្មាននរណាវាយជួងជំនួស តាយ៉ាតាបេមិនអាចស្លាប់បិទភ្នែកជិតទេ ។ គាត់ប្រកាច់ស្លួឈាម ស្រែកថ្ងូរត្រលួចសំលេងគាត់ខ្សោយជាងសំលេងចង្រិតទៅទៀត។ សំលេងរបស់គាត់បានបន្លឺលាន់ពេញត្រចៀករបស់អាគីរ៉ាដូចជាសំលេងជួងអញ្ជឹង ។ ដោយអាណិតគាត់ពេក អាគីរ៉ាចង់អោយគាត់ស្លាប់ទៅដោយសំរួល សុខក្សេមក្សាន្ត ក៏បាននិយាយច្បាស់ៗថា "សូមលោកតាកុំបារម្ភ ខ្ញុំនឹងវាយជួងនេះជំនួសលោកតា " ។ ឮដូច្នេះលោកតាញញឹម លើកដៃសំពះ រួចក៏ចែកឋានទៅ ។ អាគីរ៉ានិយាយប្រាប់មិត្តង៉ាគីអិនថាខ្លួនមិនបាននឹកស្មានថា នឹងនៅវាយជួងនេះមួយជីវិតបែបនេះទេ ។ ត្រង់នេះយើងស្ទើរតែមិនអាចវាស់បាននូវទំហំចិត្តមនុស្សធម៌ ឬ ចិត្តមនុស្សជាតិ (Humanisme) របស់តាយ៉ាតាបេ និងខ្ពស់មួយកំរិតទៅទៀត គឺអាគីរ៉ា អ្នកមានដើមកំណើតនៅទីក្រុងតូក្យូ ជាព្រះអង្គម្ចាស់ម្នាក់ ដែលជាកូនប្រុសនៃត្រកូលហាឌីវ៉ារ៉ា សុខចិត្តលះបង់អ្វីៗ មកលាក់ខ្លួនទីនេះពាក់សក់សក្បុសវាយជួង ។ គេមកពីតូក្យូ ដើរពីស្រុកមួយទៅស្រុកមួយ ដើម្បីស្រង់យករឿងព្រេងពិរោះៗ មកប្រទះតាយ៉ាតាបេ ហើយប្រុងអោយគាត់ជូនទៅមើលត្រពាំងបិសាច ។ ស្រាប់តែខ្លួនឯងហ្នឹង ក៏ក្លាយជាតួអង្គម្នាក់នៃរឿងទៅ ។ យើងនិយាយម្យ៉ាងទៀតក៏បានថា អាគីរ៉ាក្លាយជា "តួនៅក្នុងតួ" ឬ "រឿងនៅក្នុងរឿង" (le théatre dans le théatre) ជារចនាបថល្ខោនម្យ៉ាង ដែលយើងធ្លាប់ប្រទះរួចមកហើយដែរ នៅក្នុងអក្សរសិល្ប៍នាដកម្មរបស់អ្នកនិពន្ធ **ពីរ៉ង់ដែលឡូ**

(Pirandello) ។ ឯងាតីអិនក៏ដូចគ្នានិង អាគីរ៉ាដែរ តែអាគីរ៉ានៅលើមួយកំរិត គឺថាអាគីរ៉ាវាទៅជាសាច់រឿងខ្លួនវាបាត់ទៅហើយ ។ ម្យ៉ាងទៀត ឃើញមានខុសគ្នាបន្តិច ត្រង់អាគីរ៉ាជាប់ចិត្តនៅទីនេះ ដោយសារស្នេហាយ៉ាងខ្លាំងទៅលើនារី "ព្រិលស" យូរី ។ ងាតីអិនហៅនាងយូរីថាជា "អាទិទេពស្រី "នៃភូមិនេះ។ នាងកើតនៅស្រុកព្រិលក៏មិនដឹង កញ្ចឹងក ខ្នង សដូចព្រិល ល្អអ៊ីម្ល៉េះ " ។ ដោយមិនដឹងខ្លួន ងាតីអិនប្រទាញនាងយូរី ទៅប្រដូចនឹងតួនាង "ព្រិលស" មួយទៀតក្នុងរឿង ដែលទីបញ្ចប់ នាងព្រិលសយូរី នឹងត្រូវស្លាប់ដូចគ្នា ក្នុងពិធីបូជាយញ្ញារួចហើយ នឹងរស់ឡើងវិញ "ក្នុងបាថកថា" មួយដ៏ជោគជ័យ ដើម្បីជិះនាគជាមួយអាគីរ៉ា ក្នុងជីវិត លោកឯនាយមួយទៀត ។

លក្ខណៈមួយទៀតនៃរឿងត្រពាំងបិសាច គឺតួមានលាយចម្រុះគ្នាគ្រប់ប្រភេទ តាំងពីមនុស្សធម្មតា រហូតដល់សត្វក្នុងទឹក (ដែលទាក់ទងទៅនឹងត្រពាំង) មានត្រីរស់ (ស្រកាប្រាក់), ត្រីអណ្តែង (ពាក់មួកប្រផេះ ចេះមួរឈើច្រត់នឹងស្រកី), មានក្តាម (មុខក្រហម មានរោមពេញខ្លួន ពាក់អាវក្រហម បៀមបារីស្លឹកសង្កែនៅចំហៀងមាត់លើកដង្កៀបទាំងពីរសំពះ ដើរចំហៀង លោតទៅកៀបកំភួនជើង"យោជូ" ដើម្បីរំដោះត្រីរស់) ត្រីអណ្តែងជាលោកសង្ឃអ្នកនាំសារស្នេហាពីព្រះអង្គម្ចាស់គូស្នេហ៍នាងព្រិលសទៅថ្វាយព្រះនាង។ ជូនយោជូពាក់ក៏ជាតួ ក្រៅពីនោះ (ក្នុងចំរៀង) គេឮមានតួខ្មោចភ្នែកមួយ ខ្មោចសក់សេះ ខ្មោចអណ្តើកមានជើងវែងៗ ពាក់ចានលើក្បាល ។ មានភេ យូហ៊ីជើងប្រាំបី ឆ្មាព្រៃកន្ទ្រងក្រហម ខ្មោចស្លឹកឬស្សី ខ្មោចកំសៀវ

ទឹក ឆ្កែចចក ឆ្កែព្រៃពោះកំប៉ោង ខ្មោចស្រីពាក់ឆ្នាំង បុរសស្រុកស្រែមុខស្មើ អត់ចេះញញឹម... សត្វដ៏ទៃទៀតមាន ខ្លា មាន ដំបូក ( ជាយក្សផ្សំផ្អើងក្នុងដំបូក លេខ ១៣) មានព្រលឹងស្រមោល ...... ។ តួមនុស្សក៏មានលាយគ្រប់ប្រភេទ ដែរ មានអ្នកភូមិ ( មេភូមិ, សភាភូមិ) គ្រូបឋមសិក្សា អ្នកតំណាងចៅអធិការ វត្ត អ្នកលេងចំបាប់ជីកគោខ្មៅ ... ។ តួបាថកថា ខាងលោកឯនាយមួយទៀត មានតួនាងព្រិលស តួយាយមេដោះ ( អាយុមួយម៉ឺនឆ្នាំ) តួភិលៀង ( ឈ្មោះ ស៊ីបាតី) កោះហៅសេនាមកប្រជុំ ( សេនាខ្លះពាក់ក្រោះ ខ្លះពាក់ក្បាលខ្មោច ដូចយក្សដើរយប់ ...) ។ លក្ខណៈទាំងនេះបង្ហាញនូវលក្ខណៈ "មនោគតិទូលំទូលាយ" ហើយមិនត្រឹមតែប៉ុណ្ណោះសោត សាច់រឿងត្រង់អន្លើនាងព្រិលស កោះសេនាមកប្រជុំ ចង់លាតបង្ហាញនូវសេចក្ដី មហ្មងរបស់ព្រះនាង ចង់សងសឹកមនុស្សជាតិវិញ ព្រោះកាលពីមុនថ្មីៗ ( ហើយដែលយើងបានដឹងតាមសំដីអាគីរ៉ា) ថា: "នាងព្រិលស ( ក៏ជាអ្នកភូមិនេះដែរ) ត្រូវអ្នកភូមិដដែលនេះ បង្ខំចាប់នាងសម្រាតអោយអាក្រាតនៅខ្លួនទទេ ចងផ្ដោបនាងលើខ្នងគោ ដើម្បីធ្វើពិធីបូជាយញ្ញ សុំទឹកភ្លៀង ។ ពេលនោះ ដោយសារសេចក្ដីអាម៉ាស់នឹងកំហឹង នាងក្រមុំអង្អែលច្រមុះគោយកស្មៅស្ងួតគរលើខ្នងវា ហើយយកថ្មកូតគ្នា បង្កាត់ភ្លើងដុត ហើយចង្អុលទៅភូមិ និយាយលួងលោមគោថា: "គោឯងត្រូវរត់ ទៅដុតអោយរលាយអស់ដើម្បីសងសឹកជីវិត ដែលមានតំលៃស្មើគ្នានោះមកវិញ" ។ ពេលនោះព្រៃភ្នំ នឹង ភូមិស្ថានទាំងមូលត្រូវធ្លាក់ទៅជាចំណីភ្លើងខ្ទេចខ្ទីគ្មានសល់ ។ តែក្នុងពេលឥឡូវនេះ យាយមេដោះក្ដីភិលៀងក្ដី អង្វរឃាត់នាងព្រោះ

សព្វថ្ងៃ មនុស្សគេនៅចាំពាក្យសន្យា និងពាក្យសម្បថ គេនៅឡើយដោយគេនៅវាយជួង មួយថ្ងៃបីដង ទៀងទាត់របស់គេ ។

ព្រះនាងព្រិលសអន្ទះសា ចង់បំផ្លាញជួង ឯយាយមេដោះឃាត់ទៀត ព្រោះខ្សែជួងក្ដី ចំណងក្ដីវានឹងដាច់ក្នុងពេលខាងមុខយ៉ាងខ្លី ទំរាំដល់ពេលនោះសូមអោយព្រះនាងទ្រាំបន្តិច ។ ព្រះនាងព្រិលសលើកដំបងដែកបញ្ឈរទៅលើដំបងដេញពន្លឺព្រេច១ ។ ពេលនោះគេឮចម្រៀងនាងយូរីពុះជ្រែកអន្ធការនៃរាត្រីខែភ្លឺ ។ នាងយូរីច្រៀងបំពេរ កូនតុក្កតាប្រុសអោយគេងដោយនាងនៅម្នាក់ឯងរលឹកប្ដីអាគីរ៉ាពេក ។ ពេលនោះអាគីរ៉ាជូនដំណើរង៉ាគីអិនទៅមើលត្រពាំងបិសាច ។ នាងព្រិលស ផ្ទៀងត្រចៀកស្ដាប់ បេះដូងឡើងរន្ធត់ស្រយ៉ង់ហើយនិយាយថា: "ឱ នៅពេលដែលព្រាត់ពីអ្នកដែលយើងស្រលាញ់ បើយើងច្រៀង យើងអាចបន្ធូរចិត្តយើងបានឬ ? ... ចុះប្ដីប្រពន្ធពីរនាក់នេះអីក៏ស្រលាញ់គ្នាម្ល៉េះ។ គួរអោយច្រណែន គួរអោយខ្លាញ់ ..." ។ ដូចយើងឃើញស្រាប់តួទាំងពីរ( នាងព្រិលសនឹងនាងយូរី) ចាប់ផ្ដើមមានចិត្តគំនិតរលាយចូលគ្នាហើយ។ ម្ល៉ោះហើយនាងទាំងពីរត្រូវតែមានភព្វវាសនាដូច១គ្នា ទទួលអនាគតជីវិត "បូជាយញ្ញ" ដូចគ្នា ព្រោះពេលនេះ តួទាំងពីរខិតរកគ្នាកាន់តែជិតឡើង១ហើយ ។

នៅពេលដដែលនោះ"សម្លេងទទូល "ក៏ទទូលអឹងកងឡើង គឺសម្លេងផ្អែលូ នៅឯទីឆ្ងាយ សម្លេងកុកឃំ នៅទីក្បែរ១ ។

នៅពេលដដែលនេះ អ្នកភូមិទ្រាំ នឹងសភាពរឹងរាំងលែងបាន ក៏នាំគ្នា

មកបង្ខំចាប់យកនាងយូរីទៅធ្វើពិធី "បូជាយញ្ញ" ដូចនាងព្រិលសកាលពីមុននោះដែរ ។ គេចាប់បង្ខំប្រាប់អោយនាងឡើងជិះគោខ្មៅដោយសំរូលទៅ ។ បើមិនដូច្នោះទេ គេនឹងយកពួរមកចងផ្តោបទៅនឹងគោ ។ គេគ្រាន់តែយកនាងទៅសន្ទឹងនៅកណ្តាលភ្នំ ដើម្បីបូជាចំពោះនាគរាជដែលនៅត្រពាំងបិសាចទេ ។ នាងក៏ដឹងហើយថា នៅពេលប្រាំងបែបនេះ គេតែងយកនារីស្អាតលើសគេនៅក្នុងភូមិ ទៅសម្រាតហើយបូជាយញ្ញ ។ គេមិនសំលាប់នាងទេ គេគ្រាន់តែចងនាងស្រាតលើខ្នងគោ គេដុតគោ កាប់ក្បាល នឹងកន្ទុយវាសែន ។ ឯសាច់វា អ្នកភូមិកាត់ផឹកស្រា រួចមួយសន្ទុះមក ពពកខ្មៅនឹងបង្អូរទឹកភ្លៀងមកជាប់ៗគ្នាក្នុងរយៈពេលបីថ្ងៃ ។ ទាំងអស់គ្នា កំពុងតែចងនាងយូរីលើខ្នងគោ ស្រាប់តែអាគីរ៉ាមកដល់ភ្លាម ។ អាគីរ៉ាឈរពាំងមុខផ្ទះរបស់ខ្លួនដោយក្លាហាន ហូតកណ្តៀវដែលស៊កនឹងចង្កេះ កាត់ខ្សែដែលចងយូរី លើកកណ្តៀវទៅមុខ ឈរសម្លក់អ្នកភូមិ រួចនិយាយស្ងប់ស្ងាត់ថា : "ពួកយើង ( អាគីរ៉ា នឹង ង៉ាគីអិន) ធ្វើដំណើរទៅត្រពាំងបិសាចបានដល់មួយភាគបីនៃ ដំណើរផ្លូវស្រាប់តែឮសំលេងបំពេរកូនល្ហើយៗ ។ សំលេងបំពេរកូននោះ ត្រូវនឹងពន្លឺខែដូចគេភ្ជាប់ទៅនឹងទឹកសន្សើមនៃផ្កានានា ហើយដូចជាគេត្បាញស្មៅទាំងឡាយអោយទៅជាគោមនៃកំរាលព្រំ អោយឃើញខៀវ ... " ។ ទាំងពីរនាក់នឹកមកផ្ទះទ្រាំលែងបាន ។ អាគីរ៉ាក៏ចេះតែនឹកមកនាងយូរី ... ។ ថាតែប៉ុណ្ណោះ ទៅអ្នកភូមិរួចហើយ អាគីរ៉ាទាញនាងមកក្រោយខ្នង ។ អ្នកភូមិរត់ស្រូចូលមក អាគីរ៉ាទប់ទល់ ។ អ្នកស្រុកដេញអាគីរ៉ាអោយចេញពីភូមិខ្លួនទទេ ។ គេគ្មានត្រូវការអ្នកវាយដូង

ទេ ។ គេគ្មានជឿជំនឿដែលថា បើខានវាយជួងម្តង ស្រុកភូមិនឹងប្រទេះនឹងមហន្តរាយមានការលិចលង់ធំមួយរំពេចនោះទេ ។ គេរាល់គ្នា "ចង់បានអាហ្នឹង" ។ អ្នកភូមិសម្រេចកញ្ញមករកចាប់បង្ខំនាងយូរីទៀត ។ តែអាគីរ៉ាមិនអាចអោយ "យូរីនាងទៅតែឯងបានទេ គេសន្យាថានឹងអៀវនាងដើរកាត់ព្រៃ..." ។ តែនាងយូរីខ្លួនឯងក្តី អាគីរ៉ាជាប្តីក្តីក៏ដឹងដែរ ថានាងយូរីនឹងទទួលភព្វវាសនាដូចនាងព្រិលសដែរ ។ នាងនឹងទទួលសេចក្តីស្លាប់ក្នុងពិធីបូជាយញ្ញណាមួយចៀសមិនរួច ។ អាគីរ៉ានិយាយទៅនាងថា : " យូរីចាំបងនៅផ្លូវបំបែកទៅឋានសួគ៌ " គឺនៅត្រង់ផ្លូវបំបែកទៅ "ឋានសួគ៌" នោះឯងដែលជីវិតនាងយូរីត្រូវផ្តាច់ផ្តិលដោយពិធី "បូជាយញ្ញ" បែបណាមួយដែលសាមញ្ញជនមិនអាចយល់និងដឹងបាន ។ ក្រោយមក អាគីរ៉ាទៅត្រកងបី សាកសពនាងយូរី ហើយនិយាយទៅកាន់ង៉ាគីអិនថា: "ខ្ញុំគិតថា មិនវាយជួងទេ ឯងយល់ដូចម្តេច?" ង៉ាគីអិនតបវិញថា: "កុំវាយ! កុំវាយ អាគីរ៉ា !..." ហាក់ដូចជាចង់និយាយថា "ធ្វើអោយសក្តិសមនឹងប្រភេទមនុស្ស ដែលមានវិញ្ញាណស្មារតីចងចាំខ្លីពេកឆាប់ភ្លេច "(la mémoire courte) ។ អាគីរ៉ា លើកកណ្តៀវកាត់ខ្សែជួង ជួងធ្លាក់ខ្ទរ... ពេលនោះដីរញ្ជួយកក្រើក.អាគីរ៉ាស្រែក " ពួកឯងមើលទៅត្រពាំងបិសាចហ្ន " មនុស្សពីរ បីនាក់ស្រវាឡើងរោងជួង ។ អាគីរ៉ាកាប់រុញទម្លាក់រួចហើយថា: រលកមកហើយ ង៉ាគីអិនក្រាប ។ អាគីរ៉ាអារកខ្លួនឯងនឹងកណ្តៀវរួចដួលដេកទៅលើដីស្លាប់តាមយូរី ។

ម្តងនេះគេឃើញ ទស្សនីយភាពបាថកថា គឺនាងព្រិលសដែលនិយាយ

ថា: ទន្លេថ្មីនេះ យើងអោយឈ្មោះថា ទន្លេជូង គឺជាព្រះរាជដំណាក់របស់ក្សត្រា ក្សត្រី អាគីរ៉ា-យូរី ក្នុងជីវិតថ្មី ជីវិតលោកឯនាយមួយទៀត ... គឺជីវិតបាថកថា រួចមកគេឃើញអ្នកទាំងពីរគឺ អាគីរ៉ា អោបក្បាលនាគរាជហោះហើរ នាងយូរី ជិះខាងកន្ទុយ អាវវែងរបស់នាងធ្លាក់ទៅក្នុងទឹក ។ គេញញឹមដាក់គ្នា ព្រះចន្ទ្រ រះភ្លឺចិញ្ចាច ង៉ាគីអិនឈរតែឯងលើរោងជូងខ្ពស់ត្រដែត ។

នាងព្រិលស ឈរលើដំបូលខ្ទមក្នុងពន្លឺចាំងខ្លាំងរួចក៏បាត់ស្រមោល ក្នុងអន្ធការ ។ រួចមកឃើញនាងឡើងទៅលើរោងជូង ឈរក្នុងពន្លឺរន្ទះដ៏ខ្លាំងក្លា នាងគ្រវីឈើច្រត់ដែកដាក់លើជូង ធ្វើអោយជូងឡើងញ័រហើយផ្អៀង ។ អ្នកភូមិស្រឡាំងកាំង ស្លន់ស្លោ មេដោះអាយុមួយម៉ឺន សេនា ទាំងឡាយក្រោក ឈរ កាប់សំលាប់អ្នកភូមិងាប់អស់ ។ ទឹកឡើងលិចលង់ អ្នកភូមិត្រូវត្រី ស៊ីគ្មានសល់ ។ ខ្យង កូនត្រី ក៏ខំស៊ីមនុស្សតាមរបៀបវាដែរ ។

ទស្សនីយភាពនាដកម្ម រឿងត្រពាំងបិសាចដែលសំបូរតួគ្រប់ប្រភេទ (មានតួមនុស្សធម្មតា - តួខ្មោចព្រាយ- តួសត្វ- តួមនុស្សក្នុងបាថកថា...) មានចំរៀង- មានទំនុកបំពេរ- មានប្រផ្នូលដែលចិត្តថ្លើមតួរលាយចូលគ្នា (រក ពន្យល់មិនបាន)- មានសំលេងគឹកកងទទួល "choeur" (សំលេងឆ្កែលូ- សំលេងកុក) ហើយនៅទីបញ្ចប់ ទស្សនីយភាពដ៏រុងរឿង បែបបាថកថា បង្ហាញ នូវជោគជ័យខាងប្រភពនាងព្រិលស (តួបាថកថាសុទ្ធសាធ) ផង នឹងខាងប្រភព អាគីរ៉ា-យូរី ផង... ប្រមូលផ្តុំគ្នាទាំងអស់មក អាចរាប់មកថាជាល្ខោននាដកម្ម "គ្រប់លក្ខណៈ" ឬល្ខោន "ពេញទី" (Théâtre total) ជាលំអពិសេស

និងជាសោភ័ណភាពរបស់ល្ខោន លោក Izumi Kyoka នេះហើយដែលល្ខោនអឺរ៉ុប (ជាពិសេសល្ខោនបារាំង) ទើបនឹងស្វះស្វែងចង់ធ្វើ ចង់បាន នឹងបញ្ចេញទស្សនៈព្រោងព្រាតនៅប៉ុន្មានទស្សវត្សចុងក្រោយថ្មីៗនេះទេ ។

**ន.ភ**

# រឿង ត្រពាំងបិសាច

# YASHAGA IKÉ

ព្យួរសម្លេងជួងសញ្ញាម៉ោង ៦ល្ងាច ពីភូមិដែលនៅចង្កេះភ្នំ មីគីនីដាគេ ។

- វាំងននឆាកបើក -

(ហាងីវ៉ារ៉ា អាគីរ៉ា ពេលនេះពាក់សក់ដាក់ពណិសក្បុស ឈរនៅលើរោងជួង មើលព្រះអាទិត្យអស្តង្គត ។ សសររោង ជួងមានវល្លិ៍វារពាក់ព័ន្ធ ហើយជណ្តើរចោតសំរាប់ឡើងមកកាន់រោងជួងមានស្លែកាន់ ជញ្ជាំងរោងមានស្មៅដុះ។ អាគីរ៉ា ចុះជណ្តើរមួយៗសំដៅទៅយូរី ដែលកំពុងលាងអង្ករនឹងទឹកស្ទឹងដ៏ស្អាតបែរខ្នងមករកខ្លួន។)

អាគីរ៉ា : ទឹកអ្វីក៏ស្អាត អីស្អាតហ្ន៎ ! មើលពេលណាក៏...ស្អាត...។

យូរី : ចាំ ! (នៅមាត់ទឹកនោះមានផ្កាអ៊ីរីសស្វាយ ២-៣ កំពុងរីកតូចៗ)

អាគីរ៉ា : ទឹកនេះស្អាតអីស្អាត ។ (ញញឹម)

យូរី : (ដៃស្ទាបជើងសក់ក្បែរគុម្ពត្រចៀក) ប៉ុន្តែឡើងសអស់ហើយលោកបង ។

អាគីរ៉ា : ចុះឱ្យធ្វើម៉េច បើអូនឯងទើបនឹងលាងអង្ករអញ្ចឹង ។ ... (ដាក់គូថអង្គុយលើភាន) អាណិតណាស់ម៉្ងៃៗធ្វើតែបាយបំរើបងខូចដៃអស់។ តស់បងជួយខ្លះឬ?

យូរី : អត់អីទេលោកបង ។

អាគីរ៉ា : ចិត្តថាចង់ជួយហើយ បងមើលពីនេះទៅឃើញយូរី ដែលកំពុងតែលាងអង្ករចេញមុខកំផ្លង់ផ្លង់តាមប្រឡោះផ្កាអ៊ីរីស... ស្រមោលអូន ដែលឆ្លុះទៅក្នុងទឹកឃើញរឹតតែស្អាត ។

យូរី : អូនអត់ដឹងទេ ។

អាគីរ៉ា : អ្នកណាដែលឃើញមនុស្សខឹងនឹងអ្នកដែលសរសើរខ្លួននោះ

យូរី : បងឡូកលេងឱ្យខ្ញុំហ្នឹង ។ លោកប្តីសូមបងកុំនៅកន្ទុយចង្ក្រានអញ្ចឹង ប្រញាប់អញ្ជើញទៅតុសរសេរវិញទៅ ។

អាគីរ៉ា : ហៅលោកប្តីអញ្ចឹង គេសើចស្លាប់ហើយ ខ្ញុំនេះឈ្មោះ ង៉ុងវ៉ៃជូង ។ ដឹងឬនៅអ្នកនាង? ឱ ! យូរី បងឃ្លានបាយចង់ដាច់ពោះ ទៅហើយ មានស៊ីញ៉ាំទេដាក់ឱ្យបងញ៉ាំបន្តិចមក ។ អំបាញ់មិញបង គិតថា បើគោងសំរាប់វាយជួងវាវែងល្មមតែច្រត់អី បងច្បាស់ជាច្រត់វាចុះ មកពីរោងជួងហើយ ។ និយាយទៅ ដឹងអញ្ចឹងបើជំទាល ពីលើ រោងជួង ឱ្យអូនធ្វើបាយទុកឱ្យហើយទៅមានអី ។

យូរី : ហ៊ឺះ ហ៊ឺះ ហ៊ឺះ តាំងនិយាយលេងទៀតហើយលោកបង ។ ... អូន រៀបចំជូនភ្លាមហ្នឹងហើយ ។

អាគីរ៉ា : ចុះអូន យូរី ទៅរៀនលេងសៀកពីអង្កាល់ទៀតហើយ បានជាអាច ជប់អង្ករដែលទើបតែនឹងលាងឱ្យទៅជាបាយភ្លាមនោះ?

យូរី : អត់ទេ អង្ករដែលលាងអំបាញ់មិញសំរាប់ដាំបាយ ស្អែកទេបង ។

អាគីរ៉ា : អញ្ចឹងទេ? នាងតូច យូរី បានសាំនឹងការងារមេផ្ទះហើយ តើនែ! នេះទើបចំជានារីគំរូ ។ បងធូរចិត្តហើយ ។ ធូរចិត្តហើយខកចិត្តកាន់ តែឃ្លានបាយឡើង ។

យូរី : ម៉េចអញ្ជើងបង? ... បន្លែក៏មានស្រាប់ចាំអូនអាំងទាជូនបងចូលចិត្តទាណាស់មិនអញ្ជើង? ចាំតែមួយភ្លែតទេឆ្អិនហើយ ។ ឃើញបងជ្រួលច្របល់បែបនេះ អ្នកក្រៅមើលមកគេសើចស្លាប់ហើយ ។

អាគីរ៉ា : (ងើបឡើងពីរាន) យីចុះបងទៅខ្លាចនរណាគេសើចយំធ្វើអ្វី ហ្ន៎ ! យូរី !

យូរី : ចាំ !

អាគីរ៉ា : នែ កាលបងគេងជាមួយអូនពេលព្រឹក

យូរី : អូនមិនដឹងទេ (អៀនញញឹមឱនមុខ)

អាគីរ៉ា : អាមូសរោមគំរង់វាមកញ៉ៅថ្លង់អីថ្លង់ ។ រកបំពក់ផ្សេងពីរានខាងក្រោយកំចាត់វាម្តង (បែរខ្នងទៅបន្ទប់ងើយមើលទៅភ្នំ) ។ ... ពពកដែលនៅជិតកំពូលភ្នំឡើងក្រហមច្រាល ហើយភ្នំមីគីនី ង៉ាតាគេឡើងក្រហមរងាលដូចភ្លើងឆេះ ។ ពីលិចតាំងពីក្យូតូ ដល់ជើងខាងកាង៉ាតាំងពីជូរភ្នំមីណូដែលឃើញព្រាល១ ឯឆ្ងាយនោះក្តី រុំព័ទ្ធទៅដោយអណ្តាតភ្លើងនៃរដូវប្រាំង ដូចជាគេអុជចន្លុះរាប់ម៉ឺនដើមតំរៀបគ្នាយ៉ាងនោះ។ ឮថារាលដាលដល់ទៅ " ត្រពាំងបិសាច " ទៅទៀតនោះ ហើយនៅចំពីលើទឹកត្រពាំងនោះសូម្បីតែផ្កាយព្រឹកក៏ឡើងពណ៌ក្រហមដែរ ។ ... ឱ្យតែយ៉ាងហ្នឹងប្រហែលជាគ្មានផ្លូវភ្លៀងទេអូន ...

យូរី : គេថាទឹកស្ទឹងយើងនេះ វាភ្ជាប់ទៅនឹង " ត្រពាំងបិសាច " ។ ទីនោះមានពស់នាគរាជរស់នៅ ។ ទឹកស្ទឹងដ៏ថ្លានេះ ដូចជាចេះតែស្ងួចទៅៗ ។ បងឃើញអញ្ចឹងដែរទេ? ឬក៏ឃើញតែអូនម្នាក់ហ៎ ! ប៉ុន្មានថ្ងៃនេះនៅឯភូមិនោះ អ្នកភូមិនាំគ្នាជ្រួលច្របល់ ។ ... ក្តៅខ្លាំងណាស់ផង ... លោកបងអូនបារម្ភណាស់ បងអត់ឃើអត់ចាប់អ្វីទេឬ? មករស់នៅស្រុកស្រែដាច់ស្រយាល គ្មានអ្វីពិសាឆ្ងាញ់បែបនេះ មិនដឹងជាពិបាកយ៉ាងណាទេ ។

អាគីរ៉ា : អូនទៅភ័យអ្វីបើគ្រាន់តែ ទឹកស្ទឹងឡើងស្ងួចនោះ ។ បងភ័យខ្លាចតែយូរី ស្គមទេតើ ខែប្រាំងនេះ ។ យូរី ហ្ន៎ ! អូនសាកស្ទាបផ្កាត្រកួននេះបន្តិចមើល ?

យូរី : ចាំ ស្ទាបធ្វើអីបង?

អាគីរ៉ា : អូនឃើញនៅលើផ្កា ឬ ស្លឹកមានតំណក់ទឹកទេ?

យូរី : ឱ ត្រជាក់ឱ្យស្រេប ! ដៃអូនទទឹកផង ត្រជាក់ប៉ុននេះទៅហើយ ផ្កានេះទទឹកជោកបង !

អាគីរ៉ា : មនុស្សគ្រប់គ្នានៅក្នុងលោកគេត្រូវការលុយ ។ ស្រែចំការក៏ត្រូវការម្ល៉ោះហើយត្រូវការទាំងទឹកភ្លៀង ទៀត ។ ចំពោះយើងពីរនាក់វិញដើម្បីរស់ទោះជាប្រាំងរាំង ១០០ថ្ងៃ ក៏យើងរស់ដែរ ។ មានតែទឹកសន្សើមប៉ុណ្ណោះគ្រប់គ្រាន់ហើយ ។ (បិទទ្វារដែលបែរទៅរកថ្មល់)

យូរី : បងមិនក្តៅទេឬ? បើកទៅក៏មិនអីដែរបង ថ្មើរនេះទៅហើយ គ្មាននរណាគេដើរកាត់ទេ ។

អាគីរ៉ា : ហ៊ែស ! អ្នកណាទៅភ័យអីនឹងមនុស្សនោះ?... ពេលយប់អញ្ចឹងបើបិទទ្វារបំពក់ផ្កាប់ទុកតែបន្តិចច្បាស់ជាចូរមូសច្រើន (ពេលនោះគេឃើញផ្សែងធូបមូសហុយ) ។

ង៉ាគីអិន ត្រូវថ្ងៃឡើងខ្ទៅពាក់មួកស ហាមអាវធំទំនងជាមនុស្សស្ងប់ស្ងាត់ ។ ស្ពាយសំពាយឆៀងពាក់ ស្បែកជើងសង្រែកចំបើងច្រត់ឆ័ត្រវែង ដូចឈើច្រត់ដើរចេញមក ឈរក្រោមរោងជួងមើលជួង ។)

ង៉ាគីអិន : ព្រឹកមិញ ពេលដើរកាត់ស្ពាន ឮជួងម៉ោង ៦ព្រឹក ឥឡូវនេះឮជួងម៉ោង ៦យប់ ។ ... (នាងយូរី ផ្ទេរអង្ករទៅដាក់ក្នុងកញ្ជ្រែង)

ង៉ាគីអិន : សួស្តី នាងខំធ្វើការណាស់តើ (និយាយទៅកាន់យូរី)

យូរី : ចាំ (មើលទៅង៉ាគីអិន)

ង៉ាគីអិន : តាមផ្លូវត្រង់ម្តុំព្រៃឬស្សីជិតស្រែ ... ពេលងងឹតព្រាលៗទៅហើយ អម្បាញ់ហ្នឹងខ្ញុំឮសូរជួង ។ តើជួងនេះឬ ដែលវាយប្រាប់ពេលវេលានោះនាង?

យូរី : ចាំ លោក ។

ង៉ាគីអិន : សម្លេងក៏មាំ ! ... យីធំសំបើមណាស់ទេតើជួងនេះ ។ តើខ្ញុំអាចឡើងទៅលើមើលបានទេនាង?

យូរី : (ឈរកណ្ដៀតកញ្ច្រែង) ចាំ សូមអញ្ជើញលោក។ ប៉ុន្តែសូមលោកមេត្តាកុំយកឈើច្រត់ទៅគោះវាលេង ណា៎ !

ង៉ាគីអិន : ខ្ញុំបាទមិនមែនកំពុងទិញឪឡឹកឯណានាង ឱ្យខ្ញុំបាទយកដៃទៅគោះលេងនោះ? (សើច)

យូរី : លោកប្រសប់និយាយលេងណាស់ ។ ... សូមទោស ជំរាបនេះមិនមែនបានន័យថា ខ្ញុំមើលឃើញលោកថា ជាមនុស្សចូលចិត្តលេងសើចទេ។ ប៉ុន្តែជួងនោះគេពុំអាចវាយឱ្យលើសពី ៣ដង គឺពេលព្រឹក ម៉ោង ៦ម្ដង ល្ងាចម៉ោង ៦ម្ដង និងម៉ោង ២ភ្លឺទេ ។ នាងខ្ញុំគិតថាវាជាការមិនសមរម្យ នឹងជំរាបដែរប៉ុន្តែ តោងតែជំរាប។ អញ្ជើញលោក សូមលោកអញ្ជើញឡើងទៅមើលចុះ (យូរី ដើរចូលតាម ច្រកដែលមានរបាំង ផ្កាត្រកួនវ័រពាក់ព័ន្ធលើ) ។

ង៉ាគីអិន : ឈប់សិននាង ខ្ញុំមិញថាទៅមើលជួង តែបានជាមាននិស្ស័យនិយាយជាមួយនាងហើយ ឱ្យខ្ញុំមេត្តាសុំទឹកតែ ឬ ទឹកក្ដៅមួយពែងទទួលទានផងបានទេ?

យូរី : មិនពិបាកទេ ខ្ញុំជូនបាន ។ សូមលោកអញ្ជើញមកអង្គុយឯនេះមក។

ង៉ាគីអិន : អរគុណ ។

យូរី : សូមលោកកុំប្រកាន់ណា៎ ផ្ទះខ្ញុំក្រខ្វក់ណាស់ ។

ង៉ាគីអិន : នេះមើលទៅក៏ដូចជាមិនមែនជាកុដិលោក ។ ព្រះវិហារនៅឆ្ងាយពីនេះឬនាង?

យូរី : ចាំ អត់ទេ ឆេះតាំងពីយូរយារណាស់មកហើយ ។ ពីមុនមកក៏អត់មានវត្តដែរលោក ។

ង៉ាគីអិន : អញ្ចឹងមានតែជួងទទេ ...

យូរី : ចាំ ។

ង៉ាគីអិន : ឱ មានតែជួងហ្នំ... និយាយអញ្ចឹង និយាយពីរឿងឪឡឹក (ដោះមួកអង្អែលក្បាលដែលទើបនឹងដុះសក់ប្រុយៗ ដែលដុះពីកោរ) នាងអត់មានត្រសក់ស្រូវអីទេឬនៅផ្ទះនេះ? - មើលទៅក៏មិនសមជាតៀមកាហ្វេ - (គ្រលៀសភ្នែកមើលជុំវិញ) (ទិដ្ឋភាពដ៏គួរឱ្យស្រណោះនៃផ្ទះ ដែលនៅដាច់ស្រយាលតែឯងពីភូមិដ្ឋានអ្នកស្រុក នាវេលាព្រះអាទិត្យហៀបអស្តង្គត ស្រមោលដែលឆ្លុះឱ្យឃើញពន្លឺភ្លើងចង្កៀងតាមទ្វារក្រដាសពីកូនបន្ទប់ដែលមានពិដានទាបប្រក់ស្បូវ)

ង៉ាគីអិន : ខ្ញុំមិនទាមទារ ដល់ទៅឱ្យនាងរៀបចំបាយទឹកឱ្យពិបាកទេ ប៉ុន្តែនិយាយឱ្យចំទៅចង់ដាក់អ្វីឱ្យចូលពោះណាស់អ្នកនាង ។

យូរី : (សើចខឹកៗ) នៅក្រោមទរទឹកខ្ញុំមានត្រាំផ្លែព័រទុកឱ្យត្រជាក់ ។ ចាំខ្ញុំយកមកជូនលោក ។ (យូរី ដើរទៅខាងក្រោយបង្កងផ្កាត្រកួន)

ង៉ាគីអិន : (លើកទឹកទទួលទានក្បៀកៗ រួចមកដកផ្តិតបក់ ហើយលើកទៅលើ) ឱ ! រីកហើយតើ ។ ល្អដូចមុខអ្នកនាងអញ្ចឹង ។

យូរី : ចាំ ? (សួរត្រលប់មកវិញ)

ង៉ាគីអិន : ទេៗដូចពណ៌សក់នាង ។

យូរី : ខ្ញុំចាស់ហើយមិនអាចនិយាយប្រដូចទៅនឹងផ្កាបានទេ ។ បើមានប្រសាសន៍ថា ដូចត្រីងៀត ឬ ត្រីឆ្អើរ ដូចជាសមរម្យជាង ។

ង៉ាគីអិន : នេះកូនកាំបិតនាង ! មកខ្ញុំចិត ! មិនគួរមកឱ្យនាងរំខានដូច្នេះទេ ។ អ្នកដំណើរដែលតែងជួបប្រទះនូវការពិបាកគ្រប់ជំពូក បើត្រឹមចិតផ្លែឈើប៉ុនៗហ្នឹង ខ្ញុំអាចចិតបាន ។ ឱ ត្រជាក់ជាងទឹកកកទៅទៀត ។ មើលតែគេកំពុងឈូសទឹកកកតែម្តង ។

យូរី : មើលទៅលោក ដូចជាសប្បាយនឹងការធ្វើដំណើរនេះណាស់ ។ តើលោក គិតអញ្ជើញទៅណា មកណាដែរ?

ង៉ាគីអិន : ខ្ញុំសូមជំរាបនាងថា ខ្ញុំនេះមិនមែនជាអ្នកដំណើរ ឬ អ្នកក្លាហានឆ្លងភ្នំ កាត់ព្រៃអ្វីទេ ។ ដូចនាងឃើញស្រាប់ខ្ញុំនេះជាគ្រូបង្រៀនធម្មតាឆ្លៀតឱកាសវិស្សមកាលរដូវក្តៅ ដើរសិក្សាមើលស្រុកមើលទេសគេតែប៉ុណ្ណោះ ។ ហើយឥឡូវនេះ ត្រូវធ្វើដំណើរទៅវិញហើយ ។ ខ្ញុំគិតថាធ្វើម៉េចឱ្យបានចេញដំណើរទៅដល់ភ្នំ គីណ្ហូតូងេ ឱ្យទាន់ពេលត្រជាក់ ។ ខ្ញុំឮល្បីថា នៅជើងភ្នំនោះមានកន្លែងល្អមួយឈ្មោះ ណាការ៉ាជី ផង ។ (លើកដៃបាំងភ្នែកមើលទៅភ្នំឆ្ងាយ) ម្យ៉ាងទៀតឮថានៅខ្នងភ្នំជាប់ភ្នំ គីណ្ហូតូងេ នេះមានតៀមកាហ្វេ ដែលមាននារីបំរើពាក់អៀមពណ៌ក្រហមឆេះ ។ មានបំណងចង់ទៅមើលទីនោះដែរ ទោះបីជាទីនោះមានទេព្តាអុតស៊ីមុខ កំពុងតែអង្គុយសោយតែក៏គួរតែទៅមើល ។ នឹកម្យ៉ាងទៀតថា បើបានជាមកដល់ទីនេះហើយ

យកល្អគួរឆ្លងកាត់ភ្នំ ដែលនៅជាប់នឹងភ្នំដែលមានតៀមកាហ្វេនោះ គឺយូណូតូងេ សិន សឹមមកទៅក្យូតូ ជាចុងក្រោយក៏ម្យ៉ាង ។

យូរី : តើលោកគិតទៅសំរាកឯណាយប់នេះ?

ង៉ាគីអិន : អ្នកនាងកុំសួរអីល្អជាង អី? ប្រយ័ត្នខ្ញុំបាទរំអុកសុំស្នាក់ពីរបីយប់ទៅវាពិបាកណាំ ! ហាស១ និយាយលេងទេនាងកុំបារម្ភអី ។ មើលខ្ញុំសូមសួរដូចជាឆោតទៅចុះ តើអ្នកបំរើនារីភ្នំយុណូតូងេនៅតែពាក់អៀមក្រហមឆេះនៅឡើយទេឬ?

យូរី : លោកប្រហែលជាស្មានថា នេះជាពាក្យចចាមអារ៉ាមផ្ដេសផ្ដាសចាកការពិតហើយ ដោយមើលទៅឃើញតែភ្នំហើយភ្នំទៀតបែបនេះ ។ តាមពិតនោះជារឿងពិត ។

ង៉ាគីអិន : ទេនាង ខ្ញុំមិនគិតអញ្ចឹងទេ ។ សូម្បីតែផ្កា យូរីភ្នំដែលពណិសសោះក៏រីកក្រហមព្រាតនៅតាមជ្រោះទៅហើយ វាគ្មានអ្វីគួរឱ្យសង្ស័យទេ។ ប៉ុន្តែមើលចុះមើលទៅណាក៏ឃើញតែភ្នំ ភ្នំត្រួតលើភ្នំ។ រួចបើមើលទៅកំពូលភ្នំ ឯនោះវិញពពកនៅពេលព្រះអាទិត្យហៀបលិចមើលឃើញហាក់ដូចជាភ្លើងកំពុងតែឆាបឆេះសន្ធោរសន្ធៅ។ បើតែយ៉ាង១នេះ បើផ្អាកកុំទៅមើលនារីបំរើអៀមក្រហម ឬ នារីព្រីលសអីដូចជាល្អជាង។ ខ្ញុំបាទប្រហែលជានឹងចុះពីភ្នំ គីណូម៉េតូងេ ទៅណាកាការ៉ាជី រួចដើរសំដៅទៅ ក្យូតូ តែម្ដង បែបគ្រាន់បើជាង។

នាងមើលចុះក្តៅអីក្តៅតាមផ្លូវ ។ ខ្ញុំទើបនឹងបានដកដង្ហើមនៅពេលបានមកដល់ទី នេះ ។

យូរី : ចាំ ខ្ញុំឮថានៅឯភូមិនោះ មានរហូតដល់ទៅមនុស្សស្លាប់ ឯណោះលោក ។ រាំងនោះសែនរាំងឆ្នាំនេះ ។

ង៉ាគីអិន : តាំងពីព្រលឹមមក ខ្ញុំដើរឡើងទក់ទីខ្លួនប្រាណអស់ ឥឡូវដូចជាក្រណាត់ កន្ទបជូតក្តារអញ្ចឹង ។ ដើរ ៨-៩ យោជន៍ក្រោមកំដៅព្រះអាទិត្យមិនជាការស្រួលទេនាង ។ ហើយគួរឱ្យព្រឺសំបុរនោះគឺតាមផ្លូវរកតែទឹកដែលឱ្យសមថាឈ្មោះទឹកនោះគឺគ្មាន ។ មកដល់ទីនេះ គឺជាលើកដំបូងហើយដែលខ្ញុំបានបានឃើញទឹកមែនទែននោះ ។ ទឹកនេះស្អាតចំណាប់តែម្តងហើយនាង ។

យូរី : ចាំ ទឹកនេះផុសនៅជំរាលភ្នំ ខាងក្រោយផ្ទះនេះ ហើយធ្លាក់តាមទរដែលយើងធ្វើចុះមក ។ ស្ទឹងនេះតូចទេ ប៉ុន្តែវេលាដែលទឹកហូរប៉ះថ្មគេឮសូរ រ៉ឺង រ៉ឺង យ៉ាងពីរោះ ។ អញ្ចឹងបានជាគេឱ្យឈ្មោះថា " ជ្រោះកូតូហ៊ីគី " (ជ្រោះសម្លេងពិណ្យ) ។ លោកដឹងទេ ថាទឹកនេះឆ្ងាញ់ត្រជាក់ ហើយបរិសុទ្ធណាស់ ។ ... ខ្ញុំដង មកជូនមួយត្រឡោកឬ?

ង៉ាគីអិន : តើអ្នកនាងស្មានថា រហូតមកដល់ពេលនេះ ខ្ញុំអាចទ្រាំមិនទទួលទានវាបានឬ? មុនពេលឃើញដួង ខ្ញុំបានឃើញទឹកស្អាតនេះ ហើយបានឱនក្រេបពីលើ ដូចកន្ទុំរុយហួបទឹកអញ្ចឹង រួចមកបានទាំងយកដៃក្បង់ហួប ក្បឿកអស់មួយកំភ្លួសទៅហើយ ។

យូរី : ហ្អា ! វីរវធំហើយ ខ្ញុំលាងអង្ករក្នុងទឹកនេះមុនហ្នឹងបន្តិចបាត់ទៅហើយ ។

ងាគីអិន : អូទឹកដែនាងលាងអង្ករនោះ វាក្លាយទៅជាឆ្នូតស១របស់ផ្កាអ៊ីរីសពណ៌ស្វាយ និង ផ្កាត្រកួន បាត់អស់ទៅហើយ ។ ឯទឹកដែលខ្ញុំហូបឯក្រោមនោះ ស្អាតថ្លាឆ្វង់មើលតែត្បូងកែវឯនោះ។ អត់មានល្អក់អីបន្តិចទេ។ ឮថាអ្នកភូមិខ្វះទឹកហូប ចុះហេតុអ្វីបានជាគេមិនមកដងពីប្រភពទឹកនៅឯនេះ? តើគេមានហេតុផលពិសេសអ្វីរបស់គេឬនាង?

យូរី : ចាំលោក ទឹកនេះវាផុសនៅជិតជំរាលភ្នំក្រោយផ្ទះឯនោះ

ងាគីអិន : ហ៊ឺ ...

យូរី : ហើយប្រភពទឹកនេះ គឺនៅឯត្រពាំងមួយដែលនៅកណ្តាលភ្នំ គឺ "ត្រពាំងបិសាច" ឯនោះ។ ត្រពាំងនោះ ធំសំបើមណាស់លោក ។ ចាស់១និយាយថា នៅបាតត្រពាំងនោះមានពស់នាគរាជរស់នៅឱ្យតែហ៊ានទៅដល់នោះច្បាស់ជាត្រូវពិសនាគមិនខាន ។ ថ្ងៃនេះងងឹតហើយមើលមិនឃើញទេ ប៉ុន្តែលោកឃើញទេ ដុំគ្រួសដែលមើលពីលើទឹកទៅឃើញពណ៌ស្វាយ ពណ៌បៃតង មានអាតូច១ប៉ុន១បបូរមាត់ លាយឡំជាមួយស្អាត១ នេះគឺជាស្រការបស់សេនាលោកម្ចាស់ត្រពាំង ដែលជ្រុះហើយហូរមក និយាយទៅគួរឱ្យព្រឺសម្បុរ... ។

ង៉ាតីអិន : យី គ្រួសល្អៗនោះ គឺជាស្រកាពស់នាគមានពិស? ហ្អាំ រួចចុះ ខ្ញុំផឹកក្បៀកៗអស់ប៉ុន្មានកំបង់បាត់ទៅហើយ នោះមិនពុលស្លាប់ទេឬ? (រួចយកផ្ដិតគក់ទ្រូងប៊ឺបៗ) ។

យូរី : ហ្អាំ ... (សើចញឹមៗ) យើងខ្ញុំបានទទួលទានទឹកនេះ ព្រឹកល្ងាចរាប់ឆ្នាំហើយ អត់ដែលឃើញអីទេ រហូតមកដល់អាយុប៉ុននេះ ។ តែអ្នកភូមិគេចេះតែសង្ស័យផ្ដេសផ្ដាស ។

ង៉ាតីអិន : ជាតិជាមនុស្សតែងតែមានទម្លាប់សង្ស័យអញ្ចឹងឯង ខ្ញុំស្ដាប់ប្រសាសន៍នាងខ្ញុំអត់មានសង្ស័យអ្វីទេ ចុះបើនាងពិសាទឹកព្រឹកល្ងាចរហូតដល់អាយុប៉ុននេះហើយនៅជ្រងោៗអញ្ចឹង ... (គក់ទ្រូង) ... អឺ... នាងអាយុប៉ុន្មានហើយ?

យូរី : ...

ង៉ាតីអិន : ឱភ្លេច សុំទោស អាយុប៉ុន្មានហើយ?

យូរី : សូមលោកអភ័យទោស ខ្ញុំភ្លេចហើយ ។

ង៉ាតីអិន : ឱភ្លេច ! នៅក្នុងសុភាសិតបុរាណគេថា ចំពោះនារីគេអាចសួរថា " នាងស្លាប់អង្កាល់ " បាន តែមិនឱ្យសួរថា " នាងកើតអង្កាល់ " ទេ ។ ខ្ញុំដូចជាគឃ្លើនជ្រុលបន្តិចហើយ ។ ខ្ញុំឈប់សួរហើយ ។ ណ្ហើយប៉ុណ្ណឹងចុះ ថ្ងៃប៉ុន្មានអ្នកនាង?

យូរី : លោកសួរថ្ងៃអ្វី?

ង៉ាតីអិន : ថ្ងៃទទួលទាន ។

យូរី : តម្លៃ ... អ្វី? ប្រាក់? ទេលោក នរណាទៅទាមទារថ្លៃទឹកតែប៉ុណ្ណឹង១ហ្នឹង?

ង៉ាគីអិន : ទឹកតែក៏អញ្ចឹង សួរអញ្ចឹងដូចជារឹងខ្លួនណាស់ ខ្ញុំមិនត្រឹមតែទទួលទានទឹកតែប៉ុណ្ណោះទេ ថែមទាំងបានទទួលទានផ្លែព័ររបស់នាងអស់មួយកំភ្លួសទៅទៀត។ ទោះជានាងមិនលក់ដូរ ក៏ខ្ញុំដូចជាពិបាកនឹងចេញទៅវិញដោយអត់ជូនសគុណបន្តិចបន្តួចដែរ ។ បើតាមចិត្តចង់១តែដាក់មួយកំបង់ប៊ីបជូនឯណោះ តែដូចនាងឃើញស្រាប់រូបរាងនេះមើលទៅមិនឃើញថាជាមហាសេដ្ឋីឡើយ សូមនាងប្រាប់មកអស់ប៉ុន្មាន ហើយយកទៅ ។

យូរី : បើលោកមិនសុខសាប់ក្នុងចិត្តទេ ឱ្យខ្ញុំសុំសគុណបន្តិចបន្តួចទៅចុះ ។

ង៉ាគីអិន : មានប្រសាសន៍មក !

យូរី : តែសគុណទាំងអស់មិនមែនសុទ្ធតែបានន័យថា លុយទេ ។ ជំនួសលុយសូមលោកនិទានរឿងមួយពីរឱ្យខ្ញុំស្តាប់ផង ។

ង៉ាគីអិន : រឿង? រឿងអ្វីនាង?

យូរី : លោកធ្វើដំណើរទៅណេះទៅចុះ ច្បាស់ជាដឹងរឿងល្អ១ ចម្លែក១មិនលែងឡើយ ។

ង៉ាគីអិន : រឿងដែលមានក្នុងពេលធ្វើដំណើរនោះឬ?

យូរី : ចាំ នាងខ្ញុំសុំឱ្យលោកនិយាយជាថ្នូរជំនួសថ្លៃទទួលទាន។ មិនមែនតែជាមួយលោកម្នាក់ទេ ជាមួយនឹងអ្នកលក់ថ្នាំក្តី អ្នកដំណើរទៅ

ធុតុង្គក្តី អ្នកទៅវត្ត ឬ អ្នកភូមិនេះក្តី ដែលបានដើរមកដល់ទីនេះ ហើយសួរពីតម្លៃនៅពេលនាងខ្ញុំទទួលរាក់ទាក់គេ នាងខ្ញុំតែងតែសុំឱ្យគេនិយាយរឿងឱ្យស្តាប់។ បើអ្នកនោះនិទាន ច្រើនខ្ញុំឱ្យគេសំរាន្តទីនេះតែម្តង ។

ង៉ាគីអិន : អូអញ្ចឹងស្រួលហើយកំពុងអត់កន្លែងគេងផង (យកដៃទះភ្លៅទាំងពីរ) ចាំខ្ញុំនិយាយឱ្យស្តាប់ណាំ។ វាមិនមែនជារឿងអន្ទេអន្ទាយបែកអូរហូរជាស្ទឹងទេ ... មិនត្រឹមតែប៉ុណ្ណោះរឿងនេះវាមានកំណើតនៅអេជីសេង ទៅទៀតហ្នំ !

អាគីរ៉ា : (លបបង្ហើបទ្វារមើល) រួចអង្គុយចុះនៅមុខតុ បើកសៀវភៅ ចាប់ស្លាបប៉ាកាកកត់សេចក្តីដែលភ្ញៀវនិទាន ស្រាប់តែក្រសែភ្នែកទៅទង្គិច នឹងភ្នែករបស់ ង៉ាគីអិន ។ គេក៏ផ្លុំភ្លើងពន្លត់ ។

យូរី : និយាយទៅលោក រឿងអ្វី?

ង៉ាគីអិន : នៅទីនេះក្រៅពីនាង មាននរណាទៀតទេ?

យូរី : ចាំ ក្រៅពីខ្ញុំមានតែព្រះច័ន្ទមួយអស្តង្គត គ្មានមនុស្សឯណាផ្សេងទេ។

ង៉ាគីអិន : ឱ ! ព្រះច័ន្ទបានពន្លត់ភ្លើងទៀនទេតើ អញ្ចឹង ! ដោយសារតែផ្សែងធូបមួសខ្ញុំមើលមិនច្បាស់។ ព្រះច័ន្ទដូចជាកំពុងតែចោលពន្លឺនៅក្នុងបន្ទប់ ។ឈប់សិនអំបាញ់មិញខ្ញុំថានឹងនិយាយរឿងនៅអេជីសេង ។ រឿងនោះ គឺរឿងខ្មោចដែលនំអាកោរវាកាឡាខ្លួន។ អានោះវាចេះនិយាយគ្រាប់មាត់មនុស្ស ដូចឧបមាថា ឥឡូវនេះខ្ញុំនិយាយអ្វី

វានឹងថាត្រាប់តាមខ្ញុំឥតខុសមួយម៉ាត់ទេ។ ពួកអ្នកភូមិនាំគ្នារត់ស្រ
មកសួរ ថាតើអ្នកណានិយាយត្រាប់ហ្នុង? ឆ្កែចចកឬ? វាឆ្លើយថា
មិនមែនទេ អញ្ចឹងកញ្ជ្រោងឬ? ទេ ខុសហើយ ដល់តែពេលសួរ
វាថា ទំអាកោរឬ? វាក៏ថា បាទ ត្រូវហើយៗក៏រលាយខ្លួនបាត់ទៅ។
ខ្ញុំគិតថានឹងនិយាយរឿងនេះ តែលុះតែដល់ព្ទនាងថា មានព្រះច័ន្ទ
ស្តាប់ជាមួយដែរ ខ្ញុំឈប់និយាយរឿងនេះហើយ ហើយនិយាយ
រឿងផ្សេងវិញ។ សូមនាងចាំស្តាប់ណា៎ ! រឿងនេះកើតឡើងពីរឆ្នាំ
មុននៅរដូវក្តៅ។ ខ្ញុំមានសម្លាញ់ម្នាក់។ សម្លាញ់នោះ គេបានដើរពី
ភូមិមួយទៅភូមិមួយ ដើម្បីសាកសួររឿងព្រេងពិរោះៗ ចំឡែកៗពី
អ្នកស្រុក ។គេដើរសឹងតែពេញស្រុកជប៉ុនឯណោះ ហើយខែក្តៅនោះ
គេបានចេញពី តូក្យូ ឆ្លងកាត់ជ្រលងនៅក្នុងភ្នំជ្រៅ តាមផ្លូវហុកកុក
ដើរសៀវតាមកំពូលភ្នំសួរគេឯង។ តាំងពីចេញមករហូត ដល់សព្វ
ថ្ងៃបាត់ដំណឹងពីគេរហូត។ អ្នកនោះមានឪពុកម្តាយ បងប្អូន។ គេ
ទាំងនោះ បានខំដើររកគ្រប់ច្រកល្ហក តែរកមិនឃើញសោះ។ ពួក
យើងជាមិត្តភក្តិក្តីបានគិតថាគេស្លាប់បាត់ទៅហើយៗ បានកំណត់
យកថ្ងៃដែលគេចេញពី តូក្យូ ថាជាថ្ងៃខួបមរណភាពរបស់គេ។
កាសែតបានចុះផ្សាយព្រោងព្រាត នាំឱ្យផ្អើលពាសវាលពាសកាល
មួយរយៈពេលដែរ។

គេប្រហែលជាសម្លាប់ខ្លួនក៏មិនដឹង ត្រូវរបួសក៏មិនដឹង ស្លាប់ដោយហេតុអ្វីមួយក៏មិនដឹង ឥឡូវនេះគ្មានសង្ឃឹមទេ ពេលនិយាយពីគេគឺមានតែទឹកភ្នែកទេ ។

នាងឃើញទេ ថាបុរសនោះគ្មានហេតុផលអ្វីនឹងរត់ចោលស្រុក ឬសម្លាប់ខ្លួនឡើយ។ នៅក្នុងលោកយើង នេះវាមានរឿងចំឡែកបែបនេះដែរណា !

យូរី : ឱ ! បានហើយលោកភ្ញៀវ ខ្ញុំអរគុណហើយ សូមអរគុណអស់ពីដួងចិត្ត ។ (យូរីនិយាយទាំងហួរម៉ង)

ង៉ាគីអិន : បើអរគុណម្លឹង១ ធ្វើម៉េចនឹងរួចតម្លៃទទួលទានទៅ?

យូរី : ចាំ គ្រប់គ្រាន់ហើយ ។

ង៉ាគីអិន : ស្ដាប់ទៅយ៉ាងម៉េចដែរនាង?

យូរី : រឿងពិរោះ គឺរឿងទី ១ រឿងនំអាកោរឯនោះទេ រឿងក្រោយមកអត់ពិរោះទេ។

ង៉ាគីអិន : មានទាស់ចូលដល់សាច់រឿងឯណា មិញនេះគ្រាន់តែជាសេចក្ដីផ្ដើមរៀបនឹងបើកឆាកទេតើ?

យូរី : ទេអញ្ជើញ ខ្ញុំគ្រប់គ្រាន់ហើយលោកភ្ញៀវ ងងឹតហើយលោក។ តែមិនអញ្ជើញទៅឥឡូវទេ ពិបាករក កន្លែងសំរាកហើយ ។

ឈរហើយមើលទៅបន្ទប់រួចមើលមក ង៉ាគីអិនវិញ) ជំរាបលា ហើយលោក ...

ង៉ាគីអិន : ជំរាបលា ...

អាគីរ៉ា : (ចេញផ្លូវពីកន្លែងបំពក់មួស) យ៉ាម៉ាសារ៉ា យ៉ាម៉ាសារ៉ា (ហៅត្រង់ៗ អត់ញញើត)

ង៉ាគីអិន : ហ្អា ហាធីរ៉ារ៉ា ហាធីរ៉ារ៉ា ឬ មិនមែនហ្នឹង?

យូរី : បង ! (យូរីរត់ទៅទប់ទ្រូង អាគីរ៉ា ហាក់ដូចជាចង់រារាំងមិនឱ្យចេញមក)

អាគីរ៉ា : នែឯងប្រញាប់ទៅណា? អត់អីទេ មក ! មក ! (អាគីរ៉ាប្រើសម្លេងទាប) គ្នាមិនដឹងនិយាយថាម៉េចទេមក យ៉ាម៉ាសារ៉ា ចូលមកនេះ ។

ង៉ាគីអិន : ខ្ញុំក៏គ្មានពាក្យនិយាយដែរ ។ ពេលឃើញឯងភ្លាមខ្ញុំថាក្នុង ១០ ឬ ៩ គឺឯងហើយ ។ មិញនេះក៏អញ្ចឹងដែរ តែនរណាហ៊ាន បើវាប្រថុចញ៉ុចបែបនេះ? (រ៉ាគីអិនឡើងទៅលើរានហាលវិញ) រួចចុះក្បាលហ្នឹងវាយ៉ាងម៉េច?

អាគីរ៉ា : ថាក្បាលនោះវាក្បាលទៅហើយ ! ល្ហើយអត់ទោស ! មកឡើងមក !

ង៉ាគីអិន : អត់ទោស ខ្លួនគ្នាសុទ្ធតែចូលី (បោសជើងហើយចូលអង្គុយ) ក្បាលនោះវាក្បាលហើយ ហេតុអ្វីបានជាសស្គុសមើលតែសំឡីហ្នុង?

អាគីរ៉ា  : កុំព្រួយ  អាហ្នឹងមិនមែនមកពីត្រូវនាគលេបទេ។  សក់ក្លែងក្លាយហ្នឹង? (គេបោចសក់ពីក្បាលហើយ ចោលទៅលើក្ដារ)

ង៉ាគីអិន : ឱ ! (លួចមើលទៅយូរី) មែនវ៉ី ។ រូបនោះប្រពន្ធឬ?

អាគីរ៉ា  : អើ  ឈ្មោះ  យូរី។  (យូរីលាជើងដែលបត់  ហើយក្រាបទៅលើភ្លៅអាគីរ៉ា)

ង៉ាគីអិន : នាងយូរី អ្នកស្រី ភរិយា ...

អាគីរ៉ា  : ម៉េចយំយូរី?   ជូតទឹកភ្នែកទៅហើយសំពះសួរពួកម៉ាកបងឱ្យត្រឹមត្រូវមើល ! (ពេលអាគីរ៉ា និយាយ យូរីក្រោកក្រេសចូលទៅក្នុង)

អាគីរ៉ា  : គ្នាភ័យខ្លាចឯងមកដាស់ខ្ញុំ  ឱ្យខ្ញុំភ្ញាក់ពីដំណេក  ភ្ញាក់ពីសុបិននិមិត្តនេះរួចវិលត្រលប់ទៅ តូក្យូវិញចោលគ្នា

ង៉ាគីអិន : (ឃើញយូរីល្អស្មោះត្រង់កំអួលដើមក) គ្រាន់តែឃើញមុខខ្ញុំប៉ុនណ្ណឹងកុំប្រញាប់ភ្ញាក់អី ហាឆីរ៉ាក់រ៉ា។ សុបិននិមិត្តនេះ ចាំបាច់អីនឹងឯងភ្ញាក់ទេ។  បើសុបិននិមិត្តនោះល្អវាគ្មានហេតុផលអ្វីឱ្យឯងភ្ញាក់បែទៅរកការពិតវិញឡើយ... ប៉ុន្តែអាគីរ៉ា ខ្ញុំមិនភ្លេចទេ នៅតូក្យូ ម្ដាយឪពុកឯង បងប្អូនញាតិសន្ដានឯង...

អាគីរ៉ា  : អើ

ង៉ាគីអិន : ពួកគេបារម្ភពីឯងឡើងសឹងតែចង់ខេចអាយុអស់ហើយ  ។  តែអ្នកទាំងអស់បានសុខសប្បាយជានាទាំងអស់គ្នាទេ។

អាគីរ៉ា  : អរគុណ ...

ង៉ាគីអិន : មិនបាច់គុណស្រាយអ្វីទេ ។

អាគីរ៉ា : ឱ្យគ្នាសុំទោស

ង៉ាគីអិន : មើលខ្លួននិយាយពីដំណើរដើមទងរបស់ឯងទៅមើល តើវាយ៉ាងម៉េចរឿងហ្នឹង?

អាគីរ៉ា : ឯងចាំស្តាប់ណាំ គិតថាវាជារឿងយល់សប្តិទៅណាំ !

ង៉ាគីអិន : អើមិនអីទេ គ្នានឹងគិតថាវាជារឿងយល់សប្តិ ។

អាគីរ៉ា : ចាំយប់សឹមគ្នានិយាយឱ្យអស់អាចមិអស់នោម ។ ឥឡូវគ្នានិយាយត្រួស១សិនទៅចុះ ។ ដូចឯងដឹងស្រាប់ ហើយថាខ្ញុំនេះធ្វើដំណើរចេញពីតូក្យូ ថាប្រុងនឹងដើរស្រាវជ្រាវរករឿងនិទានតាមផ្លូវហុកកុក ។ តែអាខ្លួនឯងដែលជាអ្នកដើរស្រាវជ្រាវហ្នឹងស្រាប់តែក្លាយទៅជាតួអង្គម្នាក់នៃរឿងនិទានបាត់ទៅ... ។ គេថាធ្មប់ចេះដកភ្នំហើយយកទៅដាក់ឯសមុទ្រ ចេះជប់មនុស្សឱ្យទៅជាថ្ម ចេះយកថ្មមកផ្លុំឱ្យទៅជាស្លឹកឈើ ចេះធ្វើស្លឹកឈើឱ្យទៅជាកង្កែប ... ខ្លួនឯងទើបតែមកដល់ទីនេះ តែហាក់ដូចជាក្លាយទៅជាតួអង្គនៃរឿងមួយទៅហើយមិនអញ្ចឹង? ... គ្នាឯនេះវិញ នៅលើឯងមួយគិរិត ថាឱ្យចំគឺខ្ញុំនេះវាទៅជាតួអង្គសាច់រឿងខ្លួន វាបាត់ទៅហើយ ។

ង៉ាគីអិន : កុំនិយាយផ្តេសផ្តាសគ្នាខ្លាចណាស់ ។ អញ្ចឹងប្រពន្ធខ្លួនជា... (និយាយទាំងរួញរា)

អាគីរ៉ា : (បែរទៅបន្ទប់) ប្រហែលកំពុងប្តូរខោអាវហើយ បើមិននោះសោត ទេ កំពុងតែចងសក់ក៏មិនដឹង។ ផ្ទះគ្នាមានតែបន្ទប់មួយហ្នឹង (អាគីរ៉ា ចេញទៅទ្វារក្រោយ)

ង៉ាគីអិន : (ជំទើតជើងមើលតាមទ្វារ) នែ មានទឹកទេ អាគីរ៉ា? នៅមុខស្លឹក ត្រែងព្រះច័ន្ទចាំងព្រិច១ទៅលើក្រាស់សិតសក់ ឃើញក្បាលដែល ដោះសក់ពាក់ចេញមានសក់ខ្មៅរលើប ប្រហែលជាមកពីខ្ញុំបានឮថា នាង កើតនៅស្រុកព្រៃលក៏មិនដឹង កញ្ចឹងក ខ្នងសដូចព្រីល ចុះល្អអ្វី ល្អម្ល៉េះ? ... ប្រពន្ធ ឯងជាធ្នប់ឬ?

អាគីរ៉ា : និយាយបានតែផ្ដាស វាមិនដែល ធ្វើបាបគ្នា !

ង៉ាគីអិន : ហ៊ឺស ...

អាគីរ៉ា : ទឹកដីនេះ ភូមិនេះ ជ្រលងកូតូហ៊ីគីនេះ គឺជាបិសាចមួយតែម្តង ទៅចុះ នែ យ៉ាម៉ាសាកិ៍ ឯងដែលឮគេ និយាយពីឈ្មោះគ្រពាំង បិសាចទេ?

ង៉ាគីអិន : ដែល ដែល។ មិនត្រឹមតែដែលទេ ព្រោះតែចង់ឃើញគ្រពាំងនោះ ហើយទើបបានខំដើរ ២០ យោជន៍ ពីស្ថានីយ៍ អ៊ីម៉ាណេ ហើយ ខំចច្រប់មកដល់កន្លែងហ្នឹង១ហ្នាំ !

អាគីរ៉ា : ខ្ញុំក៏អញ្ចឹងដែរ ពីពីរឆ្នាំមុន ហេតុតែចង់ឃើញគ្រពាំងនោះពេក ក៏ លុកលុយចច្រប់ចូលព្រៃតាមជ្រលង នេះមកតែម្នាក់ឯង រហូតដល់ វាកើតទៅជារឿងអញ្ចឹងទៅ ។ នោះដូង !

ង៉ាគីអិន : អើគ្នាឮគេថា ១ថ្ងៃ ១យប់ វាយបានតែព្រឹកម៉ោង ៦ម្តង ល្ងាចម៉ោង ៦ម្តង និង យប់ម៉ោង ២ទេ ក្រៅពីនេះមិនត្រូវវាយទេ មែនទេ?

អាគីរ៉ា : ហ្នឹងហើយ ក្រៅពីរបីដងនេះ មិនត្រូវឱ្យលាន់សម្លេងជាដាច់ខាត ។ មួយថ្ងៃត្រូវឱ្យឮសម្លេងជួងនេះតែបីដងទេ ។

ង៉ាគីអិន : ព្រោះអ្វី?

អាគីរ៉ា : មានរឿងនិទានត១មកថា កាលពីព្រេងនាយ មនុស្សបានច្បាំងជាមួយនឹងទឹក។ នៅពេលដែលទឹកជំនន់ ហៀបនឹងវិនាសអន្តរធានលោកតាធុតុង្គឈ្មោះ លោកតា តៃជេ ដែលជាម្ចាស់ស្រុក អេជីទាំង ៣ បានប្រើមហិទ្ធិរិទ្ធិរបស់លោក ហើយបានឃុំឃាំងពស់នាគរាជ ខ្ទប់នៅបាតត្រពាំង បិសាច ។ នាគរាជ និយាយថា គេសុខចិត្តរស់ក្នុងទីឃុំឃាំងចុះឱ្យតែមនុស្សសត្វបានសុខសប្បាយ ចៀសផុតពីការលិចលង់ ការស្រុតព្រះធរណី។ ប៉ុន្តែជាថ្នូរត្រូវធ្វើជួងមួយពាក់នៅនឹងចង្កេះភ្នំ ហើយត្រូវវាយមួយថ្ងៃ បីដង ដើម្បីពញាក់គេកុំឱ្យគេភ្លេចកិច្ចសន្យារបស់គេ។ នាគនិយាយថា ធាតុពិតរបស់គេ គឺចូលចិត្តសេរីភាពចូលចិត្ត ការរស់នៅដោយទំនើងចិត្ត មិនចូលចិត្តការហាមឃាត់ឃុំឃាំងទេ ដូច្នេះគេអាចភ្លេចកិច្ចសន្យារបស់គេ ហើយអាចព្រួសទឹកឱ្យលិចលង់ផ្លូវទាំង ៧ នៃភូមិភាគដីគោកខាងជើងក៏មិនដឹង។ ចំពោះគេជានាគ ជីវិតមនុស្សសត្វ ដែលរស់នៅលើ

លោកនេះគ្មានតម្លៃសំខាន់ទាល់តែសោះ ។ ប៉ុន្តែគេនឹងគោរពពាក្យសន្យារបស់គេ មិនបំពានសំបថរបស់គេទេ។ តែសូមជួយធ្វើម៉េចកុំឱ្យគេបំភ្លេចពាក្យសន្យា និង បំពានពាក្យសំបថរបស់គេសោះឡើយ ពោលគឺមិនត្រូវខ្ជីខ្ជាក្នុងការវាយជួងជាដាច់ខាត ។ នៃយ៉ាម៉ាសាវ៉ា អញ្ចឹងហើយបានជាគេធ្វើជួងនេះទេ។ ហើយសាកធ្វើជាភ្លេចវាយម្តងលមើល បើមិនឃើញភ្លៀងធំ រន្ទះធំ ខ្យល់ព្យុះបន្ទាប់មកទឹកនៃត្រពាំងបិសាចនឹងពោរពេញបលិចលង់ ភូមិ ស្រុកដោយស្តេចនាគ នឹងហក់ហោះស្ទោះស្ទេវពាសវាលពាសកាល មួយរំពេចឥឡូវហ្នឹងហើយ! នេះគឺជារឿង ដែលគេនិទានត១គ្នាមក ។ អញ្ចឹងហើយបានជាត្រូវវាយជួងម៉ោង ៦ព្រឹក ម៉ោង ៦ ល្ងាច និង ម៉ោង ២យប់នោះ ។

ង៉ាគីអិន : ហ៊ឺ គួរឱ្យចាប់អារម្មណ៍មែន ។

អាគីរ៉ា : មិនត្រឹមតែគួរឱ្យចាប់អារម្មណ៍ប៉ុណ្ណោះទេ តែជារឿងសំខាន់ណាស់ ។

ង៉ាគីអិន : ពិតជាអញ្ចឹងមែន !

អាគីរ៉ា : មើលគ្នាសួរដូចជាឆោតទៅចុះ តើឯងដឹងទេ ថាអ្នកណាជាអ្នកវាយជួងនោះ?

ង៉ាគីអិន : ខ្លួនឯងឬ?

អាគីរ៉ា : ហ្នឹងហើយ ខ្ញុំហ្នឹងឯង ។ គឺខ្ញុំ ហាធីរ៉ាក៉ា អាគីរ៉ា តាវាយជួង ។

ង៉ាគីអិន : ម៉េចបានទៅជាអញ្ចឹង?

អាគីរ៉ា : ខ្ញុំបានមកដល់ទីនេះពីពីរឆ្នាំមុន ។ ពេលនោះអ្នកវាយជួងមុនខ្ញុំនេះ ឈ្មោះ យ៉ាតាបេ អាយុ ៧៩ឆ្នាំ។ គាត់រស់នៅតែឯង ហើយវាយជួង នេះ ៥០ឆ្នាំមកហើយ មិនដែលខានមួយថ្ងៃទេ ។ មួយថ្ងៃបីដង ព្រឹក ល្ងាច យប់ ។ យ៉ាម៉ាសាវ៉ា ! ឯងដឹងទេ? ផ្កាទាក់ទាញភ្នែក មនុស្ស ឯទឹកទាក់ទាញចិត្តមនុស្ស។ ខ្លួនឯងមកនេះក៏ព្រោះតែចង់ ឃើញទឹកត្រពាំងបិសាច។ ខ្ញុំនេះក៏អញ្ចឹងដែរ។ ព្រោះតែចង់មើល ត្រពាំងនោះទើបបានជាដើរមកដល់ទឹកដីនេះ នៅវេលាដែលជួង វាយ ម៉ោង ៦ល្ងាច ទៅហើយ។ ខ្ញុំបានមកដល់ ផ្ទះតា យ៉ាតាបេ ដើម្បីសាកសួរ គាត់ពីរឿងជួងផងហើយ សុំសំណាក់ផ្ទះគាត់មួយ យប់ ដើម្បីពឹងគាត់ឱ្យជូនទៅមើលត្រពាំងបិសាច នៅថ្ងៃបន្ទាប់ ផង ។ យើងបានសន្យាគ្នាមុនត្រូវរ៉ូវអស់ ហើយ ។ យប់នោះពេល វាយជួង ម៉ោង ២យប់ហើយ តាយ៉ាតាបេ បានចុះពីរោងជួង ហើយ បានមក ដេកដួលនៅមុខរានហាលនេះ។ គាត់មានជម្ងឺ ហើយកំពុង តែច្បាំងជាមួយ នឹងមច្ចុរាជ ។ តែគាត់ដូចជាស្លាប់មិនកើតយ៉ាង ម៉េចគាត់ ។ គាត់នៅស្ងៀម ឯងដឹងស្រាប់ហើយសម័យនេះគ្មាន នរណាគេជឿជំនឿបែបនេះទេ។ បើតាយ៉ាតាបេ ស្លាប់បាត់ តើបាននរណាវាយជួងជំនួសគាត់ ? ហើយបើប៉ានតែប្រហែសអត់ វាយ តែម្តងក្តីទឹកជំនន់ នឹងកើតឡើងធ្វើឱ្យលិចលង់អ្វីៗអស់ គ្មានសល់ប៉ុនចុងក្រចកទេ ។ ដីធ្លីស្រែ ចំការ ដីគោកទាំងប៉ុន្មាននឹង

ស្រុតកប់ទៅក្នុង ទឹកហិនហោចអន្តរធានបាត់ស្រមោល ទៅជាមហាទន្លេ។ ជីវិតមនុស្ស រាប់ពាន់ រាប់ម៉ឺន នឹងត្រូវទៅជាចំណីរបស់មច្ឆរាជ។ នៅពេលដែល គាត់គិតដល់នេះ តាយ៉ាតាបេមិនអាចស្លាប់បិទភ្នែកជិតបានទេ គាត់ប្រកាច់ស្លឈាមស្រែកថ្ងូរ គ្រលួច ។ សម្លេងគាត់ខ្សោយជាង សម្លេងចង្រិតទៅទៀត ។ ជនជរាដ៏ស្គមមានតែស្បែកដណ្តប់ឆ្អឹង បានមើលថែទាំជួងនេះ ៥០ឆ្នាំ មកហើយដោយសារតែជំនឿនេះ។ សម្លេងរបស់គាត់ បានបន្លឺលាន់ពេញត្រចៀករបស់ខ្ញុំ ដូចជាសម្លេង ជួងអញ្ចឹង។ ដោយអាណិតគាត់ពេកខ្ញុំចង់ឱ្យគាត់ស្លាប់ទៅដោយសំរួល ដោយសុខក្សេមក្សាន្ត ក៏បាននិយាយច្បាស់ៗថា សូមលោក តាកុំបារម្ភ ខ្ញុំនឹងវាយជួងនេះជំនួសលោកតា ។ ពេលឮខ្ញុំថាដូច្នេះ តាបានញញឹមដោយសេចក្តីរីករាយអស់ពីជំរៅចិត្ត ហើយលើកដៃសំពះ រួចក៏ចែកឋានទៅ។ ខ្ញុំមិនអាចបំភ្លេចមុខគាត់នៅពេលនោះ បានទេ មិនបានជាដាច់ខាត។ តែខ្ញុំមិនបានគិតស្មាន ថាខ្ញុំនឹងនៅវាយ ជួងនេះមួយជីវិតបែបនេះទាល់តែសោះ។ លោកតាបានវាយជួងម៉ោង ២យប់រួចហើយដូច្នេះខ្ញុំចាំតែវាយម៉ោង ៦ព្រឹកមួយជំនួសគាត់ទៅនឹងរួចគ្នា ។ លោកតាស្លាប់ទៅដូចខ្លួន ឃើញស្រាប់ហើយថា ភូមិគេនៅឆ្ងាយណាស់ ។ ហើយជួងនេះ សោតទោះជាមាន លិចទឹក ភ្លើងឆេះ ក៏មិនអាចវាយបានក្រៅពីបីដង ដែលគេកំណត់ទេ ។

ង៉ាគីអិន : ហេតុអ្វីបានជាអញ្ចឹង?

អាគីរ៉ា : ជួងនៅខ្ពស់ នៅនេះ-ស្រមោលវាឆ្លុះទៅលើត្រពាំងបិសាចដ៏ជ្រៅ ។ ខ្ញុំឮគេថាពេលយើងយកមោងទៅ វាយវាសូម្បីតែខ្យល់ដែលបក់ពីជើងក៏ឡើងស្ងប់ដែរ ។ ពេល នោះផ្ទៃទឹកត្រពាំងឡើងញ័រចើៗ ។ យើងវាយជួងនេះគឺដើម្បី ពញ្ញាក់នាគរាជ ។ តែគេមិនត្រូវពញ្ញាក់ឱ្យលើស ៣ដងទេ ព្រោះវាជាការមិនសមរម្យ ការខ្វះសុជីវធម៌ចំពោះនាគរាជ ។

ង៉ាគីអិន : ត្រឹមត្រូវហ្នឹងដែរ មិនខុសទេ ។

អាគីរ៉ា : ពេលនោះខ្ញុំមិនអាចវាយជួងដើម្បីប្រជុំអ្នកភូមិបានទេ។ ខ្ញុំត្រូវរត់ឆ្លេឆ្លាទៅនេះទៅនោះនៅក្នុងភូមិមួយ ដែលខ្ញុំគ្មានមិត្តគ្មានភ័ក្រ្ត ព្រមទាំងមិនដឹងលិចមិនដឹងកើតផង។ មនុស្សបានមកជុំគ្នា ហើយយើង បានបូជាសពលោកតា យ៉ាតាបេ ហើយ ប៉ុន្តែនិយាយដល់រឿង វាយជួង គ្មាននរណាម្នាក់ស្ម័គ្រចិត្តថាខ្លួនឯងនឹង វាយជំនួសតាឡើយ។ ទី១ នៅពេលដែលខ្ញុំនិយាយរឿងនិទានដែលខ្ញុំបានឮពីតាយ៉ាតាបេ ថ្មី១ថាបែបនេះមួយបែបនោះមួយ ដោយមុខមាំដូចជាគេសូត្រ ពាក្យបណ្ដាំនៃដូនតាប្រាប់កូនចៅមក ពួកអ្នកភូមិនាំគ្នាសើចគឹល ។ ថាក្មេងទៅវាក្មេងទៅហើយ អាមនុស្សចាស់ទំពែកក្បាលរលោងស្រិល ជិតដុះស្លែទៅហើយនោះ ព្រមទាំងលោកសង្ឃទៅទៀតក៏មិនជឿឯង។ គេនាំគ្នាសើចខឹក១ ហើយនិយាយឌឺដង

ថា ទៅជឿ អីអារឿងអញ្ចឹងៗ អស់ស្រូវពូជហើយស្ដាប់រឿង កំប្លែងអាជ័យ គ្រាន់បើជាង ។ គ្នាឡើងក្ដៅគុម្ពត្រចៀក ដៃរក៏ ពាក់ស្បែកជើងដើរចុះក្ដាំងៗពីទីនោះ (លើកដៃចង្អុលរានហាល) ហើយថា: ងាប់ៗទៅគ្មានឪអីអញទេ ហើយរត់ត្រីកៗចេញពី ជ្រលងនោះរកត្រលប់ទៅវិញ ។ លុះមកដល់ក្រោមស្ពាននៃភូមិ ស៊ីកាមី ខ្ញុំបានឃើញនាងនោះ (និយាយ តិចៗ) ឈរលើកដៃលា ខ្ញុំយ៉ាងស្រងេះស្រងោច ។ ថ្ងៃបន្ទាប់ទៅពេលដែល ខ្ញុំឡើងទៅ វាយជួងម៉ោង ៦ព្រឹក ពួកកូនក្មេងនាំគ្នា ចង្អុលពីក្រោមមកខ្ញុំ ព្រមទាំង សើចចំអកឱ្យខ្ញុំឮៗ ។ ខ្ញុំក្ដៅណាស់គិតក្នុងចិត្តថា ចាប់ពី ថ្ងៃនេះទៅ ពួកឯងនឹងឈប់ឮ សម្លេងជួងហើយៗ ពេលនោះផ្ទាំងថ្ម នឹងរង្គោះធ្លាក់មក ភ្នំនឹងប្រេះ ហើយបើមិននោះសោតទេ ខ្យល់ ព្យុះដ៏ធំនឹងមកកំទេចភូមិនេះ ហើយខ្ញុំមិនរវល់ទេណា ប៉ុន្តែជីវិត នាងតូចនោះក៏នឹងបាត់បង់ដែរ ។ ទេមិនបានទេ ខ្ញុំត្រូវតែនៅថែជួង នេះ ពីរបីថ្ងៃទៀតទើបបាន ។ អាពីរ បីថ្ងៃនោះវាទៅជា ៤-៥ថ្ងៃ រួចហើយ កន្លះខែ រួចហើយ ៣ឆ្នាំ យ៉ាងរហ័ស ... រហូតមកដល់ បានជួបខ្លួនឯងថ្ងៃនេះ។ ខ្ញុំភ្លេច អស់ហើយថ្ងៃខែ ពេលវេលា ... ដើម្បីនឹងអាចបំភ្លេចបានខ្ញុំបាន ធ្វើឱ្យខ្លួនខ្ញុំទៅជាមនុស្សចាស់ហើយ រស់នៅដាច់ពីមនុស្សម្នាផងទាំង ពួង ព្រោះខ្ញុំអស់ចិត្តហើយ ។ ម្យ៉ាងទៀតដើម្បីបំភ្លេចរឿងរ៉ាវ សៅហ្មងទាំងឡាយពេលថ្ងៃ ខ្ញុំ

ងើបមើលមេឃ មើលដំបូលផ្ទះ មើលទាព្រៃ ចាប់ដែលហោះដោយពាក់សក់សដាក់ ។

ង៉ាគីអិន : (មើលមុខ អាគីភ៉ាយ៉ាងស្ងៀមស្ងាត់)

អាគីភ៉ា : (នៅស្ងៀម) កុំសម្លឹងមើលខ្លាំងពេកគ្នារឹងខ្លួនណាស់

ង៉ាគីអិន : (នាងហាក់ដូចជាបារម្ភមួយស្របក់) អញ្ចឹងខ្លួនឯងសុខចិត្តលាក់ខ្លួនពួកអាត្មាទីនេះ ដោយសារនាងយូរី នោះឬ?

អាគីភ៉ា : អ៊ើ ឯងនិយាយអញ្ចឹងនាំឱ្យគ្នារឹតតែខ្មាសទៀតហើយវើយ ។

ង៉ាគីអិន : ខ្មាសស្អី? នែ ម៉េចឯងមិនអាចនាំប្រពន្ធទៅរស់នៅ តូក្យូបានទេឬ?

អាគីភ៉ា : ម៉េចខ្លួននិយាយអញ្ចឹង? បើពួកគ្នាចេញពីភូមិស្រុកនេះ តើជីវិតអ្នកស្រុកភូមិ និង អ្នកដែលនៅជើងភ្នំ នេះនឹងទៅជាយ៉ាងណា? មិនតែប៉ុណ្ណោះវាអាចជាគ្រោះដល់ទៅស្រុក អេជីសេង មួយក៏មិនដឹងស្រុក អេចជីទាំងបីក៏មិនដឹង?

ង៉ាគីអិន : (និយាយបណ្តើរដើរទៅជិត អាគីភ៉ាបណ្តើរ) ហាធីភ៉ាភ៉ា ឯងជឿជំនឿនេះឬ?

អាគីភ៉ា : អើជឿ គ្នាជឿ សូមឯងឈប់គិតរវីរវល់ពី ហាធីភ៉ាភ៉ា អាគីភ៉ាទៀតទៅ ។ គ្មានរឿងអ្វីនឹងមនុស្សនោះទៀតទេ ។ គ្នានេះគឺតាវ៉ាយជួង នៅជ្រលងសម្លេងពិណ្យ នៃភូមិ ស៊ីកាមី នៅជើងភ្នំមីគីនី ដាកេ នៃស្រុក អេជីសេង ជាប្តីនាងយូរី និង ជាតាយ៉ាតាបេទី ២ ។ យើងជឿអស់ពីជំរៅចិត្តរបស់យើង ។

ង៉ាគីអិន : (ពែនភ្នែនដាក់ដៃទាំងពីរលើភ្លៅ) ខ្ញុំមិនថាអីទេ។ សូមឯងជឿបែបនេះចុះ ជឿឱ្យជាក់ចុះ ។ ប្រពន្ធរបស់ឯងក៏ល្អលើសនារីនានា។ ព្រះអាទិទេពហាក់ដូចជាបានសាងនាងយូរី ឱ្យមកកកើតនៅក្នុងភូមិនេះហើយបាននាំផ្លូវអ្នកវាយជួងម្នាក់ឱ្យមកជួបនាង។ អ្នកទាំងពីរប្រៀបបានដូចជាជើងសសរស្តម្ភនៃភូមិ ស្រុកនេះ ជាពិសេសនាងយូរី គឺជាព្រះអាទិទេពស្រី នៃភូមិនេះតែម្តង ។

យូរី : (ដៃកាន់ចង្កៀង នាងមានសក់ខ្មៅរលើប ដើរចេញមក) ខ្ញុំគួរធ្វើយ៉ាងម៉េច?

ង៉ាគីអិន : ឱ ! អាំ !

យូរី : លោកភ្ញៀវ អំបាញ់មិញនេះ ...

ង៉ាគីអិន : ឱ ! ជំរាបសួរ អ្នកស្រី ...

យូរី : អ៊ឹម (អៀន)

អាគីវ៉ា : នែអូន គេមិននិយាយតែអ៊ឹមប៉ុណ្ណឹងទេ ចូរនាងធ្វើគារវកិច្ចដាក់គេទៅ គេប្រៀបបានដូចជាបងប្រុសបង្កើតរបស់បងណា៎ !

យូរី : (អង្គុយបត់ជើងស្ងៀមស្ងាត់)

ង៉ាគីអិន : យើងបានធ្វើគារវកិច្ចដាក់គ្នារួចហើយ ។ អ្នកស្រីអំបាញ់មិញមានកណ្តាសទេ?

អាគីវ៉ា : ប៉ិានតែកណ្តាសផ្តេសផ្តាសមើល បើមិនមូសផ្អើលរ៉ូងឥឡូវហ្នឹងហើយ ។

យូរី : បងចូលចិត្តតែនិយាយលេង !

អាគីរ៉ា : ចុះអូនឯងចាំបាច់លាបប្រេង លាបម្សៅធ្វើអ្វីយូរី?

យូរី : បងនិយាយតែអញ្ចឹង ! (យូរីលួចសម្លក់ប្ដីដោយភ្នែកស្លូតរួចលាក់មុខ)

ង៉ាគីអិន : ឯងទាំងពីរនាក់ស្រលាញ់គ្នាដល់ហើយតើនេះ ! ហាស១ មុននេះបន្តិច ខ្ញុំបានលួចនិយាយដើមនាងបន្តិចទៅហើយ ! នាង ! ឪពុកម្ដាយបងប្អូននៅឯណាដែរ?

អាគីរ៉ា : អត់មានទេ យូរី ជាកូនកំព្រា ពីមុនឪពុកជាចៅអធិការវត្ត ហាជីម៉ាំង ។ ដល់លោកគ្រូចៅអធិការនោះសុគតទៅប្អូនប្រុសលោកក៏ទៅជាតំណាងឱ្យចៅអធិការ ។ នាងយូរី ក៏នៅជាមួយមានោះ ។ តែគាត់ចូលជិតមិនសូវបានទេ ។

ង៉ាគីអិន : ខ្ញុំតែតែចង់ឃើញឱ្យឆាប់ ។ ខ្ញុំនឹងចេញយប់នេះតែម្ដង ទៅត្រពាំងបិសាច សូមមេត្តាដាក់តែម្ហូប ដែលអ្នកស្រីធ្វើដោយដៃអ្នកស្រីមកបានហើយ មិនបាច់ស្រាទេ។ ដូចឯងដឹងស្រាប់ហើយថាខ្ញុំអត់ចេះទទួលទានស្រាទេ តែមួយតំណក់ក៏មិនកើតដែរ ។

អាគីរ៉ា : ឱមែន ! ខ្លួនមកមើលត្រពាំងបិសាច ។ បើចាំដល់ស្អែក ផ្លូវដល់ទៅមួយយោជន៍ ហើយផ្លូវឡើងទៅចោតណាស់ បើដើរយប់ក៏មព្យាងដែរ វាត្រជាក់ ។ នៅលេងនឹងគ្នា ៤-៥ថ្ងៃ ទៅណា ! ស្អែកយប់សឹមចេញទៅហ្អី?

ង៉ាគីអិន : ហ៊ុ គ្នាត្រូវបង្រៀនរើយ ។ បើគ្នាជាសិស្ស ចេះតែបន្លាយពេលបាន ហើយ តែវាទាស់តែមិនមែនជាសិស្ស ហើយដើរអស់ពេលច្រើនថ្ងៃ មកហើយ ពុំអាចនៅត្រេតត្រតបានទេ ។

អាគីរ៉ា : ពិបាកដែរអញ្ចឹង ។ សាលានៅឯណាដែរ? មិញនេះឯងថានឹងទៅ ក្បូតូ?

ង៉ាគីអិន : អើគ្នាបានទៅធ្វើជាអ្នករាជការតាំងពីឆ្នាំមុនមួយ ។ ដូច្នេះត្រូវតែ ទៅបំរើរដ្ឋវិញ ។

អាគីរ៉ា : អញ្ចឹងក៏បានដែរ គ្នាទៅជាមួយ ។

ង៉ាគីអិន : ខ្លួនទៅជាមួយគ្នាដែរឬ?

អាគីរ៉ា : តស់ប្រញាប់បន្តិច ។

ង៉ាគីអិន : ដូចជាអាណិតយូរីណាស់ ។

អាគីរ៉ា : អត់អីទេ ។

យូរី : អត់ទេ (និយាយទាំងមុខស្រពោន) បង... បងថាចេញទៅឥឡូវ... ចុះបាយ ...

អាគីរ៉ា : ដាក់ខត្រីដែលមានស្រាប់បានហើយអូន រួចហើយតៅហ៊ូអាំងអី ប៉ុណ្ណឹងមក ហ្ន៎ យ៉ាម៉ាសាវ៉ា?

ង៉ាគីអិន : អ៊ើ បានហើយ

អាគីរ៉ា : ឱ្យតែបានសំរេចចិត្តថាទៅហើយ ឆាប់ទេ ។ ខ្ញុំពាក់ស្បែកជើង សង្រែកស្បូវទៅ ឯខ្លួនឯងពាក់អាកវែងទៅ ។

ង៉ាគីអិន : សប្បាយម្យ៉ាងដែរ ។ អ្នកស្រីពេលត្រលប់ទៅវិញខ្ញុំនឹងឆ្លៀតឆ្មៀង ចូលលេងទៀត ។ ពេលនោះសូមកុំភ្លេចធ្វើសំឡសៀងទុកឱ្យខ្ញុំផង ណា៎ ។ យើងមកវិញថ្ងៃណាវ៉ឺយ?

អាគីរ៉ា : គ្នាមិនដឹងទេ ប៉ុន្តែយប់ខ្លីតែមួយហ្នឹង? យើងមកដល់ពេលព្រលឹម មុនព្រះអាទិត្យរះ ហើយមើលទៅ ។

ង៉ាគីអិន : ព្រឹកព្រហាមហ្ន៎ ! មានអីអញ្ចឹង? (ពាក់ស្បែកជើងបណ្ដើរ) យឺ និយាយអញ្ចឹង បាននរណាវាយជួងយប់ម៉ោង ២?

អាគីរ៉ា : យូរីដឹងហើយ ។ យើងខុសពីតា យ៉ាតាបេ ដែលជាអ្នកវាយមុន ។ គ្នា មិនមែនឥសី ឬ អ្នកសច្ចំឯណាវ៉ឺយ ។ មនុស្សម្នាសុទ្ធសាធទេតើ ឈឺក៏ចេះឈឺ ជាក៏ចេះជា ។ ជួនកាលយូរីវាយជំនួសគ្នា ។

ង៉ាគីអិន : តោះចាំទៅនិយាយបន្តឯត្រពាំងទៀត ។ អ្នកស្រីជំរាបលាសិន ហើយ ។

យូរី : សូមកុំភ្លេចថាខ្ញុំនៅចាំផ្ទះណា៎ ! ខ្ញុំខំចាំផ្ទះ (យូរីនិយាយទាំងរអាក់ រអួល)

អាគីរ៉ា : ទៃយូរី ! យកឃ្លោកដែលតា យ៉ាតាបេ គាត់ចែកជាកេរ្តិ៍ឱ្យមកឱ្យ បង បងទិញស្រាមក ។ ហើយយកកណ្ដៀវមកផង ។ នៅលើភ្នំ មិន សូមមានមនុស្សដើរ ច្បាស់ជាស្មៅដុះទ្រុបទ្រុលពាសពេញផ្លូវ ហើយ តោងតែកាត់វា ។ លឿនឡើងអូន ។

យូរី : ចាំ ! ចាំ !

ង៉ាតីអិន : យ៉ូយ សឱ្យស្វាចគួរឱ្យខ្លាច (មើលកណ្ដៀវ)

អាតីវ៉ា : (លើកកណ្ដៀវ) ឱ្យត្រូវពន្លឺលោកខែទើរឹតតែ ចាំងស្វាចទៅទៀត ។ រឿងសំលៀងកណ្ដៀវឥឡូវទុកងារឱ្យគ្នាចុះ គ្នាចេះចាំស្ទាត់ហើយ ។ មកខាងនេះ (ចេញទៅមុន)

យូរី : សូមប្រយ័ត្នខ្លួនណា៎ (និយាយទាំងរអាក់រអួលពេលចេញជូនដំណើរប្ដី ឱបកូនតុក្កា)

អាតីវ៉ា : ស៊ីហ្នឹងអូន? (បែរមើលក្រោយ)

យូរី : អាប្រុសកូនតូចថាចង់ជូនដំណើរលោកពុក (យកដៃអាវជូតទឹកភ្នែក) លោកអុំ ក៏អញ្ចឹងដែរ ឆាប់ត្រលប់មកវិញណា៎ កូនតូចទឹកណាស់ (មើលមុខង៉ាតីអិន ហើយចង្អុលទៅក្នុងផ្ទះ ឱនមុខទឹកភ្នែកស្រក់ទៅដី)

ង៉ាតីអិន : (លើកដៃទំនងដូចជាចង់ការពារទឹកភ្នែក) ត្រឹមត្រូវណាស់អត់អីទេ នាង ទោះជានៅក្នុងសុបិននិមិត្ត ក៏មានរឿងបែបនេះ (មើលចំទៅអាតីវ៉ា) នាងភ័យខ្លាចឯងទឹកស្រុក ហើយទៅចោលនាងបាត់ហ្នឹងឯង ។

យូរី : (អៀន បែរខ្នងភ្លាម)

អាតីវ៉ា : ឱ អញ្ចឹងបានជា គិតតែពីយំ ... ហ៊ឺ... ដូចកូនក្មេងមែនប្រពន្ធខ្ញុំ ។

ង៉ាតីអិន : អាតីវ៉ា ចូលទៅថើបលាបន្ដិចទៅ ហ៊ែ?

អាគីរ៉ា : ហ៊ីនិយាយតែផ្តាស គ្នាឥឡូវជាអ្នកចុងកាត់មាត់ញក អ្នកវាយជួង រកទៅធ្វើតាមគេអ្នកក្រុងម៉េចនឹងសមរ៉ិយ ។

ទាំងពីរនាក់ដើរចេញទៅ ។

យូរី : (សម្លឹងមើលមិនដាក់ភ្នែកមួយសន្ទុះ) នែកូនប្រុស លោកពុក អត់ទៅចោលយើងទេណ៎ា កូនណ៎ា ! ហ៊ឺ បិទភ្នែកគេងហើយ ចេះងក់ក្បាលឆ្លើយ នឹងម្តាយផង កូនចេះណាស់ (ថើបតុក្កា) កូនប្រុសញ៉ាំដោះទៅ ម៉ែអត់ឃ្លានទេ ញ៉ាំម្នាក់ឯងម៉េចនឹងឆ្ងាញ់ ។ តោះរៀបចំទុកដាក់ នឹងអាលគេង តែគេឃើញយើងនៅម្នាក់ឯង អ្នកភូមិច្បាស់ជាថាអញ្ចេះថាអញ្ចុះទៀតហើយ ខែភ្លឺផង បិទភ្លើងហើយបិទទ្វារ តោះ ! (ចេញទៅរានហាល បិទទ្វារ ហើយចាក់សោក្លឹកភ្លើងក្នុងបន្ទប់រលត់) ។

ចំរៀងខ្មោច :

ខ្មោចអសុរកាយដែលចេញដើរវេលាយប់ មានតាំងពីខ្មោចភ្នែកមួយ ខ្មោចសក់សេះ ខ្មោចអណ្តើកមានជើងវែង៧ញាក់ចានលើក្បាល ភេ យូហ៊ុជើង ៨ ឆ្មាព្រៃកន្ទ្រែងក្រហម ខ្មោចស្លឹកឫស្សី ខ្មោចកំសៀវទឹក ឆ្កែចចក ឆ្កែព្រៃពោះកំប៉ោង វាយពោះទូង៧ដើរ ខ្មោចស្រីពាក់ឆ្នាំង សើច ហោះ ហោះ ... បុរសស្រុកស្រែមុខស្មេអត់ញញឹម អត់សើច ...។

កសិករឈ្មោះ យោជូ ផ្ងារដួនដាក់ត្រីរស់ចូល មើលត្រីដោយទឹកមុខញញឹមញញែម ដើរចេញមក ។

យោជូ : ថ្ងៃនេះអាត្មាអញបានធ្វើការងារធំដុំណាស់ ។

ចាស់ៗគេថាឆ្នាំដែលមានព្រិលធ្លាក់ច្រើន គឺឆ្នាំដែលស្រូវបានផល បរិបូណ៌ហូរហៀរ ។ ឯឆ្នាំដែលរាំង គឺឆ្នាំដែលចាប់ត្រីបានច្រើន បឹងធំ បឹងតូច រីងរាំងហួតអស់ មានទឹករីមៗ ត្រីហែលខ្ញើកៗធ្វើឱ្យអាត្មាអញចាប់បានយ៉ាងស្រួល ( ត្រីរស់លោត) ហ៊ូ ! ស្រការប្រាក់ទេតើ? ធ្ងន់អស់ពីចិត្ត យ៉ាងហោចក៏ពីរដណ្ដប់គីឡូដែរនេះ ! អានេះធំជាងត្រីឈើ ដែលឯងឃើញគេព្យួរលើចង្រ្កាននៅផ្ទះមេឃុំទៅទៀត បើហូបវាឃើញថាស្ដាយ ត្រូវយកវាទៅលក់ឱ្យលោកតំណាងពុកមាត់ស្រមូម ប្រហែលជាបានថ្លៃ ។ នែ នាយរស់ ខ្ញុំយកនាយឯងទៅលក់ឱ្យលោកតំណាងស្រមូម ហើយ ! ជួយបន់ឱ្យលក់ឱ្យបានថ្លៃណាំ ! ឱ្យលក់ឱ្យបានថ្លៃណាំ ! ( ត្រីរស់លោត) ហ៊ូយ ស្រកាប្រាក់រ៉ើយត្រីនេះ ! ចាំងភ្លឺមើលតែមាស ! និយាយពីរឿងចាំងភ្លឺ និយាយពីរឿងស្រកា នាំឱ្យនឹកទៅដល់ឯនោះ ( មើលទៅផ្ទះខ្ទម) លោកគ្រូដែលវាយជួង វាយជួង ម៉ឹង ! ឯអ្នកនាងជាកូនលោកចៅអធិការនោះឮថា កាលពីរស់នៅក្នុងខេត្ត មានស្រកា ៨ ដុះលើ ខ្នងដែលជាខ្លួនពស់សុទ្ធសាធ ។ ... រួចមកណាំ នៅវេលាយប់ ពួកអាក្មេងខូចដែលរកទៅលបនាងនោះ ឡើងទៅលួចមើលក្នុងបន្ទប់ ស្រាប់តែឃើញពស់ស វែងមួយលូនព័ទ្ធពេន នៅជុំអ្នកនាងនោះរាល់ថ្ងៃ ។ មិនត្រឹមតែប៉ុណ្ណោះ អាសត្វពស់នោះ

ថែមទាំង ចេះព្រួសភ្លើងតាមភ្នែករួៗទៀត ហ្អុំក ! លោកគ្រូវាយជួងដូច ជានៅ រស់កក្រើក មិនទាន់អីនៅឡើយទេណាំ ! បែបមិនទាន់ពស់ រួតរឹតសម្លាប់នៅឡើយទេមើលទៅ។ មើលទៅ! ធម្មតាវាមិនដែលមានត្រីរស់ ឯណាមានស្រកាពណ៌ប្រាក់ ហើយស្រកានេះវាចាំងព្រិចៗ នឹងពន្លឺខែទៀត (មើលទៅត្រី រស់) អាណាក៏ស្មានថាអាត្រីឯងជាខ្មោច ឬក៏ជាពស់ដែរ រួចនរណាទៅហ៊ានចាប់ឯង បើមិនចាប់បានន័យថាមិនអាចក្លែមស្រាឆ្ងាញ់បានទេ ដូចមានអ្នកនាងយូរី ជាគំរូស្រាប់ ។ ហ្អាំ យប់នេះ ម៉េចក៏ ងងឹតឈឹងអញ្ចឹងលោកគ្រូវាយជួងត្រូវពស់លិទ្ធសំលាប់បាត់ ទេដឹង? កុំអាលសិនលបមើលសិន (ដើរលបៗ) ហើយទៅលប មើលតាម ប្រឡោះជញ្ជាំងខ្ទម) ។

ខ្មោចក្តាមមុខក្រហម មានរោមពេញខ្លួន ពាក់អាវក្រហមបៀមបារីស្លឹកសង្កែនៅចំហៀងមាត់ បង្អួយផ្សែងទ្រលោម លើកដៃទាំងពីរដាក់លើក្បាល ប្រុងប្រៀបដង្កៀបរបស់វា ហើយដើរទៅចំហៀងខ្ទាប់ៗ រួចលោកទៅខាំកំភួនជើងរបស់យោជូ ។

យោជូ : អូយ (ស្រែក) យោជូ ផ្ងារទៅក្រោយផាំង គ្រវែងត្រីរស់ដែលនៅក្នុងដូនទៅលើផ្កាត្រកួន ។ អូយ អាក្តាមចង្រៃ ! រួចភ្ញាក់ លោតផ្លោតរត់ទៅបាត់ ក្តាមដេញតាមដោយរត់ចំហៀងៗ។ ត្រីរស់ គឺជាព្រលឹងត្រីរស់ដែលបានស្លាប់ ចេញពីគុម្ពផ្កាត្រកួនរអិលៗ មាន

ស្រកាខ្មៅស ពាក់អាវ គីម៉ូណូមួយជាន់ ពាក់ស្បែកជើងរំភើយផាយ ផាត់ដូចស្រកី លាក់មុខក្នុងជួនបណ្ដើរ ដើរចេញមកបណ្ដើរ រួចមក គ្រវែងជួននោះចោល មុខស្លាំង នៅមាត់មានពុកមាត់ខ្មៅៗ ។ ក្ដាម ឃើញក៏ចេញទៅវិញ ។

ត្រីរស់ : (បើកមាត់ម្ដបៗ ដកដង្ហើមធំមួយខ្សាក) មនុស្សលោកបានទទួល ការរងគ្រោះពីការរីងស្ងួត ហើយវាពិបាកមកដល់ឯងជាសត្វទៅ ទៀត មើលទៅមិនខុសពីខ្ញុំដែលជាត្រីនៅក្រៅទឹកទេ ... ឱលោក ធំក្ដាមសូមអរគុណលោក ដោយលោកបានជួយខ្ញុំ ។

ក្ដាម : ចាំបាច់គុណស្រាយអី ទឹកគឺត្រី ត្រីគឺទឹក ។ រួចល្បងឯងវាយ៉ាងម៉េច បានជាទៅលោតចូលជួនមនុស្សអញ្ចឹង ក្រែងល្បីថាពូកែលោតហក់ ឡើងតាមជ្រោះឯណោះអី ?

ត្រីរស់ : វាអញ្ចេះ ខ្ញុំគិតថារកទៅលេងស្រុក ក៏រកផ្លូវកាត់ក្រែងវាឆាប់ ហើយក៏ហែលត្រដរកាត់បង្ហូរពិបាក ដល់អញ្ចឹងទៅវាទាក់ស្រកីនឹង ថ្ម រួចមកវាត្រូវ អារំបល់យក៏នោះចាក់ចំកន្លែងអត់ស្រកា ឈឺផ្ដាំ ថែមទៀត ។

ក្ដាម : អាស៊ីហ្នឹងឬ? (ក្ដាមរត់ទៅកៀបជួនដែលជ្រុះ)

ត្រីរស់ : តាំងពីរួចពីអាយក្សណានោះម្ដងមក គ្នាមិនដែលជួបការពិបាកដូច លើកនេះទេ ។ ឃីអាអ្នកស្រែជំលើយ ហើយហ្វេងហ្នឹងក៏អញ្ចឹងដែរ (លោតទៅជាន់ជួន)

ដូន : ខ្ញុំអត់មានធ្វើអីលោកទេ ខ្ញុំអត់ធ្វើអីផង (ចាំតែចារត់ត្រង់កន្ទុយទៅពូន)

ត្រីរស់ : អើគិតឱ្យសព្វៗទៅ ហ្នឹងមិនមែនអាឯងចង់ធ្វើអញ្ចឹងទេ អញដឹងហើយ ។ ល្មើយព្រលែងហ្មែងឱ្យរួចខ្លួនចុះ ទៅ ! (លែងដូនឫស្សីៗក៏រត់ត្រហេបត្រហបយ៉ាងលឿនទៅបាត់ទៅ) ហាស ហាស ហាសអូហ៎ មើលវាហោះ ទៅប្រញាប់ហោះទៅចំការល្ពៅឱ្យបាត់ពីមុខអញ ទៅ។

ក្អាម : មើលទៅដូចក្បាលមនុស្សហោះអញ្ចឹង រឺ គួរឱ្យខ្លាច ហ៊ឺ ... (សើច) នែត្រីរស់គិតទៅណាឥឡូវហ្នឹង?

ត្រីរស់ : អើគ្មារកទៅស្រុកកំណើតសិនហើយ ។ និយាយអញ្ចឹងគ្នាចុះតាមជ្រោះមក ឃើញពួកអ្នកស្រុក ថាអត់ភ្លៀង គ្មានទឹកចង់ឱ្យភ្លៀងបន់ស្រន់ព្រះនាងព្រីលស ឱ្យឡើងថ្លង់ដូចរុយខែ ៥ អញ្ចឹង។ គ្រាន់តែលើកទ័ពទទេ អញមិនថាទេ លេងគេឧបកិច្ចស៊ីគេទេរ៉ឺយ អាខ្លះកាន់ដែកគោល អាខ្លះកាន់ចង្កឹះដែក អាខ្លះកាន់ដាវកញ្ច្រោះ អាខ្លះទៀតកាន់ផ្លាំងកំបែកក្អិតខ្មៅអ៊ូញ ទៅប្រជុំឱ្យត្រៀបត្រា ។ ប៉ុណ្ណឹងនៅទ្រាំបានទេ គេថាសំណែនស៊ីគេទេរ៉ឺយ មានអាខ្លះកាន់ក្បាលឆ្កែប្រលាក់សុទ្ធតែឈាម អាខ្លះយួរក្បាលឆ្មា ខ្លះភ្នែកលៀន ខ្លះពាក់ពុកមាន់ ខ្លះខមលៀនអណ្តាត សឹងតែធ្លាក់ដល់ដី ធ្លាក់ឈាមពព្រិះពព្រុះ គគ្រិចមហាសែនគគ្រិច យកទៅសែន ។ មើលទៅឃើញ

ឆ្អែមចង់ក្អួត អញថាយកត្រសក់ទៅសែនអីក្រែងពួកណ្ដុរគ្នាចេញមកទទួលទានបានបុណ្យខ្លះ ម៉ែអើយពួកសាលាសង្កាត់ពិបាកទៅបោសសំអាតស្លាប់ហើយ ។

និយាយពីមេដោះទេពធិតាព្រឹលស នៅភ្នំយូណូតូងេ គឺយាយអាយុ ១០០ គាត់ឈរជំទែងនិយាយខ្សិបៗថា ទោះបីពួកឯងស្រែករហូតដល់ធ្លាយបំពង់កទៀត ក៏ភ្លៀងមិនធ្លាក់មកដែរ បើគេមិនចង់ធ្លាក់នោះ ។ រួចទៅខំយករបស់ក្រខិកក្រខ្វក់អីមកបាចរាយប៉ាយពេញវាលពេញកាល ។

គាត់ថាហើយក៏ទៅស្រុកគាត់វិញទៅ ។ គ្រាន់តែរឿងប៉ុននឹងវាមកធ្វើបាបស្រុកឯង យីអាមនុស្សពាល ។

ក្ដាម : ឱ អញ្ចឹង? អូ ! អូ ! រួចព្រះនាងព្រឹលស គិតថានឹងមិនប្រទានទឹកភ្លៀងឱ្យប៉ុន្មានឆ្នាំទៀតទៅ?

ត្រីរស់ : ហ៊ឺ ខ្ញុំមិនដឹងទេ ព្រះនាងកំពុងតែធ្លាក់ក្នុងសេចក្ដីស្នេហាចំពោះព្រះអង្គម្ចាស់ម្នាក់ នៅត្រពាំង មីនេសិងយ៉ា ឯភ្នំសងណោះ ។ លោកស្រលាញ់គេពេកទៅ លែងគិតឃើញអ្វីផ្សេងហើយ តើលោកមានពេលឯណាទៅគិតដល់រឿងខះរឿងប្រាំងរបស់មនុស្សលោកនោះ?

ក្ដាម : ព្រះកាមទេពមានឥទ្ធិរិទ្ធិណាស់ ។ តាមយោបល់គ្នា ព្រះនាងចាំបាច់អីទៅគិតច្រើន លោកមានស្លាបទេតើ? ម៉េចក៏មិនត្រដាងស្លាបនោះ ហោះទៅ គេងង៉ាមិណោ ភ្លាមទៅហ្ន៎?

ត្រីរស់ : បញ្ហាហ្នងហើយដែលហៅថាបញ្ហាហ្នឹង ! បើព្រះនាងព្រីលសហ៊ាន តែប្តូរទីលំនៅរបស់ទ្រង់ នឹងមានទឹកជំនន់ ធ្វើឱ្យលិចលង់ភូមិស្រុក នេះស្លាប់មនុស្ស សត្វ ភ្លាមឥឡូវហ្នឹងហើយ ។

ក្តាម : ស្អី ! ស្អី ! មានអ្វីជាបញ្ហានោះ? បើមានទឹកជំនន់ ទីលំនៅរបស់គ្នា មិនកាន់តែធំទូលាយទេ? គ្មានអ្វីគួរឱ្យគិតច្រើនទេ ឱ្យព្រះនាងទៅ ឱ្យឆាប់ៗទៅ !

ត្រីរស់ : ឯងភ្លេចហើយ នៅកន្លែងនោះមានព្យុះវង្វង ។ គឺជាខសន្យាដ៏រឹងជា មួយនឹងមនុស្សតាំងពីដូនតាមក យប់ថ្ងៃត្រូវវាយបីដង នៅពេល ដែល ពួកអស់នោះមិនភ្លេចវាយទេ ភូមិស្រុកក៏មិនងាយនឹងលិច លង់ទៅក្នុង បាតគង្គាទេ ។ នេះគឺការស្បថរវាងមនុស្ស និង អាទិទេព ។ ដូច្នេះព្រះនាងព្រីលស មិនអាចធ្វើអ្វីតាមចិត្តនាង ចង់ទេ ។ អញ្ចឹងហើយ បានជានាង ពិបាកចិត្ត រួចហើយនាង នឹក នាងពិបាក ...

ក្តាម : ពុទ្ធោអរហំ នៅខាងក្រោម គេចង់ភ្លេចពាក្យសំបថ ហើយរកជាន់ ស្រមោលជួង ។ ប៉ុន្តែភ្នំក្តី វាលស្រែក្តី ភ្លឺចែសដោយសារខែភ្លឺ ។ ផេះដែលទទឹកក៏មិនទាន់ធ្លាក់មកនៅឡើយ គ្នាត្រូវតែទៅជ្រលង ស្ទឹង ទៅត្រពាំង ដែលព្រះនាងនៅ ។ នែត្រីរស់ សូមឯងទៅជាមួយ គ្នា ។

ត្រីរស់ : អ៊ឺ ខ្ញុំយល់ស្របតាមឯង តែជាថ្នូរពេលខ្ញុំទៅស្រុក ឯងត្រូវជូនខ្ញុំទៅដែរណា៎ ព្រោះផ្លូវស្ងាត់ណាស់ ។

ក្ដាម : ដល់គ្រលប់មកវិញទៅត្រពាំងបិសាចពីរនាក់ណា៎ !

ត្រីរស់ : តស់យើងដើរតាមភ្លឺស្រែក្រោមពន្លឺខែ ទៅបណ្ដើរ ច្រៀងបណ្ដើរណា៎ !

ក្ដាម : ច្រៀងបទអីហ៎?

ត្រីរស់ : ច្រៀងបទមួយដែលមានទំនុកថា " ចូរយើងធ្វើឱ្យភ្នំទៅជាទន្លេ "

ក្ដាម : អ៊ឺ សប្បាយណាស់តើនែ !

គេដើរទៅពីរនាក់ ត្រីរស់បក់ស្រកីរញ៉ីរញ៉ូរ ក្ដាមផ្ទិតពុះចេញពីមាត់ភល១ ហើយច្រៀងទាំងពីរនាក់ ចូរយើងធ្វើភ្នំឱ្យទៅជាទន្លេ ។

លុះទៅដល់ជិតកន្លែងត្រពាំង គេក៏ឈប់ហើយសម្លឹងទៅរកត្រពាំង

ត្រីរស់ : ឈប់សិន ដូចជាមានអ្វីដើរសូតាមភ្លឺស្រែ មិនដែលឃើញទេនរណាហ្នឹង?

ក្ដាម : ហាស១ គួរឱ្យសង្ស័យ ។ មើល៍ លបមើលវាបន្តិច ។
(ទាំងពីរពួន)

យូរី : (ឱបកូនតុក្កា ស្លៀកពាក់ខោអាវយប់បញ្ចេញសាច់សស្រឡូន បើកទ្វារផ្ទះរកចេញទៅក្រៅ) ព្រះអើយចុះវេលារាត្រីក៏វែងអីវែងម្ល៉េះ? ធ្វើម៉េចឱ្យរដូវប្រាំងកន្លងទៅឆាប់បាន? កូនតូចគេងមិនលក់ទេ (ចំរៀង) ឱព្រះច័ន្ទអ្នកអាយុប៉ុន្មានហើយ ២០ឆ្នាំហើយ ហ្គាំ

ដូចជាញ្ញ នរណាគេច្រៀង ចូរយើងធ្វើភ្នំឱ្យទៅជាទន្លេ ឱដល់តែខ្វះទឹក ខ្លាំងពេកទៅ អ្នកភូមិចង់ឱ្យសូម្បីតែភ្នំក៏ឱ្យទៅជាទន្លេដែរ អាណិត ណាស់ លោកអើយ... ឱព្រះច័ន្ទភ្លឺល្អណាស់ ភ្លឺរហូតដល់មើលឃើញ ស្មៅដែលនៅជិតកំពូលភ្នំឯណោះ ។ ស្រមោលបងអាតីវ៉ា និង លោកភ្ញៀវ ប្រហែលជានៅម្តុំៗ ដើមស្រល់នោះហើយមើលទៅ តែកុំអីខ្លាចទៅដល់នោះ ច្រឡំវ៉ាសដៃប៉ះអីវីវហើយទៅវ៉ាលស្រែ ឯណោះវិញហ្ន៎ ! (ដើរវាងតាមក្រោយខ្ទមចូលទៅ)

(ត្រីអណ្តែង ពាក់មួកប្រផេះជិតខ្មៅ មុខក៏ខ្មៅ ដុះពុកមាត់ពីរសរសៃសៗ ពី ក្រោមច្រមុះ លូតឆ្វេង ស្តាំ រហូតដល់ដៃអាវ ផាយដែលមានពណ៌ ទឹកខ្មៅ ស្រគីវាងដូចស្បែកជើងកណ្តុរ ។ វ៉ាឈរលើជើងមួយ ដៃម្ខាងកាន់កន្សែងក្រហម ទ្រប្រអប់ដាក់សំបុត្រដ៏ល្អមួយ ដើរត្រេង ត្រាងចេញមក)

ត្រីអណ្តែង : យើងមកពីស្រុកឆ្ងាយ ... ដោយសារតែប្រាំងរាំងរីង ការធ្វើដំណើរតាមផ្លូវមកពិបាកអស់ពីចិត្តហួសពីការស្មាន ។ គេងើយមើលទៅមេឃដ៏ឆ្ងាយ) ឱ ទឹក ! សម្លាញ់ទឹក ! ហ៎ នៅលើមេឃជិតកំពូលភ្នំឯនោះ គេឃើញចំហាយទឹក ឱខ្ញុំសប្បាយចិត្តណាស់ ! ត្រពាំងបិសាចច្បាស់ជានៅជិតនោះហើយ ។ (ដើរទៅជិត)

(ត្រីរស់ ក្តាម ចេញមកបង្ហាញខ្លួនខាងមុខ)

ត្រីរស់ : អ្នកណាហ្នឹង? អ្នកណាហ្នឹង ដែលហ៊ានចូលមកដល់កន្លែងនេះហ្នឹង?

ក្អាម : យើងជាឆ្មាំទ្វារនៃស្រុកយ៉ាប៊ីសាវ៉ា ។ មុននឹងចូលត្រូវប្រាប់ពីប្រវត្តិរូបឯងសិន ។

ត្រីអំណ្ដែង : ( មួរឈើច្រត់នឹងស្រកី ហើយសម្លឹងតែ្មរ) ខ្ញុំមិនមែនជាមនុស្សដែលគ្មាននិស្ស័យទេ ។ ខ្ញុំជាអ្នកនាំសារពីព្រះអង្គម្ចាស់ ដែលនៅត្រពាំងសេងចាង៉ា នៃភ្នំ គេងវ៉ាមិណោ ភ្នំស ទៅថ្វាយព្រះនាងព្រីលស នៅត្រពាំងបិសាចនៃ មីគីទីដាតេ នាប្រទេសនេះ

ត្រីរ៉ស់ : ឱ ខ្ញុំធ្លាប់ឮព្រះនាមហើយ ព្រះសង្ឃខ្មៅ ឬ មិនមែន?

ក្អាម : ស្អីត្រីអំណ្ដែងហ្នឹង ជាលោកសង្ឃឬ?

ត្រីអំណ្ដែង : អ្នកទាំងពីរត្រូវជាព្រះរាជវង្សានុវង្សនៃព្រះនាងព្រីលសឬ? ឬជាញាតិសន្តាននៃត្រពាំងបិសាច? យើងបានជួបគ្នានៅកន្លែងនេះចំពេលល្អណាស់ ។ ខ្ញុំសូមពឹងលោកឱ្យជួយនាំផ្លូវទៅព្រះត្រពាំងផង ។

ក្អាម : សូមគំនាប់ ។

ត្រីរ៉ស់ : យើងមានការចង់ស្នើនឹងព្រះនាងក៏មកនេះ ។ ព្រះតេជគុណជាអ្នកនាំសាររបស់ព្រះអង្គម្ចាស់ឬ? តស់យើងខ្ញុំករុណាទៅជាមួយព្រះតេជគុណ ។ យើងអាចស្មានបានពីទឹកមុខដ៏សប្បាយរីករាយរបស់ព្រះនាងជាមុនបាន ។ យើងខ្ញុំឯនេះ ក៏មានកិត្តយសដោយសារនេះដែរ ។ តស់ព្រះសង្ឃនិមន្តទាន !

ក្អាម : ព្រះតេជព្រះគុណ !

ត្រីអំណ្ដែង : ( ឡើងហាត់ហោវហែលទៅមុខលែងរួច) ឈប់សិន ឈប់សិន ។

ត្រីរស់ : ព្រះតេជគុណ ប្រើព្រះអង្គហត់ មកខ្ញុំករុណាកាន់ព្រះហស្តប្រគេនទាន ។

ក្តាម : មកខ្ញុំករុណាជួយរុញគូថព្រះតេជគុណ

ត្រីអណ្តែង : ទេអាត្មាអត់មានហត់អីទេ កន្ទុយ ស្រកីនៅបក់នៅឡើយទេតើ ។ តែមកដល់កន្លែងនេះស្រាប់តែដូចជាបារម្ភ ...

ត្រីរស់ : បារម្ភអីតេជគុណ?

ត្រីអណ្តែង : ពេលខំធ្វើដំណើរអត់អីទេ លុះតែមកដល់ជិតព្រះត្រពាំងស្រាប់តែប្រអប់ដាក់សំបុត្រឡើងធ្ងន់កណ្តុកជុកតែម្តង ។ ខ្ញុំបារម្ភរឿងនេះឯង ។

ត្រីរស់ : ឱនេះហើយ ដែលគេហៅថា ទម្ងន់ត្រីរស់ ឱមិនមែនទេទម្ងន់ស្នេហា ! ហេតុតែទឹកចិត្តស្នេហានោះវាមានទម្ងន់ធ្ងន់ធ្ងរ គ្រាន់តែមកដល់ជិតព្រះត្រពាំង ទឹកចិត្តស្នេហារបស់ព្រះអង្គម្ចាស់ទាំងពីរត្របាញ់ចូលគ្នា នាំឱ្យទម្ងន់នោះវាឡើងទ្វេណា ព្រះតេជគុណ ។ ដូច្នេះប្រអប់ឡើងធ្ងន់នោះគ្មានអ្វីជាការគួរឱ្យភ្ញាក់ផ្អើលទេ !

ក្តាម : ទេខុសទេ តាមគ្នាយល់ប្រហែលជាព្រះនាងព្រីលសលោកចង់ប្រគេនរង្វាន់ព្រះតេជគុណដែលខំនិមន្តមកពីឆ្ងាយទេដឹង? ក្នុងនោះប្រហែលជាមាន មាស ប្រាក់ ស្រូវ អង្ករ ស្រាបៀរយៃមានពពុះហៀរ ឬក៏ត្បាល់កិនដ៏ធ្ងន់ទេដឹង?

ត្រីអំណ្ដែង : (ឆោឡោ) ទេ ទេ បើតាមអារម្មណ៍ដែលខ្ញុំទទួល ដូចជាមានស្ទី ប្រាប់ទេហ្នឹងនែ ! បើជាត្បាល់កិនវាមិនអីទេ ខ្ញុំខ្លាចតែសេចក្ដីនោះ សរសេរថា " ព្រះនាងបើតើនពីព្រះបន្ទំថ្ងៃពេលណា សូមកាប់ចិញ្ច្រាំ ត្រីអណ្ដែងនេះជាកង់ៗដាក់ស្ងោរជាមួយកន្ទាយ សោយទៅ ឱខ្ញុំ ខ្លាចណាស់ (ត្រីអំណ្ដែងញ័រខ្លួនចំប្រប់ ញ័រជើងតគាត់)

ត្រីរ៉ស់ : ចុះវាយ៉ាងម៉េច បានជាព្រះតេជព្រះគុណនឹងឃើញដល់រឿង អាក្រក់អាក្រីបែបនេះអញ្ចឹង?

ត្រីអំណ្ដែង : អត់ទេ ដល់តែប្រអប់ឡើងធ្ងន់ក៏នឹងដល់ទៅរឿងបាបកម្ម ដែលខ្លួនឯងធ្លាប់ប្រព្រឹត្ត ។ ណ្ហើយលាក់បាំងអីអាត្មានិយាយទាំងកាត់កេរ្ដិ៍កាត់ខ្មាសទៅចុះ ។ (ត្រីអំណ្ដែងក៏ងាកក្បាលទៅចំហៀង ហើយយកដៃអង្អែលក្បាល) ថ្មីៗនេះអាត្មាបានជិះខ្លាឃ្មុំទៅដំណាក់នៅត្រពាំង សេងចាងអ៊ា ពេលនោះគាប់ជួនជាបានឃើញនារីចាស់ម្នាក់មកកក់សក់ ស្រាតងូតទឹក ខ្លួនទន់ទលគកសដូចចាន ខ្ញុំក៏ភ្លេចអស់កិត្តិយសហើយដើរសៀវៗទៅលួកលាន់គាត់ ។ ឯព្រះអង្គម្ចាស់ អាត្មាលោកឃើញហើយ ខ្ទាល់ទ្រង់បានបញ្ជាឱ្យអាត្មា មុជទៅក្រោមបាតភក់ជាសញ្ញាឃុំឃាំងអាត្មា ។ លុះដល់ព្រលោកមានព្រះបន្ទូលឱ្យយករាជសារចៅថ្វាយព្រះនាងព្រីលស អាត្មានេះក៏អរកខិបកខុបភ្លេចគិតវែងឆ្ងាយ ហក់ចេញមកផ្លូច ។ ឥឡូវដល់តែគិតសព្វៗទៅដូចជាស្រៀវស្រគីដល់ហើយ (ញ័រទទ្រើកទៀត)

ក្ដាម : ហាស់ៗ (សើច) ព្រះសង្ឃ ! ព្រះអង្គចំជាមាំទាំមានកំលាំង មែនតែម្ដង មើល៍សូមចែកកំលាំងនោះ មកខ្ញុំករុណាខ្លះមកទាន ។

ត្រីអណ្ដែង : មែនគួរឱ្យចង់សើចមែន ។ ខ្ញុំខុសហើយ ទោះបីថាលោកមិនយកទោសដល់ប្រហារជីវិត ក៏មិនលែងអីលោកសរសេរក្នុងសំបុត្រឱ្យគេដកស្រកី ដកកន្ទុយ ពុកមាត់អាត្មា ហើយឱ្យគេចិញ្ច្រាំឱ្យខ្ទេចមិនលែងឡើយ ចប់ហើយ ចប់អស់ហើយ ! (យំដោយពិបាកចិត្ត) ធ្វើម៉េចទៅខ្ញុំ? (ឃើញបែបនេះត្រីរ៉ស់ និង ក្ដាមនាំគ្នាឱ្យបខ្សៀវគ្នា ហើយងក់ក្បាលផ្ងក់ៗ) ។

ត្រីរ៉ស់ : ឱព្រះសង្ឃដ៏ចំរើនអើយ វាអាចទៅជាអញ្ចឹងដែរណា៎ ! ខ្ញុំធ្លាប់ឮគេនិយាយនៅក្នុងរឿងបុរាណថា នៅតាមវិថី អូមី មានអ្នកជិះសេះម្នាក់ ជិះសេះមកដល់លើស្ពានក៏បានជួបនារីចម្លែកម្នាក់ ។ នាងនោះពឹងគេឱ្យយកសំបុត្រទៅឱ្យប្អូនស្រីដែលនៅចំងាយ ១០ យោជន៍ពីទីនោះ ។ លុះដល់កពាក់កណ្ដាលផ្លូវ កើតក្ដីសង្ស័យ ក៏លបបើកសំបុត្រនោះមើល ស្រាប់តែឃើញមានសរសេរថា : មកដល់នាងប្អូន បើបុរសជិះសេះនេះទៅដល់សូមគ្រៀវពោះវៀនតូច ពោះវៀនធំវា ។ ប្រសិនបើមិនបានដឹង ហើយចេះតែយកទៅឱ្យទៅមិនវិវរធំហើយនោះ ?

ត្រីអណ្ដែង : ព្រះ ! (ដួលផ្ងារក្រោយអុកគូថ ឮសូរតែញ៉ាច់)

ក្ដាម : ខ្ញុំថាលេងទេ ខ្ញុំថាលេងទេ ! ហាសៗ ហា ...

ត្រីរ័ស់ : សំណាងល្អណាស់ តេជគុណ បានបងក្ដាមមានដង្កៀបស្រាប់ មើល បងក្ដាមកាត់សំបុត្រនេះបន្តិចទៅមើល !

ត្រីអណ្ដែង : ចំរើនពរ សុំបងមេត្តាបើកមើល អាត្មាកាត់កេរ្តិ៍កាត់ខ្មាស ដាច់សីល ដាច់ទានអស់ហើយបង ! ឱ អរណាស់ ! កុំខឹងកុំសម្បារអីណាំ !

ក្ដាម : អត់អីទេៗ

ត្រីរ័ស់ : (និយាយខ្សិបៗ) សំបុត្រស្នេហាអ្នកធំខ្ពង់ខ្ពស់បែបនេះពួកយើង មិនងាយបានឃើញទេ ចង់ឃើញដល់ហើយ ។

ត្រីអណ្ដែង : (យកដៃទាំងពីរទ្រប្រអប់សំបុត្រដាក់លើក្បាល ខ្លួនញ័រចំប្រប់ហើយ ស្រាយខ្សែ) ត្រីរ័ស់ ក្ដាម ចូលទៅជិតគ្នា ហើយបើកគំរបប្រអប់ មើលទាំងពីរនាក់ ។

ត្រីអណ្ដែង : ហ្អេស !

ត្រីរ័ស់ : ហ្អាក !

ក្ដាម : ហ៊ឺ !

ត្រីអណ្ដែង : ម៉េចក៏សុទ្ធតែទឹកអញ្ចឹង? ឱទឹកដ៏ស្អាតដ៏ច្រើនអើយ !

ត្រីរ័ស់ : ឱ នោះព្រះនាងព្រីលសយាងមកហើយ ។

ត្រីរ័ស់ : ក្រាបដូចហែលលើទឹក ជាមួយត្រីអណ្ដែង ក្ដាម លុតជង្គង់ឱបដៃ ហើយងើបក្បាលយឺតៗ ។ ព្រះនាងព្រីលសនៃត្រពាំងបិសាចពាក់ អាវស្ដើង ឆ្លុះឃើញសាច់សដូចព្រីល ពណ៌ផ្ទៃមេឃ ដែលមានប៉ាក់រូប

អណ្តាតភ្លើង ក្រវាត់ខ្សែ អូប៊ី (ក្រវាត់) ស្រកានាគ ស្បែកសំពត់វែងខ្មៅ ពាក់ស្បែកជើងប្រាក់ ។ សក់នាងវែងហួសកែងជើង ។ នៅចង្កេះមានសៀតឈើច្រត់ ធ្វើពីលោហៈធាតុក្នុង អូប៊ី ដេញព្រិច១ដូចគុជ ។ នាងលូកដៃយកសំបុត្រមកអាន ។ នៅសងខាងនាង ខាងស្តាំមានមេដោះ អាយុ ១០០នៃភ្នំ យូណូតូងេ ដែលមានសក់សដូចសំឡី ពាក់អាវពណ៌ស្លឹកឈើទុំ មានអៀមពីមុខ។ នៅខាង ឆ្វេងមានភីលៀងឈ្មោះនាង ស៊ុំបាគី ដែលនៅភ្នំ គីណុ-មេតូងេ ពាក់ អាវពណ៌បៃតងខ្ចី សៀតផ្កា កាមេលីយ៉ានៅសក់ ។ អ្នកទាំងពីរឱន ក្បាលអង្គុយនៅអមសងខាងព្រះនាងព្រីលស ។ ព្រះច័ន្ទនៃថ្ងៃ ១៥កើត មិនទាន់រះទេ

ព្រះនាងព្រីលស : ឱ្យខ្ញុំអានព្រះរាជសារនេះយ៉ាងម៉េចបើខ្វះពន្លឺខែអញ្ចឹងនោះ?

មេដោះ : ស្បែរបស់ទ្រង់ភ្លឺត្រចះ ទ្រង់អាចអាននឹងពន្លឺស្បែបាន។

ព្រះនាងព្រីលស : បញ្ចេញអាវក្នុង ទាញលើកដាក់ពីលើក្បាល ហើយអានសំបុត្រ រួចហើយនាងធ្វើមុខស្រពោន ។

ស៊ុំបាគី : ព្រះនាង !

មេដោះ : ព្រះនាង !

ព្រះនាងព្រីលស : ឱព្រះអង្គម្ចាស់ដ៏ល្អអើយ ទ្រង់ក៏មានព្រះទ័យល្អម្ល៉េះ? ខ្ញុំអរណាស់ដោយបានដំណឹងល្អពីទ្រង់ ។ ម៉ែយាយខ្ញុំទៅហើយ !

មេដោះ : ទៅក្រសាលឯជើងភ្នំ ឬ ក្សត្រីយ៍?

ស៊ីបាតី : ទ្រង់យាងទៅដំណាក់វិញឬ?

ព្រះនាងព្រីលស : យាងទៅណា? (សួរតបបកមកវិញ)

មេដោះ : ទៅត្រពាំងបិសាច មិនអញ្ចឹងឬព្រះនាងកូន?

ព្រះនាងព្រីលស : ម៉ែយាយ ! និយាយតែផ្តាសទៀតហើយ ខ្ញុំទៅ គេងង៉ាមិណោ ណាំ !

ទាំងអស់គ្នា : ទៅ គេងង៉ាមិណោ !

ព្រះនាងព្រីលស : ចុះចាំបាច់ឱ្យយើងពន្យល់ច្រើនអី ក្រែង ដឹងហើយមិនអញ្ចឹង? យើងទៅត្រពាំង សេងចាង៉ាអ៊ីគេ ។ ទៅកន្លែងព្រះអង្គម្ចាស់ដែលជាម្ចាស់ព្រះរាជសារនេះហ្ន៎ ! (ថារួចនាងក៏មួរព្រះរាជសារដាក់ចូលក្នុងអាវឱបជាប់នឹងឱរ៉ា)

យាយមេដោះ : សូមក្សត្រីកុំភ្លេច ពីដើមមកប្រសិនបើព្រះអយ្យកោរអយ្យការទ្រង់ប្តូរព្រះដំណាក់ទោះជាទៅឯភ្នំក្តី ស្ទឹងក្តី ពេលនោះជីវិតមនុស្សសត្វរាប់ម៉ឺន រាប់ពាន់នឹងត្រូវក្សិណក្ស័យ ។ ហើយព្រះអង្គម្ចាស់នៃភ្នំ គេងង៉ាមិណោ ក៏បែបនោះដែរ បើទ្រង់ហ៊ានតែផ្លាស់ព្រះដំណាក់មកទីនេះភ្នំ

សក៏នឹងទៅជាបឹងទន្លេ ... ដូច្នេះអាពាហ៍ពិពាហ៍របស់ទ្រង់ទាំងពីរព្រះអង្គមិនអាចប្រព្រឹត្តទៅបានទេ។ (យាយមេដោះ ឈឺចុកចាប់ក្នុងទ្រូងជាដំបូងហើយ ដោយអាណិតព្រះនាង ជាទីស្នេហារបស់គាត់) ខ្ញុំម្ចាស់អាណិតព្រះនាងណាស់ ប៉ុន្តែមិនដឹងធ្វើម៉េចទេព្រះនាងកូន ។

ព្រះនាងព្រីលស : ម៉ែយាយតាំងនិយាយអញ្ចឹងទៀតហើយ ។ ម៉ែយាយកាន់ជើងតែមនុស្សលោករាល់តែដងហ្នឹង !

យាយមេដោះ : (សើចសោះកក្រោះ) នរណាទៅកាន់ជើងស្វាអត់កន្ទុយនោះម្ចាស់ក្សត្រិយ៍? ទោះជាយើងស្អប់គេក្តី ទោះគិតថាពួកនោះជាមនុស្សខ្វះសុជីវធម៌ក្តី ឬគិតថាគួរឱ្យជិនឬកគេក្តីឬ មានគំនុំត្រូវសងសឹកគេក្តី ក៏យើងមិនត្រូវបំភ្លេចពាក្យសន្យា ឬបំពានពាក្យសំបថដែរ ។

ព្រះនាងព្រីលស : តើនរណាសន្យា? នរណាស្បថ?

យាយមេដោះ : គឺព្រះរាជអយ្យកោរ អយ្យការ មិនដឹងប៉ុន្មានតំណមកហើយទេ ហើយអ្នកដែលបានសន្យាចុងក្រោយគេ គឺព្រះបិតា ព្រះមាតា តែម្តង ។ ព្រះនាងភ្លេចពាក្យបណ្តាំមុនទ្រង់សុគតហើយឬ?

ព្រះនាងព្រីលស : ថ្វីមិនចាំ? (នាងឆ្លើយធ្វើឆីយ)

| | | |
|---|---|---|
| យាយមេដោះ | : | ព្រះនាងមើលចុះ សូម្បីតែមនុស្សដ៏ខ្លះសុជីវធម៌ក៏ដោយ ក៏គេចេះគោរពពាក្យសន្យារបស់គេ ធ្វើតាមការសន្យារបស់គេហ្មត់ចត់ ដោយវាយជួង ម៉ោង ៦ព្រឹក ម៉ោង ៦ល្ងាច និង ម៉ោង ២យប់គ្មានខានដែរ ។ ដរាបណាដែលជួងនេះនៅតែលាន់ឮសម្លេង បីដង ជារៀងរាល់ថ្ងៃដូច្នេះទេ យើងមិនអាចបណ្ដោយឱ្យអ្នកស្រុកធ្លាក់ទៅនៅបាតទន្លេបានទេ ។ |
| ស៊ីបាគី | : | (ក្រោកឈរហើយហៅសេនាទាំងឡាយ) មកឱ្យលឿនឡើង ! តម្រៀបជួរគ្នាឆ្វេងស្ដាំ គេនាំគ្នាពាក់គ្រឿងសញ្ញាវុធតាមថ្នាក់ តាមលំដាប់ ខ្លះពាក់ក្រោះ ខ្លះពាក់ក្បាលខ្មោច ដូចយក្សដើរយប់ ។ |
| ខ្លា | : | ខ្លាមកហើយ ! |
| ត្រី ១ | : | បងប្អូនពីរនាក់ ខ្ញុំបាទត្រី ១ |
| ត្រី ២ | : | ខ្ញុំបាទត្រី ២ |
| | | ទាំងពីរនាក់ជាបងប្អូនគ្នា គេបន្លឺសម្លេងព្រមគ្នាប្រាប់ឈ្មោះគេ ។ |
| ដំបូក | : | ខ្ញុំជាយក្ស ផ្សំផ្អឹងនៅដំបូកលេខ ១៣ ។ |
| ក្ដាម | : | ខ្ញុំជាឆ្មាំទ្វារនៃ យ៉ាប៊ីសាវ៉ា ។ |

ស៊ីបាតី : ក្រៅពីនេះមានអាទិទេពច្រើនអង្គ ដូចជាអាទិទេពទឹក អាទិទេពដី ព្រលឹងស្រមោល អាទិទេពរូបរាងដូចគ្នា ក៏ច្រើន អាទិទេពអត់ភ្នែក អាទិទេពអត់ច្រមុះ អាទិទេពខ្លះរុំក្បាលនឹងក្រណាត់ប្រផេះ

ព្រះសង្ឃស្រមោល : យើងជាព្រលឹងស្រមោលមកដល់ហើយ ។ ពេលថាដូច្នេះគេឃើញមានដុំភ្លើងព្រលឹងជាច្រើន ឆេះភ្លឹបភ្លែត១ពីចំងាយមកផង ។

ត្រីរស់ : ពួកយើងជាសេនាបានមកជួបជុំគ្នាអស់ហើយ

ត្រីអណ្ដែង : លោកសង្ឃក៏បាននិមន្តមកទាំងញញើតញញើមដែរ ។

ព្រះនាងព្រីលស : សូមអរគុណ ដោយបានអញ្ជើញ និង និមន្តពីឆ្ងាយ ។ យើងនឹងសរសេរសារចំលើយ ទៅព្រះអង្គម្ចាស់ឥឡូវនេះឯង ។ ហេតុនេះហើយ បានជាយើងកោះឱ្យមកប្រជុំគ្នានេះ ។

យាយមេដោះ : ចម្លើយទៅព្រះអង្គម្ចាស់ត្រូវការសាក្សីឬ? ចុះឯណាទៅពិធីបញ្ជាម៉េចមិនឃើញមានព្រះនាងកូន?

ព្រះនាងព្រីលស : ទោះជាម៉ែយាយ យាត់ក៏ខ្ញុំទៅដែរ ។ ខ្ញុំត្រូវតែទៅគេងង៉ាមិណោ បើគ្មានអាជូងនោះទេ ពាក្យសន្យាក៏នឹងអស់ន័យដែរ ។ ...

សេនាចូរឯងនាំគ្នាទៅចាប់ទាញអាជូងនោះទម្លាក់មកដី ហើយវាយកំទេចវាឱ្យទៅជាផង់ធូលីភ្លាម !

យាយមេដោះ : ព្រះនាងកូនគិតថា បើទ្រង់បញ្ជាអ្វីៗនឹងកំរើក នឹងប្រព្រឹត្តទៅឬ? (ភ្នែកគាត់ចាំងព្រិចៗសំដៅទៅព្រះនាង) ព្រះនាងនៅតែមានព្រះសុវណ្ណី អត់គិតវែងឆ្ងាយទៀតហើយ ។ ព្រះអង្គបញ្ជាសេនាឱ្យមកជុំហើយ មានព្រះសុវណ្ណីតាមតែចិត្តនឹកឃើញ នេះបើព្រះអាទិទេពនៅលើមេឃពួមិនរវីរវទេឬ? ប្រសិនបើជីវិតមនុស្សក្ស័យ ព្រះនាងនឹងត្រូវពិន័យមិនខានទេ ។

ព្រះនាងព្រលស : ជីវិតមនុស្សសត្វ គ្មានទាក់ទងអ្វីជាមួយខ្ញុំទេ ម៉ែយាយ ។ ដើម្បីស្នេហាខ្ញុំសុខចិត្តលះបង់ជីវិតចោលម៉ែយាយ! សូមម៉ែយាយអនុញ្ញាតឱ្យខ្ញុំទៅណាំម៉ែយាយ ។

យាយមេដោះ : ខ្ញុំម្ចាស់អាណិតព្រះនាងណាស់ ម្ចាស់ក្សត្រីយ៍ ។ តែយើងធ្វើទៅពុំបានទេកូន ។ សូមនាងទ្រាំបន្តិចទៅ ។ ខ្ញុំម្ចាស់មិនឱ្យព្រះនាងចាំ ៣០ឆ្នាំ ឬ ៥០ឆ្នាំទេ ។ មនុស្សលោកសព្វថ្ងៃលែងស្គាល់ធមិព្រះហើយ ។ សូម្បីតែព្រះសង្ឃដ៏ចំរើនខ្លះក៏ទ្រង់ភ្លេចពាក្យសន្យារបស់ទ្រង់ដែរ ។ ខ្ញុំទើបតែនឹងឃើញអ្នកដែលបន្តចងភ្ជាប់ពាក្យសន្យា តែម្នាក់គត់ គឺជូងនោះ ! ខ្សែដែលចងជូងនោះមិនខុសពី

ខ្សែដែលគេយកសំបុកចាបទៅចងទេ ខ្សែចងក្ដី ចំណងក្ដីវានឹងដាច់ក្នុងពេលខាងមុខដ៏ខ្លីនេះ ។ ទំរាំដល់ពេលនោះសូមព្រះនាងទ្រាំបន្តិចណាំព្រះអង្គ ។

ព្រះនាងព្រីលស : ម៉ែយាយ និយាយតែរឿងទ្រាំ ម៉ែយាយមិនដែលចេះគិតពីទឹកចិត្តស្នេហាទេ។ នរណាគេអាចចាំដល់ព្រឹកបានម៉ែយាយ? ណ្ហើយបើគ្មាននរណាស្ដាប់បញ្ជាខ្ញុំទេ ខ្ញុំនឹងធ្វើខ្លួនឯង ។

ស៊ីបាតី : ឱ ម្ចាស់ក្សត្រិយ៍ !

យាយមេដោះ : ព្រះនាងទ្រង់មិនអាចធ្វើដូច្នោះបានទេ ។ ជួងនោះបើវាជាជួងធម្មតា ពុំមានបង្កប់នូវអត្ថន័យអ្វី ខ្ញុំម្ចាស់មិនបាច់ចាំព្រះបញ្ជាទេ ខ្ញុំម្ចាស់នឹងចាប់ភើចវា នឹងដៃដ៏សំគមរបស់ខ្ញុំម្ចាស់នឹងគ្រោមដៃខ្ញុំម្ចាស់ កុំសូម្បីតែជួងនោះទម្ងន់ដល់ទៅ ២០០គីឡូ ចង់ប៉ុន្មានតោនក៏ខ្ញុំម្ចាស់កំទេចដែរ។ ប៉ុន្តែទម្ងន់នេះ គឺជាទម្ងន់នៃកិច្ចសន្យា ។ ព្រះនាងយល់ទេ?

ព្រះនាងព្រីលស : កិច្ចសន្យាឬច្បាប់ គឺជាវត្ថុដែលមនុស្សចេះតែបង្កើតដោយគ្មានន័យ ស្រេចតែនឹងចិត្តរបស់គេ ។ ឱខ្សែព្យួរដែលចងខ្ញុំ ដែលបង្ខាំងខ្ញុំពីទឹកចិត្តរបស់ខ្ញុំនឹងទង្វើរបស់ខ្ញុំ ។ ឱយក្ស អាសុរកាយ បិសាច ពស់អាសិរពិសដែល

គេនាំគ្នាគិតថាខ្លួនរបស់ខ្ញុំ ដៃអាវ ជាយអាវ អ្នកឃាឃាំង ស្នេហាខ្ញុំ ។

ជូនតា ម៉ែឪ ពាក្យសន្យាក្ដី ពាក្យសំបថក្ដី គឺសុទ្ធតែធ្វើតាមឱកាស និង កាលៈទេសៈរបស់លោក ។ ជាមួយនឹងមនុស្សលោក នៅពេលណាដែលពេលវេលាកន្លងទៅពេលនោះជាការកំប៉ិកកំប៉ុកហើយ ។ ចុះបើខ្ញុំគ្រាន់តែបំពានកិច្ចសន្យានេះ មុនពេលដែលពួកមនុស្សលោកទាំងអស់ គេនឹងបំភ្លេចតែមួយដង្ហើមមុនសោះ តើវាខុសទាស់អ្វី? បើគេគង់តែបំពានវាដដែលជាដដែលនោះ? ឱសង្សាសំលាញ់ អូនឱបសំបុត្របង ខ្ញុំឆ្កួតលែងដឹងអីហើយម៉ែយាយ !

យាយមេដោះ : ឱមែន ! ព្រះនាងទ្រង់វក់ព្រះទ័យ លែងគិត លែងដឹងអ្វីអស់ហើយ ។ ជួងម៉ោ ង ៦ព្រឹក ជួងម៉ោង ៦ល្ងាច ។ បើបន្តិចទៀត មនុស្សលោកភ្លេចវាយ ជួងម៉ោង ២យប់នោះ ម៉ែយាយនេះ នឹងមិនចាំសូម្បីតែមួយប៉ព្រិចភ្នែកទេ ម៉ែយាយនឹងបីព្រះនាងដោយមិនចាំបាច់ពាក់ស្បែកជើងឱ្យ យូរការ ហោះកាត់ភ្នំនានាទៅ គេងង៉ាមិណោភ្លាមមួយរំពេច ទោះជាពេលនោះមនុស្សកំពុងស្លាប់ភ្លឺកំពុងរលំ ឬ ជើងភ្នំកំពុងតែស្រុតក្ដី ។

តែផ្ទុយទៅវិញ បើជួងនោះលាន់ ហើយយើងបំពានមិនគោរពសន្យាជាមួយគេអ្នកវាយព្រះជាម្ចាស់ទាំងឡាយទ្រង់នឹងដាក់បណ្ដាសារយើងហើយ ។ តើយើងត្រូវធ្វើយ៉ាងម៉េច?

ត្រីរស់ : នៅស្រុកនេះ កង្កែប នាគក្បាល ៩ នឹងបញ្ចូលដៃទន្លេទាំងឡាយឱ្យទៅជាទន្លេធំមួយ គឺទន្លេធំ ហ៊ីណូម៉ាភ៉ា។

ក្ដាម : ហើយនៅឯខេត្ត មិណូវិញ ដៃទន្លេនឹងរួមបញ្ចូលទៅជាទន្លេដ៏ល្បី គឺទន្លេ ហ៊ីប៊ីង៉ាភ៉ា ។

យាយមេដោះ : ព្រះនាងទៅនៅទន្លេទាំងពីរនោះទៅ ។

ស៊ីបាគី : ឱព្រះម្ចាស់ក្សត្រីយ៍នៃថ្មទាំង ១លានដុំ

យាយមេដោះ : ការធ្វើតាមទំនើងចិត្តនឹង ...

ទាំងអស់គ្នា : មិនបានទេ ...

យាយមេដោះ : រូបកាយព្រះនាង

ទាំងអស់គ្នា : សំខាន់ណាស់ ។

ព្រះនាងព្រីលស : ថ្លង់ណាស់ ឯងទាំងអស់គ្នា ! បើឯងចេះដឹងស្គាល់កិច្ចសន្យា កិច្ចសំបថ ចង់រស់យូរ រស់តែឯងទៅ ខ្ញុំមិនអាចបោលស្នេហាដើម្បីនឹងរស់ឱ្យបានយូរទេ ចេញទៅៗ (សេនាទាំងឡាយជ្រួលជ្រើមបែកខ្ញែក ម្ខាងទប់ ម្ខាងច្រានចេញ ម្ខាងវែកចេញ ចុងបញ្ចប់ក្សត្រីយ៍ក៏ស្ថិតនៅ

ចំកណ្តាលហ្វូងសេនា› យើងថាឱ្យចេញ ! ចេញភ្លាម ទៅ ! ព្រះនាងព្រីលស រំខានចិត្តពេកក៏ដកដិបងដែក ដែលចាំងនឹងពន្លឺខែព្រាក១មក។ សេនាទាំងអស់ភ័យ ថយក្រោយខ្សាក១ ។ ព្រះនាងដើរញាប់១មកជិត ហើយ ឡើងជណ្តើរថ្ម ទៅដល់សសរនាងអង្គុយ ចុះក្បែរជើងសសរជួងហ្គឹង...ឱព្រះអាទិទេពទាំងឡាយ ខ្ញុំគ្មានរឿងអ្វីជាមួយព្រះអង្គទេ ទោះជារូបរាងកាយ នាងព្រីលស នេះហើយរូបខ្ញុំត្រូវទទួលទណ្ឌកម្មពីព្រះ ក៏ដោយ នៅ ពេលដែលថ្ងៃរះ ហើយរូបខ្ញុំជាព្រីលនេះ ត្រូវរលាយខ្យល ដោយកំដៅនោះក្តី ក៏ខ្ញុំសប្បាយចិត្ត ដែរព្រោះខ្ញុំរលាយ ដោយសេចក្តីស្នេហា ចំពោះអ្នក ផ្សេង ។ ទោះជារូបរាងកាយវិញ្ញាណខ្ញុំត្រូវគេយកទៅ កាត់ចិញ្ច្រាំជា ៨ចំណិត ឬ ជាផង់ធូលីក្តី បើខ្ញុំបាន ស្រោចស្រប់ទៅដោយលោហិត នៃមនុស្សជាទីស្នេហា និង ត្រូវគេបូជា ទោះជាព្រលឹង ខ្ញុំក្លាយទៅជាកូនភ្លើង តូចមួយរបស់អំពិលអំពែកក្តី ក៏ ព្រលឹងនោះពិតជាហោះ សំដៅទៅភ្នំ គេងង៉ាមីណិ ដោយប្រាកដ ។ នាងលើក ដិបងដែកទៅលើ ដាក់ត្រង់ទៅលើ ដាវដេញ ព្រិច១

ដោយពន្លឺខែ ... ពេលនោះគេឮសម្លេងចំរៀង ដែលពុះ
ជ្រែកស្រមោលរាត្រីខែភ្លឺ ...

គេងទៅគេងទៅ កុំយំកូនពៅ
កូនតូចម៉ែអើយ ចុះមេដោះកូន
គាត់ទៅណាហើយ ទុកកូនឱ្យកើយ
ខ្នើយតូចតែមួយ ។
គាត់ដើរកាត់ភ្នំ ជ្រលងតូចធំ
ទៅភូមិស្ថានស្ថិត ទៅជួបម៉ែឪ
សាច់សារលោហិត រួចហើយទើបពិត
រកទិញបញ្ញើ ។
គេទិញស្ករស្នូក បង្អិលប៉ូក១
រួចរកទិញតែន មកធ្វើកូនម្តាយ
តូចកាយអនអែន កុំកូនអួលណែន
គេងឱ្យសុខទៅ ។

ព្រះនាងព្រីលស : (ខំផ្ទៀងត្រចៀកស្តាប់ បេះដូងឡើងរន្ធត់ស្រយង់ចិត្ត ហើយចុះដណ្តើរមកវិញ ស្រែកហៅ) ម៉ែយាយ ម៉ែយាយ សម្លេងអ្វីហ្នឹង?

យាយមេដោះ : នោះពីសម្លេងនាងយូរី កូនលោកគ្រូសង្គ្រាជ

ព្រះនាងព្រីលស : ឱ នាងយូរី ដែលមានរូបស្អាតនោះឬ? នាងកំពុងតែធ្វើអ្វីហ្នឹង?

យាយមេដោះ : នាងកំពុងតែឱបកូនតុក្កា ច្រៀងបំពេរ ដើម្បីបន្ធូរទឹកចិត្តដែលកំពុងតែនឹកដល់សង្សារ ដែលឃ្លាតទៅឆ្ងាយ ។

ព្រះនាងព្រីលស : ឱ ! នៅពេលដែលព្រាត់ពីអ្នកដែលយើងស្រលាញ់ បើយើងច្រៀង យើងអាចបន្ធូរចិត្តយើងបានឬ ម៉ែយាយ?

យាយមេដោះ : ត្រូវហើយម្ចាស់ក្សត្រីយ៍ ។

សេនាទាំងឡាយ : ម្ចាស់ក្សត្រីយ៍ សូមព្រះនាងច្រៀងទៅព្រះអង្គ ។

ព្រះនាងព្រីលស : ខ្ញុំគិតច្រើនពេក ភ្លេចអ្វីៗអស់រលីង ។ បើខ្ញុំធ្វេសប្រហែស ហើយធ្វើឱ្យភូមិនេះលិចលង់ ពេលនោះជីវិតនារីដ៏ស្អាត យូរី ក៏នឹងត្រូវទៅនឹងគេនឹងឯងដែរ ។ គេបានវាយជួង ការវាយនេះជាទង្វើមិនល្អសំរាប់យើងមែន (ចុះជណ្តើរស្ងៀមស្ងាត់) ប៉ុន្តែចុះប្តីប្រពន្ធពីរនាក់នេះ ក៏ស្រលាញ់គ្នាម្ល៉េះ ! គួរឱ្យច្រណែន គួរឱ្យខ្ពាញ់ ... ម៉ែយាយ ...

យាយមេដោះ : (ស្រក់ទឹកភ្នែក) ម៉ែយាយសប្បាយចិត្តណាស់ព្រះនាង

ព្រះនាងព្រីលស : (និយាយទៅរកស៊ីបាគី) នាងស៊ីបាគីចេះច្រៀងទេ?

ស៊ីបាគី : ព្រះមែម្ចាស់ ខ្ញុំម្ចាស់ចេះច្រើនដែរ ។

ត្រីរស់ : អ្នកនាង ស៊ីបាគី ចេះច្រៀងច្រើនជាការល្អហើយ តែសុំកុំច្រៀងបទដែលកំពុងតែទទួលការនិយមពីប្រជាជន គឺ

បទដែលច្រៀងថា ឱត្រីរ៉ស់នៅក្នុងត្រពាំងអើយ ត្រីរ៉ស់ស្រកាក្រហម ឆាប់ចេញមកអាយ ហូបនំចេក ណាំ ខ្ញុំខ្មាសគេណាស់ ។ វាដូចជាចំរៀងដែលមើលងាយត្រីរ៉ស់ជ្រុលពេក ។

ស៊ីបាគី : យីល្បែងនេះ ចេះដល់ហើយ !

សេនា : សើចទាំងអស់គ្នាគីល

ព្រះនាងព្រីលស : ខ្ញុំរកតុក្កាមកឱបសិនបានច្រៀង ។ ណាំអ្នកនាំសារព្រះអង្គម្ចាស់ !

ត្រីអំណ្តែង : ករុណាថ្លៃវិសេស ! តោះយើង សរសេរឆ្លើយតបទៅព្រះអង្គម្ចាស់ទាំងអស់គ្នា ស៊ីបាគី ចូរនាងទៅយកប្រអប់ដាក់ព្រះរាជសារ ... ឯសេនាឯទៀត ខ្ញុំសូមអត់ទោសដែលបានធ្វើឱ្យហត់គ្រប់គ្នា ។ (ទាំងអស់គ្នាឱនក្បាលគំនាប់ គេនាំគ្នាច្រៀងថា : « ស្គរតូច មានដងបង្ហិលមានខ្សែដែលចងគ្រាប់សណ្តែកបង្ហិលប៉ះទៅឮប៉ូក១ និងគែន និង កង្ហារដែលត្រូវខ្យល់ទៅប៉ះកូនលោកដែលកំពុងក្រោកឈរ » ច្រៀងបណ្តើរ វាតជូរជាពីរជូរឆ្វេង ស្តាំ រួចមកសេនាទាំងអស់ក៏ប្រជុំគ្នាម្តងទៀត ។ ដុំភ្លើងរលត់បាត់អស់ ។) នៅតែពន្លឺព្រះច័ន្ទ ឆ្លៃលួង

ឆ្ងាយ កុកយំនៅក្បែរៗ។ នាងយូរី លាត់ជាយសំពត់កាន់ រត់ប្រហោបត្រហបមកពួនក្នុងផ្ទះខ្ទម។ ពីក្រោយនាង មេភូមិឈ្មោះ ហាត់ស៊ីអូ រត់ដេញតាមនាងជាមួយ នឹងអ្នកភូមិឯទៀតៗ ។ ពីម្ខាងទៀត អ្នកតំណាងចៅ អធិការវត្ត តាគីសែង អ្នកលេងចំបាច់ ឡូស៊ីគេ ហើយ នៅពីមុខពីក្រោយគេមានអ្នកភូមិ ៥នាក់ អេបូស៊ី ស៊ីអូ សូស៊ីគី ស៊ីជោ និង អ៊ីដេតាធី ។ ពួកគេប្រកប ដោយគ្រឿងអាវុធ ហើយដឹកគោខ្មៅធំមួយចេញមក។ អ្នកកាន់ខ្សែគោ គឺអ្នកលេងចំបាប់ ។

អ្នកភូមិ ១ : នោះវាចូលទៅពួនឯក្នុងហើយ ទៅហើយ !

អ្នកភូមិ ២ : ឯងឹតឱ្យស្ងួបតែម្តងវ៉ើយ !

ហាត់ស៊ីអូ : ទោះជាបិទភ្លើង ក៏មីនាងឯងគ្រាន់តែជាចង្រិតមួយ ប៉ុណ្ណឹង ! វាវតែបន្តិចទៅចាប់បានហើយ ។

កាំងប៉ាជី : ទៅ ចូលទៅចាប់អូសវាចេញមក អ្នកភូមិ ៤-៥នាក់ ចូលពព្រិសពព្រុសទៅ ។ នៅក្នុងផ្ទះគេឮសម្លេង ហ្ហា ហ្ហា ! ។ ទ្វារបាក់បែក យូរី ធ្វើមុខមាំ ពីឆ្វេងពី ស្តាំ គេលើកនាង ។

យូរី : អ្នកឯងចូលមកផ្ទះគេធ្វើផ្តេសផ្តាស !

កាំងបាជី : គ្មានផ្ទះគេផ្ទះឯងអីទេវ៉ើយ នេះគឺស្រុក ស៊ីកាមី ស្រុកដែលមានភូមិ ៦ ។

ហាត់ស៊ីអូ : នែនាងស្រី ដីឡើងរឹងមើលតែគេដុតអស់ទៅហើយ សឹងតែក្លាយទៅជាធ្យូងហើយ ។

តាគីសេង : (ចេញមកភ្លាម) នែនាងយូរី ដូចជាពិបាកមើលណាស់ ស្រែកហៅអ្វី? អំបាញ់មិញខ្ញុំស្រែកប្រាប់តាមផ្លូវរួចហើយ ថាយើងនឹងយកនាងទៅបូជាយញ្ញ ទោះនាងចង់ឬ មិនចង់ក្តី ព្រោះដូចដឹងស្រាប់ហើយថា ភូមិទាំង ៦ អស់ទឹករលីងហើយ នាងត្រូវជួយស្រូវ ៥០០០០ ថាំង ជីវិតមនុស្ស ៨០០០នាក់ ហើយព្រមទៅធ្វើជាគ្រឿងសំណែនដង្វាយបូជាយញ្ញ។ តាំងពីតូចមកនាងក៏ធ្លាប់ដឹងហើយ ថានៅពេលប្រាំងបែបនេះ គេតែងតែយកនារីដ៏ស្អាតលើសគេនៅក្នុងភូមិ ទៅសំរាតហើយបូជាយញ្ញ ។

យូរី : (ញ័រចំប្រប់) យី !

តាគីសេង : ទៅ ! ឡើងជិះគោខ្មៅតាមសំរូលទៅ។ ទៅតាមសំរូល វាគ្រាន់បើជាងឱ្យគេចាប់បង្ខំ ឱ្យជិះទាំងគ្មានកូប រួចគេនឹងយកពួរមកចងផ្ដោបនាងទៅនឹងគោ ។ បើនាង

ព្រមគេមិនចងទេ គឺគេគ្រាន់តែយកនាងឯងទៅសន្និង នៅកណ្តាលភ្នំ ដើម្បីបូជាចំពោះនាគរាជដែលនៅត្រពាំង បិសាចប៉ុណ្ណោះ គេមិនសំលាប់នាងទេ គេគ្រាន់តែចង នាងល្អឯងស្រាតលើខ្នងគោនៅមាត់ត្រពាំង គេដុត គោកាប់ក្បាល និង កន្ទុយវាសែន ។ ឯសាច់វាអ្នក ភូមិកាត់ផឹកស្រា រួចមួយសន្ទុះពពកខ្មៅនឹងផុសព្រោង ព្រាតហើយភ្លៀងនឹងធ្លាក់ជាប់គ្នា ៣ថ្ងៃ។ ស្រែចំការ នឹងរីកស្រស់បំព្រង ។ ពីដើមមកគេតែងតែធ្វើអញ្ចឹង មកយូរី គ្មានពិបាកអ្វីទេ ទ្រាំតែបន្តិច ហើយដើរទៅ មុខឈរគោរពលោកមេស្រុក ហើយនិយាយតែពីរបី ម៉ាត់ថា ខ្ញុំសូមពលីខ្លួន ។ ឆើបឡើង នៅចាំដល់ណា ទៀត !

យូរី : លោកពូ ! ខ្ញុំមិនប្រកែកទេ ។ តែសូមចាំបង អាគីរ៉ា ជាប្តីខ្ញុំ ។ ឱ លោកអ្នកសូមមេត្តាខ្ញុំផង ខ្ញុំលើកដៃពីរ សំពះលោក ។ រឿងបូជាយញ្ញ ហេតុអ្វីបានជារូបខ្ញុំ...

កាំងប៉ាជី : ថាស៊ីហ្គីងហ៊ែស !

ហាត់ស៊ីអូ : នាងឯងនេះហើយឈ្មោះ យូរីនោះមែនទេ?

យូរី : លោកពូ សូមចាំបង អាគីរ៉ា សិន ។ ខ្ញុំសូមអង្វរ ។

តាគីសេង : អានោះវាជាប្តី ! មិនដឹងជាស្អីទេ អាគីរ៉ា អាគីរ៉ា អញហួសចិត្ត ! ថ្ងៃនេះសូមចិត្តហើយ កុំវាយជួង ម៉ោង ២ ឱ្យសោះរើយ ! ក្រោកឡើង ! ក្រោក !

កាំងបាជី : នាងឯងតែមិនស្តាប់ទេ យើងចងណាំ !

ដេងយី : នេះគឺសំរាប់ភូមិស្រុកយើងទេ វាគ្មាននរណាខុស នរណា ត្រូវទេ ។ អាណិតនោះវា អាណិតហើយ !

កាំងប៉ាជី : លោកគ្រូ ទៅមិនរួចទេ ទាន បែបៗនេះ !

តាគីសេង : ចាប់បង្ខំវាទៅអត់អីទេ !

កាំងប៉ាជី : មក ! មក ! ពួកអ្នកភូមិរត់មកឡោមព័ទ្ធយូរី ។ យូរី រត់ឆ្លេឆ្លា ។

ហ៊្សូស៊ីគេ : មើលទុកងារឱ្យខ្ញុំម្តង!វាលោទៅឱបយូរីជាប់ ស៊ីជោរ ជួយចាប់ ហើយចាប់ដាក់ទៅឱ្យក្រាបលើខ្នងគោ ។

យូរី : ទេ ! ទេ ! (បំរះ) គេយកខ្សែមកចងនាងភ្ជាប់ទៅនឹង ខ្នងគោ យូរី ផ្កាប់មុខលើខ្នងគោ ។ ភ្លូងសក់នាងក៏ រំសាយជ្រុះសក់ដែលឡើងសើងម៉ើងរហូតដល់ក្រចក ជើងគោ ។

ដេងយី : អត់អីទេ យើងទៅព្រៃហើយដល់វេលាបូជាយញ្ញតែ ម្តងសឹមសំរាត ។ នៅទីនោះលោកម្ចាស់ដីធំដែលឥឡូវ

ធ្វើតំណាងរាស្ត្រ លោកធំៗ អ្នកភូមិក៏នាំគ្នាមកមើលពិធីនេះដែរ ។

ដេងយី : អូហ៍អញ្ចឹង?

ហាត់ស៊ីអូ : តស់ប្រញាប់ឡើង !

កាំងប៉ាជី : អ្នកទាំងអស់ខំឡើង ហាស់ ហាស់ ទាំងអស់គ្នាប្រុងប្រៀបនឹងចេញដំណើរ ។

អាគីរ៉ា : (មកដល់ភ្លឺប ឈរពាំងមុខនៅមុខផ្ទះរបស់ខ្លួនយ៉ាងក្លាហាន គេហូតកណ្ដៀវដែលស៊កនៅនឹងចង្កេះ ហើយកាត់ខ្សែដែលចងយូរីផាច់ គ្មាននិយាយមួយម៉ាត់)

យូរី : (មើលភ្លាម) បងអាគីរ៉ា (រួចក៏រមៀលធ្លាក់ពីខ្នងគោរត់ទៅឈរក្រោយអាគីរ៉ាពួន ឱបចង្កេះអាគីរ៉ា) ប្ដីសម្លាញ់ បងមកទាន់ពេលល្អណាស់ ម៉េចបានជាមកអញ្ចឹង ឱ ! ម៉េចបងឆាប់មករកខ្ញុំវិញអញ្ចឹង? ហ្ហ៎?

អាគីរ៉ា : (ពាំងយូរីពីក្រោយខ្នង លើកកណ្ដៀវត្រង់ទៅមុខ ហើយឈរសម្លក់អ្នកភូមិទាំងឡាយ រួចមកនិយាយដោយស្ងប់ស្ងាត់ថា) ពួកយើងរកធ្វើដំណើរទៅត្រពាំងបិសាច លុះដល់ចម្ងាយ ១ភាគ៣ ហើយស្រាប់តែឮសូរពីក្រោយប្រហែលម្ភៃត្រពាំងមក ល្មើយៗ

នូវសំលេងបំពេរកូននោះត្រូវនឹងពន្លឺខែទៅប្រៀបដូចជាគេភ្ជាប់ទឹកសន្សើមនៃផ្កានានា ហើយដូចជាគេត្បាញស្មៅទាំងឡាយ ឱ្យទៅជាគោមនៃកំរាលព្រះឱ្យឃើញខៀវ ... មិត្តបងគេរំភើបចិត្តណាស់ ។ យ៉ាម៉ាសាវ៉ា មានកូន តូចអាយុ ៣ឆ្នាំ... គេនឹកស្រុកហើយទ្រាំលែងបាន។

នឹកឃើញថាពុំគួរមកវង្វេងវង្វាន់ក្នុងព្រៃដ៏ជ្រៅ នៃភូមិ ស្រុកមួយដែលមិនដែលស្គាល់ដូច្នេះទេ ចាំមកម្តងទៀតឆ្នាំក្រោយ ។ ខ្យល់បក់ត្រជាក់រងាអស់សព្វសារពាង្គកាយ ។ ឯរូបបងឯនេះក៏ហាក់ដូចជា ចេះតែយ៉ាងម៉េចទេ។ នេះតែនឹកមកអូន។ រួចយើងក៏ប្រញាប់ ត្រលប់មកវិញភ្លាមមក (អាគីរ៉ានិយាយធម្មតាទៅរក យូរី ព្រមទាំងបែរទៅរកនាង បន្ទាប់មកគេងើយមើលលោកខែ រួចលើក រួចហើយផឹកស្រាដែលនៅក្នុងនោះ) យូរីងើប អាគីរ៉ាទប់ខ្សែមួយកដែលចង នៅនឹងក ទាញឃ្លោកចេញ ។ យូរីទទួលឃ្លោកពីអាគីរ៉ា ហើយយកទៅទុកលើរានហាល។ យូរីឱបដៃ អាគីរ៉ា ដែលកាន់កណ្តៀវ ។

អាគីរ៉ា : ម៉េចក៏មិនទៅវិញ ឯងទាំងអស់គ្នា។ នៅធ្វើអីទៀត?

ហាត់ស៊ីអូ : អញសូមប្រាប់ឯងឱ្យដឹងទៅចុះ អញអាណិតឯងដែរ ចូរឯងចេញពីភូមិនេះទៅ !

អាគីរ៉ា : ឯងម៉េច? ឯងមិនឱ្យអញនៅភូមិនេះ អញ្ចឹងឬ?

ហាត់ស៊ីអូ : អើ ! ដូចឯងដឹងហើយ ឬបើមិនដឹងទេ មានតែឯងជាមនុស្សមិនគ្រប់ទឹក។ សព្វថ្ងៃនេះប្រាំង រាំង។ គ្មានភ្លៀងមួយតំណក់ទេ។ ឯងកំពុងតែជឿជំនឿអកុសល ហ៊ុំជួងនោះហ៊ុំ ! ឯងធ្លាប់ថាបើខានវាយម្តង ស្រុកភូមិ នឹងលិចលង់ក្លាមមួយរំពេច ។ ភូមិនឹងទៅជាទន្លេ ! អើគ្នាចង់បានអាហ្នុង ហ៊ុំក ! ដូច្នេះពីយប់នេះទៅសូម ឈប់វាយ ជាដាច់ខាតជាបន្ទាន់ ។ តាំងពីឯងវាយជួងមក ស្អីបានឈ្មោះថ្មីថា តាវាយជួង តាវាយជួងផង ! ហ៊ឺះ ហ៊ឺះ អញជិនឬកណាស់ កួតឥឡូវហើយ !

អ្នកភូមិ ២-៣ : ហ៊ឺ ព្រឺសម្បុរណាស់ !

អ្នកភូមិ ៤-៥ : អាគ្មោង អា ដំបងមូល (ខឹងស្រែកដេរ)

ហាត់ស៊ីអូ : ចំពោះភូមិនេះ អាឯងគ្មានតម្លៃអ្វីបន្តិចទេ មិនបាននឹងអាចមិធ្វើដីផង ! ណ្ហើយថាឱ្យត្រង់ទៅចុះ អាឯងជា

មនុស្សចោលម្សៀតឥតបានការ គ្នាសូមហាមឱ្យឈប់វាយជួង ហើយជាមួយគ្នានេះ សូមចេញពីភូមិនេះជាប្រញាប់!

អ្នកភូមិ ២-៣ : ត្រូវហើយ ! ត្រូវហើយ ! ចេញ ! ចេញ !

អាគីរ៉ា : កុំបារម្ភអញគង់តែទៅទេ។
បើពួកឯងឱ្យអញឈប់វាយ ជួង ។ ឱល្អ !
តើអាណាមួយដែលចង់នៅវាយជួងនោះ!
កុំភ័យអញចេញទៅមួយរំពេចហ្នឹងហើយ !

អ្នកភូមិ ៤-៥ : ចេញទៅ ចេញទៅ ! (និយាយព្រមគ្នា)

អាគីរ៉ា : មកយូរី ! ទៅយើង ! (ឃើញយូរីនៅរៀបចំ) មិនបាច់យកអីទៅទេ មកជើងទទេមក បងនឹងពរអូនដើរតាមភ្នំ (ទាញដៃយូរី) (នាងយូរីយកដៃអាវបាំងមុខដើរកាត់មុខមនុស្សម្នាទាំងឡាយ) ង៉ាគីអិន លបមើលហើយដើរចេញមក ។

កាំងប៉ាជី : (ស្រែកដោយសំលេងគ្រោតគ្រាត) ឈប់សិនអានេះ

អាគីរ៉ា : (ធ្វើជាមិនឮ ហើយដើរភ្លឹបៗ)

កាំងប៉ាជី : ឈប់ អាចោលម្សៀត !

អាគីរ៉ា : ស្អី? (សួរបកមកវិញ)

កាំងប៉ាជី : មិនត្រូវលួចរបស់អ្នកភូមិទៅជាមួយទេ !

អាតីវ៉ា : អញគ្មានយកធូលី ឬ សំរាមមួយសរសៃរបស់នរណាទៅទេ !

កាំងប៉ាជី : នាងនោះជារបស់អ្នកភូមិ !

អាតីវ៉ា : ទេ យូរី ជាប្រពន្ធអញ !

ដេងយី : បិទមាត់ទៅអាភ្លើ នាងនេះជារបស់អ្នកភូមិ ។

អាតីវ៉ា : របស់អ្នកណាក៏គ្មានទើសអ្វីអញដែរ ។ យូរីចង់មកជាមួយអញ ទើបមកនេះ បើនាងចង់នៅនាងនឹងនៅហើយ ។ មើលទៅ នាងឱប ហាងីវ៉ាវ៉ា ជាប់ អត់ព្រមលែងទេ (ញញឹម) បើអញទុកនាងទីនេះ នាងច្បាស់ជាសំលាប់ខ្លួន ។ មនុស្សយើងមានសិទ្ធិធ្វើអ្វីតាមចិត្តខ្លួនចង់ ។ ពួកអាឯងទាំងអស់មិនយល់ទេរឿងអញ្ចឹង ! និយាយទៅក៏អត់បានការដែរ ! តស់យូរី ! ទៅអូន !

តាគីសេង : (ដើរត្រេតត្រតចេញទៅមុខ) នែយុវជនឈាមរាវភ្លា មិនអាចអត់ឱនចំពោះការអត់ខ្មាសអៀន របស់អាឯងបានទេ ក្មួយខ្ញុំមិនត្រឹមតែជារបស់អ្នកភូមិនេះទេ ថែមទាំងជាជីវិតរបស់មនុស្ស ៨ពាន់នាក់ ថែមទៀត ។ យើងត្រូវយកនាងទៅបូជាយញ្ញ ។ ការនាំនារីសំរាប់បូជាយញ្ញចេញទៅបែបនេះ គឺដូចជាសំលាប់ជីវិតអ្នកស្រុក

៨ ពាន់នាក់ បែបនោះដែរ ។ បើឯងមិនទុកយូរីទេ កុំថា ឡើយតែមួយជំហាន តែបន្តិចក៏ឯងមិនអាចចេញពីភូមិ នេះបានដែរ ។ យូរី ជាជីវិតមនុស្ស ៨ពាន់នាក់ ! ម៉េច គិតយ៉ាងម៉េច?

ង៉ាគីអិន : ឈប់សិន ! (ស្រែកហើយដាក់យូរី ឱ្យឈរកណ្ដាល ខ្លួន ឯងនិងអាគីរ៉ាឈរសងខាង) ចម្លើយនេះ ហាងីរ៉ារ៉ា ប្រហែលជាពិបាកឆ្លើយណាស់ ! ខ្ញុំសូមឆ្លើយជំនួស ។ ទោះមានរឿងអ្វីកើតឡើងក៏ដោយ ខ្ញុំដឹងច្បាស់ថានាង យូរី គឺជាអាយុជីវិតរបស់អ្នកភូមិ ។ ដោយសារតែអញ្ជឹង ហើយបានជាព្រះអង្គម្ចាស់ម្នាក់ ដែលជាកូនប្រុសទី ៣ នៃត្រកូល ហាងីរ៉ារ៉ា បានមកសុខចិត្តលះបង់អ្វីៗហើយ នៅទីនេះលាក់ខ្លួនវាយជួង ដោយសារតែរូបដ៏ល្អរបស់ នាងតែម្យ៉ាង។ ចំពោះពួកឯង ដែលចេះដល់ទៅអាច ធ្វើបាបនាង យកនាងចងនឹងខ្សែពួរ ដាក់លើ ខ្នងគោធ្វើ ឱ្យនាងខ្មាសអៀន ខ្ញុំគិតថាគ្មានប្រយោជន៍ អ្វីនឹង ពន្យល់ ពួកឯងទេ ឯងចងនាងអូសអាក្រាសមុខ ប្រជាជនក្រោមពន្លឺខែ សំរាតខោអាវនារី ដ៏ប្រសើរ ថ្លៃថ្នូរ ទោសកំហុស នឹងបាបកម្មពួកឯងនេះ មិនខុសពី មនុស្សដែលធ្វើបាបកម្ម ប្រហារជីវិតអ្នកដ៏មានគុណ គឺ

ឪពុកម្តាយដែលមានគុណ មកលើខ្លួនទេ ។ ខ្ញុំមិនដែលឮទេតាំងពីកើតមក នៅលើលោកនេះ។ អើថាភ្លៀងនឹងធ្លាក់មកទៅចុះ ពពកខ្មៅនឹងផុសខ្ញើក១ចេញមកទៅចុះ ប៉ុន្តែនៅពេលដែលឃើញ សំណែនបូជាយញ្ញដ៏គួរឱ្យអាណិតហួសហេតុ ទៅលើខ្នងគោខ្មៅ លោកច្បាស់ជាមិនអាចទ្រាំមើលបានទេ ព្រះច្បាស់ជាសំរក់ទឹក ភ្នែកយំមិនខានទេ។ ព្រះច័ន្ទច្បាស់ជា នឹងលាក់មុខលោកនឹងពពក។ តើពួកឯងអាចរស់បានដែរ ឬនៅពេលដែលពួកឯងធ្វើឱ្យព្រះយំ ធ្វើឱ្យពន្លឺខែបាត់បង់។ត្រូវហើយស្រូវច្បាស់ជានឹងរស់ប៉ុន្តែមនុស្សនៅតែអត់ ឃ្លានអញ្ចឹងទឹកមានមែន ប៉ុន្តែមនុស្សនៅតែស្រេក អញ្ចឹង។ ពួកឯងធ្វើអំពើខុស ពួកឯងបណ្តេញប្តីប្រពន្ធ ហាងីវ៉ាវ៉ា ពីភូមិនេះ ហើយឈប់វាយជួង ចុះប្រសិនបើដីក្លាយទៅជាសមុទ្រទៅ តើត្រូវធ្វើម៉េច? ភូមិ ៦ ប្រជាជន ៨ពាន់នាក់ គឺពួកឯងខ្លួនឯងនេះហើយ ដែលផ្តាច់ជីវិតអ្នកទាំងនោះ និង ខ្លួនឯង បើយល់ថានេះជាជំនឿអកុសលថាទៅ១ ប្តីប្រពន្ធដែលស្រលាញ់គ្នាបួរផ្តាច់នេះ សុខចិត្តចោលឋានៈ បុណ្យសក្តិ ទ្រព្យសម្បត្តិមហាសាល ហើយទ្រាំរស់នៅបំបាំងខ្លួនយ៉ាងទាបវាយតែជួង។

តើគេមានធ្វើ អីអ្នកណាំ មានធ្វើឱ្យឈឺចាប់ដល់នរណា បំផ្លិចបំផ្លាញ នរណា?

កាំងប៉ាជី : បិទមាត់ទៅ ថ្លង់ណាស់ ! អាចោលម្សៀតឯងថាតាមតែចង់ ។

តាគីសេង : អាចំកួតចេញពីណាពីណីមិនដឹងខ្យល់ មកកួតក្អែអីហ្នឹង?

ង៉ាគីអិន : យើងឬ? យើងជាពួកម៉ាកដ៏ល្អរបស់ ហាធីវ៉ាវ៉ា ។ ហ្នឹងហើយអញនេះជាសង្ឃ ។ សង្ឃដែលមានវត្តនៅទីក្រុងក្យូតុ ។ អញមានសញ្ញាប័ត្រខាងអក្សរសាស្ត្រជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យ ។ ឈ្មោះយើងគឺ " យ៉ាម៉ាសាវ៉ា ង៉ាគីអិន " ។ យើងខ្មាសខ្លួនណាស់ដោយនិយាយអួតពីខ្លួនឯងបែបនេះ ។ បើរឿងព្រះពុទ្ធសាសនា គឺវត្តយើងនៅក្យូតុ ជាមាតាបិតាគេហើយ ។ នៅក្នុងចំណោមពួកឯងនេះ គឺមិនលែងមានអ្នកដែលកាន់ព្រះពុទ្ធសាសនាទេ ។ ដូច្នេះប្រហែលជាស្តាប់គ្នាបានហើយ ។ (និយាយទៅគ្រូសាលារៀនបឋមសិក្សា) ឯងនោះជាគ្រូមែនទេ យើងជាអ្នកអប់រំដូចគ្នា មិនមែនអ្នកក្រៅទេ ស្តាប់យើង! (និយាយទៅតំណាងចៅអធិការ) អ្នកឯងក៏ជាញាតិសន្តាននឹងគ្រូបង្រៀនដែរ ។ (និយាយទៅមេភូមិ) ខ្ញុំ

សូមរំពឹងលើកិត្តិយសរបស់លោកមេភូមិហើយ ។ ... (និយាយទៅអ្នកចំបាប់) ឯងអ្នកចំបាប់ គឺសមតែជាអ្នកមានចិត្តមេត្តា ចិត្តករុណា ខ្ញុំអង្វរសូមឈប់ធ្វើ ធ្វើបូជាយញ្ញទៅ ។ (ឮដូច្នេះពួកអ្នកភូមិក៏រាវែរកមួយភ្លែត) ពេលនោះតំណាងរាស្ត្រឈ្មោះ កូសូ ជក់បារីស៊ីហ្គារ ហើយដើរអ៊ឹកអ៊ាកចូលមក)

កូសូ : អាកំភរ ទោះជាអាមិនភរក៏ដោយ ស្អីពូជស្តេចស្អី? សាស្ត្រាចារ្យស្អី? ម៉េចមិនគិតរឿងជីវភាពប្រជាជនគិតពីជីវិតប្រជាជនផង? គ្នាជាអ្នកទទួលខុសត្រូវអ្វីៗទាំងអស់ទីនៅ ! ទៅ ពួកអាចោលម្សៀតគ្រប់គ្នា ទោះពួកយើងសំរាតអាណាក៏ដោយ ដកឆ្អឹងអាណាក៏ដោយស្រីម្នាក់ទៀយ ដើម្បីជីវិតមនុស្ស ៨ពាន់នាក់។ កុំមកជជែកវែកញែកស្អី ! ទៅពួកយើង ប្រុងប្រៀបពិធីបូជាយញ្ញភ្លាម ! (អ្នកចំបាប់ចេញមកមុនគេ ក្រោយមកអ្នកឯទៀតៗក៏ក្រោកស្រមក ។)

ង៉ាគីអិន : ចាប់យើងចង (គេដោះអាវធំចោល) បើយើងអង្វរហើយមិនព្រមស្តាប់សំណូមពរយើងមិនដឹងធ្វើម៉េចទេ ចងយើងដាក់លើគោជន្ទួសយូរីទៅ !

អាគីរ៉ា : (ចោលកណ្ដៀវព្រួស) ទេកុំ ចងយើងជំនួសយូរីទៅ។ ជា ៨ចំណែកទៅ យើងមិនរត់ទេ ដាក់យើងលើគោហើយ ដឹកទៅត្រពាំងបិសាចទៅ ។ យកទៅបូជាយញ្ញទៅ ដើម្បីឱ្យភ្លៀងធ្លាក់ ! យើងនឹងទៅចរចាជាមួយស្ដេច នាគរាជឱ្យឯង ។

យូរី : ទេ បងអាគីរ៉ា លោកភ្ញៀវ ទុកឱ្យខ្ញុំទៅចុះ។ សូមលោក ទាំងអស់យកខ្ញុំទៅ !

អាគីរ៉ា : មិនបានទេ ទោះជាភ្នាល់ជីវិតក៏អញមិនលក់ប្រពន្ធអញ ដែរ ស្អីស្ដេចនាគស្អី? ៨ពាន់នាក់ស្អី? អញមិនលក់ ស្នេហាអញឱ្យអាទិទេព ឱ្យព្រះណាជាដាច់ខាត។ ទោះ ប្រពន្ធអញគិតថាសុខចិត្តធ្វើពលិកម្ម ឬ យល់ពីសេចក្ដី ត្រូវការរបស់ពួកឯង ក៏អញត្រូវតែហាមឃាត់ដែរ។

កូសូ : (ដើរចូលមករបៀបដូចជាមេអំបៅហោះស្រាល១ រោ១ ហើយគោះឈើច្រត់ប៉ូក១) កុំនិយាយឆ្កួត១ បើឆ្កួតក៏ កុំឆ្កួតដល់នេះពេក មីស្រីនោះក៏មីស្រីនោះ ! នាងឯងងូត ទឹកយ៉ាងម៉េចរាល់ដងនោះ? មីចំកួត អាចំកួត (សើចឮ១) បើពួកអ្នកចេះស្រលាញ់ជាតិពីដើម គេសុខចិត្តចាក់សំលាប់ ប្រពន្ធកូន ហើយចេញទៅច្បាំងណាំ មនុស្សប្រុសទ្រូង ៥ហត្ថ គឺអញ្ចឹង ។ នេះគឺជាស្មារតីរបស់ស្រុកជប៉ុនយើង

គឺ ប៊ីស៊ីដូ ( ស្មារតីសាមូរ៉ៃ ពូជអ្នកចំបាំង) ការជួយមនុស្ស ជួយភូមិ ការធ្វើពលិកម្មដើម្បីប្រទេសជាតិ គឺការស្រលាញ់ជាតិមាតុភូមិជាការធម្មតា ។ គេត្រូវតែស្រលាញ់ជាតិមាតុភូមិ ។ គ្រាន់តែដាក់ស្រីកញ្ចាស់ម្នាក់លើខ្នងគោមួយយប់ វាអាក្រក់អីដល់ថ្នាក់ហ្នុងទៅ អាក្មេងហៀវសំបោរ នេះបានអញចិត្តល្អទេ បើតាមធម្មតាពួកអាឯងត្រូវចាត់ថាជាមនុស្សក្បត់ជាតិហើយ អាចោលម្សៀត ។ អញនេះ កូសូនេះ ដែលនៅទីនេះ គឺដើម្បីប្រជាជនតែប៉ុណ្ណោះទេ ។ អញសុខចិត្តបូជាជីវិតគ្រប់ពេលវេលា ... ។ ( អ្នកភូមិនាំគ្នាលើកដៃគំនាប់ មេភូមិអង្អែលចង្កាហើយសភាភូមិបង្ហាញនូវមោទនភាព)

អាគីរ៉ា : ស្លាប់ទៅ ! ( រើសកណ្ដៀវដែលធ្លាក់ ហើយបុកសំដៅទៅ

កូសូ : ប៉ែ ( ថយដោយមិនដឹងខ្លួន)

អាគីរ៉ា : ស្លាប់ទៅ ! ស្លាប់ទៅ ! អាឯងត្រូវតែស្លាប់ទៅដើម្បីប្រជាជន ! បើអាឯងស្លាប់យ៉ាងអស្ចារ្យ ហើយអញស្លាប់ទើបអញសុខចិត្តឱ្យយូរី ។ ស្លាប់ទៅ ! ម៉េចមិនស្លាប់ ! ( វេលាអាគីរ៉ា សង្ហើញមកជិត វេលានោះកូសូថយក្រោក។ យូរីឱបដៃរបស់អាគីរ៉ា ធ្វើឱ្យអាគីរ៉ាញ័រដៃ) មៅ ! ចូលមៅ ! មៅ តជាមួយអញ ! ( អ្នកភូមិរត់ស្រមក...

អាគីរ៉ាទប់ទល់) កុំមកជិតអញ មាត់ពួកអាឯងស្អុយណាស់ ។ ពួកអាឯងឱ្យអាអ្នកមានជំនាន់ថ្មី វាទិញក្បាលបានហើយ ។ ពួកអាចាំទេរឿងនាងព្រីលស? នាងព្រីលសដែលជាក្មេងស្រីបរិសុទ្ធនៅភូមិនេះ ។ ពួកអាបានចាប់បង្ខំនាងដោយអំណាច និង ការសង្កត់សង្កិន សំរាតនាងចងនាងលើគោទោះជានាងប្រកែក តវ៉ាយ៉ាងណាក៏ដោយ ។ ពួកអាឯងបានដេញគោដែលដឹកនាងទាំងស្រាតនទលគកឱ្យរត់ឡើងទៅលើភ្នំ ឱ្យទៅមាត់ត្រពាំងបិសាច ។ តើនាងខ្មាសអៀន ក្តៅក្រហាយ សោកស្តាយប៉ុនណាអាម៉ាស់ប៉ុនណា អាដែលនឹកឃើញពីចិត្តនាងទេ ។ អញបានឮនាងក្រមុំបានយកដៃនាងអង្អែលច្រមុះគោ យកស្មៅស្ងួតគរលើខ្នងវា ហើយយកថ្មគូសគ្នា បង្កាត់ភ្លើងដុត ហើយចង្អុលទៅភូមិ និយាយថា "គោឯងត្រូវរត់ទៅដុតឱ្យរលាយឱ្យអស់ ដើម្បីសងជីវិតដែលមានតម្លៃស្មើគ្នានោះមកវិញ " ។ អស្ចារ្យណាស់សូម្បីតែគោក៏វាក្តៅក្រហាយដែរ គ្រាន់តែនាងក្រមុំ លើកដៃចង្អុលទៅភូមិមិនទាំងបានស្រួលបួលផង វាបានរត់ស្ទុះដូចរន្ទះសំដៅទៅភូមិហើយដុត ។ ជើងភ្នំទាំងមូលឡើងឆេះក្រហមរងាលហុយធូលីក្រហមឆ្អៅ ។ នាងព្រីលសលបញ្ចញីម

ហើយក៏លោតទឹកត្រពាំងបិសាច សំលាប់ខ្លួនបាត់ទៅ នៅបាតត្រពាំងទៅ។ តើពួកឯងដឹងរឿងនេះទេ? ឬក៏ភ្លេចហើយ? ពួកអាចោលម្សៀត ធ្វើចាក់ពួកអញលមើល ភ្លៀងក៏មិនធ្លាក់ ហើយភូមិ ស៊ីកាមី នេះនឹងត្រូវឆេះហ្មត់។ អាពួកមុខក្រាស់គ្មានខ្មាសអៀន។

កូសូ : កុំនិយាយប៉ប៉ាច់ប៉ប៉ោចរឿងឆ្កួតៗ នោះអាក្មេងក្តិតខ្យេវ។ ភូមិបានដុតឆេះឆាបឆ្លួល ដោយការហួតហែងបាត់ទៅហើយ មកពីអញ្ចឹងហើយបានជាយើងធ្វើពិធីបន់ស្រន់សុំទឹកភ្លៀង ភ្លើទេហ្ន៎? ទៅពួកយើង ! នៅយឺតណាស់ លឿនឡើងឱ្យស្វាហាប់ឡើង ! លេងវាទៅ ( មើលឃើញអ្នកភូមិ រោរាអត់ព្រមចូលសោះ) ទៅកុំរោរា ! អាដេងគីជី ក៏ចូលទៅ (ស្រែក) ដេងគីជី បញ្ចាំងដាវវែងផ្លេកៗមក គ្រវីដាវចេញមក។

ដេងគីជី : កាប់វាទៅ ! កាប់វាទៅ !

កូប៊ឹង : អើ !

អាគីរ៉ា : យ៉ាម៉ាសាវ៉ា ប្រយ័ត្ន ! ឱបយូរីទាំងបីនាក់ រត់ឡើងទៅរោងដាក់ជ្រូង។ ង៉ាគីអិន ចូលទៅខាងក្នុង អាគីរ៉ា នៅមាត់ទ្វារជាមួយយូរី ការពារគ្នាទៅវិញទៅមក ហើយច្បាំងជាមួយគេ។ រួចមករុញយូរីទៅម្ខាង អាគីរ៉ាឈរក្បីបលើក

កណ្ដៀវ ។ ហាកតូឡើងមកជាមួយអ្នកស្រុក ឯទៀតមក ព័ទ្ធពីក្រោម ។ យូរីឱបដៃដែលត្រីកណ្ដៀវរបស់អាគីរ៉ា

អ្នកភូមិ : លេងទៅៗ លេងឱ្យវាដឹងដៃម្ដងទៅ !

ង៉ាគីអិន : ចុះពួកអាឯងក៏សំពីកម្លេះ? រឹងក្បាលហើយ កាចសាហាវទៀត ព្រះអើយ សូមផ្លូវទឹកប្រាក់នៃស្ថានសួគ៌ក្លាយទៅជាជ្រោះបង្ហូរធ្លាក់មក (សំពះ)

អាគីរ៉ា : យ៉ាម៉ាសាវ៉ា រត់ទៅឯងជាមនុស្សមានប្រយោជន៍ ! ថាបណ្ដើរវាត់ដាវច្បាំងតបតជាមួយនឹង ដេងគីជី ដែលរត់ស្ទេវឡើងជណ្ដើរមក ដួចផ្ដេកបន្ទោរបណ្ដើរ ។ ដេងគីជីថយខ្សាក មានអ្នកខ្លះចោលគ្រួសមក ។

អាគីរ៉ា : (មានរបួសថ្ងាស យកដៃទប់ឈាម) អាហ៍ (ធ្វើឱ្យជ្រុះកណ្ដៀវ)

យូរី : (រើសកណ្ដៀវនោះយ៉ាងឆាប់) លោកអ្នកទាំងអស់គ្នាខ្ញុំសុខចិត្តស្លាប់ចុះ ។ ខ្ញុំគ្មានពាក្យតវ៉ាទេ (នាងលើកកណ្ដៀវអារទ្រូង)

អាគីរ៉ា : ព្រះអើយ ! (ទៅដណ្ដើមកណ្ដៀវមកវិញ)

យូរី : បងអាគីរ៉ា សូមបងបានសុខណាំ បងអាគីរ៉ា (យូរីដកចង្ការមាន់) (អ្នកភូមិឡើងស្លាំងមុខឈរថ្ងាំង) យូរីបងមិនឱ្យនាងទៅតែឯងទេ បងបានសន្យាថានឹងអៀវ

នាងដើរកាត់ព្រៃ យូរីចាំបងនៅឯផ្លូវបំបែកទៅស្ថានសួគ៌ណា ! បងទៅឥឡូវហើយ ! (អាគីរ៉ា ក្រោកឈរ បីសាកសពយូរី មើលទៅ ង៉ាគីអ៊ិន) ង៉ាគីអ៊ិន ម៉ោងប៉ុន្មានហើយ? (សួរដោយសម្លេងស្មើធម្មតា)

ង៉ាគីអ៊ិន : (មើលនាឡិកាដោយស្ងប់ស្ងាត់) ម៉ោង២ និង ៣នាទី។

អាគីរ៉ា : អ៊ឺ ! គ្នាធ្លាប់អស់ហើយរាល់ថ្ងៃ មើលតែផ្កាយក៏អាចដឹងដែរ ដល់ម៉ោងត្រូវវាយជួងហើយ ង៉ាគីអ៊ិន (សម្លឹងមើលទៅ ជួងមិនដាក់ភ្នែក ដោយសេចក្ដីអង់អាច និង មោទនភាព) ង៉ាគីអ៊ិន ខ្ញុំគិតថាខ្ញុំនឹងមិនវាយជួងទេ ឯងយល់ យ៉ាងម៉េចដែរ?

ង៉ាគីអ៊ិន : (គិតមួយភ្លែត) អើ ! កុំវាយ ! ដើម្បីឱ្យព្រលឹងនាងយូរី បានស្ងប់ស្ងាត់ផង ! កុំវាយ ! អាគីរ៉ា !

អាគីរ៉ា : (លើកកណ្ដៀវកាត់វិប ជួងព្រមទាំងអន្លូងធ្លាក់ក្ដាំងមកក្រោម) រំពេចនោះ គេឮសូរសម្លេងលាន់ខ្ទរមកវិញយ៉ាងខ្លាំងដីរញ្ជួយ ភ្ញាក់ក្រើក) -អារាល់គ្នា ! មើលទៅត្រពាំងបិសាចហ្ន៎ ! មើលទៅត្រពាំងបិសាច ! អារាល់គ្នាឮអញឱ្យមើលទៅត្រពាំងបិសាចទេ? (ពពកដើខ្មៅផុសចេញមករន្ទះបាញ់ក្ដាំងស្ទើរតែព្រិចភ្នែកមិនទាន់ ។

អ្នកភូមិទាំងឡាយញ៉ូរជើងតតាត់ គោផ្អើលគោះជើងក្រោយហើយបោលភឹងទៅភូមិ)

កូស្ង : ជួង ! ជួង ! វ៉ាយជួង !

ដេងជី : ជួយផងលោកអើយ វ៉ាយជួងលោក ! សូមមេត្តាវ៉ាយជួង

តាតីសេង : ជួយផងលោកអើយ ! ស្រែក រត់ឆ្វេឆ្វា។ មនុស្ស ២-៣នាក់ លូនឡើងជណ្តើររោងជួង។ អាតីវ៉ាកាប់វាហើយរុញទម្លាក់ទៅវិញ រួចហើយគេឈរមើលថ្មឹង ដូចរូបចំលាក់លែងរវីរវល់នឹងនរណាទៀត ។

អាតីវ៉ា : ឱរលក ! រលកមកហើយ ! ង៉ាតីអិនញបែបនេះក៏ក្រាបអាតីវ៉ាកាត់បំពង់កខ្លួន ហើយដួលដេកទៅលើដី ។ ព្រះនាងព្រីលស ឈរលើដំបូលខ្ទមក្នុងពន្លឺចាំងខ្លាំង។ មួយរំពេចនោះក៏បាត់ស្រមោលទៅក្នុងអន្ធការ។ រួចមកឡើងលើរោងជួងឈរក្នុងពន្លឺរន្ទះដ៏ខ្លាំងក្លា គ្រវីឈើច្រត់ដែកដៃដាក់លើជួង១ឡើងញ៉ូរហើយផ្ទៀង ។ អ្នកភូមិទាំងឡាយស្រឡាំងកាំង ស្លន់ស្លោ លែងដឹងទិសតំបន់។ មេដោះអាយុ ១ម៉ឺន សេនាទាំងឡាយក្រោកឈរ កាប់សំលាប់អ្នកភូមិឱ្យងាប់អស់គ្មានសល់ម្នាក់ ។

ព្រះនាងព្រីលស : ម៉ែយាយ ! ខ្ញុំសប្បាយចិត្តណាស់ !

ទាំងអស់គ្នា : ព្រះនាង ! (ថាព្រមគ្នា)

ព្រះនាងព្រើលស : មនុស្សទាំងឡាយយ៉ាងម៉េចទៅហើយ?

យាយមេដោះ : ពួកវាត្រូវត្រីស៊ីអស់ហើយ ព្រះនាងកូន ។ អ្នកដែលមិនទាន់ត្រីស៊ីកំពុងខំហែលទឹក នោះខ្យង កូនត្រីក៏ខំស៊ីមនុស្សតាមភាវៈរបស់វាដែរ ។

ទាំងអស់គ្នា : (សើចគឹល) ហាស១១

ព្រះនាងព្រើលស : ទន្លេថ្មីនេះយើងឱ្យឈ្មោះថាទន្លេងជួង គឺជាព្រះរាជដំណាក់របស់ក្សត្រា ក្សត្រី អាគីរ៉ា យូរី ។ ព្រះនាងយូរី ព្រះនាងយូរី យើងច្រៀងពីរនាក់ណាំ ! (អន្ធកាលបានចូលមកសន្ធឹង ភ្លើងរលត់ឆាកឡើងងងឹត ។ មានជួងធំគេឃើញ អាគីរ៉ា និង យូរីពីរនាក់ ។ អាគីរ៉ា ឱបក្បាលនាគ នាងយូរីជិះខាងកន្ទុយ អាវវែងរបស់នាងធ្លាក់ទៅក្នុងទឹក ។ ក្បាលនាងងើយទៅរក អាគីរ៉ា ។ គេទាំងពីរសម្លឹងមើលមុខគ្នាមិនប៉ប្រិច ។ ហើយគេញញឹមដាក់គ្នា ។ ព្រះច័ន្ទរះភ្លឺចិញ្ចាច ។ ង៉ាគីអិន ឈរតែឯងធ្មឹងលើរោងជួងដ៏ខ្ពស់ មើលទៅទឹក ។ គេឱនក្បាលគោរពហើយលើកដៃសំពះ ។ ព្រះច័ន្ទឡើងភ្លឺច្បាស់ ។

**ឆាកបិទ**

# រឿង ព្រះសង្ឃនៅភ្នំកូយ៉ា

# KOYA HIJIRI


អ្នកនិពន្ធ អ៊ីស៊ុមី ក្យូកា

(IZUMI KYOKA)

បកប្រែសំរួលដោយ ឈឹន សេដ្ឋារិន

ដោយជំនួយពី ម៉ាជិជិម៉ា តូមីអ៊ុជិ

# អារម្ភបទ ចំពោះរឿង ព្រះសង្ឃនៅភ្នំកូយ៉ា

គឺជាភារៈមួយដ៏លំបាក ដើម្បីនឹងសរសេរអារម្ភបទមួយលើរឿងដ៏មានទេពកោសល្យ ដូចរឿង ព្រះសង្ឃនៅភ្នំកូយ៉ារបស់លោក Izumi Kyoka ។ ទេពកោសល្យនៃរឿងមានច្រើនជ្រុងជ្រោយណាស់ អាចលើកយកមកពណ៌នាមិនអស់សព្វគ្រប់ទេ ។ តែកាលបើគេចាប់គំនិតច្បងបាន គំនិតបន្ទាប់បន្សំប្រហែលជាអាចនឹងត្រងយកបានដោយឯងៗ ។

ផ្ដើមរឿងនេះឡើង គឺការជួបគ្នា ក្នុងដំណើរតាមរថភ្លើង រវាងបុរសម្នាក់ និង ព្រះសង្ឃមួយអង្គ ដែលមើលទៅហាក់ដូចជាមានឬកពារធំខ្ពស់ ហើយហាក់ដូចជាមិនចង់មើលអ្វីទាំងអស់ផង ។ លោកគង់នៅភ្នំកូយ៉ាព្រះជន្មប្រហែល ៤៥ រឺ ៤៦ព្រះវស្សា ស្លៀកពាក់អាវរងាជ្រុង រុំកដោយកន្សែងកាំម្វីសពាក់មួកទូរគី ស្រោមដៃឡែន ស្រោមជើងស ស្បែកជើងជប៉ុនឈើ មើលទៅមិនសមជាព្រះសង្ឃទេ ។ បើនិយាយថាជាសាស្ត្រាចារ្យសិល្បៈដូចជាសមជាង ។ ក្រោយមកទើបគេដឹងថា ព្រះសង្ឃអង្គនេះជាលោកគ្រូសង្ឃ្រាជវត្ត " រីគីម៉ាន់យី " ដ៏ល្បីល្បាញហើយលោកពូកែទេសន៍លេខមួយ ។

ភាគដំបូងនៃរឿង ជាភាគមនុស្សលោកសុទ្ធសាធ ព្រះអង្គធ្លាប់ស្គាល់ផ្ទះសំណាក់មួយ បុរសសុំអោយលោកមកសំណាក់ជាមួយផង ។ ដូចសន្យានៅតាមរថភ្លើងយប់នោះឯង បុរសនោះទទួចសុំអោយព្រះសង្ឃអង្គនេះនិទានរឿងពិរោះៗ ព្រោះលោកធ្លាប់ធ្វើដំណើរច្រើន ច្បាស់ជួបប្រទះនិងរឿងចម្លែកៗជា

មិនខាន ។ យប់នោះឯងព្រះសង្ឃមានពុទ្ធដីកា និទានរឿងថា: រឿងដែលអាត្មានឹងនិយាយនេះ មិនទាក់ទងនឹងធម៌អាថ៌បុណ្យទានទេ ថ្វីត្បិតតែអាត្មាជាសង្ឃមែន ។ លោកនិយាយពីរឿងអ្នកលក់ថ្នាំ ដែលមានចរិតលក្ខណៈអាក្រក់សែនអាក្រក់ម្នាក់ ដែលលោកបានជួប កន្លងពេលយូរណាស់មកហើយ នៅហាងកាហ្វេមួយ ។ នៅពីមុខហាង មានកូនស្ទឹងមួយ ដោយពេលនោះជារដូវក្តៅ លោកស្រេកទឹកខ្លាំង លោកបំរុងនឹងដួសទឹកនោះឆាន់ តែគាប់ជួននឹកឃើញពីរឿងជំងឺឆ្លងដែលរាតត្បាតភូមិជាច្រើន លោកក៏ផ្អាកទៅវិញ ពេលនោះអ្នកលក់ថ្នាំ និយាយទៅកាន់លោកថា: " មកខ្ញុំករុណាប្រាប់ ព្រះសង្ឃដ៏មានមហិទ្ធិរិទ្ធអើយ ! (ជននោះដាក់ជើងលើ ភ្លៅនារីបំរើម្នាក់ចិបស្រា ស )... មើលគេជគុណ អោយខ្ញុំព្រះករុណាសុំយោបល់បន្តិច ។ ឮតែគេនិយាយណាំទានណាំ ថាមនុស្សប្រុស តែដល់ពេលដែល ស្រលាញ់ស្រីលែងបាន ក៏តាំងនាំគ្នារត់ទៅបួស តើត្រូវទេទាន? លុះតែបួសទៅជាសង្ឃ ដាច់ឃៃហើយក៏នៅតែខ្លាចស្លាប់ដូចតែមនុស្សមានកិលេសដែរឬទាន? ខ្ញុំព្រះករុណាឆ្ងល់ណាស់ ! នាំគ្នាសើចគិល អាត្មាខ្មាសគេអើយខ្មាស មុខឡើងក្រហម ។ វាបន្តទៅទៀតថា : " បានជាខំដងទឹកហើយ ម៉េចមិនឆាន់ ទៅនៅរារែកធ្វើអ្វី ទៀត? ឆាន់អោយឆ្អែត ឆាន់ដូចគេងូតទៅទាន ។ បើមានគ្រោះថ្នាក់ ដល់ជីវិតខ្ញុំព្រះករុណាមានថ្នាំទេតើ? នេះជានាទីខ្ញុំព្រះករុណាហើយ ទាន... តែថ្នាំនេះមិនប្រគេនទទេ ទេណាំទាន ។ ខ្ញុំព្រះករុណាមិនចូលចិត្តការ បិណ្ឌបាត្រទទេ ដែលជាទោសដ៏ធ្ងន់មួយ ដូចអស់ផងគេ និយមធ្វើទេ ... " ។ អាត្មាក្តៅគុម្ពត្រចៀកតែមិនឆ្លើយតបទេ ប្រញាប់ចាកចេញពីទីនោះ កុំអោយប៉ះទង្គិចនឹងវា ។ ដើរ

ចេញពីទីនោះទៅ អាត្មាដើរឡើង ផ្លូវចោតមួយទៅជួបនិងអ្នកលក់ថ្នាំទៀត។ វាដើរវាងអាត្មាផុតទៅ តំរង់ទៅផ្លូវមួយផ្សេង ។ មុនបែកទៅ វាងាកមក និយាយប្រាប់អាត្មាថា : "នែ៎ លោកសង្ឃ ផ្លូវត្រង់ឯណោះ នែ៎! " ។ ចំណែក អាត្មា បានទៅជួបសួរផ្លូវកសិករម្នាក់គេនិយាយថា ផ្លូវអ្នកលក់ថ្នាំដើរទៅមាន គ្រោះថ្នាក់ ផ្លូវត្រូវគឺផ្លូវអាត្មាដើរនេះហើយ ។ ដូច្នេះឃើញថា មនុស្សម្នាក់ដើរ ឆ្ពោះទៅផ្លូវមានគ្រោះថ្នាក់ហើយ បើមិនទៅទាញវាមកផ្លូវត្រូវវិញ ឃើញថា មើលទឹងភ្នែក មិន ជួយសង្គ្រោះសត្វលង់ទឹក ។ ខ្លួនឯងជាសង្ឃ ដូច្នេះត្រូវតែ ទៅទាញមកវិញ ។ អ្នកឯង (បុរសដែលកំពុងស្តាប់លោកនិទានរឿង) អាច ដឹងខ្លះៗដែរ ថាអាត្មានេះកំសាក ទន់ខ្សោយ សូម្បីតែទឹកស្ទឹងមិនហ៊ានផឹកទៅ ហើយ ព្រោះតែខ្លាចស្លាប់ ចុះហេតុអ្វីបានជារញ៉ីរញ៉ូរទៅរកសង្គ្រោះគេ ។ ទីបំផុត អាត្មាក៏ប្ដេជ្ញាចិត្ត ដើរឡើងផ្លូវទួលផុតទៅ ។ បើត្រឹមតែស្គាល់គ្នា ដោយគ្រាន់តែងក់ក្បាលគំនាប់គ្នាអី អាត្មាប្រហែលជាមិនទៅ វាទាស់តែអាត្មា បានដឹងថា អ្នកនោះជាមនុស្សមានចរិត្តមិនល្អហើយ បើមិនទៅទាញវាមកវិញ ទេ វាហាក់ដូចជាអាត្មានេះ មានបំណងចង់សងសឹកនឹងវា ... ។

ព្រះសង្ឃតាមទំលាប់ លោកនៅតែសឹងផ្កាប់ព្រះភ័ក្ត្រដដែល ដៃ លោកប្រណម្យ លោកមានពុទ្ធដីកាទៀតថា : "ត្រឹមសូត្រធម៌ទទេ មិនអាច ប្រោសសត្វបានទេញោម! " ។ ពាក្យនេះមានន័យដូចម្ដេច? មិនគឺជាពាក្យ ស្តាយក្រោយ ពាក្យដែលមនសិការ បន្ទោសខ្លួនលោកទេឬ ពិតមែនហើយថា កាលនៅពេលនោះ លោកនៅក្មេង នៅជា"កូនលោក" រៀនធ្វើធម្មយាត្រា

និមន្តកាត់ព្រៃភ្នំ សូត្រធម៌អប់រំខ្លួន លោកនៅខ្លាច នៅកំសាក ហើយនៅគំនុំគុំគួន បន្តិចបន្តួចផង ។

សាច់រឿងដែលព្រះសង្ឃនឹងមានពុទ្ធដីកាអោយបុរសស្តាប់ ជាបន្តទៅនេះ គឺជាភាគធម្មយាត្រាកាត់ព្រៃភ្នំ ។ រឿងចាប់ផ្តើមពីកន្លែងមួយ ដែលមានផ្លូវនោះ អាក្រក់សែនអាក្រក់ គឺជាផ្លូវគ្មានមនុស្សដើរ ហើយដែលគួរអោយខ្លាចគឺមានពស់ ។ វាចាក់កន្ទុយគ្នាទៅគុម្ពោតដែលនៅផ្លូវ ហើយចាក់ក្បាលវាទៅក្នុងគុម្ពោតផ្លូវម្ខាងទៀត ខ្លួនដេកកណ្តាលផ្លូវដូចស្ពាន ។ ព្រះសង្ឃអង្គនេះស្អប់ពស់ តែបើនិយាយអោយចំគឺលោកខ្លាច ។ លោកនិទានថាៈ ពស់វាមានច្រើន អាខ្លះអត់ កំរើកភ្លាមៗទេ ខ្លួនវាធាត់ទ្រលុកៗ រអិលអន្ទិល ដើម្បីលួនអោយផុតក្បាលកន្ទុយ វាត្រូវការប្រាំនាទី ខ្លួនវាវែង អាត្មាភ័យញ័រញាក់រោមអាត្មាព្រឺ រន្ធរោមទាំងឡាយ ទាំងពួង វាក្លាយទៅជាស្រកា ។ អាត្មាញ័រជើងតគាត់ឈរសឹងមិនជាប់ ខំដើរទៅមុខទាំងរញ្ជាក់រញ័រ ហើយក៏ទៅជួបនឹងពស់ទៀត ។ អាត្មាគិតថា ទោះបីអាសត្វនោះ វាលងសំលាប់អាត្មា ក៏អាត្មាមិនហ៊ានលោតកន្លងវាដែរ ហើយអាត្មានឹកថា ប្រសិនបើកសិករ គាត់ប្រាប់អាត្មាតែមួយម៉ាត់ថាផ្លូវនេះមានពស់ អាត្មានេះ ទោះជាធ្លាក់នរកទៅទៀត ក៏មិនមកឡើយ មិនមកជាដាច់ខាត ។ សត្វនេះ វាធ្វើអោយអាត្មា ញាប់ញ័រអស់សព្វសព៌ាង្គកាយ អាត្មាគិតតែបង្ហូរទឹកភ្នែករកពុទ្ធោ ឥឡូវគ្រាន់តែ និយាយប៉ុណ្ណឹង ក៏ព្រឺសំបុរបាត់ទៅហើយ ។ មានសាកសពពស់មួយកំណាត់ខ្លួន អាត្មាក៏រត់គេចទៅឆ្ងាយអោយផុត តែចេះតែគិតថា អាមួយកំណាត់ទៀត ច្បាស់ជាដេញមកតាមក្រោយឥឡូវហើយ អាត្មាទៅជាលែងទុកចិត្តខ្លួនឯង ។ តាមផ្លូវក្រោមជើង ស្អីទេដូចជាពងសត្វស្លាបធំៗ ។ អាត្មាខំសូត្រធម៌ ស្រាប់មានពស់

វារកាត់មុខទៀត។ អាត្មាគិតថាគឺ អារុក្ខអារក្ខ អ្នកតាទេវតា ឬក៏ព្រាយ អសុរកាយ ដែលនៅក្នុងព្រៃភ្នំ អាត្មាបោះឈើច្រត់ចោល លុតជង្គង់ អោន សំពះព្រះធរណីបន់ស្រន់ដល់ អារុក្ខអារក្ស អ្នកតា ទេវតា សូមបើកផ្លូវអោយ អាត្មាដើរទៅផង ។ ពេលនោះក៏ លឺសំលេងសម្បើមលាន់ឮឡើង អាត្មាភ័យ នោះសែនភ័យ ពេលវិញ្ញាណត្រលប់ មករូបរាងវិញ អាត្មាចុះមកដល់ក្រោម ស្រេចទៅហើយ លើកនេះស្បែកជើងអាត្មាឡើងត្រជាក់ ហាក់បីដូចជាក្ដាមវារ ជំនួសពស់ ។ បើរៀបរាប់ពីការព្រួយបារម្ភ គឺរៀបរាប់យ៉ាងម៉េចក៏មិន សមល្មមដែរ ។ ស្រាប់តែមានអ្វីធ្លាក់ពីលើមែកឈើ ដែលខ្ពស់ពីលើក្បាលអាត្មា ខ្លួនវា ត្រជាក់ទន់ៗ ។ អាត្មាដោះមួកមកមើលឃើញសត្វអីម្យ៉ាង រអិលធ្លាក់ មកដល់ចុងម្រាមដៃ ហើយក៏ឃើញឈាមអាត្មាពណ៌ក្រហមស្អាត ចេញពីចុង ម្រាមដៃ ស្រក់ធ្លាក់តក់ៗចុះមកក្រោម ។ អាត្មាភ្ញាក់ ស្រាប់តែមានមួយទៀត កំពុងតែទាមកួយដៃអាត្មា ប្រវែងវាប្រហែល១៥សង់ទីម៉ែត្រ ហើយទំហំ ប្រហែល ២-៣ធ្នាប់ ។ អាត្មាសំលឹងទៅវា ឃើញវារួញ ហើយឡើងធាត់ ទ្រលុកៗ ដោយសារវាបឺតឈាមអាត្មា សាច់អាត្មាឡើងខ្មៅល្អក់ រលោងមាន ឆ្នូតពណ៌ដី ។ អាសត្វដែលចេះជញ្ជក់ឈាមនេះ គ្មានអ្វីក្រៅពីឈ្លើងឡើយ ។ អាត្មាមិនអាចដឹងទាល់តែសោះ មិនដឹងជាឈ្លើងអ្វី មានចំណាស់ពីអង្កាល់ បាន ជាវាធំដល់ថ្នាក់នេះ ។ អាត្មារលាស់ដៃ តែវាស្អិតណាស់ មិនងាយជ្រុះធួរៗទេ អាត្មាព្រឺសំបុរ ប៉ុន្តែខំទាញវាឡើងយឺត ហើយចុងបញ្ចប់ក៏អាចទាញវា ផ្ដាច់ពី សាច់បាន។ អាត្មាវាត់វាយវាទៅនឹងដី ប៉ុន្តែមិនឈ្នះ ចាប់មួយចេញមួយ ព្រោះ ហាក់ដូចជាមកជាន់លើសំបុកវា ។ មានអ្វីកំរើកខ្មើកៗនៅកអាវ យកដៃស្ទាប ទៅ ក៏ប៉ះខ្លួនវាទន់ៗ រអិលៗ ។ ស្ទាបទ្រូងក៏មាន អាខ្លះសសុលចូលទៅក្រោម

ខ្សែក្រវ៉ាត់ ។ អាត្មាឡើងស្លក់ស្លាំងអស់ហើយ ហើយរាវមើលទៅលើស្មាក៏មានឈ្លើងទាមដែរ អាត្មាលោតភ័យតក្កម្មា ភ្លេចភ្លាំងស្មារតី ញាប់ញ័រសព្វសព៌ាង្គកាយ ខំរត់ចេញពីក្រោមមែកឈើបណ្ដើរ ខំទាញឈ្លើងដែលរកឃើញក្នុងខ្លួនបណ្ដើរ ងប់ងល់លែងគិតឃើញអ្វីទៀតហើយ ។

អង្គបាតុភូតពស់ ដែលមកនៅរន្ធូករណែល ស្ទេកស្ទះពេញផ្លូវ ចាំបង្អាក់ដំណើរ និងចាំបន្លាចព្រះសង្ឃជាបដិហារទីមួយ ដែលថៃជន្យ ឬ ទេវតាឧប្បតិកអោយឃើញ ដើម្បីលង និងជួយអប់រំចិត្តព្រះសង្ឃអោយទំលាប់បាត់ខ្លាច បាត់តក់ស្លុត នៅមុខសេចក្ដីស្លាប់ សូម្បីនៅចំពោះមុខ ពពួកសត្វពស់ដែលជាសត្វចិកព្រួសពិសដ៏សាហាវនេះក៏ដោយ ។ ដើម្បីដិកល់ចិត្តអោយរឹង ជំនះសេចក្ដីភិតភ័យ ញាប់ញ័រទាំងឡាយ ព្រះសង្ឃគួរប្រមូលអារម្មណ៍សូត្រធម័តបវិញ ដើម្បីជំនះបាតុភូតអាក្រក់ទាំងឡាយក្នុងលោក ។

ផុតពីពស់ និង សាកសពពស់ពាក់កណ្ដាលខ្លួនមក មិនទាន់ទាំងបានប៉ុន្មាន ផង ព្រះសង្ឃនិមន្តមកជួបនិងបដិហារទីពីរ ម្ដងនេះ គឺឈ្លើង ។ ពស់ជាបាតុភូតលោកិយ៍ ចំណែកឯឈ្លើងជាបដិហារដែលសំដែងចេញមកពិត១ សុទ្ធសាធ ។ ឈ្លើងទាម ហើយបឺតជញ្ជក់ឈាមពីរាងកាយមនុស្សលោកញ៉ាំងអោយរាងកាយឡើងស្លក់ស្លឹតស្លាំង ដូចអសុភ។ "លោកសង្ឃ កាលនោះភិតភ័យញាប់ញ័រ ស្រែករកគេជួយ។ ដំណក់ឈាមដែលហូរស្រក់ពីម្រាមដៃស្រស់១ មិនសមបើធ្វើអោយតក្កម្មាឡើយ តែគួរអោយសង្វេគដល់ លោកយើងនេះ ដែលមានសត្វឈ្លើងរស់នឹងឈាម ហើយបើសិនជាឈាមមនុស្ស

សត្វទាំងអស់ ដែលឈ្លើងបឹតជញ្ជក់បាន ប្រមូលផ្ដុំមក នឹងផ្សំបានទៅជាស្ទឹង បឹង ទន្លេឈាមសុទ្ធសាធមួយ មានអ្វីនឹងគួរអោយត្រេកត្រអាល មានអ្វីនឹងគួរអោយក្រាញរស់នៅដោយភ្លើតភ្លើនភ្លេចខ្លួនបាន? ផ្ទុយទៅវិញ គួរតែសាងសន្សំកុសល ដកខ្លួនចេញអោយផុត ដើម្បីរលាស់ ច្រានចោលអោយអស់នូវកិលេសផងទាំងពួង ស្វែងរក "និព្វាន" ជាទីបំផុត ។

ផុតពីនោះ ព្រះសង្ឃបានមកដល់ទីកន្លែងមួយ ដែលលោកព្ទសេះកញ្ច្រៀវ ។ រួចមក១ ឃើញផ្ទះមួយមានបុរសម្នាក់ លោកក៏ហៅរកអោយគេជួយ តែបុរសនោះដូចជាអមនុស្ស គឺថា គេមិនគ្រប់លក្ខណៈជាមនុស្សទេ ជាបុរសមិនគ្រប់ទឹក កក្រងាក ពោះកំប៉ោង មាត់ចំហធ្លុង អណ្ដាតធ្លាក់ស្បៃ៉ះ មិនចេះនិយាយស្ដី ។ ព្រះសង្ឃដង្ហោយរកលោកអ្នកឯណាផ្សេងទៀតមកជួយ ។ លេចស្រីម្នាក់ ល្អចំណាប់ សំលេងថ្លា គ្មានកករល្អក់ ហើយស្លូតសុភាព ព្រះសង្ឃសុំកន្លែងដាក់ចប បង្គី ឬក្រោលគោ ក្រោលសេះអ្វីក៏ដោយអោយតែលោកសំរាកបាន ។ អ្នកស្រីម្ចាស់ផ្ទះក៏ព្រម ។ "អ្នកស្រីម្ចាស់"នេះ ដូចយើងគង់នឹងបានដឹងទៅខាងក្រោយថា ជាបដិហារទីបី លងចិត្តព្រះសង្ឃ ។

នាងចង់ លាងព្រះបាទប្រគេន តែនាងនឹកឃើញថា នៅក្រោយផ្ទះមានស្ទឹងដ៏ស្អាតមួយ ទើបនាងនិមន្តលោកទៅលាងខ្លួនប្រាណក្នុងស្ទឹងនោះ... " ហ្ន៎ ទទឹកស្បង់អស់ហើយ " ។ ថាហើយនាង "ដោះស្បង់អាត្មា អស់រលីង ។ អាត្មារួញខ្លួនខ្សៀន ។ នារីឥតរវល់ទេ គិតតែពីទាញស្បង់អាត្មាអស់ អាត្មាអោនខ្លួន អោបជង្គង់ក្រវៀន១ ។ នារី នោះលូកដៃ ដែលសដូចកប្បាសមក

ពាល់អាត្មាខ្លង ចង្កេះព្រមទាំងដុសថ្នម១។ ដៃនាងនោះហាក់ដូចជាមានកំដៅ។ ទឹកដែលលាងអាត្មាឡើងក្តៅឧណ្ហ១... ស្រួលជ្រាបចូលក្នុងសាច់អាត្មា ទឹកមានគុណភាពល្អ ទន់ណាស់ នាំអោយភ្លែករលីវ១ មី១ ចង់ងងុយដេក ។ អាការឈឺឆៀប១ ដោយឈ្លើងទាម ក៏របេះបាត់ ។ អាត្មាស្ទើរតែបាត់បង់ស្មារតី ។ អាត្មាប្រុងនឹងបដិសេធ ប៉ុន្តែទោះបីដឹងខ្លួនថា ត្រូវតែបដិសេធក្តី ក៏សេចក្តីត្រេកត្រអាល រវើរវាយ វាបានបណ្តោយអោយ គេលុបលាងខ្លួនប្រាណរហូតទៅ ។ អាត្មាកំពុងតែត្រូវបានក្តោបក្រសោបយ៉ាងទន់ភ្លន់ ដោយផ្កាមួយទង ដែលមានក្លិនក្រអូប ហើយកក់ក្តៅ ។ ជើង ត្រគាក ដៃ កញ្ចឹងក រួចបន្ទាប់មក ក្បាល រាងកាយទាំងមូល... អាត្មាភ្ញាក់រកអុកគូថទៅលើថ្មទៅហើយ ហើយជើងអាត្មាក៏បានត្រវែងទៅក្នុងទឹក រកកលនឹងលិច តែស្រីនោះបានលូកដៃពីក្រោយមកទប់ទ្រូងអាត្មា នាំអោយអាត្មាអាចឈរនឹង បាន... ។ ដើម្បីស្រាតមុជទឹកក្រោយអាត្មាដែរ អ្នកស្រីម្ចាស់យកលេសថា នាងបានចូលក្រោលសេះជាប់ក្លិនស្អុយឆ្អេះឆ្អាប ។ នៅមុំស៊ីងនោះ គេប្រទះឃើញ សត្វគង្គក់ ជ្រីង ស្វា ដែលមកលិបលរលេងជាមួយនាង ។

ពេលព្រលប់ព្រះចន្ទ្ររះភ្លឺច្បាស់ នៅមុនពេលបាយ តាចាស់ម្នាក់ដឹកសេះមកមុខផ្ទះនាង ដើរយកទៅលក់ឯផ្សារ ។ តែសេះវាមិនព្រមដើរទៅមុខទេ វាសុខចិត្តដេកទៅលើដី ទើបតាចាស់ស្រែកហៅអ្នកស្រីម្ចាស់អោយមកជួយ ។ នាងក៏មក រួចរវៅរបាំមួយពោរពេញដោយអច្ឆរិយភាព ទាំងរាងកាយស្រាតនទល ។ ពេលនោះ នាងមានសភាពដូច "ព្រះជាម្ចាស់" ឬ ដូច

"ព្រាយបិសាច" លែងជាមនុស្សហើយ ។ សេះវាហាក់ដូចជាមានកំលាំងងើប ឡើង ហើយតាចាស់ឃើញឱកាសល្អមកហើយ ក៏ទាញបង្ហៀរសេះដឹកវាដើរទៅ ។ យប់នោះ អ្នកស្រីម្ចាស់ក៏ផ្ដេកយុវជនមិនគ្រប់ទឹក អោយដេកលក់ហើយ នាងក៏ ចេញមកនិយាយនិងអាត្មាថា: ជាជាងនៅទទួលការវេទនាគ្រប់យ៉ាងពី ពិភព ខាងក្រៅ សូមអោយអាត្មានេះនៅជិតនាង នៅទីត្រជាក់ នារដូវក្ដៅ ហើយ កក់ក្ដៅនៅរដូវរងា ត្រាំទឹកស្ទឹងជាមួយនាង... ។

បដិហារកាមគុណនេះមកបញ្ចប់ នៅពេលព្រះសង្ឃហៀបសឹងក្នុង យប់នោះឯង ។ លោកបានឮមិនដឹងជាស្អីខ្លះទេ វាហាក់ដូចជារូបភាពនៃឋាន នរកអវិចីនៃស្រមោលដ៏គួរអោយសង្ស័យ... ដូចជាសំលេងបិសាចនៅលើ ឬ បិសាចនៅក្នុងទឹក... លោកទ្រង់អត់ដង្ហើម... ផ្ទះយោលយោក ព្រះសង្ឃចាប់ ផ្ដើមសូត្រធម៌ ។

ព្រឹកឡើង ពេលលាអ្នកស្រីម្ចាស់ផ្ទះចេញមក និមន្តមកចប់តាមផ្លូវ ព្រះសង្ឃគិតតែពីរឿងនេះ ។ លោកលែងគិតថា ធម្មយាត្រាដែលជាផ្លូវសំរាប់ នាំលោកធ្វើដំណើរទៅកាន់ភាវៈជាសង្ឃពេញលក្ខណៈមួយអង្គ លែងមានន័យ ចំពោះលោកទៀតហើយ ។ តាមផ្លូវ ពេលឃើញទឹកជ្រោះ លោកមើលទៅ ឃើញរូបស្រីនោះ ។ លោកគិតថា ត្រូវតែត្រឡប់ក្រោយវិញ ឬលោតទឹកទៅ អោបក្រសោបនាង ។ ដោយសារតែខ្លួនលោកមានកិលេសដ៏ក្រខ្វក់បែបនេះ បានជាវាទៅជាអញ្ចឹង ។

ភ័ព្វសំណាងល្អ តាលក់សេះ គាត់មកប្រទះព្រះសង្ឃនៅពេលនោះ ហើយគាត់ចាប់អារម្មណ៍ដឹងថា: " កូនលោកអង្គនេះ កំពុងតែគិតពីអ្នកស្រីម្ចាស់ហើយតើ?" ទើបគាត់និយាយរឿងពិតប្រាប់លោកសង្ឃថា: "អោយដឹងកូនលោក! អ្នកដែលប៉ះពាល់ដៃអ្នកស្រីម្ចាស់ ហើយបានងូតទឹកស្ទឹងនោះ មិនអាចនៅមានរូបរាងជាមនុស្សដូចដើមទេ ។ ច្បាស់ជាក្លាយទៅជាគោ ឬ សេះ ឬស្វា ឬ គង្គក់ ឬ ជ្រូង....

ដោយសារកូនលោកបង នៅក្មេងខ្ចីអីចឹងមែន តែមានការតាំងចិត្តមុតមាំ គួរអោយសរសើរនេះឯង តែម្តង ទើបនៅរស់រានមានជីវិត ។ សេះដែលតាដឹកទៅលក់នោះ គឺអ្នកលក់ថ្នាំ អាប្រុសជ្រើមកំហូចដែលជួបកូនលោកឯងតាមផ្លូវនោះហើយ .... ។

ពាក្យដែលព្រះសង្ឃមានពុទ្ធដីកាថា " ធម្មយាត្រាជាផ្លូវសំរាប់នាំព្រះអង្គអោយធ្វើដំណើរទៅកាន់ភាវៈជាសង្ឃពេញលក្ខណៈមួយអង្គ" ជាពាក្យសង្ខេប ពាក្យដាក់ខ្លួនណាស់ ។ តាមពិតរឿង "ព្រះសង្ឃនៅភ្នំកូយ៉ា " ជារឿងប្រយុទ្ធមួយដ៏លំបាក ហៅសែនលំបាក រវាងការដាក់ចិត្តអោយស្ថិតនៅជាសង្ឃពេញលក្ខណៈ នឹង ការត្រលប់ទៅរស់ជាសាមញ្ញជនប្រកបដោយកិលេសលោកីយ៍វិញ ។

បើសិនជាយើងនិយាយពន្លើសទៅវិញ ថាជាការប្រយុទ្ធរវាងផ្លូវទៅរកព្រះនិព្វាន ( ផុតរលត់កិលេស នឹងផ្លូវរស់នៅក្នុងលោកីយ៍ក្នុងភក់ជ្រាំនៃកាមតណ្ហាសព្វបែបយ៉ាងរបស់សត្វលោក) ។ ចំពោះព្រះសង្ឃអង្គនេះទំរាំលោកអាច

វក្សាភាវៈជាសង្ឃបានរហូតមកដល់សព្វថ្ងៃ លោកបានប្រទះសព្វគ្រប់អស់ហើយ : បដិហារនរកអវចី បដិហារលោកីយ៍ ( ស្នេហាងប់ងល់ គ្រោតគ្រាតលើអ្នកស្រីម្នាស់ដែលមានធាតុជា " ទេវតា ឬ បិសាច" ដែលកំរមាននរណាជំនះបាន ក៏ព្រះអង្គបានឈ្នះរួចហើយ ដោយគុណបុណ្យតាលក់សេះ ដែលចៃដន្យនាំមកជួបនឹងព្រះអង្គនៅពេលចុងក្រោយគឺពេលដែលព្រះអង្គ កំពុងប្តេជ្ញាចិត្ត ហៀបនឹងត្រលប់ទៅរួមរស់ស្នេហាជាមួយនឹងនាង "អមនុស្ស" ចេះមន្តអាគមបំប្លែងមនុស្សអោយទៅជាសត្វធាតុសព្វបែបយ៉ាង នោះវិញទៅហើយ) ....

រឿងនេះ បង្ហាញជាអាទិ៍ថា ភាវៈវក្សាខ្លួនអោយនៅជាសង្ឃ ពេញលក្ខណៈមួយអង្គ ជាផ្លូវមួយតឹងតែង យូរយា ហើយប្រកបដោយឧបសគ្គរាប់មិនអស់ទេ ។ គេត្រូវការ សេចក្តីអំណត់ អត់ធ្មត់ តស៊ូ នៅមុខបាតុភូតធម្មជាតិ ឬបដិហារសព្វបែបយ៉ាងទាំងអស់ផង ។

**សាស្ត្រាចារ្យ**

**នួន កន**

# រឿង ព្រះសង្ឃនៅភ្នំកូយ៉ា

# KOYA HIJIRI

## ជំពូកទី ១

អាត្មាបានគិតថា ទោះជាមិនបាច់លាផែនទី សំរាប់កងទាហានធ្វើប្រតិបត្តិការសឹកមើល ក៏អាត្មាអាចរកផ្លូវទៅមុខបានដែរ ក៏ប៉ុន្តែនៅពេលដែលដើរទៅឃើញថាផ្លូវនៅក្នុងភ្នំនោះតូចសែនតូច រុក្ខជាតិដែលនៅសងខាងខ្លួនអាត្មាដុះដេរដាស ប្រែខ្លួនទៅក្តៅសឹងតែរលាកដោយសារកំដៅព្រះអាទិត្យ ។

អាត្មាបានលាត់ដៃអាវ គីម៉ូណូ ដែលគេសំរាប់ពាក់ធ្វើដំណើរ រួចហើយក៏លាផែនទីដែលអាត្មាបានធ្វើក្របក្រៅដាក់អោយវា ហើយបានបត់ជាផ្នត់ៗនោះមើលសាជាថ្មីម្តងទៀត ។

នៅតាមភ្នំដ៏សែនជ្រៅ ដែលអាត្មាត្រូវតែឆ្លងកាត់ ពី " ហ៊ីដា " ទៅ "ស៊ីនស៊ូ " គេឃើញមានតែដើមឈើតូចៗ អោយរកដើមឈើស្គមស្ដែ ត្រឈឹងត្រឈៃគួរអោយសំរាកសំចតយកកំលាំងធ្វើដំណើរទៅមុខទៀត គឺពុំមានឡើយ ។ បើងាកទៅឆ្វេងក៏ឃើញតែថ្មភ្នំ មើលទៅស្ដាំក៏ភ្នំ សឹងតែថាអាចលោដៃទៅចាប់មកលេងបាន ។ ពីចង្កេះភ្នំមួយ ដុះភ្នំថ្មីមួយទៀត មើលទៅលើមានកំពូលដែលហាក់ដូចជាមួក ហើយគ្មានឃើញសត្វស្លាបឯណាមួយហើរ ឬក៏ពពកមួយដុំឡើយ ។

នៅចន្លោះមេឃ និង ដី ហាក់ដូចជាមានតែអាត្មាមួយអង្គឯង ដើរម៉ង់ៗក្រោមកាំរស្មីព្រះអាទិត្យដ៏ក្តៅចែស ពណិស ចាំងព្រាកៗ ។ អាត្មាអាចមើល

ផែនទី បានក៏ដោយសារតែមួកឫស្សីដែលធំដូចឆ័ត្រ ដែលអាត្មាពាក់គ្របពីលើក្បាល យ៉ាងជ្រៅសឹងតែមើលមុខមើលមាត់មិនឃើញ ។

ព្រះសង្ឃដែលនិមន្តធ្វើធម្មយាត្រា សឹងផ្កាប់មុខ ក្តាប់ដៃទាំងពីររបស់លោកបញ្ឈរពីលើខ្នើយទ្រថ្ងាស លោកសឹងបណ្តើរនិទានរឿងអោយខ្ញុំស្តាប់បណ្តើរ ។

ខ្ញុំបានធ្វើដំណើរជាមួយលោកពី "ណាង៉ូយ៉ា" រហូតមកដល់ "ស៊ីគីដា" នៃខេត្ត អេជីសេង មកដល់ផ្ទះសំណាក់ឈ្មោះ " កាតូរីយ៉ា " នេះ រហូតដល់ពេលដែលលោកសឹងនេះ ខ្ញុំពុំដែលឃើញលោកសឹងផ្ងារម្តងណាឡើយ ។

មើលទៅលោក ហាក់ដូចជាមានបូកពារធំខ្ពស់ ហើយហាក់ដូចជាមិនចង់មើលអ្វីទាំងអស់ ។

ខ្ញុំចាំបានថា ខ្ញុំបានជួបនឹងព្រះសង្ឃនេះតាមខ្សែរថភ្លើង " តូកៃដូ " នៅភូមិ "កាគេង៉ាវ៉ា " នៅពេលដែលខ្ញុំឡើងជិះរថភ្លើងពីចំណតនោះ ។ វេលានោះលោកអង្គុយលើកៅអីមួយក្បែរជញ្ជាំងបិទភ្នែក ធ្លាក់ព្រះកេសស្ប៉ាប ប្រៀបបាននឹងជាសាកសព ទន់ករងាក យ៉ាងស្រងេះស្រងោច ហើយខ្ញុំក៏ពុំបានជាចាប់អារម្មណ៍ទៅលើលោកប៉ុន្មានឡើយ ។

លុះរថភ្លើងបានទៅឈប់នៅចំណត " អូវ៉ារី " អ្នកដំណើរទាំងឡាយបានចុះចេញពីរថភ្លើងអស់រលីង ហាក់ដូចជាគេណាត់គ្នា នៅសល់តែព្រះសង្ឃ និងរូបខ្ញុំតែពីរនាក់គត់ ។

រថភ្លើងដែលយើងជិះនេះ បានចាកចេញពី "ស៊ុមបាស៊ី " នៅម៉ោង ៩កន្លះយប់នៃថ្ងៃម្សិល ហើយយើងបានជិតមកដល់ "ស៊ីរ៉ង់ា " ហើយ ។

ដោយយើងទៅដល់ "ណាង៉ូយ៉ា " នៅវេលាថ្ងៃត្រង់ យើងគោងតែទិញបាយកញ្ចប់ទទួលទាន ។ ព្រះសង្ឃបានទិញបាយកញ្ចប់ឆាន់ដូចខ្ញុំដែរ ។

នៅវេលាយើងស្រាយសំណុំបាយកញ្ចប់នោះ យើងឃើញមានតែសារ៉ាយក្រៀមៗនៅរោយពីលើបាយតែប៉ុណ្ណោះ ។ និយាយទៅបាយកញ្ចប់នោះ គឺបាយលេខចកធុនអន់ ។

- ប៉ែ! មានតែការ៉ុត និង សារ៉ាយហ្នឹង?

ព្រះសង្ឃលាន់មាត់ ហាក់ដូចជាទ្រាំលែងបាននៅពេលដែលលោកមើលមកមុខខ្ញុំ រួចហើយលោកក៏តាំងសើចខឹកៗ ។

ដោយសារតែនៅក្នុងទូររថភ្លើងមានតែយើងពីរនាក់ យើងក៏បានទៅជាមិត្តជិតស្និទ្ធនឹងគ្នាភ្លាម ហើយខ្ញុំក៏បានទូលសួរលោកថា តើលោកនិមន្តទៅណា? លោកបានឆ្លើយថា លោកនិមន្តទៅ " អេជីសេង " លោកបានមានសង្ឃដីកាថា លោកធ្លាប់បាននិមន្តទៅវត្ត " អេហេ " ដែលជាវត្តមួយនៅក្នុងគណៈដែលខ្ញុំគោរព ថ្វីត្បិតតែឋានៈលោកខុសពីខ្ញុំក្តី ហើយលោកនឹងគង់នៅ " ស៊ីរ៉ង់ា " មួយយប់ ។

ដោយខ្ញុំត្រូវវិលត្រឡប់ទៅស្រុកកំណើតនៅ " វ៉ាកសា " ហើយក៏ត្រូវតែស្នាក់នៅកន្លែងដូចលោកដែរ យើងក៏បានសន្យាគ្នាថា នឹងទៅស្នាក់នៅទីនេះជាមួយគ្នា ។

ព្រះសង្ឃបានមានសង្ឃដីកាថាលោកគង់នៅភ្នំ " កូយ៉ា " ព្រះជន្មប្រហែលជា ៤៥ ឬ ៤៦ព្រះវស្សា ។ លោកពុំមានសភាពជាមនុស្សផ្ដេសផ្ដាសទេ មានភាពគួរអោយរំលឹកឃើញដល់នរណាម្នាក់ ហើយស្ងប់ស្ងាប់ ។ លោកពាក់អាវរងាដៃជ្រុង រុំកដោយកន្សែងកាំម៉ីស ពាក់មួកចាមទូរគី ស្រោមដៃឡែន ស្រោមជើងស ស្បែកជើង យីពុនឈើ ។ មើលទៅមិនសមជាព្រះសង្ឃទេ ។ បើអោយនិយាយថាជាសាស្ត្រាចារ្យបង្រៀនសិល្បៈដូចជាសមជាង ហើយបើថាជាមនុស្សសាមញ្ញទៀតរឹតតែត្រូវ ។

លោកបានសួរថា :

- តើយប់នេះ អ្នកឯងស្នាក់ឯណា?

ខ្ញុំបានទូលលោកថា ខ្ញុំធ្វើដំណើរតែឯង ពុំមានទីសំណាក់ថ្លៃថ្នូរទេ ។

ខ្ញុំបានដកដង្ហើមធំមួយឃ្មូស ហើយក៏បន្តថា :

- រឿងកន្លែងអាចទ្រាំទ្របានខ្លះៗទេ តែរឿងដែលពុំអាចទ្រាំទ្របានគឺត្រង់ថានារីបំរើ បំរើភ្ញៀវទាំងភ្លែកបិទរលីវៗ អ្នកបំរើចូលចិត្តនិយាយបញ្ចើចបញ្ចើ ហើយបើអោយតែហ៊ានចេញដើរតាមរបងបន្តិចមើល បើមិនគេនាំគ្នាតាមមើលយើងអោយលាន់ ។ លើសពីនេះទៅទៀត គ្រាន់តែដាក់បាយល្ងាច

អោយភ្ញៀវទទួលទានហើយ ពួកគេនាំគ្នាប្រញាប់ប្រញាប់ពន្លត់ចង្កៀង ហើយដុតគោមជំនួសវិញ រួចបង្ខំអោយភ្ញៀវទទួលទានដំណេកក្នុងទីងងឹត ។

ដោយខ្លួនខ្ញុំពុំសូវចេះគេងឆាប់ ទំរាំតែបានដេកលក់ ខ្ញុំត្រូវលំបាកអស់យ៉ាង ។ ជាពិសេសប៉ុន្មានថ្ងៃនេះវេលាយប់វែងផង តាំងពីមុនចេញពីតូក្យូបន្តិចម្លេះ ខ្ញុំតែងតែបារម្ភពីរឿងសំរាកពេលយប់សឹងតែធ្វើអ្វីមិនកើត ។ ហើយខ្ញុំបាននិយាយធ្វើសំណូមពរថា ដូច្នេះបើព្រះសង្ឃពុំយល់ទាស់ទេ សូមអោយព្រះអង្គមេត្តានាំខ្ញុំទៅស្នាក់នៅកន្លែងដែលលោកសំណាក់ផង ។

ព្រះសង្ឃធម្មយាត្រាបានងក់ព្រះកេស យល់ព្រមទទួលសេចក្តីស្នើរបស់ខ្ញុំដោយរីករាយ ។ លោកបានមានសង្ឃដីកាថា នៅវេលាដែលលោកនិមន្តទៅធម្មយាត្រានៅតំបន់ខាងជើងឯ "ហុកនីគី " លោកតែងតែទៅសំណាក់នៅផ្ទះមួយឈ្មោះ " កាតូរីយ៉ា " ។ " កាតូរីយ៉ា " នេះពីដើមជាផ្ទះសំណាក់ ។ ប៉ុន្តែនៅពេលដែលបុត្រីតែមួយរបស់ម្ចាស់ផ្ទះស្លាប់ទៅ មាតាបិតាចាស់ៗ បានដកយីហោផ្ទះសំណាក់ចេញឈប់ធ្វើ ។ ប៉ុន្តែគេនៅតែទទួលភ្ញៀវជិតស្និទ្ធអោយសំរាកជារឿយៗដូចមុនដែរ ។ ម្ចាស់ផ្ទះប្តីប្រពន្ធចាស់ៗ រាក់ទាក់បំរើភ្ញៀវហាក់ដូចជាញាតិសន្តានរបស់គេអញ្ចឹង ។ ហើយប្រសិនបើខ្ញុំមិនយល់ទាស់ទេ លោកនឹងនាំខ្ញុំទៅសំណាក់នៅផ្ទះនោះជាមួយលោកដែរ ។

វេលាមានសង្ឃដីកាដល់នេះ ព្រះសង្ឃធម្មយាត្រា បានដាក់កញ្ចប់បាយសំណុំទៅក្រោម :

- ប៉ុន្តែអាត្មាប្រាប់អោយហើយថា ម្ហូបមានតែការ៉ុត និង សារ៉ាយទេ ហ្នាំ !

មានសង្ឃដីកា ហើយព្រះសង្ឃក៏សើច ហាស ហាស ហាស យ៉ាងស្រួល មិនសមនឹងសភាពរមទម្យ ថ្លៃថ្នូរ ខាងក្រៅរបស់លោកសោះ ។

## ជំពូកទី ២

នៅ " ងីហ៊ុ " គេអាចឃើញមេឃពណ៌ខៀវខ្លះៗបាន ប៉ុន្តែនៅឯខាងតំបន់ " ហុករីគី " ដ៏ល្បីល្បាញឯណោះវិញ នៅខាង "ម៉ៃបារ៉ា " ឬ ណាង៉ាហាម៉ា មានពពកស្តើងៗហើយព្រះអាទិត្យបញ្ចេញពន្លឺដ៏ខ្សោយ ដែលនាំអោយរងា។ ហើយនៅឯ " យ៉ាណាង៉ាសេ " ពេលនោះភ្លៀងធ្លាក់ ។

នៅវេលាដែលបង្អួចនៃរថភ្លើងឡើងងងឹត មានអ្វីសៗធ្លាក់ប្រុយៗលាយឡំនឹងទឹកភ្លៀងមក ។

- ហ្គាំ ព្រិលទេតើ?
- អើ ! ឥចឹងមែន ។

ព្រះសង្ឃមានសង្ឃដីកាបែបនោះមែន តែចំលើយរបស់លោកទ្រង់រាងបែបហីៗ ហើយព្រះអង្គមិនទាំងងើយព្រះកេសរបស់ទ្រង់ផង ។ នេះមិនមែនជាលើកទីមួយទេ ។ នៅវេលាដែលខ្ញុំបានបង្ហាញលោកពីសមរភូមិចាស់នៅពេលសង្គ្រាមនៅឯ " ស៊ីស៊ីង៉ាតាគេ " ក្តី ពេលខ្ញុំបង្ហាញលោកពីទេសភាពដ៏ល្អនៃ "ទន្លេប៊ីវ៉ា " ក្តី ក៏ព្រះសង្ឃមិនដែលឆ្លើយអ្វីអោយសមជាពាក្យចំលើយក្រៅពីងក់ព្រះកេសរបស់ទ្រង់តែប៉ុណ្ណោះឡើយ ។

ពេលនៅដល់ " ស៊ីរីង៉ា " ខ្ញុំភ័យឡើងសម្បុរតឹងក្តក់ ដោយសារពួកអ្នកធ្វើការនៅផ្ទះសំណាក់វាប្រទាញប្រទង់ ភ្ញៀវរញ៉ីរញ៉ៃ អនាធិបតេយ្យផុតលេខតាមស្ថានីយ៍ ។

នៅថ្ងៃនោះ គ្រាន់តែរថភ្លើងឈប់ង៉ក់ភ្លាម ពួកគេនោះបានស្ទុះងើបមកតំរៀបជួរត្រៀបត្រាតាំងពីមុខស្ថានីយ៍ រហូតដល់ចុងភូមិ ណែនណាន់តាន់តាប់កាន់គោមក្រដាស និង ឆ័ត្រដែលមានសរសេរឃីហោ ផ្ទះសំណាក់បីដូចជាទំនប់ទឹក សឹងតែរកច្រកចេញទៅក្រៅក៏ពុំបាន ។

ពួកនោះចោមរោមភ្ញៀវអោយស្អិត ស្រែកពពាយនាយពីផ្ទះសំណាក់របស់ខ្លួនឮទ្រហឹងអ៊ឹងអាប់ ល្បងខ្លះទាញឥវ៉ាន់កញ្ចាក់កញ្ចែងពីដៃភ្ញៀវហើយនិយាយថា :

- អញ្ជើញលោកភ្ញៀវ អញ្ជើញតាមខ្ញុំ សូមអរគុណណាំទានណាំ !

អ្នកមានជំងឺឈឺក្បាលជាប្រចាំ ច្បាស់ជាឡើងឈាមទ្រាំលែងបានពុំខានព្រោះវាហួសហេតុពេក ។

ឯព្រះសង្ឃយើងវិញលោកនិមន្តត្រុក១ ដើរចេញធ្វើជាហី គ្មានប្រែតងណាមកទាញដៃទាញជើងលោកម្នាក់ឡើយ ។ ឯខ្ញុំឯនេះក៏បានស្រួលតាមនោះគឺ គ្រាន់តែដើរតត្រុកពីក្រោយលោកទៅ ក៏បានចេញមកក្រៅហ្វូងមនុស្សដោយសំរួល ហើយយើងទាំងពីរ បានដើររហូតទៅដល់ផ្សារ ទើបបានធូរដង្ហើមបន្តិច ។

ព្រិលមិនព្រមរាំងសោះ ។ គេឈប់ឃើញតំណក់ភ្លៀងដែលធ្លាក់លាយជាមួយនឹងព្រិល ហើយឃើញតែព្រិលតែម្យ៉ាងដែលធ្លាក់រវូ១មកប៉ះត្រូវមុខយើងឡើងត្រជាក់ស្រេប ។

ផ្ទះសំណាក់ទាំងឡាយដែលតែងបិទទ្វារនៅម៉ោង ៨យប់ បានប្រញិប ប្រញាប់បិទទ្វារអស់ នាំអោយវិថីទាំងឡាយនៃទីក្រុង " ស៊ីរ៉ង់ា " ឡើងស្ងាត់ជ្រងំ ។ យើងបានដើរតាមផ្លូវក្រឡាៗ ឆ្លងកាត់ផ្លូវមួយពីរ ទទឹងបណ្តោយៗ ទៅដល់ផ្លូវកាច់ជ្រុងត្រឡែងកែង ដ៏ទូលាយមួយ ។ យើងដើរជិត ៣គីឡូម៉ែត្រ ទំរាំតែបានទៅដល់ផ្ទះសំណាក់ដែលយើងមានបំណងមករក គឺ "កាតូរីយ៉ា "នេះ ។

គេពុំឃើញមានគ្រឿងតុបតែងលំអអ្វីពិសេស នៅលើក្តារក្រាល ឬក៏ កន្ទេលតាតាមី នៃបន្ទប់នានាទេ ប៉ុន្តែសសរទ្រូងនៃគេហដ្ឋាននេះធំស្កុកស្កម កន្ទេលតាតាមីហាប់រឹងក្រាស់ឃ្មឹក ឡកំដៅធំសំបើមណាស់ ។ លើសពីនេះ រូបចំលាក់ត្រីរស់ធ្វើពីឈើដែលដាក់បន្តោងពីលើឡកំដៅនេះឡើងខ្មៅរលោង ប្រៀបបានដូចជាត្រីដែលធ្វើពីសំរិទ្ធ ។

គេឃើញជើងក្រាន ធំអស្ចារ្យពីរដាក់តម្រៀបគ្នា មានឆ្នាំងយក្សធំៗ តើតពីលើ សឹងតែថាអាចដាំបាយនឹងអង្ករមួយបាវបាន ។ ពោលអោយខ្លីទៅគឺជាគេហដ្ឋានបុរាណដ៏ស្កុកស្កមមួយ ។

ម្ចាស់ផ្ទះប្រុសមានក្បាលត្រងោលស្រិល ដៃគាត់ពន្លឹបចូលក្នុងដៃអាវគីម៉ូណូ អត់បញ្ចេញមកក្រៅទេ សូម្បីតែនៅពេលដែលគាត់អង្គុយអាំងភ្លើងនៅមុខឡក៏ដៃទាំងពីររបស់គាត់នៅតែលីប ឥតបញ្ចេញមកក្រៅដែរ ។ គាត់ជាបុរសចំណាស់ដ៏ទក់មក់ ។ ឯដូនចាស់ជាប្រពន្ធគាត់វិញ រាក់ទាក់ណាស់តែដូចជាចូលចិត្តបញ្ចិបបញ្ចុបភ្លៀវបន្តិច ។

នៅពេលដែលឮព្រះសង្ឃមានសង្ឃដីកាពីការ៉ុត និង សារ៉ាយ គាត់សើចញឹមៗ ហើយគាត់បានទទួលយើងដោយត្រីប្រឡាក់គ្រៀម និង កូនត្រីសៗព្រមទាំងសម្លស្ងោរដែលមានសារ៉ាយស្រស់ៗ ។ ការទទួលយើងក្តី ពាក្យសម្តីសំដៅរបស់គាត់ចំពោះយើងក្តី សុទ្ធសឹងតែបង្ហាញអោយឃើញថា គាត់មានទំនាក់ទំនងពិសេសជាមួយព្រះសង្ឃ ដែលនាំអោយខ្ញុំដែលគ្រាន់តែជាមិត្តរួមដំណើររបស់លោកបានក៏កក់ក្តៅជាមួយដែរ ។

បន្ទាប់មកគេបានរៀបចំក្រាលពូក អោយយើងទទួលទានដំណេកនៅជាន់ទី ២ ។ ពិតានផ្ទះនេះទាបមែន ប៉ុន្តែធ្នឹមធ្វើពីឈើមួយដើមមូលមានទំហំប្រហែលជាពីរឱប ដំបូលឡើងជ្រេមានសំយ៉ាប ធ្លាក់មកសឹងតែប៉ះក្បាល ។ ផ្ទះនេះមើលទៅឃើញមាំទាំណាស់ បើទោះជាភ្លៀងដែលនៅខាងក្រោយនោះរលំបាក់មកសង្កត់ក៏មិនទៅណាដែរ ។

វេលានេះដោយម្ចាស់ផ្ទះបានដាក់តុកំដៅអោយយើង ខ្ញុំក៏ចូលទៅសំរាកទាំងត្រេកអរកខិបកខុបឥតវារែក ។ ម្ចាស់ផ្ទះបានក្រាលពូកមួយទៀត នៅក្នុងតុកំដៅនេះសំរាប់ព្រះសង្ឃដែរ ប៉ុន្តែលោកពុំចូលមកទេ លោកដកយកតែខ្នើយកើយទៅដាក់លើកន្ទេល តាតាមី ហើយសឹងនៅក្រៅតុកំដៅ ។

វេលាសឹងព្រះសង្ឃមិនដោះ គីម៉ូណូ និងខ្សែក្រវ៉ាត់ អូប៊ី សំរាប់រុំ គិម៉ូណូ អោយវាជាប់នឹងខ្លួនលោកឡើយ លោកសឹងដូចគេក្រាប ផ្កាប់មុខលោកទៅលើខ្នើយ ។ ហើយនៅពេលដែលខ្ញុំយកភួយទៅគ្របពីលើ លោកឱនក្បាលថ្លែង

អំណរគុណចំពោះខ្ញុំ ។ មើលទៅព្រះសង្ឃសឹងខុសពីយើងជាឧបាសកធម្មតា ដែលដាក់ក្បាលលើខ្នើយ ។

មួយសន្ទុះមកខ្ញុំក៏នៅស្ងៀមដោយស្រួលពេក ព្រមទាំងគិតថា ខ្ញុំច្បាស់ជាធ្វេចភ្លេកលង់លក់ទៅទាំងអញ្ចឹងហើយ ។ ប៉ុន្តែដោយពីកាលដែលយើងនៅក្នុងរទេះភ្លើង ខ្ញុំបានទូលលោកថា ខ្ញុំមានដំណេករឹងពុំងាយទទួលទានដំណេកលក់បានភ្លាមៗ លោកក៏នឹកអាណិតខ្ញុំក៏ពុំដឹង ក៏នៅកំដរខ្ញុំអោយបានជាគ្នា ។

ខ្ញុំបានទទូចលោកដោយឥតរអែងចិត្តលោក សុំអោយលោកនិទានរឿងប្លែកៗ ពិរោះៗ អោយខ្ញុំស្តាប់ ពីព្រោះលោកធ្វើដំណើរច្រើន ច្បាស់ជាជួបប្រទះនឹងរឿងចំឡែកៗមិនលែងឡើយ . ។ ពេលឮខ្ញុំនិយាយបែបនេះ ព្រះសង្ឃងក់ព្រះកេសហើយមានពុទ្ធដីកាថា :

- អាត្មានេះធ្លាប់អស់ហើយ មិនចេះសឹងផ្ងាដូចគេ ពេលសឹងគឺសឹងបែបនេះ ។ ប៉ុន្តែឥឡូវនេះមិនទាន់ងងុយទេ ។ អាត្មាក៏ដូចតែអ្នកឯងដែរ មិនសូវចេះសឹងលក់ភ្លាមៗទេ ។ ឯរឿងដែលអាត្មានឹងនិយាយនេះ មិនមែនជារឿងដែលទាក់ទងទៅនឹងធម៌អាថ៌ បុណ្យទានអ្វីទេ ថ្វីត្បិតតែអាត្មាជាសង្ឃមែន ។

សូមអ្នកឯងចាំស្តាប់ណាំ !

រួចហើយលោកក៏ចាប់និទានរឿង ។

ក្រោយមកទើបខ្ញុំបានដឹងថាព្រះសង្ឃនេះ ជាព្រះសង្គ្រាជនៃវត្ត "រីគីមិនយី" ដ៏ល្បីល្បាញ ហើយលោកជាព្រះសង្ឃដែលពូកែទេសនីលេខមួយ ។

## ជំពូកទី ៣

អ្នកឯងបាននិយាយថាបន្តិចទៀត មិត្តអ្នកដែលធ្វើដំណើរមកពីស្រុក "វ៉ាកាសា " ដែរ នឹងមកសំណាក់នៅទីនេះដែរ ។ គេជាឈ្មួញដើរលក់ចានក្បាន ឈើលាបខ្មុកម្រក្សាហ្ន៎? តាមពួអ្នកឯងនិយាយ គេក្មេងមែន ប៉ុន្តែជាយុវជនល្អ ដឹងខុសត្រូវស្គាល់បុណ្យស្គាល់បាប ។

ឯមនុស្សដែលអាត្មានឹងនិយាយនៅក្នុងរឿងអាត្មានេះ គឺជាឈ្មួញដែល ដើរលក់ទំនិញពីស្រុកមួយទៅស្រុកមួយដូចមិត្តអ្នកដែរ តែជាអ្នកលក់ថ្នាំ ដែល មានចរិតលក្ខណៈអាក្រក់មហាសែនអាក្រក់ មកពី " តូយ៉ាម៉ា " ។ អាត្មាបាន ជួបគេនៅហាងកាហ្វេមួយនៅពេលដែលអាត្មារកឆ្លងភ្នំ " ហ៊ុដា " គឺនៅចង្កេះភ្នំ នោះ ។

ដំបូងនៅពេលចេញពីផ្ទះសំណាក់ អាត្មាបានគិតថាត្រូវចេញអោយបាន ពីព្រលឹមដើម្បីនឹងឡើងអោយទៅដល់កំពូលភ្នំ ហើយចុះទៅវិញអោយទាន់ថ្ងៃ តែមួយនោះ ។ អាត្មាគិតថាដើរលេងៗមិនបាច់បន្ទាន់ក៏គង់នឹងដល់ ហើយវេលា ព្រឹកត្រជាក់ផង ដើរ៦យោជន៍ នឹងទៅដល់ហាងកាហ្វេហើយ ។ ប៉ុន្តែដោយ មេឃស្រឡះបើកថ្ងៃ ធាតុអាកាសក៏ឡើងក្តៅសឹងតែឆេះ ។ អាត្មាក៏តាំងចាប់ បង្ហំដំណើរដើម្បីអោយឆាប់ទៅដល់ ។ ទាល់តែឥចឹងទៅ អាត្មាក៏ខះកទ្រាំលែង បានវេលាទៅដល់ភ្លាមក៏ហៅបំរើអោយដាក់ ទឹកតែមួយពែងអោយ ។ ប៉ុន្តែ អ្នកបំរើបាន និយាយថា ថ្មើនេះទឹកមិនទាន់ពុះទេ ។ ពីព្រោះថាពេលថ្មើនេះពុំ

ដែលមានមនុស្ស ដើរកាត់មកផ្លូវនេះ ហើយគេធ្វើបាយបំរើតែអ្នកភ្ញៀវ ដែលមកសំណាក់ វេលាយប់នៅទីនេះទេ ។

នៅពីមុខកៅអីវែង មានកូនស្ទឹងតូចមួយហូរយ៉ាងត្រជាក់ ។ អាត្មាក៏យកកូនចានដែកមួយមកបំរុងនឹងដួសទឹកស្ទឹងនោះឆាន់ ។ តែគាប់ជួនជានឹកឃើញរឿងមួយក៏ទុចទៅវិញ ។ រឿងនោះ គឺដោយសារតែធាតុអាកាសឡើងក្តៅហួសកំរិតបែបនេះជំងឺឆ្លងបានរាតត្បាតភូមិស្រុកជាច្រើន ។ តួយ៉ាងភូមិ " ស៊ីយី " ដែលអាត្មាបានដើរកាត់មកមុននេះ ក៏ឃើញមានតែកំបោររោយរាយអោយសំព្រុះពាសពេញ ។ អាត្មាក៏បានសួរទៅនារីបំរើទាំងញញើតញញើមថា :

- អ្នកនាងតើទឹកនេះ ហូរពីអណ្តូងឬនាង?
- អត់ទេតេជគុណ នេះជាទឹកស្ទឹង ។

  នារីនោះឆ្លើយដោយទឹកមុខ ចំឡែក ។

- អាត្មាឮគេថាមានជំងឺ រាតត្បាត ឆ្លងរាលដាល ។ តើទឹកនេះមិនមែនហូរពីភូមិ " ស៊ីយី " មកទេឬ?
- មិនមែនទេ ព្រះតេជគុណ ។

  នារីឆ្លើយធម្មតា ។ អាត្មាបានធូរចិត្ត ។ ពេលនោះស្រាប់តែ :

- មកខ្ញុំករុណាប្រាប់ ព្រះសង្ឃដ៏មានឥទ្ធិឫទ្ធិអើយ ។

អ្នកដែលនិយាយនោះ គឺជាអ្នកលក់ថ្នាំដែលអាត្មានិយាយអំបាញ់មិញនោះ ។ គេមកសំរាកទីនេះ មុនអាត្មាមកដល់ ។ គេលក់ថ្នាំស្អីទេឈ្មោះ " ម៉ាំង

គីនតាំង ។ គេពាក់ គីម៉ូណូ សំរាប់រដូវក្តៅ ក្រវាត់ខ្សែក្រវាត់សំរាប់រុំពោះអូប៊ី ព្រមទាំងព្យួរនាឡិកាមួយពីលើនោះផង ។ គេស្លៀកខោខ្លី ពាក់ស្បែកជើងចំបើង ហើយនៅកគេមានព្យួរកូនបង្វិចមួយ ដែលត្បាញពីស្មៅមួយពាន់ជំពូក ពាក់អាវភ្លៀងនីឡុងមានកាន់ឆ័ត្រមួយធ្វើពីអំបោះ ។

របៀបតែងខ្លួន និង ខោអាវ គេសមរម្យស្អាតបាតណាស់ ។ មុខមាត់ក៏សមតែជាអ្នកចេះដឹងមានប្រាជ្ញា ។ គេថាគេនឹងសំណាក់នៅទីនោះ ហើយក៏ប្តូរស្លៀក គីម៉ូណូ សំរាប់ស្លៀកពាក់នៅផ្ទះវិញ ហើយបើកចំហាតក្រវាត់ អូប៊ីទេ។ ជននោះដាក់ជើងទៅលើភ្លៅរបស់នារីបំរើធាត់ម្នាក់ ចីបស្រាសបណ្តើរនិយាយមករកអាត្មាបណ្តើរ ។ គេលេងអាត្មាអស់ដៃ :

- មើលតេជគុណ អោយខ្ញុំករុណាសុំមានយោបល់បន្តិច ។ ពួតែគេថាទេ ណាទានណា ! ថាមនុស្សប្រុសតែដល់ពេលដែលស្រលាញ់ស្រីលែងបានក៏តាំងនាំគ្នារត់ទៅបួស តើត្រូវទេទាន? លុះតែបួសទៅជាសង្ឃដាច់ឃៃ ហើយក៏នៅតែខ្លាចងាប់ដូចតែមនុស្សមានកិលេសដែរឬទាន? ខ្ញុំករុណាឆ្ងល់ណាស់ហ្អែ ! គិតទៅកំពូជទាវានៅតែទា ប្រវឹកនៅតែប្រវឹក មិនថាឥចឹង ឬ មេអូន? តែដូចជាគួរអោយអាណិតគួរអោយស្រលាញ់បន្តិច១ដែរ ដោយសង្ឃនៅមានចិត្តដូចមនុស្សក្បាលខ្មៅដែរ ។

ថាហើយពួកគេ ក៏មើលមុខគ្នាសើចកក្អឹកទាំងពីរនាក់ ។

ពេលនោះអាត្មានៅក្មេង អាត្មាខ្មាសគេនោះខ្មាស មុខឡើងក្រហម ។ វាក៏គោះខ្សៀបុំងហើយនិយាយតទៅទៀតថា :

- បានជាខំដងទឹកហើយម៉េចក៏មិនឆាន់ទៅ នៅរារែកធ្វើអ្វីទៀត? ឆាន់អោយឆ្អែត ឆាន់អោយដូចគេង្វូតទៅទាន ។ បើមានគ្រោះថ្នាក់ដល់ជីវិត ខ្ញុំករុណាមានថ្នាំទេតើ? ខ្ញុំករុណានៅនេះគឺដើម្បីសង្គ្រោះជីវិតមនុស្សសត្វហើយតើ? នេះជាតួនាទីខ្ញុំករុណាណាំទាន ! មិនថាឥចឹងឬមេអូន? តែនិយាយលេងសើចអីមិនប្រគេនទទេទេណាំទាន ។ ថ្នាំខ្ញុំករុណានេះពូកែដូចថ្នាំទិព្វ ។ ថ្នាំ "មាំងគីនតាំង" នេះមួយគ្រាប់ ពារៀលណាទាន ។ ខ្ញុំព្រះករុណាមិនចូលចិត្តការបិណ្ឌបាត្រទទេ ដែលជាទោសដ៏ធ្ងន់មួយដូចអស់ផងគេនិយមធ្វើទេ ។ ម៉េចមេអូន? មេអូនឯងទិញទេ?

ថាហើយវាក៏ទះខ្នងនារីបំរើញូស្ទូវតែប៉ុង ។

និយាយពីរឿងដាក់ជើងលើភ្លៅ ឬរឿងស្ត្រីបែបនេះ វាមិនសមនឹងព្រះសង្ឃដែលមានអាយុច្រើនដូចអាត្មានិយាយទេ ។

- ចូរឯងកុំប្រកាន់ណាំ ទាំងអស់វាជារឿងពិតដែលអាត្មាបានប្រទះ ។

## ជំពូកទី ៤

ព្វជននេះនិយាយបែបនេះអាត្មាក៏ក្តៅគុម្ពត្រចៀក តែមិនឆ្លើយតបទេ ។ ផ្ទុយទៅវិញអាត្មាបានប្រញិបប្រញាប់ចាកចេញពីទីនោះ ដើម្បីកុំអោយប៉ះទង្គិចជាមួយវា ហើយចុះតាមជំរាលភ្នំយ៉ាងលឿនទៅដល់ជើងភ្នំ ព្រមទាំងផ្លូវដែលមានស្រែនៅជុំវិញ ។

វេលាដើរបានប្រហែលជា ៥០ម៉ែត្រ ផ្លូវក៏ស្រាប់តែឡើងចោតមួយរំពេច ហើយកន្លែងដែលសំរាប់ឡើងទៅមានតែមួយទេ គេអាចមើលពីចំហៀងទៅឃើញច្បាស់ រាងដូចជាធ្នូហាក់ដូចជាបង្កាន់ស្ពានដែលមានរាងកោងធ្វើពីដី ។ អាត្មាមើលទៅលើប្រុងនឹងឡើងទៅហើយ ស្រាប់តែអ្នកលក់ថ្នាំអំបាញ់មិញនោះវាដើរស្តេស្តា ស្តេស្តាមកដល់ដែរ ។ យើងទាំងពីរឥតបាននិយាយអ្វីជាមួយគ្នាទេ ម្យ៉ាងទៀតទោះបីជាអ្នកបាទនោះ វានិយាយអ្វីមករកអាត្មា ក៏ប្រហែលជាអាត្មាមិនតបតទៅគេវិញដែរ ។

អ្នកបាទលក់ថ្នាំដែលចូលចិត្តចំអកឡកឡឺយ ទុកគេឯងមិនស្មើវានោះ បានចោលកន្ទុយភ្នែកមកសំឡក់អាត្មាបន្តិច រួចហើយក៏តាំង ស្តេស្តា ស្តេស្តា ដើរយ៉ាងលឿនជែងអាត្មាទៅមុខអាត្មាបាត់ រួចក៏ច្រត់ឆ័ត្រជំនួសឈើច្រត់ទប់ខ្លួនឡើងផ្លូវចោទដូចកូនភ្នំដែលនៅពីមុខនោះ ហើយចុះទៅក្រោមបាត់ទៅ ។

អាត្មាបានខំឡើងពីក្រោយវា ក៏បានទៅដល់ផ្លូវដ៏ទូលាយ ដូចពោះស្ពានមួយ ។ រួចពីនោះទៅគេត្រូវដើរចុះជំរាលទៅទៀត ។

អ្នកលក់ថ្នាំបានចុះទៅមុន ហើយឈររវេរា១សំលឹងជុំវិញទំនងដូចជាចង់រកស្នៀតលេងអាត្មាម្តងទៀត ។ អាត្មាដូចជាធុញថប់ក្នុងចិត្តមួយរយៈ ។ លុះដល់មើលអោយល្អិតល្អន់ទៅក៏បានដឹងពីហេតុផលអោយជននោះឈររវេរ ។ នៅចំពីមុខវា ផ្លូវបានចែកចេញជាពីរប្រៀបបានដូចជាចំពាម ។ ផ្លូវមួយចេញទៅជាទូលហើយជាផ្លូវដែលត្រូវឡើងទៅលើយ៉ាងចោត មានស្មៅដុះសងខាង ហើយផ្លូវនោះជាបន្តទៀត ក្រងិកក្រងក់ពីក្រោយដើមស្រល់មួយដែលដុះនៅលើចិញ្ចើមផ្លូវនោះ ត្រង់កន្លែងកាច់ជ្រុង ដែលមានទំហំប្រហែលជា ៤ឱប ឬ ៥ឱប ។ នៅលើផ្លូវនោះចាប់ពីត្រង់ដើមស្រល់នោះទៅ គេឃើញមានផ្ទាំងថ្មធំៗ ២-៣ តម្រៀបគ្នាហើយតពីលើគ្នាទៅទៀត ។ អាត្មាបានពិនិត្យយ៉ាងស្រួលបួលទៅក៏បានដឹងច្បាស់ក្នុងចិត្តថា មិនមែនផ្លូវនេះទេ ផ្លូវដែលអាត្មាបានដើរមក គឺផ្លូវដែលទូលាយ ហើយមិនក្រងិកក្រងុកមិនចោតឯនោះទេ ដែលជាផ្លូវត្រឹមត្រូវ ។ បើដើរប្រហែលជាជិតពីរយោជន៍ទៅមុខទៅ នឹងបានទៅដល់ភ្នំមួយរួចហើយនឹងទៅជាជំរាលចុះទៅក្រោមដោយប្រាកដ ។

លុះមើលៗទៅស្រាប់តែមិនដឹងជាយ៉ាងម៉េចទេ ដើមស្រល់ដ៏ធំអំបាញ់មិញនោះ ស្រាប់តែមានរាងកោងដូចឥន្ទធនូ ទៅលើលំហអាកាសដែលនៅពីលើវាលស្រែវែងធំទូលាយដាច់កន្ទុយភ្នែកកាត់ពីលើផ្លូវ ។ ឯដីដែលនៅម្តុំឫសដ៏ធំសំបើមរបស់វា ឡើងរបើករបាញលេចឫសវាដែលមានសភាពដូចអន្ទង់ធំៗព័ទ្ធពេន វិណ្ឌលើគ្នាយ៉ាងច្រើន ។ គេឃើញមានទឹកបាញ់ឆ្ពាច ចេញពីឫសទាំង

នោះមក ហើយហូរហៀរទៅលើដី ហើយបង្កើតទៅជាថ្លុក ទឹកនៅចំកណ្តាលផ្លូវ ។

ចំឡែកដែរ ដោយទឹកនេះវាមិនបណ្តាលអោយលិចស្រែ ហើយគ្រាន់តែកើតជាថ្លុកទឹកដ៏រាក់មួយតែប៉ុណ្ណោះ ។ ហួសពីនោះបន្តិចមានគុម្ពោតស្មៅមួយកណ្តុប ។

គុម្ពោតនេះបានទៅជាខ្សែសីមាខ័ណ្ឌថ្លុកដែលមានប្រវែងប្រហែលជា ២០០ម៉ែត្រ នៅលើផ្លូវ ។ នៅក្នុងថ្លុកទឹកគេឃើញមានដុំថ្មតូចៗ ហាក់ដូចជាមានមនុស្សតម្រៀបសំរាប់ឆ្លងថ្លុកនេះ ។ ដោយថ្មនោះតម្រៀបគ្នាជារាងសមរម្យឥតទាស់ ទើបអាត្មាគិតថាវាពុំមែនមានពីធម្មជាតិទេ ច្បាស់ជាមនុស្សយកមកតម្រៀបហើយ ។

ប្រហែលជាឃើញបែបនេះទេដឹង បានជាអ្នកលក់ថ្នាំរារែក ។ ពេលអាត្មាកំពុងតែគិតស្រាប់តែអ្នកលក់ថ្នាំ ដើរស្តេស្តាប្រវេប្រវា ជ្រើសរើសយកផ្លូវចោតដូចភ្នំខាងស្តាំ ហើយឡើងទៅ ។ អាត្មាតាមមើលនៅគេឃើញ គេមុជក្រោមដើមស្រល់ទៅក្រោយឡើងទៅឈរពីលើក្បាលអាត្មារួចឱនមកក្រោមហើយថា :

- នែលោកសង្ឃ ! ផ្លូវទៅ " ម៉ាតស៊ីម៉ូតូ " នៅខាងនេះហ្នែ !

ថាហើយគេក៏ដើរស្តេស្តាទៅមុខ ៤-៥ជំហានទៀត ។ បន្ទាប់មកគេក៏លោមួយកំណាត់ខ្លួនខាងលើរបស់គេពីលើផ្ទាំងសិលាមក ។

- កុំភ្លឹកយូរពេក ប្រយ័ត្នសម្លេងខ្ទរមកវិញពីភ្នំវាលេបលោកសង្ឃឯងបាត់ណា៎ ! កុំស្មានថាពេលថ្ងៃភ្លឺទែងបែបនេះ គ្មានគ្រោះថ្នាក់ ។

គេស្រែកមកហើយក៏រលុបខ្លួនបាត់ស្រមោល ទៅក្រោយផ្ទាំងថ្ម ហើយបាត់ស្រមោលទៅក្រោយដើមស្នោខ្ពស់ៗបាត់ទៅ ។

មួយសន្ទុះក្រោយមកអាត្មាបានឃើញចុងឆ័ត្ររបស់គេ ដែលលេចចេញពីទីមួយដែលទាល់តែងើយមើលទៅទើបឃើញ ។ ចុងឆ័ត្រនោះលេចចេញប្រផិតប្រផើយពីប្រឡោះមែករុក្ខជាតិទាំងឡាយ ហើយក៏រលុបទៅក្នុងគុម្ពោតព្រៃបាត់ទៅ ។

- ហ្វេ ហ៊ីប ! ហ្វេ ហ៊ីប ! អាត្មាឮសូរសម្លេងដូចជាកូនក្មេងលោតលេងនៅលើថ្មដែលគេតម្រៀបនៅក្នុងថ្លុកទឹក តំរង់មកទីដែលអាត្មាឈរ ។ គឺកសិករម្នាក់ដែលមានវីណ្ឌកន្ទេលតូចមួយនៅនឹងចង្កេះស្នាម្ខាងស្ពាយដងរែកទទេមួយ ។

## ជំពូកទី ៥

- តាំងពីអាត្មាចេញពីហាងកាហ្វេមករហូតមកដល់ទីនេះ អាត្មាពុំបានជួបអ្នកណាក្រៅពីអ្នកលក់ថ្នាំទេ ដូចអ្នកឯងឃើញស្រាប់ ។ មុនពេលដែលយើងបែកគ្នា ដោយគេបានចោលសម្ដីមករកអាត្មាប្រាប់ផ្លូវអាត្មា និង ដោយអាត្មាបានឃើញថាគេជាអ្នកដើរលក់ថ្នាំ ដើរកាត់ស្រុកភូមិច្រើន គេច្បាស់ជាស្គាល់ផ្លូវមិនវង្វេងទេ ឯអាត្មាដែលមិនធ្លាប់ មុននឹងចេញពីហាងកាហ្វេ អាត្មាបានលាផែនទីមើលហ្មត់ចត់ល្អិតល្អន់ណាស់ ហើយឥឡូវនេះសោតក៏អាត្មាប្រុងនឹងលាវាមើលម្ដងទៀតដែរ ។

- អោយអាត្មាសូមសួរបន្តិច ។

- ព្រះករុណា ព្រះតេជគុណចង់សួរពីអ្វីទាន? គេសួរមកអាត្មាវិញយ៉ាងសុភាព ព្រោះមនុស្សដែលនៅជនបទ តែងតែមានទម្លាប់ប្រើពាក្យគួរសមពិរោះពិសាចំពោះព្រះសង្ឃ ។

- ទេ អាត្មាមិនមានបំណងសួរអ្វីអោយធំដុំទេ គ្រាន់តែចង់ដឹងថាតើផ្លូវនេះទៅត្រង់ទៅដល់ " ម៉ាតស៊ីម៉ូតូ " ទេអ្នក?

- ឱព្រះតេជព្រះគុណនិមន្តទៅ " ម៉ាតស៊ីម៉ូតូ " ឬទាន? ត្រូវហើយសូមនិមន្តចុះ ។

- តើទីកនេះ វានៅអញ្ជើងរហូតចប់តែផ្លូវទៅឬញ្លោម?

- ទេ ព្រះតេជគុណ ដូចព្រះតេជគុណឃើញហើយទេតើ អត់អញ្ចឹងទេ ទឹកទៅដល់ត្រឹមតែគុម្ពោតនោះប៉ុណ្ណឹងទេ រួចតែពីនោះទៅ គឺផ្លូវធម្មតាដូចអញ្ចឹងដែរ សឹងតែថាបររទេះដឹកឥវ៉ាន់តម្រៀបគ្នាក៏ទៅបានរហូតដល់ភ្នំឯនោះ ផ្លូវគេទូលាយណាស់ ។ កន្លែងគុម្ពោតនោះពីដើម គឺជាផ្ទះដ៏ធំរបស់លោកគ្រូពេទ្យម្នាក់ ហើយម្តុំៗនេះថ្មីត្បិតតែឃើញអញ្ចឹងទេ ពីដើមគឺជាភូមិមួយ ។ កាលពី ១៣ឆ្នាំមុន មានទឹកជំនន់ធំដែលធ្វើទីនេះក្លាយទៅជាទីរហោស្ថាន មានមនុស្សស្លាប់ច្រើនណាស់ ។ ព្រះតេជគុណ បើនិមន្តទៅសូមព្រះអង្គមេត្តាសូត្រមន្តផ្តល់សេចក្តីមេត្តាដល់ព្រលឹងរបស់អ្នកទាំងអស់នោះផង ។

កសិករបាននិយាយយ៉ាងរាក់ទាក់ ប្រាប់ទាំងរឿងដែលអាត្មាមិនទាំងបានសួរផង ។ តែប៉ុណ្ណេះអាត្មាដឹងរឿងរ៉ាវល្អិតល្អន់ហើយមិនច្រឡំទេ ក៏ប៉ុន្តែវាទាស់តែមានមនុស្សម្នាក់វង្វេងផ្លូវ ។ អាត្មាក៏សួរពីផ្លូវទូលខាងឆ្វេងដៃដែលអ្នកលក់ថ្នាំដើរទៅលមើល ។

- ចុះផ្លូវខាងនេះទៅណាដែរ?

- ព្រះករុណា ផ្លូវនេះពី ៥០ឆ្នាំមុន គឺជាផ្លូវថ្មល់ចាស់ដែលអ្នកស្រុកដើរចុះឡើងមិនដាច់ទេទាន ។ ផ្លូវនេះទៅ " ស៊ីនស៊ូ " ដូចតែគ្នាទេ ។ និយាយពីប្រវែង គឺខ្លីជាងផ្លូវខាងស្តាំ ៧យោជន៍ ប៉ុន្តែឥឡូវនេះពុំមែនជាផ្លូវដែលអាចធ្វើដំណើរបានទេ ។ ឆ្នាំមុននេះមានគ្រួសារមួយធ្វើធម្មយាត្រា ហើយច្រឡំទៅផ្លូវនោះ ។ ពេលនោះរឹករវដល់សួរហើយ ព្រះតេជព្រះគុណអើយ អ្នកទាំងនោះ មិនខុសពី

អ្នកសុំទានប៉ុន្មានទេ ប៉ុន្តែជីវិតគេទាំងមូល គឺជីវិតមនុស្ស ត្រូវតែទៅសង្គ្រោះ សំរេចដូច្នេះប៉ូលីស ៣នាក់ និង អ្នកស្រុក ១២នាក់ បានបង្កើតជាក្រុមសង្គ្រោះ ហើយឡើងទៅជួយគេទំរាំនឹងរំដោះបានមកវិញ ។ ព្រះតេជព្រះគុណសូមកុំចង់លកុំបីមានឈាមភាវ ហើយកុំចង់ជ្រើសរើសផ្លូវជិត។ បើទ្រង់ហត់ខ្លាំងសូមសឹងតាមផ្លូវ លើវាលលើស្មៅទៅប្រសើរជាងទៅតាមផ្លូវនោះ ។ ខ្ញុំករុណាសូមថ្វាយបង្គំលាហើយ សូមព្រះតេជព្រះគុណនិមន្តអោយបានសុខតាមផ្លូវណាំទានណាំ !

អាត្មាបានបែកពីកសិករនៅទីនោះ ហើយប្រុងនឹងលើកជើងជាន់ជុំថ្មនៅក្នុងថ្លុកដើរទៅមុខទៅហើយ ទទួលនឹកដល់អ្នកលក់ថ្នាំក៏រារែក ។ អំបាញ់មិញអាត្មាបានឮកសិករនិយាយថាផ្លូវនោះគ្រោះថ្នាក់ បើរឿងនេះវាពិតជាអញ្ចឹងហើយអាត្មាមិនទៅទាញវាមកផ្លូវត្រូវវិញ ឃើញថាអាត្មាមើលនឹងភ្នែក មិនសង្គ្រោះសត្វលង់ទឹក ។ ខ្លួនឯងនេះជាសង្ឃ ។ អាត្មាមិនចាំបាច់អ្វីនឹងប្រញាប់ដើរអោយទៅដល់ផ្ទះសំណាក់ ហើយសឹងមុនថ្ងៃលិចក៏ទេដែរ ដូច្នេះត្រូវតែទៅតាមវាហើយទាញវាមកវិញ ។

ដើរតាមផ្លូវចាស់ ក៏មិនមែនជាផ្លូវដែលមានចោរ ហើយក៏មិនមែនជារដូវចចកចេញដែរ បើថាមានខ្មោចភ្នំ ឬ ខ្មោចទឹកវាចេញមកទាញជើង ក៏ទៅតាមវាសនាទៅចុះ មិនដឹងធ្វើម៉េចទេ គិតបែបនេះហើយអាត្មាក៏តាមមើលកសិករចិត្តល្អនោះ ទាល់តែបាត់ស្រមោលគាត់ទៅ ។

- ទៅយើង !

អាត្មាបានប្ដេជ្ញាចិត្តដើរឡើងផ្លូវទូលទៅ ។ អាត្មាមិនមែនជាមនុស្សក្លាហាន ឬក៏ជាមនុស្សពុះកញ្ជ្រោល ឈាមភាវដែរ តាំងពីណាពីណើមក ។ ដូចអាត្មាបាននិយាយប្រាប់ខ្លះៗមកហើយ ។ អ្នកឯងក៏អាចដឹងបានខ្លះៗដែរ ថាអាត្មានេះកំសាក ទន់ខ្សោយ សូម្បីតែទឹកស្ទឹងក៏មិនហ៊ានផឹកទៅហើយ ព្រោះតែខ្លាចស្លាប់ ចុះហេតុអ្វីបានជារញ៉ីរញ៉ូរទៅរកជួយសង្គ្រោះគេ ។

បើត្រឹមតែស្គាល់គ្នា ដោយគ្រាន់តែបានងក់ក្បាលគំនាប់គ្នាអី អាត្មាប្រហែលជាមិនទៅទេ វាទាស់តែអាត្មាបានដឹងថាអ្នកនោះជាមនុស្សមានចរិតមិនល្អហើយបើមិនទៅទាញវាមកវិញទេ វាហាក់ដូចជាអាត្មានេះមានបំណងចង់សងសឹកនឹងវា ...

ព្រះសង្ឃរាជនៅតែសឹងផ្ទាប់ព្រះភ័ក្ត្រដដែល ដៃលោកប្រណម្យ ។

- ត្រឹមតែសូត្រធម៌ទទេ មិនអាចប្រោសសត្វបានទេ ញោម !

## ជំពូកទី ៦

- សូមឯងទ្រាំស្តាប់បន្តណា !

បន្ទាប់ពីនោះមក អាត្មាក៏បានដើរឆ្លងកាត់ដើមស្រល់ទៅដល់ផ្ទាំងសិលាខាងក្រោយនោះ រួចចេញពីក្រោមផ្ទាំងសិលាមួយឡើងទៅលើផ្ទាំងសិលាមួយទៀត មុជក្នុងដើមឈើក៏បានទៅដល់កូនផ្លូវតូចមួយ ដែលមានស្មៅដុះទ្រុបទ្រល់រហូត រហូត ...

រួចហើយតែមួយភ្លែតសោះ ក៏បានចុះភ្នំដែលបានឡើងអំបាញ់មិញនេះ ហើយក៏បានឃើញភ្នំមួយទៀតនៅពីមុខអាត្មា ។ អាត្មាដើរតាមវាលដ៏ទូលាយមួយរយៈពេល ហើយក៏បានទៅដល់ផ្លូវមួយដ៏ធំទូលាយ ស្រួលជាងផ្លូវដែលអាត្មា បានដើរពីមុននេះទៅទៀត ។

មើលអោយសព្វទៅ ហាក់ដូចជាគេយកភ្នំមួយមកដាក់ចំកណ្តាលទិសខាងលិច និង ខាងកើត អោយកើតចេញជាផ្លូវពីរតម្រៀបគ្នា បើឥចឹងទោះជាទ័ពស្តេចក្រាញ់ កាន់ខែលក៏អាចដើរកាត់បានដែរ ។

នៅលើផ្លូវដ៏ធំទូលាយបែបនេះ តើអោយអាត្មាទៅរកស្រមោលអ្នកលក់ថ្នាំដែលតូចប៉ុនចៃឯណាឃើញកើត? នៅក្នុងលំហមេឃ ដែលឡើងក្រហមដូចជាដុត គេឃើញតែកូនសត្វល្អិតតូចៗហោះឆ្លៀវឆ្លា ។

អាត្មាដើរទាំងក្តីបារម្ភលួល្ហេវនៅក្នុងចិត្តណាស់ ពីព្រោះទីនោះវាធំទូលាយពេក រកអ្វីជាទីបង្អែកក៏គ្មាន ។

ពិតណាស់ថ្ងៃដែលអាត្មាបានសំរេចថានឹងឆ្លង " ហ៊ីដា " អោយផុត អាត្មាបានដឹងថាក្នុងចំងាយ ៧យោជន៍ នឹងមានផ្ទះអ្នកស្រុកមួយខ្នង ហើយក្នុងចំងាយ ១០យោជន៍នឹងមាន ៥ខ្នង ។ ក្នុងខណៈបែបនេះយើងមិនអាចរំពឹងថា នឹងអាចហូបបាយបានទេ បើបានត្រឹមតែចុងអង្ករហូបក៏វាគ្រាន់ណាស់ណាទៅហើយ ។ លុះអាត្មាគិតបែបនេះហើយជើងអាត្មាក៏មានកំលាំងព្រឹស ទេថាឥចឹងក៏បានដែរ គឺថាចិត្តកំឡាចទាំងឡាយបានអន្តរធានបាត់ទៅណាអស់ ហើយអាត្មាដើរទៅមុខទ្រុលតែម្តង ។ រំពេចនោះភ្នំដែលនៅសងខាង កាន់តែសង្កើញមកជិតអាត្មា ឯផ្លូវសោះទៀតក៏កាន់តែចង្អៀតទៅៗ សឹងតែដើរប៉ះស្មា បន្ទាប់មកអាត្មាត្រូវឡើងភ្នំមួយទៀត ។

អាត្មាដឹងថាបន្តិចទៀត នឹងទៅដល់ភ្នំ " អាម៉ៅ " ដំល្បីល្បាញអាត្មាក៏ដូចជាភ័យតិចៗដែរ ព្រោះវាក្តៅ ដូច្នេះអាត្មាក៏ចាប់ចងខ្សែស្បែកជើងសាជាថ្មីទាំងដង្ហក់ ។

អាត្មាបានដឹងនៅពេលក្រោយមកទៀតនោះទេ គឺនៅពេលដែលអាត្មាចាស់ហើយថានៅខាងក្រោមកន្លែងដែលអាត្មាឡើងនោះមានឧមង្គ ដែលបន្តភ្ជាប់ទៅដល់បន្ទប់ក្រោមដីនៃព្រះវិហារវត្ត " រ៉េងដៃយិ " នៃខេត្ត " មិណុ " ។ វេលានោះអាត្មាអត់ដឹងទាល់តែសោះ ។ អាត្មាពឹតតែខំឡើងភ្នំពុំបានចោលភ្នែកទៅមើលទេសភាពថាវាស្អាតវាល្អ ឬក៏គួរអោយខ្លាចគួរអោយញញើតក៏ពុំដឹងដែរ ។ ហើយ

សូម្បីតែថាពេលនោះស្រទំ ឬបើកថ្ងៃក៏អាត្មាពុំបានចាប់អារម្មណ៏ដែរ គិតតែខំប្រវេប្រវាស្តេស្តាឡើងភ្នំមិនទាំងហ៊ានប៉ប្រិចភ្នែកផង ។

សាច់រឿងដែលអាត្មានឹងនិយាយអោយអ្នកឯងស្តាប់ គឺចាប់ផ្តើមពីត្រង់នេះទៅ ។ ដូចអាត្មាបាននិយាយហើយថា ផ្លូវដែលត្រូវធ្វើដំណើរនោះអាក្រក់សែនអាក្រក់ គឺជាផ្លូវដែលគ្មានមនុស្សដើរ ហើយដែលគួរអោយខ្លាច គឺមានពស់ទៅទៀត ។ អាសត្វនេះវាដាក់កន្ទុយវាទៅគុម្ពោតដែលនៅផ្លូវម្ខាង ហើយចាក់ក្បាលវាទៅក្នុងគុម្ពោតនៃផ្លូវម្ខាងទៀត ខ្លួនវានៅដេកស្បៀចកណ្តាលផ្លូវដូចស្ពានឥចឹង ។

ពេលឃើញវាដំបូងអាត្មាពាក់មួកឫស្សី ហើយកាន់ឈើច្រត់ដដែលថប់ដង្ហើមសឹងតែដាច់ ដាក់គូថអង្គុយបត់ជើងប៉ុក ។ ឱអាត្មានេះស្អប់ពស់ហៅមហាសែនស្អប់តាំងពីកំណើត ។ និយាយថាស្អប់គ្រាន់ទេ ថាអោយចំទៅគឺខ្លាចតែម្តង ។

ដំបូងថាទៅជួយស្រង់សត្វលង់ទឹក អាការៈនេះវាទៅជាចំណោះជិះកឯង ។ លោកពស់នោះគាត់លា កដូចកណ្ដៀវផ្ទក់ចេញមក រួចក៏លូនកាត់ស្មៅលាន់ឮប្រស់ៗ។ យូរណាស់ដែរ ទំរាំនឹងអាចងើបរួច ហើយក៏ដើរប្រហែល ២០០ ឬ ៣០០ម៉ែត្រ ក៏ស្រាប់តែទៅប្រទះឃើញពស់មួយផ្សេងទៀតដូចគ្នាបេះបិតខ្លួនវាឡើងស្លូតឥតក្បាល ឥតកន្ទុយទេ ។ ដេកស្ប៉ាប ។

អាត្មាភ្ញាក់ព្រើតស្រែករកពុទ្ធោ ហើយលោតទៅក្រោយ វាក៏អន្តរធានទៅណាបាត់ទៅ ។

លើកទី ៣ អាត្មាក៏ប្រទះពស់មួយទៀត ។ អានោះវាអត់កំរើកភ្លាម១ទេ ខ្លួនវាធាត់ទ្រលុក១រអិលអន្ទិលស្អិត១ បើវាចង់លូនដើម្បីអោយទៅផុតទាំងក្បាលទាំងកន្ទុយប្រហែលជាត្រូវការពេល ៥នាទី ហើយមើលទៅ គឺខ្លួនវាវែងអស្ចារ្យទៅណាំ ពុំដឹងធ្វើម៉េច អាត្មាក៏ដើរកន្លងវាស្រាប់តែ ពោះអាត្មាវាឡើងហើម រោមអាត្មាព្រឺរន្ធរោមទាំងឡាយទាំងពួង វាក្លាយទៅជាស្រកា ទឹកមុខអាត្មាទាំងអស់ ហាក់ដូចជាទៅជាពស់អស់ បើមានកញ្ចក់ក៏អាត្មាច្បាស់ជាមិនហ៊ានមើលមុខខ្លួនឯងដែរ ។ អាត្មាខ្លាចឡើងបែកញើសស្រោក់ ញ័រជើងតគាត់ឈរសឹងមិនជាប់ តែអាត្មាខំដើរទៅមុខទាំងខ្លាចរញ្ជាក់រញ័រ ។ វេលានោះតាំងលេចអាមួយទៀតចេញមក ។ ម្តងនេះមានតែមួយកំណាត់ខាងកន្ទុយទេ ។ កន្លែងស្នាមកាត់ឡើងពណ៌ស្វាយជាំ ហើយមានទឹកពណ៌លឿង១ហូរចេញមក ខ្លួនវាកំរើកខ្ញោក១ ។

អាត្មាដល់តែខ្លាចពេកទៅ លែងនឹកឃើញអ្វីទាំងអស់រត់ត្រឡប់ក្រោយទីណាត់ទីណែង ពេលដឹងខ្លួនវិញក៏នៅតែឃើញវាទៀត ។ អាត្មាបានគិតស្រេចហើយថាបើទោះជាអាសត្វនោះវាលងសម្លាប់អាត្មាទៅទៀត ក៏អាត្មាមិនហ៊ានលោតកន្លងវាដែរ ។ អាត្មានឹកថា ប្រសិនបើកសិករគាត់ប្រាប់អាត្មាតែមួយម៉ាត់ថានៅផ្លូវនេះមានពស់ ម្ល៉េះហើយអាត្មានេះទោះជាធ្លាក់នរកទៅទៀតក៏មិនមក

ឡើយមិនមកជាដាច់ខាត ។ សត្វនេះវាបានធ្វើអោយអាត្មាញាប់ញ័រអស់សព្វសព៌ាង្គកាយ អាត្មាគិតតែបង្ហូរទឹកភ្នែករកពុទ្ធោឥឡូវនេះ គ្រាន់តែនិយាយប៉ុណ្ណឹង ក៏ព្រឹសម្បុរបាត់ទៅហើយ ។ មានសង្ឃដីកាហើយព្រះសង្ឃក៏យកព្រះហស្ថ ច្រត់ថ្ងាសលោក ។

## ជំពូកទី ៧

គិតទៅថាវាមិនចេះចប់ទេ ក៏គិតតែខិតខំប្រមូលកំលាំងចិត្ត ហើយសំរេចថាមិនត្រលប់ទៅក្រោយទេ ។ នៅកន្លែងនោះមានសាកសពពស់ដែលមានតែមួយកំណាត់ខ្លួន អាត្មាបានរត់ទៅឆ្ងាយអោយផុតពីវា ហើយបានទៅដល់ក្នុងគុម្ពោតស្មៅ ប៉ុន្តែក្នុងចិត្តចេះតែនឹកភ័យប៉ផ្អុកថា អាមួយកំណាត់ទៀតច្បាស់ជាដេញមកតាមអាត្មា តាមក្រោយមកឥឡូវហើយឡើងទៅជាលែងទុកចិត្តខ្លួនឯងជើងឡើងរឹងរួយទៅជំពប់នឹងថ្មដួលត្រឡប់ត្រឡិន អាត្មាក៏ឈឺជង្គង់យ៉ាងខ្លាំង ។

បន្ទាប់ពីនោះមក អាត្មាក៏ប្រវេប្រវាដើរទាំងលំបាក ព្រោះនឹកថាបើនៅអង្គុយស្ងៀមទីនេះក៏អាត្មាច្បាស់ជានឹងស្លាប់ឥតប្រយោជន៍ ដោយត្រូវចំហុយដោយកំដៅដ៏ខ្លាំងនេះមិនលែងឡើយ ។ អាត្មាបានកំឡាខ្លួនឯង ខំពង្រឹងកញ្ជឹងក និងទប់ខ្លួនបណ្តើរដើរបណ្តើររហូតដល់ជិតកំពូលភ្នំ ។

ស្មៅដែលនៅសងខាងផ្លូវ ចេញចំហាយពីក្រោមហាក់ដូចជាចេះបញ្ចេញដង្ហើមដ៏ក្តៅ មកនាំអោយព្រឺសម្បុរអស្ចារ្យ រួចនៅក្រោមជើងមានស្អីគេទេ ដូចពងសត្វស្លាបធំៗ ដេករណ្តូករណែលពាសពេញតែផ្លូវ ។

អាត្មាខំបន្តដំណើរប្រហែលជាពីរយោជន៏ទៅមុខតាមផ្លូវចោត ក្រវិកក្រវៀក់ដូចពស់ដ៏ធំមួយលូនទៅដល់ចង្កេះភ្នំនោះ ហើយក៏បានប្រទះនឹងជ្រុងផ្ទាំងថ្មមួយក៏បត់ទៅក៏បានឃើញឬសឈើមួយ ។ ដោយផ្លូវនោះវាយ៉ាប់ពេកអាត្មាក៏បើកផែនទីមើលម្តងទៀត ។

ផ្លូវចាស់ គឺផ្លូវហ្នឹងហើយ អត់ច្រឡំទេ ដូចគេបាននិយាយប្រាប់មក និងដូចដែលបានឃើញប្រត្យក្សនឹងភ្នែក។ ដូច្នេះអោយគិតយ៉ាងម៉េច ធ្វើយ៉ាងម៉េចក៏ដោះស្រាយមិនចេញ ម្យ៉ាងទៀតផែនទីនេះ គេគូរត្រឹមត្រូវរបស់គេ ហើយវិធីដែលបង្ហាញនៅលើផែនទីនេះ ចេញតែជាខ្សែក្រហមៗដែលគេគូសពីលើក្រដាសសំរាប់តែភ្ជាប់ចំណុចមួយទៅចំណុចមួយទៀតតែប៉ុណ្ណោះ ។

នៅក្នុងផែនទី គេអត់មានសរសេរអំពីការលំបាកពីពស់ ពីដង្កូវរោម ឬពីពងសត្វធំៗ ឬពីស្មៅដែលហាក់ដូចជាចេះដកដង្ហើមជាដើមទេ។ ដូច្នេះទោះជាមើលទៅក៏គ្មានបានការដដែល ជាដដែលអាត្មាក៏បត់វាទុកទៅក្នុងអាវរបស់អាត្មាវិញទៅ ។ នៅពេលដែលអាត្មាច្រកវាទៅប៉ះនឹងទ្រូងរបស់អាត្មាៗ ក៏បានសូត្រធម៌កំឡាចិត្ត សូត្រនោះ វាចេះតែសូត្រហើយ តែមិនទាន់ទាំងបានដកដង្ហើមអោយធូរស្រួលបួលផង ស្រាប់តែគួរអោយអស់សំណើចណាស់ពស់មួយបានលូនកាត់មុខអាត្មាមកតែម្តង ។

អាត្មាអស់តិរិះហើយៗក៏គិតថានេះ គឺជាអារុក្ខអារក្ខ អ្នកតាទេវតា ឬក៏ព្រាយអសុរកាយ ដែលនៅក្នុងព្រៃភ្នំនេះមិនលែងឡើយ ។ អាត្មាគ្រវែងឈើច្រត់ចោល លុតជង្គង់ឱនសំពះព្រះធរណីផ្ដិតផ្ដូងៗ :

- ឱព្រះអារុក្ខអារក្ខអ្នកតាទេវតា ឬព្រាយអសុរកាយ ដែលថែរក្សាទឹកដីព្រៃភ្នំនេះ សូមលោកមេត្តាបើកផ្លូវអោយអាត្មាដើរទៅផង អាត្មានឹងប្រុង

ប្រយ័ត្នមិនអោយប៉ះពាល់ ឬ រំខានដល់ដំណេកពេលថ្ងៃរបស់លោកទេ ។ អាត្មានឹងដើរថ្នមៗជើង ។

លោកឃើញទេ អាត្មាចោលឈើច្រត់ហើយ ។

អាត្មាបានឱនក្បាលសុំចុះចាញ់ ហើយក៏ងើបមុខឡើង ពេលនោះក៏ឮសូរសម្លេងសំបើមមួយលាន់ឡើង ។ អាត្មាបានគិតថាជាសម្លេងកំរើករបស់ពស់ធំហើយ ។ អាត្មាឃើញស្មៅញ័រម្តង ៣ហត្ថ ៤ហត្ថ ៥ហត្ថ ទាំង៤ទិស ជាង ៣ម៉ែត្រ ហើយបរិវេណនោះកាន់តែរាតធំឡើងៗ ឡើងដូចជាជ្រោះជ្រលងនិងភ្នំទាំងឡាយឡើងញ័រព្រមគ្នា ។ អាត្មាភ័យនោះសែនភ័យ ហាក់ដូចជាមានខ្យល់ត្រជាក់មករួបរឹតអោយខ្លួនអាត្មារងា បាត់បង់ស្មារតីមួយស្របក់ ។ ហើយនៅពេលដែលវិញ្ញាណអាត្មាបានត្រឡប់មករករូបរាងអាត្មាវិញ អាត្មាបានដើរចុះភ្នំមកដល់ខាងក្រោមស្រេចបាត់ទៅហើយ ។ អាត្មាបានឮសម្លេងខ្ទរពីភ្នំមកវិញ ហើយមានអារម្មណ៍ដូចជាមានខ្យល់កួចមួយរិបបក់ពីប្រហោងដ៏ធំធ្លុងមួយពីបាតជ្រលងដ៏ជ្រៅ ។

អាត្មាមិនដឹងថាពស់នោះ ជាអារុក្ខអារក្ខអ្នកតាទេវតាឬព្រាយអសុរកាយនៅក្នុងភ្នំ ដែលចេះស្តាប់វាចាបន់ស្រន់ ឬយ៉ាងណា មិនដឹងទេ វាបានអន្តរធានទៅណាបាត់នៅក្រោយពេលដែលអាត្មាបន់ស្រន់ហើយ ។ ធាតុក្តៅក៏បានធូរស្រាកស្រាន្តបន្តិច នាំអោយអាត្មាមានកំលាំងបន្តដំណើរទៅមុខបាន ។ អាត្មា

បានដឹងថាហេតុផល ដែលនាំអោយខ្យល់ឡើងត្រជាក់ភ្លាមនោះ គឺមកពីនៅមុខអាត្មាមានព្រៃព្រឹក្សាដ៏ធំមួយ ។

ចាស់បូរាណនិយាយតៗគ្នាមកថា នៅក្នុងព្រៃភ្នំ " អាម៉ៅ " នេះជូនកាលមេឃស្រឡះសោះក៏ស្រាប់តែមានភ្លៀងបង្អុរមកដែរ ។ នៅក្នុងរឿងនិទានដែរថានៅជិតនាំព្រះ មានព្រៃដែលគេកាប់ឈើហើយមិនបានដាំឈើជំនួសវិញ ហើយដល់ឥឡូវដើមឈើក៏ចុះតិចសឹងតែថាគ្មាន ។

លើកនេះស្បែកជើងអាត្មាឡើងត្រជាក់ ហាក់បីដូចជាមានក្តាមវារ ជំនួសពស់ ។ មួយសន្ទុះមកព្រៃក៏ចេះតែឡើងងងឹតទៅៗ តែនៅមានកន្លែងដែលកាំរស្មីព្រះអាទិត្យឆ្លុះចូលមកពីឆ្ងាយយ៉ាងខ្សោយ យើងអាចមើលឃើញផ្ទៃដីខ្មៅក្រឹបបាន ។ នៅកន្លែងខ្លះតាមកំលាំងនៃកាំរស្មីព្រះអាទិត្យ យើងឃើញមានពណ៌ខៀវ ក្រហម ផ្ងត់ៗល្អមើលណាស់ ។ ជូនកាលមានតំណក់ទឹកដែលធ្លាក់ទៅផ្ទុំលើស្លឹកឈើ វាហូរមកក្រោមដូចជាខ្សែអំបោះមកព័ទ្ធស្រេះចុងជើងអាត្មាពីព្រោះវាជ្រុះទៅបោកនឹងមែកឈើសិន ហើយរត់ចុះពីទីខ្ពស់ ។

រួចមកស្លឹកនៃរុក្ខជាតិពណ៌បៃតងជានិច្ចជាកាល បានធ្លាក់មកដែលយើងមិនអាចដឹងថា ជាស្លឹកអ្វីៗបានទេ ។ វាធ្លាក់មកដោយបន្លឺសម្លេងប្រឹសប្រស់ៗមកលើមួកឫស្សីរបស់អាត្មា ។ ជួនកាលទាល់តែដើរហួសទើបវាធ្លាក់រ៉ាវមកក៏មាន។ ស្លឹកទាំងឡាយនោះវាជ្រុះពីមែកមួយទៅប្រមូលផ្តុំលើមែកមួយរាប់សិបឆ្នាំសិនទើបបានវាជ្រុះមកលើដី តាមមើលទៅ ។

# ជំពូកទី ៨

បើអោយរៀបរាប់អំពីការព្រួយបារម្ភ គឺរៀបរាប់យ៉ាងម៉េចក៏មិនសមល្មមដែរ ចំពោះអាត្មាដែលកំសាក ហើយពុំបានរៀនធម៌ចេះជ្រៅជ្រះបែបនេះ ប៉ុន្តែដល់តែទៅនៅទីងងឹតវាហាក់ដូចជាត្រូវធាតុគ្នាយ៉ាងម៉េច ។

ខ្លួនអាត្មាបានធូរ ហើយអាត្មាបានភ្លេចពីការរោយជើង មើលទៅឃើញផ្លូវឡើងទូលាយ ។ អាត្មាបានដឹងថា អាត្មាដើរក្នុងព្រៃបាន ៧០ភាគរយហើយ ។ វេលាដែលកំពុងតែគិតដូច្នេះស្រាប់តែមានអ្វីធ្លាក់ពីលើមែកឈើ ដែលនៅខ្ពស់ពីលើក្បាលអាត្មាប្រហែល ៥-៦ហត្ថ មកលើមួកឫស្សីរបស់អាត្មា ឮតែខ្ទោក១ ។

អាត្មាមានអារម្មណ៍ហាក់ដូចជាមានដុំសំណ ឬក៏ផ្លែរុក្ខជាតិអ្វីវាធ្លាក់មកក៏គ្រវីគ្រលែងក្បាលជំរុះអោយវាជ្រុះមក ប៉ុន្តែវាពុំធ្លាក់ទេ នៅស្អិតជាប់ ។ អាត្មាក៏យកដៃរាវបោសវា តែដៃអាត្មាទទួលអារម្មណ៍ថា បានកាន់អ្វីត្រជាក់១ទន់១ អាត្មាបានដោះមួកមកមើល ឃើញសត្វអ្វីម្យ៉ាងដូចសត្វត្រែបានសមុទ្រ ដែលគេហែកជាពីរ ភ្នែកក៏គ្មានមាត់ក៏អត់តែវាច្បាស់ជាសត្វហើយ ។ អាត្មាភ័យស្លោសឹងតែរត់តែសត្វនោះបានរអិលធ្លាក់មកដល់ចុងម្រាមដៃអាត្មា វាទាមដៃអាត្មាហើយសំយោកខ្លួនតេកតោក១ពីម្រាមនោះ ។ អាត្មាឃើញឈាមអាត្មាពណ៌ក្រហមស្រស់ចេញពីចុងម្រាមដៃហើយធ្លាក់តក់១ចុះមកក្រោម អាត្មាភ្ញាក់ខំសម្លឹងវាពីជិតភ្នែក ស្រាប់តែមានមួយទៀតកំពុងតែទាមកួយដៃអាត្មា ដែលអាត្មាបត់ ។ ទំហំវាប្រហែលជា ១តឹកកន្លះ ហើយទំហំប្រហែល ២-៣ធ្នាប់ ។

អាត្មាហួសចិត្តសម្លឹងទៅវា ក៏ឃើញសត្វនោះឡើងរួញបន្តិចម្ដងៗ ពីក្រោមមកវិញ ហើយឡើងធាត់កន្ទុចធុចដោយសារវាបឺតឈាមអាត្មា ។ អាត្មាឃើញសាច់អាត្មាឡើងពណ៌ខ្មៅល្អក់រលោងមានឆ្នូតពណ៌ដី ។ អាសត្វដែលមានរូបរាងដូចត្រសក់ក្អួត ហើយចេះជញ្ជក់ឈាមនេះ គ្មានអ្វីក្រៅពីឈ្លើងឡើយ ។ ប៉ុន្តែដោយរូបរាងវាធំជ្រុលពេក អាត្មាក៏មើលវាមិនស្គាល់ពីដើមដំបូងបាន ។ អាត្មាពុំអាចដឹងដល់ទាល់តែសោះ មិនដឹងថាជាឈ្លើងនៃចំការអ្វី ត្រពាំងអ្វី មានចំណាស់ពីអង្កាល់ បានជាវាធំដល់ថ្នាក់នេះ?

អាត្មាខំរលាស់ដៃ ប៉ុន្តែវាស្អិតណាស់ មិនងាយជ្រុះធូរៗទេ អាត្មាហាក់ដូចជាព្រឺសម្បុរដែរ ប៉ុន្តែខំទាញវា។ វាឡើងយឺត ហើយចុងបញ្ចប់អាត្មាក៏អាចទាញវាផ្ដាច់ពីសាច់បាន ។ មិនបានទេម្ចាស់ថ្លៃអើយ អាត្មាបានចាប់ទាញវាហើយវាត់វាយវាទៅលើដី ប៉ុន្តែដែលឯណាទៅឈ្នះ ចាប់មួយចេញមួយ ព្រោះហាក់ដូចជាបានមកជាន់លើសំបុកវា វាចេញមកច្រើននោះច្រើន ហើយវៃឫកធ្វើមើលតែនេះជាប្រទេសជាតិដាច់មុខរបស់វា ជញ្ជក់ឈាមបែបនោះឯង ។

ផ្ទៃដីនៅក្នុងព្រៃទន់ល្មើយ ទោះជាវាត់វាយបែបណាក៏មិនងាយធ្វើអ្វីវានឹងស្លាប់ដែរ ។

បន្ទាប់មក អាត្មាមានអារម្មណ៍ហាក់ដូចជាមានអ្វីបំរះខ្វើកៗនៅម្ដុំកអាវ អាត្មាៗបានយកដៃស្ទាបទៅក៏ប៉ះខ្នងវាដែលទន់ៗរអិលៗ ម្ចាស់ថ្លៃស្ទាបទៅទ្រូងក៏មាន ហើយមានលោកឈ្លើងមួយវាត្រសុលចូលទៅដល់ក្រោមខ្សែក្រវាត់ អូបី។

អាត្មាឡើងស្លេកស្លាំងអស់ហើយៗ រាវៗមើលទៅឃើញថានៅលើស្នាក់មានឈ្លើងទាមដែរ ។

អាត្មាលោតផ្លោត ភ័យតក្កមាភ្លេចភ្លាំងស្មារតីញាប់ញ័រសព្វសព៌ាង្គកាយខំរត់ចេញពីក្រោមមែកឈើបណ្ដើរ ខំទាញអាសត្វឈ្លើងដែលអាត្មារកឃើញនៅលើខ្លួនបណ្ដើរ ទាំងច្រួលច្របល់ភ្លេចគិតឃើញអ្វីផ្សេង ។

ព្រះអើយគ្រាន់តែរំលឹកឡើងវិញ ក៏ឡើងសម្បុរគីង្គក់បាត់ទៅហើយនៅលើមែកឈើទាំងមូលនោះ គឺមានសុទ្ធតែឈ្លើងនៅពេលនោះ ហើយមានមែកណាមួយនោះឃើញសំបកឈ្លើងធ្លាក់រាយប៉ាយ ។

មើលចុះនៅលើមែកស្ដាំក៏ដោយ មែកឆ្វេងក៏ដោយ មែកដែលនៅពីមុខអាត្មាក៏ដោយ អាត្មាឃើញឈ្លើងអោយស្ញែង ។ អាត្មាស្រែកភ្លាត់សម្លេងព្រោះវាព្រឺក្បាលពេក ។ ពេលនោះ ... មានសរសៃអ្វីស្ដួមៗខ្មៅៗធ្លាក់ទៅលើជើងដែលពាក់ស្បែកជើងសង្រែកចំបើងមួយត្រួតលើមួយ ហើយនៅលើជើងមួយចំហៀងទៀតក៏បែបនោះដែរ ។ អាត្មាហាក់លែងទទួលអារម្មណ៍អ្វីទាំងអស់ហើយចុងជើងឡើងស្ពឹក ។ ឈ្លើងនីមួយៗខំបឺតស្រូបឈាមពីសរសៃឈាមអាត្មា អាខ្លីសោះឡើងលូតវែងធាត់ មើលទៅភ័យសឹងតែសន្លប់បាត់ស្មារតី ។ នៅពេលនោះ មានគំនិតដ៏ចំឡែកអាក្រក់មួយវាមកសណ្ឋិតនៅក្នុងខួរក្បាលរបស់អាត្មា ។ អាត្មាគិតថា អាឈ្លើងចង្រៃនេះវាច្បាស់ជាកកើតរស់នៅទីនេះតាំងពីជំនាន់ ដែលព្រះទើបតែនឹងបង្កើតស្រុកនេះម្ល៉េះមើលទៅ ហើយវារស់តែនឹង

ជញ្ជក់ឈាមមនុស្សណា សត្វណាដែលបានធ្វើដំណើរមកដល់កន្លែងនេះ ។ តើក្នុងរយៈពេលដ៏យូរអង្វែងនេះ តើអាសត្វអស់នេះវាបានទាមឈាមមនុស្សអស់ប៉ុន្មានលីត្រ ប៉ុន្មានដបទៅហើយ? ឧបមាថាបើឈ្លើងដ៏ច្រើនរាប់មិនអស់នេះវាជញ្ជក់ឈាម ហើយវាក្អួតឈាមនោះមកវិញមកលើដីៗនោះមិនលែងឡើយនឹងក្លាយទៅជាភក់ឈាម ហើយភ្នំមួយចំហៀងនឹងក្លាយទៅជាថ្លុកឈាមមិនខានឡើយ ។ សមនឹងទីនេះគ្មានពន្លឺថ្ងៃចាំងមកដល់ផង ម្ល៉េះហើយរុក្ខជាតិធំៗទាំងឡាយគង់តែនឹងក្លាយទៅជាឈ្លើងគួរអោយស្ញើបមិនលែងឡើយ ។

## ជំពូកទី ៩

មនុស្សជាតិនឹងអន្តរាយរលត់រលាយអស់ មិនមែននៅពេលដែលសំបកផែនដីដ៏ស្តើងរបែកឆេះដោយដុំភ្លើង ដែលធ្លាក់ពីចក្រវាឡមក ឆាបឆ្ងូលរោលរាល ឬក៏នៅពេលដែលមហាសាគរ ត្រូវគេកំទេចអោយទៅជាបំណែកតូចៗទេ គឺមក តែពីព្រៃឈើនៃស្រុក " ហ៊ុដា " ទាំងមូលទៅជាឈ្លើង ហើយចុងបញ្ចប់ទៅ នៅក្នុងត្រពាំងឬថ្លុកឈាម មានសត្វដែលមានរាងដូចជាសសៃខ្មៅៗ ហែលស្វេះ រាប់តំណជាប់គ្នាឯនោះទេ ។

ត្រូវហើយនរណាអាចជឿបាន នៅមាត់ព្រៃមើលទៅឃើញធម្មតាសោះ មិនគួរអ្វីនៅពេលចូលទៅដល់ខាងក្នុងឃើញនូវអ្វីៗ ដូចដែលអាត្មាបានរៀបរាប់មកដូច្នេះអញ្ចឹង? ហើយនៅពេលដែលយើងជាន់ជើងទៅក្នុងនោះកាន់តែជ្រៅទៅ ឫសឈើទាំងឡាយដែលឡើងពុកចាស់ ហើយក្លាយទៅជាឈ្លើង តើនឹងអោយមានជីវិតអ្វីរស់នៅកើត? លែងអ្វីនឹងមិនត្រូវពូកនេះសំលាប់ ។ អាត្មាហាក់ដូចជាត្រាស់ដឹងថា មនុស្សយើងនៅពេលដែលវេលាមរណៈខិតចូលមកកាន់តែជិត វេលានោះក៏ចេះតែមានអារម្មណ៍រវើរវាយ គំនិតផ្តេសផ្តាសចូលមកលង ។

បំណាច់តែនឹងស្លាប់ដដែល ត្រូវតែប្រថុយដើរទៅមុខអោយទៅឃើញនឹងភ្នែកនេះនូវជ្រុងត្រពាំងឈាម ដែលពុំដែលមាននរណាឃើញ ឬក៏យល់សុបិន្តឃើញទាល់តែសោះនោះអោយឃើញម្តង ។ លុះដល់អាត្មាសំរេចចិត្ត

បែបនេះហើយ សេចក្ដីខ្ញើមរអើម ភ័យខ្លាចមិនដឹងជារលុបបាត់ទៅណាអស់ ហើយរូបរាងកាយអាត្មាទាំងមូល ហាក់ដូចជាបានក្លាយទៅជាគ្រាប់អង្ករស់មួយ អាត្មាក៏បានអេះ រលាស់ឈ្លើង ចាប់ទាញវា លើកដៃ ទន្ទ្រាំជើង ជាន់ឈ្លេចវា មើលមកដូចជាគេឡូករបាំញាក់អាទំនើបផុតលេខ ដូចឆ្កួតរញាក់រញ៉េរនោះឯង ។

រួចហើយអាត្មាក៏ចាកចេញពីទីនោះ បន្តដំណើរទៅមុខទៀត។ មុនដំបូងនៅរមាស់ទ្រាំសឹងមិនបាន តែក្រោយមកក៏មានអារម្មណ៍ដូចជាខ្លួនឯងឡើងស្ពឹមហើយឈឺផ្សាពេញទាំងខ្លួន ។ ហើយដែលអាត្មាទ្រាំមិនបានគឺ សត្វនេះវាមិនឈប់រវៃសំរុកមកធ្វើទុក្ខទោសអាត្មាសោះ ។ អាត្មាវិលមុខ បាត់ស្មារតី ហើយវេលាដែលទារុណកម្មដ៏កាចសាហាវនោះវាឡើងដល់កំពូល វេលានោះអាត្មាក៏ដឹងខ្លួនថា ខ្លួនឯងកំពុងតែលើកដៃប្រណម្យព្រះអាទិត្យមួយវង់ដែលរះនៅឆ្ងាយ ...

បានន័យថាអាត្មាបានចាកចេញមកដល់ក្រៅខុម្ពឈ្លើងហើយ... វេលាដែលបានទៅដល់ក្រោមផ្ទៃមេឃពណ៌ខៀវហើយ អាត្មាក៏បានភ្លេចអស់នូវអ្វីៗដែលកន្លងមក ហើយអាត្មាបានបោកវាត់វាយខ្លួន ប្រមៀលខ្លួន ប្រកិតខ្លួនទៅនឹងផ្លូវភ្នំ ហាក់ដូចជាចង់លំអិតខ្លួនឯងអោយទៅជាផង់ធូលី។ ទោះជានៅលើដីនោះមានគ្រួស ឬ ម្ជុល ក៏អាត្មាពុំបានគិតដែរ ខ្លួនអាត្មាកកិតនឹងដី ឈូសដី រត់ទៅមុខ ៤-៥ជំហាន ខំរលាស់ជំរុះខ្មោចឈ្លើងពីរូបរាងកាយ។ រែកណ្ដឹងយំបណ្ដាក់យ៉ាងពិរោះ ហាក់ដូចជាសើចចំអកអោយអាត្មាពីភ្នំដែលនៅក្បែរនោះ ដែល

ហៀប តែនឹងក្លាយទៅជាថ្លុកឈាមដ៏ធំ ។ ព្រះអាទិត្យជ្រេទៅក្រោយភ្នំទៅហើយៗ ជ្រលងភ្នំក៏ឡើងងងឹតស្លុប ។ តែប៉ុណ្ណេះទោះជារូបកាយនេះ ក្លាយទៅជាចំណី របស់ចចកក៏អាត្មាអស់ចិត្តដែរ អាត្មាបានគិត ហើយដើរចុះតាមផ្លូវក្រវិកក្រវក់ មានអីលោកអើយ កូននេនច្រមក់បានលីឈើច្រត់លើស្មា ហើយដើរស្ពេស្ពា ៗ លឿនត្រុលសឹងតែមិនគួរអោយជឿ ។

បើរាងកាយដែលឈ្លើងទាមសុសសព្វសាច់ដែលឡើងឈឺផង រមាស់ផងរសើបផង នេះវាជាសះស្រួលបួលអីអាត្មាច្បាស់ជាច្រៀងបទទំនើបអ្វីមួយ ដោយរកព្រះធម៌ជាចម្រៀង ហើយលោតកញ្ឆក់កញ្ឆេងរាំមិនខាន ។ ស្មារតីអាត្មាបានវិលត្រឡប់មកសភាពធម្មតាវិញហើយៗចង់បានថ្នាំអ្វីមកខាំកំទេច ដើម្បីបិទមុខរបួសខ្លួនឯង ។ អាត្មាចង់សាកល្បងថា តើរូបអាត្មានេះជារូបមានជីវិត ឬក្លាយទៅជាខ្មោចទៅហើយ ក៏យកដៃក្តិចខ្លួនឯង ហើយក៏មានអារម្មណ៍ឈឺ ទើបបានដឹងថាខ្លួនឯងនៅរស់នៅឡើយទេ ។

វេលានោះក៏បាននឹកឃើញដល់អ្នកលក់ថ្នាំដែលមកពី " កូយ៉ាម៉ា " ដែរថាតើគេកំពុងតែមានវាសនាយ៉ាងម៉េច? បើតាមតែរបៀបដែលអាត្មាបានទទួលការពិសោធន៍រួចមកហើយនេះមិនលែងឡើយ អ្នកនោះបានក្លាយទៅជាត្រពាំងឈាម ឬក៏សាកសពដែលនៅតែស្បែកដណ្តប់ឆ្អឹងរបស់គេនៅដេកស្តូកស្តឹងក្នុងព្រៃស្មសានដ៏ងងឹត ហើយច្បាស់ជានឹងត្រូវសត្វម្រឹគទាំងឡាយជញ្ជក់ឆ្អឹងនោះ ទាំងរយទាំងពាន់ មិនលែងឡើយ ។

លុះគិតបែបនេះ ផ្លូវចោតដែលអាត្មាកំពុងដើរ ក៏ដូចជាឡើងវែង ។ នៅពេលដែលអាត្មាដើរចុះពីផ្លូវនោះ ហើយអាត្មាក៏បានឃើញស្ពានតូចមួយប្រវែងប្រហែល ២-៣ម៉ែត្រ ធ្វើពីដី នៅកន្លែងដែលមិនគួរមានស្ពានបែបនេះឡើយ ។

អាត្មាបានឮសំលេងទឹកហូរ ហើយមានអារម្មណ៍ចង់តែលោតប្រួងទម្លាក់ខ្លួនដែលត្រូវឈ្លើងទាម ដាំទីង ទៅត្រាំទឹកនោះអោយសប្បាយ ស្រណុក ...

អាត្មាបានដើរឆ្លងស្ពាននោះដោយពុំបានគិតទៅដល់គ្រោះថ្នាក់ សូម្បីតែប៉ុនចុងក្រចកក៏គ្មាន ហើយទីបំផុតក៏បានទៅដល់ទីមួយអង្អើ១យ៉ាងយ៉ាប់អស់ពីចិត្ត ។ អស់ពីនោះទៅ ក៏បានទៅដល់ទួលមួយទៀត ។ ឱព្រះអើយអាត្មាគ្មានកំលាំងដើរឡើងទេ ។ នេះបានចំជាពិបាកមហាសែនពិបាក ។

# ជំពូកទី ១០

ជាមួយនឹងរាងកាយដ៏ហត់ហេវ រសេះរសោះ បែបនេះ អាត្មាបានគិតថា មិនអាចដើរឡើងទួលនោះបានទេ។ កំពុងតែគិតបែបនេះ អាត្មាក៏បានឮសំលេងសេះកញ្ច្រៀវ ហេះ ហេះ ហេះ ហើយសំលេងនោះវាបានទៅជាសំលេងលាន់ត្រឡប់ខ្ទរពីភ្នំមកវិញ ។

អាត្មាគិតថាប្រហែលជាអ្នកជិះសេះ គេបរវាត្រឡប់ពីទីណាមួយ ឬក៏មានអ្នកជំនួញអ្វីមួយគេជិះកាត់ទីនេះ ។ ពេលព្រឹក នៅវេលាដែលអាត្មាបានជួបកសិករហើយបែកពីគាត់រហូតមកដល់ពេលនេះ ពេលវេលាទើបនឹងបានកន្លងទៅតែបន្តិចទេ ប៉ុន្តែអាត្មាមានអារម្មណ៍ហាក់ដូចជា ពេលវេលានោះវាកន្លងទៅ ៣ ឬក៏ ៥ឆ្នាំ បាត់ទៅហើយ ។

ម្យ៉ាងទៀតបើមានសេះច្បាស់ជាមានភូមិអ្នកស្រុក ពេលគិតដល់នេះអាត្មាក៏ហាក់ដូចជាមានចិត្តក្លាហាន។ អាត្មាក៏បានដើរឡើងរហូតដល់បានទៅដល់មុខផ្ទះមួយទាំងមិនបានគិតថាមានក្តីលំបាកអ្វីបន្តិចសោះ ។

ដោយហេតុថានេះជារដូវក្តៅ ផ្ទះនេះក៏បើកទ្វារចំហធ្លុង ។ ម្យ៉ាងទៀតជាផ្ទះដែលនៅដាច់ឡែកតែឯង មិនមានក្លោងទ្វារទេ ។ រំពេចនោះ មានបុរសម្នាក់បានលេចមុខមក ។

អាត្មាបានប្រញាប់ប្រញាប់ និយាយទៅរកគេ :

- ជួយអាត្មាផង សូមជួយអាត្មាផង !

អាត្មាគ្មានពាក្យអ្វីនិយាយ ក្រៅពីពោលពាក្យបែបនេះទៅរកគេទេ ។

- ឱលោកអ្នកអើយ !

ទោះបីជាអាត្មាហៅគេ ក៏គេពុំឆ្លើយតបមករកអាត្មាវិញដែរ។ មើលទៅឃើញករបស់គេទន់ល្វៀក ក្បាលរបស់គេផ្ទៀងធ្លាក់ទៅលើស្មាម្ខាង សឹងតែខ្ទប់ត្រចៀករបស់គេ ។ មើលៗទៅដូចជាកូនក្មេង ភ្នែកប៉ោងឥតន័យ សំលឹងស្លីទៅរកមនុស្សដែលឈរនៅខ្លោងទ្វារ។ វាហាក់ដូចជាខ្ចិលនឹងកំរើក ប្រស្រីភ្នែករបស់វាទៅទៀត គឺជាមនុស្សដែលហាក់ដូចជាគ្មានព្រលឹងព្រលះងនៅក្នុងខ្លួនរបស់គេ។ ដៃអាវរបស់គេខ្លីខើចមកនៅលើកួយដៃរបស់គេ ។ គេពាក់អាវ គឺម៉ូណូ ដែលអ៊ុតក្អឹង ពីលើអាវធម្មតា មានខ្សែចងនៅត្រង់ទ្រូង ចេញក្បាលពោះទ្រលុកៗរលោងរលើបដូចស្គរ ហើយមានផ្ចិតល្វៀន ដូចទងល្ពៅ ដៃម្ខាងអង្អែលផ្ចិត ដៃម្ខាងទៀតលើកឆ្វក់ធ្វើញ៉ូរៗ ដូចខ្មោចលង ។

អ្នកនោះអត់បត់ជើងអោយស្រួលបួលទេ ឬក៏ភ្លេចមិនដឹងជើងនោះបោះច្រងេងច្រងាង ហើយគេអង្គុយស្រុញដូចមនុស្សអត់ឆ្អឹង ឬក៏ដូចរាំងននខ្លីដែល.. គ្មានឈើទ្រធ្លាក់ស្បាប់បែបនោះឯង ។

អាយុមើលទៅប្រហែលជា ២២ ឬ ២៣ឆ្នាំ មាត់បើកចំហធ្លុងសឹងតែស្រូបអ្វីមួយចូលទៅក្នុងនោះ ច្រមុះទាល ថ្ងាសពយ សក់កោរជុក ហើយដុះមកវិញប្រុយៗ ឯសក់ជុកនោះវាឡើងដូចជាសិរមាន់ ធ្លាក់មកលើកញ្ចឹងកគ្របពីលើ ត្រចៀករបស់គេ ។

-អ្នកនោះថ្លង់ទេដឹង? ឬក៏មិនគ្រប់ទឹក ឬមួយក៏ជាកុមារដែលប្រុងប្រៀប នឹងប្រែខ្លួនទៅជាគីង្កក់?

អាត្មាភ្ញាក់តែគិតថា អ្នកនេះវាមិនមានពិសពុលអ្វីដល់ជីវិតរបស់ខ្ញុំទេ។ ប៉ុន្តែរូបរាងនឹងមុខមាត់របស់គេបែបនេះ ដូចជាមិនស្រួលទេ ។ ទេ ! វាច្បាស់ជានឹង មានពិសពុលយ៉ាងខ្លាំងដល់អាត្មា ។

- សុំជួយអាត្មាផង !

ដោយពុំដឹងធ្វើម៉េច អាត្មាក៏និយាយម្តងទៀត ។ តែគេហាក់ដូចជាស្តាប់អាត្មាមិនបាន ហើយគ្រាន់តែប្តូរទីតាំងរបស់កគេពីស្តាំ ហើយលើកនេះគេយកស្មាឆ្វេងរបស់គេធ្វើជាខ្នើយរបស់ក្បាលគេវិញមាត់នៅតែបើកចំហដដែល ។ បើព្លអាត្មានិយាយបែបនេះអ្នកបាទនោះលោតែភ័ព្វអាក្រក់អ្វី លោមកចាប់អាត្មាជាប់ចាប់ទាញផ្ចិតអាត្មា ហើយជំនួសការឆ្លើយតប គេបែរជាចាប់អាត្មាលិទ្ធទៅវិញ ក៏មិនដឹង ។

អាត្មាថយក្រោយក្រាកមួយជំហាន ព្រមទាំងគិតថាបើទោះជាយ៉ាងណាក៏មិនដែលមានអ្នកណាគេទុកមនុស្សមិនគ្រប់ទឹកបែបនេះ អោយនៅតែឯកោអនាថាកណ្តាលព្រៃភ្នំបែបនេះឡើយ ។ រួចអាត្មាក៏ជំទើតជើងស្រែកថា :

- ឱលោកអ្នកឯណាអើយ អោយអាត្មាសុំរកបន្តិច !

អាត្មាបានឮសំលេងសេះកញ្ច្រៀវម្តងទៀតពីក្រោយផ្ទះមក:

- អ្នកណា ហ្នឹង?

អាត្មាបានឮសួរសំលេង ស្ត្រីស្រែកសួរពីក្នុងមក ។ ឱពុទ្ធោអរហំ តើរូបរាងដែលនឹងចេញមកបង្ហាញពីមុខអាត្មា គឺច្បាស់ជាក្បាលដំសស្គុះមួយ ខ្លួនមានស្រកាហើយលូនខ្សាក១ទាញកន្ទុយបណ្តើរនៅលើក្តារក្រាល មិនលែងឡើង។

អាត្មាក៏ថយក្រោយមួយក្រាកទៀត ។

- ឱ ! ព្រះសង្ឃទេតើ?

គឺស្ត្រីដ៏ល្អចំណាប់ម្នាក់ ។ ស្ត្រីដើរចេញមក សំលេងថ្លាគ្មានកករល្អក់ហើយស្លូត ។

អាត្មាដកដង្ហើមធំតតថាអ្វីក្រៅពី :

- ពរ ។

រួចហើយ អាត្មាឱនមុខចុះ ។

នារីលុតជង្គង់ចុះលោខ្លួនមកមុខបន្តិច សំលឹងមកអាត្មាដែលឈរក្នុងថ្ងៃហៀបអស្តង្គត សឹងតែឆ្លុះពីម្ខាងទៅម្ខាង ។

- ព្រះតេជគុណមានធុរៈអ្វីទាន?

ស្ត្រីនិយាយហាក់ដូចជាគ្មានន័យ នឹងនិមន្តអាត្មាអោយចូលសំរាក ឬក៏សាកសួរអាត្មាពីរឿងសំណាក់ឡើយ ។ អាត្មាក៏ដឹងថាទីនេះ មិនមែនជាទីសំរាប់ទទួលមនុស្សអោយសំណាក់ឡើយ ។ បើអាត្មាមិនប្រមូលសេចក្តីក្លាហានទាំងឡាយ ហើយហ៊ានសាកសួរគេត្រង់ៗទេ វាអាចនាំអោយអាត្មាបរាជ័យក្នុង

ការសុំសំណាក់ទីនេះមិនលែងឡើយ ។ គិតបែបនេះហើយអាត្មាក៏ដើរទៅមុខបន្តិច ហើយបង្អោនខ្លួនគោរពគេយ៉ាងគួរសម ។

- អាត្មានេះដើរកាត់ភ្នំ ប្រុងនឹងធ្វើដំណើរទៅ " ស៊ីនស៊ូ " ។ តើពីកន្លែងនេះដល់ផ្ទះសំណាក់ តើមានចំងាយប៉ុន្មានគីឡូទៅញោម?

## ជំពូកទី ១១

- ឱព្រះសង្ឃដ៏ចំរើនអើយ នៅដល់ទៅជា ៨យោជន៍ឯណោះទាន

- តើនៅជិតៗនេះមានផ្ទះអ្នកណាគេទទួល អ្នកដំណើរអោយសំណាក់ទេ ញោម?

- ទេ ពុំមានទេព្រះតេជព្រះគុណ ។

ស្ត្រីនិយាយទាំងមិនប៉ប្រិចភ្នែក ។ គេសំលឹងមើលមកអាត្មាដោយភ្នែកដ៏ស្អាតថ្លាឆ្វង់ ។

- ឱបើទោះជាដឹងថានៅ ១០០ម៉ែត្រខាងមុខនេះមានផ្ទះសំណាក់ធំដុំមានអ្នកបំរើបក់អោយឆ្វេងស្ដាំ នៅក្នុងបន្ទប់ដ៏ល្អក្ដី ក៏អាត្មានេះពុំមានកំលាំងនឹងដើរអោយបានទៅដល់ទីនោះដែរ ។ បើញោមមានកន្លែងដាក់ ចប បង្គី ឬក៏ក្រោលគោ ក្រោលសេះ អ្វីមួយក្រវិច សំរាប់អោយអាត្មាសំរាក សូមញោមមេត្តាយកអាសាអាត្មាយកតែបុណ្យចុះញោម ។

អាត្មានិយាយដោយគិតថា សំលេងសេះកញ្ច្រៀវអំបាញ់មិញ គឺច្បាស់ជាចេញពីទីកន្លែងនេះមិនលែងឡើយ ។

ស្ត្រីបានគិតមួយសន្ទុះ ហើយបែរទៅម្ខាង ចាប់យកស្បោងក្រណាត់មួយមកកាន់រួចចាក់របស់ដែលនៅខាងក្នុងថង់នោះ ដាក់ទៅក្នុងថាំង ដែលដាក់លើភ្លៅនាង ១ដៃ ប្រៀបបានដូចជាគេចាក់ទឹក មួយរ៉ាវ រួចមកនាងយកដៃមួយទប់មាត់ថាំង ហើយដៃមួយទៀតវាចអង្ករ ។

- សូមប្រគេនព្រះតេជគុណ សំណាក់ទៅចុះ ព្រោះអង្ករសំរាប់ដាំបាយប្រគេនក៏មានល្មមមួយពេល ហើយចំពេលរដូវក្តៅផង ទោះជាផ្ទះដែលនៅក្នុងព្រៃភ្នំបែបនេះវងា ពេលយប់ក៏វាមិននាំអោយលំបាកដល់លោកភ្ញៀវណាស់ណាដែរ សូមព្រះតេជព្រះគុណនិមន្តមកទាន ។

ពេលលឺគេនិមន្តបែបនេះ អាត្មាក៏ប្រញាប់ដាក់បង្គុយចុះភ្លាមខ្លាចក្រែងស្រ្តីប្តូរគំនិតរបស់នាង ។ ស្រ្តីងើបឡើងឈរហើយនិយាយថា :

- ព្រះតេជព្រះគុណ ខ្ញុំព្រះករុណាមានសំណូមពរមួយ ។

ពេលឮស្រ្តីនិយាយច្បាស់ៗបែបនេះ អាត្មាក៏បុកពោះភីបៗ :

- ពរ ...

- ពុំមែនជារឿងធំដុំទេព្រះតេជព្រះគុណ ខ្ញុំព្រះករុណានេះមានជំងឺចំឡែកមួយ គឺចូលចិត្តស្តាប់រឿង ដែលកើតមានឡើងនៅទីក្រុង ។ ទោះជាព្រះអង្គមិនចូលចិត្តនិទានក៏ដោយ ក៏ជូនកាលខ្ញុំព្រះករុណាទទូចសុំអោយនិទានក៏មិនដឹង។ ហើយបើព្រះតេជគុណភ្លេច ខ្ញុំព្រះករុណាសុំអោយទុកវេលានោះអោយខ្ញុំព្រះករុណាសួរ សូមព្រះតេជព្រះគុណមេត្តាកុំប្រកែកណាទានណា ! ខ្ញុំព្រះករុណាសូមទូលហើយទូលទៀតទុកជាមុន ។

ស្រ្តីនិយាយប្រាប់ពីមូលហេតុនិងនិយាយតាំងពីរឿងកំប៉ិកកំប៉ុកនឹង អាត្មា។

អាត្មាបានគិតថា នេះគ្រាន់តែជាពាក្យសម្តីរបស់ស្រ្តីម្នាក់ដែលរស់នៅក្នុងផ្ទះមួយដែលនៅក្នុងភ្នំមួយដែលមិនដឹងជាមានកំពស់ប៉ុន្មាន និងជ្រលងជ្រោះ

មួយដែលគេមិនដឹងថាមានជំរៅប៉ុន្មាន ប៉ុន្តែវាមិនមែនជា កិច្ចសន្យាដែលពិបាក នឹងគោរព ក៏ងក់ក្បាលយល់ព្រម ។

- ពរ មិនថ្វីទេ អាត្មាយល់ព្រម ញោមចង់អោយអាត្មាធ្វើដូចម្តេច អាត្មាមិនជំទាស់ទេ ។

នារីក៏ភាក់ទាក់ដាក់អាត្មាមួយរំពេច ។

- ព្រះតេជព្រះគុណ ទីនេះក្រខ្វក់ណាស់ទាន សូមនិមន្តមកខាងនេះទាន ហើយសំរួលព្រះឥរិយាបថអោយស្រួល កុំបីខ្វាចចិត្តថ្លើមឡើយទាន ។ ខ្ញុំករុណាប្រគេនព្រះអង្គ ។

- ទេ ញោមមិនបាច់ទេ អោយអាត្មាសុំកន្ទបកញ្ចាស់កន្ទំមួយមក ហើយបើញោមអាចជ្រលក់ទឹក ហើយពូតវាអោយអាត្មា១ ត្រេកអរណាស់និងសូមអរគុណញោមជាមុន ។ វេលាដើរតាមផ្លូវមក មានជួបប្រទះនូវហេតុភេទជាច្រើនដ៏គួរអោយឆ្អេះឆ្អាបខ្ពើមរអើម ដូច្នេះអាត្មាចង់ជូតខ្លួនអាត្មាបន្តិច សូមញោមអភ័យទោស ។

- ឱមែន ព្រះតេជព្រះគុណ មានញើសហូរដាប ប្រហែលជាតេជគុណក្តៅខ្លាំងណាស់ សូមចាំបន្តិចណាំទានណាំ ! ខ្ញុំករុណាដឹងថាចំពោះអ្នកដំណើរផ្លូវឆ្ងាយ បើគេបានទៅដល់ផ្ទះសំណាក់ ហើយបានចូលងូតទឹកក្តៅ គឺហាក់ដូចជាបានម្ហូបអាហារដ៏ឆ្ងាញ់ជាងអ្វី១ដូច្នេះឯង ។ សូមព្រះតេជព្រះគុណអភ័យទោសអោយខ្ញុំព្រះករុណាផង ដោយគ្មានទាំងទឹកតែ ឬទឹកក្តៅប្រគេនឆាន់ក៏គ្មាន ។

ឱ ព្រះតេជព្រះគុណ បើព្រះអង្គមិនយល់ទាស់ទេ សូមនិមន្តទៅឯក្រោយផ្ទះនឹងមានស្ទឹងដ៏ស្អាតមួយនៅក្រោមចំណោតខ្ពស់នោះ ។ សូមលាងខ្លួនប្រាណទៅក្នុងស្ទឹងនោះក៏ជាការល្អម្យ៉ាងដែរ ។

ឮស្ត្រីនិយាយបែបនេះ អាត្មាក៏មានចិត្តត្រេកអរសឹងតែហោះទៅឥឡូវ ។

- ឱ ប្រសើរណាស់ញោម គ្មានអ្វីល្អជាងនេះទេ ។

- ចាំខ្ញុំករុណាណែនាំផ្លូវព្រះតេជព្រះគុណ ។ ចំនឹងពេលដែលខ្ញុំព្រះករុណាត្រូវទៅលាងអង្ករផង ។

ថាហើយស្ត្រីក៏យកកូនចានដែក ដែលនាងដាក់អង្ករអំបាញ់មិញមកកណ្ដៀត ហើយពាក់ស្បែកជើងសង្រែកចំបើង ដែលដាក់នៅលើគ្រែឫស្សី ។ បន្ទាប់មកស្ត្រីក៏ឱនទៅក្រោមគ្រែ ហើយដកយកស្បែកជើងឈើ កញ្ចាស់មួយគូចេញមក ។ ស្ត្រីយកដៃទាំងពីរសិកវាទាំងសងខាង ហើយយកមកគោះជំរុះធូលីនិងដីចេញ ហើយដាក់តម្រៀបនៅក្បែរជើងអាត្មា ។

- សូមព្រះតេជព្រះគុណពាក់ស្បែកជើងឈើនេះទៅទាន ។ ឯស្បែកជើងសង្រែកសូមទុកទីនេះចុះ ។

អាត្មាបានលើកដៃថ្លែងអំណរគុណចំពោះស្ត្រីនោះ ។

- អាត្មាសូមអភ័យទោស ដោយធ្វើអោយញោមលំបាកដោយសារអាត្មា ។ សូមអរគុណ ។

- ខ្ញុំព្រះករុណា បានប្រគេនព្រះតេជព្រះគុណសំរាកទីនេះ ក៏ដោយសារតែមាននិស្ស័យពីជាតិមុនមកដែរ ។ សូមព្រះតេជគុណកុំបីខ្លាចចិត្តអោយសោះ ។

អាត្មាបានគិតថា នេះពិតជាសំណាងដ៏ល្អមែន ។

## ជំពូកទី ១២

- សូមព្រះតេជព្រះគុណនិមន្តមកតាមខ្ញុំព្រះករុណាមក ។

ស្ត្រីកណ្តៀតចានដែកសំរាប់លាងអង្ករ រួចហើយសៀតកូនកន្សែងពោះគោ ទៅក្នុងខ្សែក្រវាត់រំពោះ អូប៊ី របស់អាវ គីម៉ូណូ នាង ហើយក្រោកឈរឡើង ។ សក់ក្បាលនាងចងក្បង់ទៅលើមួយក្របង់មានសៀតក្រាស និង តំបៀតសំរាប់លំអសក់ មើលទៅឃើញថាល្អ រកអ្វីមកប្រៀបប្រដូចក៏ពុំបាន ។

អាត្មារវៀសរវៃដោះស្បែកជើងសំរែក ហើយពាក់ស្បែកជើងឈើចាស់ ។ នៅវេលាដែលអាត្មាងើបគូថពីគ្រែប្ញស្សី ហើយអាត្មាគ្រលៀសភ្នែកទៅ ក៏ឃើញអ្នកកម្លោះមិនគ្រប់ទឹក ។ គេមើលទៅស្ត្រីដូចអាត្មាដែរ ហើយនិយាយ ដូចជាមនុស្សអណ្តាតធំពូឡុល១រកយល់ន័យមិនកើត :

- បងស្រី មកនេះ១ ។

ថាបណ្តើរ លើកដៃដូចជាល្វើយបណ្តើរ ហើយអង្អែលក្បាលសើងមម៉ើងរបស់គេ ។

- ព្រះសង្ឃឬ? ព្រះសង្ឃឬ?

ឮដូច្នេះស្ត្រីក៏ងក់ក្បាលញញឹមដោយបញ្ចេញស្នាមខូចនៅលើថ្ពាល់ពេញរបស់នាង ហើយឆ្លើយទៅវិញបីដងដោយឆាប់រហ័ស :

- ចា៎ ! ចា៎ ! ចា៎ !

អ្នកកម្លោះថា បាទ រួចហើយក៏បើកមាត់ធ្លាក់អណ្តាតខ្លែមក ហើយយក ដៃឆ្កិះឆ្កៀលផ្ចិតរបស់គេទៀត ។

ដោយអាណិតពេកអាត្មាក៏មិនហ៊ានងើយមុខមើលចំ ហើយលួចចោល ភ្នែកមួយភ្លែត១ទៅ ក៏ឃើញស្ត្រីហាក់ដូចជាពុំមានកង្វល់អ្វីធំដុំប៉ុន្មាន ក៏ថយទៅ ក្រោយប្រុងនឹងចេញទៅ ។ វេលានោះ ស្រាប់តែមានតាចាស់ម្នាក់ ប្រហែលជា ចេញពីក្រោយផ្ទះមក ចេញតាមគុម្ពផ្កាកញ្ចុំ១មក គាត់ពាក់ស្បែកជើងសង្រែក ចំបើង មានកាន់កូនប្រអប់តូចមួយសំរាប់ដាក់បារី ឬថ្នាំបន្តិចបន្តួចដែលមានចង រូបតុក្កតាលំអ បៀមខ្សៀហើយមកឈរក្បែរស្ត្រី ។

- ព្រះតេជព្រះគុណ សូមនិមន្តទាន !

រួចស្ត្រីក៏និយាយទៅរកតាចាស់ :

- ពូមានការណ៍អ្វី?

- និយាយអញ្ចឹង អ្នកម្ចាស់ស្រីដែលហៅថាមនុស្សឆ្កួត មនុស្សឡប់គឺ អាហ្នឹងទេតើ? បើធម្មជាតិ អាល្បងនោះ ជាមនុស្សខូចដូចកញ្ច្រោង យើងពុំអាច បញ្ចោរវាអោយវាដោរតាមយើងបានទេ ។ ត្រង់នេះទុកងារអោយខ្ញុំបាទចុះ ។ ចាំខ្ញុំបាទបញ្ចុះបញ្ចូលវា ។ ហើយតែប៉ុននេះ អ្នកស្រីម្ចាស់មិនបាច់ព្រួយរឿងខ្វះ ទេក្នុងរយៈពេល ២-៣ខែ ។ ស្អែកគេនឹងដឹកឥវ៉ាន់មកជូនហើយ ។

- សូម ពូជួយគិតផងឥចឹង ។

- បាទ មិនអីទេ ។ ចុះអ្នកម្ចាស់ស្រី គិតអញ្ជើញទៅណាហ្នឹង?

- ខ្ញុំទៅស្ទឹងខាងក្រោយបន្តិច ។

- យីទៅជាមួយព្រះសង្ឃក្មេងឥចឹង តិចលោតែបេះដូងលោតជ្រុលពេក ដួលធ្លាក់ទឹកណាំ ។ ខ្ញុំចាំនៅឯនេះណាំ អ្នកស្រីម្ចាស់ ។

- ព្រះតេជគុណមើលហ្ន៎ គាត់ចូលចិត្តតែចំអន់គេអញ្ចឹងតែម្តង ។

ស្ត្រីមើលមកអាត្មាហើយសើច ។

- អាត្មាទៅតែឯងបានហើយ ។

អាត្មាបានដើរថយក្រោយ ឃើញដូច្នេះតាចាស់ក៏សើចកក្អៀក :

- ហាស១ និមន្តទៅអោយឆាប់ទៅទាន !

- ពូ ថ្ងៃនេះយើងមានភ្ញៀវចំឡែកពីរនាក់បាត់ហើយ ។ ថ្ងៃអញ្ចឹង១ វាច្រើនតែមានទៀត ។ អោយអ្នកជីវ៉ូ ទទួលទៅដឹករូចទេ ដូច្នេះសូមពូជួយនៅសំរាកលេងលេងបន្តិចសិនទៅ ។

- ចុះមានអី អ្នកស្រីម្ចាស់ថាហើយគាត់ក៏ដើរទៅក្បែរអ្នកកម្លោះមិនគ្រប់ទឹក ក្តាប់ដៃគក់ខ្នងគេឮតែបឿក កម្លោះមិនគ្រប់ទឹកកំរើកក្បាលពោះពេបមាត់រួចសើចស្ងាញ ។

អាត្មាព្រឺរោម បែរមុខចេញ ប៉ុន្តែស្ត្រីធ្វើវាហីធម្មតា ។

តាចាស់បើកមាត់ធំ១:

- ពេលអ្នកស្រីម្ចាស់មិននៅ ខ្ញុំសុំលួចលោកប្តីអ្នកស្រីម្ចាស់ហើយណាំ!

- ឱ បើពូ អាចធ្វើបាន ជាការប្រសើរផុតលេខហើយ តស់និមន្តព្រះតេជព្រះគុណ ។

អាត្មាដូចជាមានអារម្មណ៍ថា តាចាស់លបមើលអាត្មាពីក្រោយ តែអាត្មាបានធ្វើតាមការណែនាំរបស់ស្ត្រី ដើរសូរតាមជញ្ជាំងសំដៅទៅរកទីដែលផ្ទុយពីទីដែលមានផ្កាកញ្ចុំ ។

លុះដើរទៅដល់ក្រោយផ្ទះ ក៏បានឃើញក្រោលសេះនៅខាងឆ្វេងដៃ ។ អាត្មាឮសូរសម្លេងកុប១ ប្រហែលជាសេះធាក់ជញ្ជាំងក្ដារហើយមើលទៅ។ វេលានោះស្បែអន្ទការបានលាតសន្ធឹងលើពិភពនេះហើយ ។

- ព្រះតេជព្រះគុណ យើងចុះពីកន្លែងនេះទៅ។ រអិលណាស់សូមព្រះតេជព្រះគុណ ប្រយ័ត្នណាំទានណាំ !

## ជំពូកទី ១៣

អាត្មាបានគិតថា គេត្រូវចុះពីទីនោះហើយ ។ នៅទីនោះមានដើមស្រល់ដ៏រាវស្តួចមួយខ្ពស់ឥតឧបមា ប្រហែលជា ១៥-១៦ម៉ែត្រ ហើយគ្មានមែកទេ។ អាត្មាបានត្រសុលពីក្រោយដើមស្រល់នោះ។ វេលាងើយ មើលទៅលើចុងស្រល់ក៏ឃើញព្រះច័ន្ទពណ៌ស រាងរបស់លោកមិនចំឡែកខុសពីព្រះច័ន្ទធម្មតាទេ គឺព្រះច័ន្ទ ១៣កើត ។ តើឯណាទៅពិភពពិតនោះ?

ស្ត្រីដែលចេញទៅមុនអាត្មា ក៏បាត់ស្រមោល ពុំដឹងទៅឯណាអាត្មាបានឱបដើមស្រល់រកមើលនាងក៏បានឃើញថា ស្ត្រីនោះនៅខាងក្រោម ។ គេមើលមកលើហើយនិយាយថា :

- សូមព្រះតេជព្រះគុណប្រយ័ត្នទាន ពីព្រោះជំរាលនេះចុះទាប។ ស្បែកជើងឈើប្រហែលជានាំអោយព្រះតេជគុណពិបាកចុះហើយ ប្តូរពាក់ស្បែកជើងសង្រែកវិញឬទាន?

ប្រហែលជាស្ត្រីនោះឃើញអាត្មាដើរយឺត ក៏គិតស្មានថាអាត្មាពិបាកដើរអាត្មាឯនេះប្រញាប់ដើរអោយទៅដល់ នឹងអាលបានលាងខ្លួនជំរុះក្អែលសត្វឈ្លើងទោះជាដួលធ្លាក់ចុះទៅទៀតក៏មិនគិតដែរ ។

- ទេ អ្នកស្រីម្ចាស់ បើអាត្មាពិបាកដើរ អាត្មានឹងដោះវា ដើរជើងទទេហើយសូមនាងកុំបារម្ភ ។ អាត្មាសូមអភ័យទោសដោយធ្វើអោយអ្នកនាងម្ចាស់រំខានដោយសារអាត្មា ។

- ឱ ! អ្នកនាងម្ចាស់ !

ស្ត្រីហាក់ដូចជាត្រេកអរនិយាយឮៗ ហើយសើចប្រកបដោយសំរស់គួរអោយជាប់ចិត្ត ។

- ពរ អាត្មាបានឮគាត់ហៅនាងថា អ្នកស្រីម្ចាស់ តើនាងមានស្វាមីហើយឬ?

- ឱ ចាំបាច់នឹងអ្វីព្រះតេជព្រះគុណ គ្រាន់តែដឹងថាខ្ញុំព្រះករុណានេះមានចំណាស់អាចធ្វើម្ដាយមីងព្រះអង្គបានហើយទាន ។ មកនិមន្តមក ពាក់ស្បែកជើងសង្រែកក៏បានដែរ ប៉ុន្តែក្រែងលោតែមុតបន្លាអីទៅនាំអោយពិបាក ហើយម្យ៉ាងទៀតស្បែកជើងសង្រែកនេះទទឹកជោគផង ពាក់ទៅក៏មិនស្រួលព្រះទ័យដែរ ។

ស្ត្រីនិយាយដោយមិនបែរមករកអាត្មាទេ នាងលើកជាយសំពត់ដើរ នាំអោយឃើញកែងជើងដ៏ស ប្រៀបបាននឹងគុជដែលចាំងឆ្លុះយ៉ាងច្បាស់ក្នុងអន្ធការ ហើយរលុបបាត់ទៅវិញ ប្រៀបបានដូចជា ទឹកកកដែលរលាយ ។

យើងដើរចុះជំរាលត្រុកៗៗទៅមុខ ។ វេលានោះមានគីង្គក់មួយ លោតផ្លោតចេញពីគុម្ពោតស្មៅដែលនៅជិតនោះ ។

- យី ខ្ពើមណាស់ ស្ត្រីថាហើយក៏លោតឡើងយ៉ាងខ្ពស់ ហើយលោតទៅម្ខាងឯនោះ ។

- ឯងមិនឃើញថាមានភ្ញៀវទេឬ? មកឱបជើងមនុស្ស យីសត្វនេះកោតតែទៅរួច ! ពួកឯងនេះជញ្ជក់តែសត្វល្អិតទៅវាគ្រប់គ្រាន់ហួសពីលើសទៅទៀត ។

ព្រះតេជព្រះគុណ សូមព្រះអង្គនិមន្ត ឥតមានគ្រោះថ្នាក់អ្វីទេទាន ។ ទីព្រៃភ្នំបែបនេះ សូម្បីតែពួកសត្វបែបនេះក៏វាសាំងនឹងមនុស្សដែរ ។

យីពួកអស់នេះ ធ្វើមើលតែគ្នាពួកម៉ាកឯង គ្នាខ្មាសគេណាស់វើយ ។

ពេលឮស្ត្រីថាបែបនេះ គីង្គក់ក៏លោតចូលទៅក្នុងគុម្ពោតស្មៅវិញ ។ ស្ត្រីក៏ឡើងយ៉ាងរហ័សទៅលើ :

- ព្រះតេជគុណ សូមឡើងមកទាន ទៅនោះដីវាទន់ ហើយពុក ពុំអាចដើរពីលើបានទេ ។

គេឃើញមានដើមឈើធំមួយដេកដួល មានស្មៅដុះពីលើដើម ហើយនៅពេលដែលយើងដើរលើវា ដោយស្បែកជើងឈើ ហាក់ដូចជាពុំមានការពិបាកអ្វីទេ ហើយអាត្មាបានដើរផុតដើមឈើមួយដើមនោះទៅ ក៏ឮសូរសំលេងទឹកហូរខ្លាំង ។ ងើយមើលទៅលើទៅអាត្មាក៏ឈប់ឃើញស្រមោលនៃដើមស្រល់ទៀតហើយ ។ ហើយព្រះច័ន្ទ ១៣កើត បានចុះទៅទាប ប្រហែលទៅដល់ពាក់កណ្តាលភ្នំដែលអាត្មាចុះមកសឹងតែថាអាចលោដៃឈោងចាប់បាន ប៉ុន្តែគេពុំអាចស្មានថាកំពស់ប៉ុន្មានទេ ។

- ព្រះតេជព្រះគុណ សូមនិមន្តមកខាងនេះទាន ។

ស្ត្រីបានចាំអាត្មានៅខាងក្រោម ។

ទីនោះគឺជាផ្ទាំងថ្មមួយផ្ទាំង មានទឹកស្ទឹងហូរពីលើ ហើយបង្កើតជាអាងមួយទទឹងមានប្រហែលបីម៉ែត្រ មើលពីលើទឹកទៅមិនសូវជាថ្លាស្អាតណាស់ណាទេ ប៉ុន្តែស្អាតដូចជាត្បូងកែវ ហូរទៅគេឮសូរសំលេងដែលបោកលើសិលាឯឆ្ងាយនោះគ្រាំៗទៅវិញ ។

នៅឯត្រើយម្ខាង កំពូលភ្នំឡើងងងឹតស្អិប ប៉ុន្តែនៅជើងជួរភ្នំដ៏ច្រើន គេឃើញមានដុំថ្មតូចធំ ក្រួស ឬថ្មដែលលេចចេញមកដូចជាគេចិតជា ៦ជ្រុង មានខ្លះស្រួចដូចជាកាំបិតបន្ទោះ ខ្លះរាងមូលដូចបាល់ ឆ្លុះបញ្ចាំងដោយពន្លឺព្រះច័ន្ទដែលរះលើចង្កេះភ្នំ ។ វិសាលភាពដែលភ្នែកយើងអាចចោលទៅដល់ឃើញដុំថ្មទាំងនេះព្រមទាំងផ្ទាំងថ្មដេកត្រាំនៅក្នុងទឹក តលើគ្នាប្រៀបបានជាកូនភ្នំ ។

## ជំពូកទី ១៤

- សំណាងល្អណាស់ ថ្ងៃនេះទឹកច្រើន ទោះជាមិនចូលទៅក្នុងស្ទឹងក៏អាចលុបលាងខ្លួនពីទីនេះបាន

ស្ត្រីបង្កោងប្រអប់ជើងរបស់នាងដាក់នៅក្នុងទឹក។ជើងរបស់នាង ប្រៀបដូចជាព្រីល ឈរនៅលើផ្ទៃថ្មរាបធេង ។

ខាងដែលយើងទាំងពីរឈរ ផ្ទប់ទឹកពីជើងភ្នំខាងនេះបង្កើតជារាងក្រឡូមដូចជាល្អមតែសំរាប់អោយគេដាំត្បូងថ្មទាំងនោះបញ្ចូលមកលំអ ។ គេពុំអាចរកមើលប្រភពទឹក ឬក៏ចុងទឹកឃើញទេ ប៉ុន្តែនៅឯភ្នំថ្មខាងនោះ ទឹកហូរបត់បែនទទឹង ៥ហត្ថ ៣ហត្ថ ៣ម៉ែត្រ ម្តង ហើយប្រភពទឹកហាក់ដូចជាកាន់តែខិតឆ្ងាយទៅៗ។ គេឃើញផ្ទាំងថ្មមួយដុំបត្រង់នេះ មួយដុំបត្រង់នោះ ទាំងអស់សុទ្ធតែបានទទួលពន្លឺព្រះច័ន្ទគ្របពីលើហាក់ដូចគេពាក់ក្រោះពណ៌ប្រាក់ ។ ទីដែលនៅជិតយើងជាងគេ មើលទៅហាក់ជាមានមនុស្សកំពុងតែរកវាត់ខ្សែសន្ទូចដែលប្រែពណ៌ទៅជាឡើងសស្វាច ។

- ទេសភាពនេះល្អណាស់តើ !

- ករុណា ទឹកនេះមានប្រភពចេញមកពីជ្រោះ។ អ្នកដែលបានធ្វើដំណើរមកភ្នំនេះ សុទ្ធតែបានឮសូរសម្លេងដូចខ្យល់ព្យុះ ចេញពីកន្លែងណាមួយមក ។ កាលពីព្រះតេជព្រះគុណនិមន្តមកទីនេះ តើព្រះអង្គមានចាប់អារម្មណ៍ថាបានឮសម្លេងនោះទេទាន?

នោះហើយ គឺនៅពេលដែលអាត្មាហៀបនឹងឈានជើងចូលទៅព្រៃឈើង បន្តិចមុននោះ អាត្មាបានឮសម្លេងនោះ ។

- តើនោះមិនមែនជាសម្លេងដែលខ្យល់បក់ទៅប៉ះនឹងព្រៃទេឬ ញោម?

- ទេ ព្រះតេជព្រះគុណ ។ នរណាក៏ដឹងដែរនៅចំងាយប្រហែល ៣យោជន៍ ពីព្រៃនោះបត់ចូលទៅក្នុងបន្តិចមានទឹកជ្រោះដ៏ធំមួយ ។ ទឹកជ្រោះនោះ ធំជាង គេមួយប្រទេសជប៉ុនយើងនេះ ។ ដោយសារផ្លូវចោតខ្លាំងក្នុងមនុស្ស ១០នាក់ គ្មានមនុស្សណាម្នាក់ទៅទេទាន ។ ទឹកជ្រោះនោះបានកញ្ជ្រោលបក់បោកទៅជា ទឹកជំនន់ធំ គិតពីឥឡូវនេះទៅ ១៣ឆ្នាំហើយទាន គឺជាទឹកជំនន់ដ៏សាហាវឡើង សូម្បីតែកន្លែងដែលយើងកំពុងឈរនេះក៏បានក្លាយទៅជាបាតស្ទឹងដែរ ភូមិដ្ឋាន ដែលនៅជើងភ្នំក្តី ផ្ទះនានាដែលនៅលើភ្នំក្តីទាំអស់បានត្រូវទឹកលិចអស់រលីង ។ ឯឧម្មង្គដែលនៅឯលើនេះ មុនដំបូងមានផ្ទះតែ ២០ទេ ហើយស្ទឹងនេះបានកើត ឡើងពីវេលានោះមក ។ មើលមើល៏តេជគុណ ដុំថ្មហូរមកជាមួយនឹងទឹក ។

ស្ត្រីបានលាងអង្ករ ហើយពុំដឹងពីអង្កាលទេកអាវ គីម៉ូណូ របស់នាងឡើង បាត់សណ្តាប់ធ្នាប់មើលឃើញទ្រូងនាង ដែលមូលក្លំ ។ ស្ត្រីពើងដើមទ្រូងឈរ គេឃើញច្រមុះដ៏ស្រួចរបស់នាង ។ មាត់បិទ ភ្នែកដូចជារវើរវាយមើលទៅកំពូល ភ្នំ ។ ឯព្រះច័ន្ទដែលរះនៅពាក់កណ្តាលភ្នំបានចាំងពន្លឺទៅលើដុំសិលា ដ៏ច្រើនឥត គណនា ។

- ឥឡូវគ្រាន់តែនឹកឃើញក៏ខ្លាចដែរ ។

អាត្មានិយាយហើយឱនខ្លួនលាងជើមដៃទាំងពីរ ។

- ហ្ន៎ ព្រះតេជព្រះគុណ ម៉េចព្រះអង្គមិនដោះស្បង់ចេញទាន ទទឹកអស់ហើយ តិចប្រឈូនទៅ ដោះស្បង់ចីពរង្វូតទៅស្រួលទាន ។ ខ្ញុំព្រះករុណាជួយលាង ។

- ទេ ញោម !

- កុំមានសង្ឃដីកាអញ្ចឹង មើលហ្ន៎ទទឹកដៃអាវអស់ហើយទាន ថាហើយ ស្ត្រីក៏លោដៃមកដោះខ្សែក្រវាត់ អូបីនៃចីពរ គឺម៉ូណូអាត្មា យ៉ាងរូសរាន់ពីក្រោយមក ។ អាត្មារួញខ្លួនខ្មៀន ។ តែនារីនោះគ្មានរវល់ទេ គេគិតតែពីទាញស្បង់អាត្មាចេញអស់រលីង។ អាត្មាធ្លាប់តែត្រូវគ្រូឧប្បឈាប្រដៅយ៉ាងប្រិតប្រៀន គឺជាសង្ឃមិនដែលបង្ហាញសាច់ស្មាអោយនរណាឃើញម្តងផងស្រាប់តែត្រូវនារី ចាប់សំរាតអោយនៅខ្លួនទទេដូចខ្យងដែលត្រូវគេដកសំបកចេញអស់ អាត្មាឡើងគាំងសំដី ដៃជើងរឹងស្ពឹក ។ អាត្មាឱនខ្លួនឱបជង្គង់ក្រវៀនវៀន ឯនារីក្រវាត់ គឺម៉ូណូ អាត្មាទៅលើមែកឈើដែលនៅក្បែរនោះ ។

- ស្បង់ចីពរទុកលើនេះហើយ មើលព្រះតេជគុណ នៅអោយស្ងៀមមើលទាន ឯណាខ្លងព្រះអង្គ? ខ្ញុំ... ព្រះករុណាសងព្រះគុណវិញដោយទ្រង់ហៅខ្ញុំព្រះករុណាថា "អ្នកនាងម្ចាស់ " ។ អ្នកនាងដែលចាស់ហើយនេះ សូមបំរើព្រះតេជគុណបន្តិចចុះ ឱ ខ្ញុចណាស់ ។

ស្ត្រីថាហើយក៏ខាំជាយដៃអាវម្ខាងរបស់នាងឡើង ដាក់ដៃទាំងពីរដែលសជូចគុជលើខ្នងអាត្មា ហើយសំលឹងមើលមិនដាក់ភ្នែក ។

- ឱ!
- យ៉ាងម៉េចនាង?
- ឡើងជាំពេញខ្លួនព្រះតេជព្រះគុណ !
- ប្រាកដហើយ ព្រោះអាត្មាបានជួបប្រទះនឹងគ្រោះលំបាកណាស់។

គ្រាន់តែនឹកឃើញឡើងវិញក៏ព្រឺឆ្អឹងខ្នងដែរ ។

## ជំពូកទី ១៥

នារីធ្វើមុខដូចជាភ្ញាក់ :

- នៅក្នុងព្រៃ យ៉ាប់យ៉ឺនមែនព្រះតេជព្រះគុណ ។ ចំពោះអ្នកដំណើរនៅតាមភ្នំ " ហ៊ីដា " មានតែកន្លែងនោះទេ ដែលមានឈ្លើងជ្រុះមក ។ នេះមកពីព្រះតេជគុណមិនស្គាល់ផ្លូវវាងទាន ហើយព្រះអង្គនិមន្តទៅប៉ះចំសំបុករបស់វា។ ជីវិតព្រះអង្គថ្លៃណាស់ តាមពិតវាទាមតោ ក្របី សេះ ស្លាប់ឯណោះ ។ តើព្រះតេជគុណរមាស់ដល់ទៅចង់អេះទេទាន?

- ឥឡូវអត់រមាស់ទេ តែអាត្មាឈឺ ។

- បើឥចឹងព្រះអង្គមិនត្រូវយករបស់បែប១នេះដុសវាទេ របកស្បែកអស់ហើយព្រះតេជព្រះគុណ ។

នារីនោះថាហើយក៏លូកដៃដែលដូចជាផ្កាកប្បាសមកពាល់អាត្មា រួចមកនាងនោះបានចាក់ទឹកពីលើស្មាទាំងពីររបស់អាត្មា លើខ្នង លើចង្កេះ ព្រមទាំងដុសថ្នម១ ។ ទឹកនោះអាត្មាគិតថាវាច្បាស់ជាត្រជាក់ដល់ឆ្អឹងហើយ តែផ្ទុយទៅវិញវាមិនអញ្ជឹងទេ ។ គឺជាពេលក្តៅ អាត្មាមិនយកលេសមកនិយាយទេ ឬមួយក៏ឈាមអាត្មាវាពុះកញ្ជ្រោល ឬមួយសាច់របស់នារីនោះមានកំដៅ? ទឹកដែលគេយកមកលុបលាងខ្លួនអោយអាត្មាឡើងក្តៅឧណ្ហ១ ស្រួលជ្រាបចូលមកក្នុងសាច់អាត្មា ទឹកដែលមានគុណភាពល្អណាស់ ។ និយាយពីចិត្តដែលស្រួលនាំអោយភ្នែកឡើងរលីវមីរ១ចង់ងងុយ ហើយមុខរបួសដែលឈឺឆៀប១ ក៏របេះ

បាត់ អាត្មាសឹងតែបាត់បង់ស្មារតី រាងកាយនារីដែលស្អិតជាប់មកនឹងខ្លួនអាត្មា ធ្វើអោយអាត្មាមានអារម្មណ៍ថា ខ្លួនឯងកំពុងតែរួមក្រសោបដោយគ្របកផ្កា ។

ដៃដែលស្រាលថ្មមៗនេះ វាមិនសមជាដៃរបស់មនុស្សដែលនៅក្នុងស្រុកជនបទ ហើយទោះជាអ្នកដែលនៅទីក្រុង ក៏កំរនឹងមានដៃបែបនេះដែរ ។ នៅពេលដែលគេដុសខ្លួនប្រាណអោយអាត្មា អាត្មាបានដកដង្ហើមដោយលួចលាក់នៅក្នុងជំរៅដើមទ្រូង ។ អាត្មាប្រុងនឹងបដិសេធ ប៉ុន្តែទោះបីដឹងថា ខ្លួនត្រូវតែបដិសេធក្តី ក៏សេចក្តីត្រេកត្រអាលរវើរវាយ វាបានបណ្តោយអោយគេលុបលាងខ្លួនប្រាណរហូតទៅ ។

មិនដឹងជាក្លិនអ្វី ក្លិនដែលភាយពីភ្នំ ឬក៏ក្លិនដែលភាយពីរាងកាយរបស់ស្ត្រីក៏មិនដឹង មានក្លិនដ៏ក្រអូបប្រហើរៗភាយចេញមក អាត្មាបានគិតថា វាភាយពីដង្ហើមដែលនៅក្រោយអាត្មា ។

ព្រះសង្ឃបង្អង់មួយសន្ទុះ :

- អ្នកឯងនៅជិតនាង ចូរឯងមូលភ្លើងអោយភ្លឺបន្តិចមើល ងងឹតឥចឹងមិនស្រួលទេ ចាប់ពីកន្លែងនេះទៅ គឺកន្លែងគួរអោយខ្មាសអៀនណាំ រូបព្រះសង្ឃឡើងងងឹត ហើយភ្លើងក៏ឡើងខ្សោយដែរ ។ នៅវេលាដែលខ្ញុំបើកភ្លើងអោយខ្លាំងព្រះសង្ឃញញឹមហើយនិយាយរឿងបន្តទៅទៀត ។

- ឱ មិនយូរប៉ុន្មាននឹងទៅជាការពិត អាត្មាកំពុងតែត្រូវបានក្តោបក្រសោបយ៉ាងទន់ភ្លន់ដោយផ្កាមួយទងដែលមានក្លិនក្រអូប ហើយកក់ក្តៅ ។

ជើង ត្រចៀក ដៃ ស្មា កញ្ចឹងក រួចបន្ទាប់មកក្បាល រាងកាយទាំងមូល ... អាត្មាភ្ញាក់រកអុកគួចទៅលើថ្មហើយៗ ជើងអាត្មាបានត្រវែងទៅក្នុងទឹករកកល និងលិចតែស្ត្រីបានយកដៃទប់ទ្រូងអាត្មាពីក្រោយ នាំអោយអាត្មាអាចឈរនឹងបាន ។

# ជំពូកទី ១៦

ឱ ស្ត្រីនេះវេលាដែលនាងស្លៀកពាក់ខោអាវ ខុសពីវេលាដែលនាងនៅខ្លួនទទេ ។

នាងមានសាច់សទ្រលុកទ្រលន់ល្អណាស់ ។

- អំបាញ់មិញ ខ្ញុំព្រះករុណាបានចូលទៅក្រោលសេះ ដើម្បីថែទាំវាដូច្នេះក្លិនសេះ បាននៅជាប់ឆ្អេះឆ្អាបនឹងខ្លួនរបស់ខ្ញុំព្រះករុណាគួរអោយរអើម ។ បានជាមកហើយ ខ្ញុំព្រះករុណាក៏លុបលាងខ្លួនដែរបណ្តោយទៅ ។

នាងនិយាយនឹងអាត្មា ប្រៀបបានដូចជាគេនិយាយគ្នាលេងជាមួយបងប្អូន ។ នាងលើកដៃទប់សក់ខ្មៅ ហើយលុបលាងក្បៀកដោយកូនកន្សែង រួចក៏ពូតកូនកន្សែងនោះដោយដៃទាំងពីរ ហើយឈរ ។ ស្រមោលនិងរូបរាងនោះដូចជាព្រីលដែលគេសំអាតដោយទឹកមន្ត ហើយញើសពណ៌ផ្កាឈូក បានចេញពីរូបរាងកាយនោះ ហើយហូរចុះទៅ ។

- ឱ ស្ត្រីដែលរលាមដូចសេះកុបបែបនេះ បើធ្លាក់ទៅក្នុងស្ទឹងហើយហូរទៅភូមិ តើអ្នកភូមិគេថាម៉េចទៅហ្ន៎?

- គេច្បាស់ជាគិតថា ជាផ្កាម៉ូម៉ូស មិនលែងឡើយ ។

អាត្មាបានដឹងថានៅពេលដែលអាត្មានិយាយបែបនេះ ដោយមិនបានគិតច្រើនផង ភ្នែករបស់យើងក៏ប៉ះគ្នា ។

វេលានោះ អាត្មាឃើញថាស្ត្រីអរហើយញញឹមតូច ដូចជានារីក្រមុំព្រហ្មចារីយ៍ ឱនមុខចុះក្រោម ។

អាត្មាបានគេចមុខចេញ ប៉ុន្តែបានឃើញស្រមោលស្ត្រីដែលទទួលរស្មីនៃព្រះច័ន្ទ ចាំងទៅលើថ្មដែលនៅខាងឆ្នេរម្ខាង ដូចជារុំព័ទ្ធទៅដោយផ្សែងថើៗពណ៌ខ្មៅ និង ខៀវបន្តិចៗឡើងថ្លាឆ្វង់ ។ រំពេចនោះស្រាប់តែឃើញមានសត្វអ្វីចេញពីរន្ធមូលនៅនឹងដី ដែលមើលឃើញមិនច្បាស់នៅវេលាយប់ ហើរផែលផាលៗមករកទិសដែលអាត្មានៅ ។ អាត្មាបានគិតថា ប្រហែលជាសត្វស្លាបហើយ ។ នោះគឺជាជ្រឹងដ៏ធំមួយ។ វាហើរមកកាត់មុខអាត្មាហាក់ដូចជាចង់បាំងភ្នែកអាត្មាកុំអោយមើលទៅស្ត្រី។

- យីចុះវាយ៉ាងម៉េចហ្នឹង? ឯងមិនឃើញភ្ញៀវទេឬ?

ស្ត្រីស្រែកដោយបង្អោងខ្លួន ដើម្បីបិទបាំងរូបននលគករបស់នាង ដោយភ្ញាក់ ។

- ហ្អា៎ យ៉ាងម៉េចអ្នកស្រី?

ដោយអាត្មាបានស្ញៀកពាក់ស្រួលបួលហើយ អាត្មាក៏អាចសួរទៅនាងដោយគ្មានញញើតញញើម ។

- ទេ ព្រះតេជគុណ ។

នាងឆ្លើយ តែឆ្លើយ ប៉ុន្តែមើលទៅហាក់ដូចជាអៀនខ្មាស ហើយបែរទៅក្រោយ ។

វេលានោះមានអ្វីមួយ ដូចជាកូនក្មេងដែលកោរក្បាលត្រងិល១ មាឌប៉ុនកូនភ្លៃ ពណ៌ប្រផេះ ដើរតេះតះ តេះតះ មកដល់លើចំណោតក៏ហក់កាត់លំហអាកាសមកឱបពីក្រោយស្ត្រី ។

សត្វនោះ ឱបនាងពីក្រោមចង្កេះមកនាំអោយលែងឃើញដងខ្លួននាងខាងក្រោម ដែលនៅទទេ ។

- អាស់គិះ មិនឃើញក្បៀវទេឬ?

ស្ត្រីបានស្រែកដោយកំហឹង ។

- ពួកអាឯងឡើងចាងណាស់ទេតើ? នាងស្តីអោយវាខ្លាំង១ រួចហើយនាងក៏យកកែងដៃខោកក្បាលសត្វនោះដែលរកឱនមើលក្បៀកនាង ។

សត្វស្រែកដោយសម្លេងចំឡែកឮ ចាច ចាច ហើយហក់ទៅក្រោយ ។ បន្ទាប់មកវាក៏ហក់កាត់លំហអាកាសម្តងទៀត ហើយលោតទៅតោងមែកឈើដែលស្ត្រីបានផ្ទុកស្បង់ចីពរអាត្មាអំបាញ់មិញ ដោយដៃដ៏វែងរបស់វា រួចក៏បង្វិលខ្លួនមួយជុំយោលទោង ហើយឡើងដើមឈើប្រូចទៅ ។ អាត្មាក៏បានដឹងថាសត្វនោះគឺសត្វស្វា ។

វាសរសៀរពីមែកមួយទៅមែកមួយ រួចមើលទៅចុងឈើហើយក៏ដាំដួងយោលទោង ។

ព្រះច័ន្ទបានចាកចេញពីកៀនភ្នំ គេឃើញស្រមោលរបស់ព្រះច័ន្ទលេចចេញតាមប្រឡោះស្លឹកដែលនៅចុងឈើ ។

ស្ត្រីហាក់ដូចជា ពុំសប្បាយចិត្តដោយសារការឡកលេងសើចអំបាញ់មិញនេះ ទេ។ នៅត្រង់ការលេងសើចរបស់គីង្គក់ ជ្រឹង និង ស្វាទាំងបីដឹងនេះ ។

ការលេងសើចទាំងឡាយនេះ វាធ្វើអោយនាងមានអារម្មណ៍មិនល្អ ហាក់ដូចជាម្តាយក្មេងដែលតែងតែខឹងនឹងកូនដែលស្រែកខ្សៀវខ្សាវបែបនោះឯង ។ ស្ត្រីខឹងមែន។ ។ រួចហើយនាងក៏ស្លៀកពាក់ទាំងល្ងើយ ។ ឯអាត្មាក៏មិនសួរនាំអ្វីនាងដែរ អាត្មានៅឈរក្រវៀន។យ៉ាងស្ងៀមស្ងាត់ ។

## ជំពូកទី ១៧

នៅក្នុងសេចក្តីស្លូតបូត ទន់ភ្លន់ របស់នាង អាត្មាបានឃើញភាពក្លាហានប្រកបដោយថាមពលរបស់នាង ព្រមទាំងភាពហ្មត់ចត់តឹងរ៉ឹងនៅក្នុងភាពស្រាល "ធូរ" របស់នាង ។ គេមើលឃើញភាពថ្លៃថ្នូរបស់នាង ដែលមិនអាចនិយាយលេងលូកលាន់នាងដោយស្រួល។បានទេ ហើយយើងមិនបាច់ចាំភ្ញាក់ទេ នៅវេលាដែល "ព្រឹត្តិការណ៍" អ្វីមួយប្រុងនឹងកើតឡើង ។ ហើយបើយើងធ្វើអោយនារីដ៏ស្រស់នេះខឹង នាងច្បាស់ជាធ្វើអោយយើងសមមុខ មិនខុសអ្វីពីស្វាដែលរបូតដៃធ្លាក់ពីលើដើមឈើឡើយ ។ អាត្មាភ្ញាក់ហើយនៅស្ងៀមចង់ភ័យ ។ ប៉ុន្តែអ្វី។ពុំមានប្រែប្រួលទៅរកសភាពការណ៍អាក្រក់ទេ ។

- ព្រះតេជព្រះគុណប្រហែលជាលបសើច នឹងខ្ញុំព្រះករុណាហើយ ។

ស្ត្រីហាក់ដូចជានឹកឃើញពីទង្វើដែលនាងបានធ្វើ រួចហើយសើចយ៉ាងស្រួល ។

- មិនដឹងធ្វើម៉េចទេ ទាន ។

នាងនិយាយហាក់ដូចជាពុំមានកែប្រែ សេចក្តីរាក់ទាក់របស់នាងចំពោះអាត្មាបន្តិចឡើយ ។ រួចហើយក៏ប្រញាប់ប្រញាល់ចងខ្សែក្រវាត់ អូប៊ី ។

- គស់សូមនិមន្ត ព្រះតេជព្រះគុណ ។

ថាហើយនាងក៏កណ្តៀតកូនចានដែក សំរាប់លាងអង្ករ ស៊កស្បែកជើងសង្រែក ហើយហក់ទៅលើទួល ។

- សូមព្រះអង្គប្រយ័ត្នរអិលទាន ។

- មិនអីទេ អាត្មាបានស្ទាត់ហើយ ។

អាត្មាគិតស្មានថា ខ្លួនឯងបានធ្លាប់នឹងទីកន្លែងនេះហើយ ប៉ុន្តែលុះដល់តែលោខ្លួនប្រុងនឹងឡើងទៅលើទួល ក៏ចាប់អារម្មណ៍ថាទួលនេះខ្ពស់ណាស់មិនងាយឡើងទេ ។

លុះឡើងទៅលើទួលនោះ បានហើយក៏ត្រូវឆ្លងដើមឈើមូលមួយដើម ដូចអាត្មាបាននិយាយ ពីមុនមកហើយថា វាដួលដេកទៅក្នុងស្មៅនានា ហើយសភាពខាងក្រៅលើសំបកវា មើលទៅហាក់ដូចជាស្រកាពស់ អាហ្នឹងអាត្មាតែងតែឮគេនិយាយដែរមកទេ ថាដើមស្រល់ដូចជាពស់ថ្លាន់ឥចឹង ។ ជាពិសេសរូបរាងវាដែលបត់បែនទៅលើទួលយ៉ាងសម វារឹតតែនាំអោយយើង មើលឃើញវាថាជាពស់ទៅទៀត ។ ពេលដែលគិតឃើញថានោះជាពស់ដែលលាក់ក្បាលនឹងកន្ទុយទៅក្នុងគុម្ពោតស្មៅ អាត្មាក៏បានឃើញហាក់ដូចជា ដើមឈើនោះជាពស់ពិតៗនៅក្រោមពន្លឺព្រះច័ន្ទ ។

ហើយក៏បានគិតដល់អាត្មា ហើយនាងបានប្រយ័ត្នប្រយែងអ្វីៗគ្រប់យ៉ាង ដើម្បីអាត្មា ដោយទឹកចិត្តដ៏ល្អរបស់នាង ។

- វេលាដែលព្រះតេជគុណ និមន្តឆ្លងកាត់ទីនេះ សូមទ្រង់កុំមើលទៅក្រោម នៅចំពីក្រោមនេះមានជ្រោះដ៏សែនជ្រៅ ។ តែហ៊ានមើលព្រះតេជគុណច្បាស់ជាវិលមុខពុំខានទេ ។

- ពរ ។

អាត្មាបានទទួនខ្លួនឯងថាមិនត្រូវច្រេមច្រំទេ ។ ដំបូងអាត្មាបានជាន់វា ហើយដោយតាមថ្នាំងថ្នាក់របស់វា បើយើងមិនវិវរវល់គិតពីអ្វីផ្សេងទេ ទោះជាពាក់ស្បែកជើងឈើក៏យើងអាចដើរឆ្លងលើវាបានដែរ ។

ប៉ុន្តែវាទៅមិនរួចពីព្រោះ អាត្មាវាធ្លាប់ចុះស្នាមជួបពស់ថ្លាន់ម្តងហើយ វេលាដើរជាន់ដើមឈើនោះទៅឃើញវាទន់ប៉ប្លិកប៉ប្លក់ ហើយដូចជាប្រុងប្រៀបរកកល់តែនឹងលូនទៅមុខខ្សៀកៗ អាត្មាក៏ស្រែកវ៉ាសហើយអុកគូថដូចគេអង្គុយច្រកកៀវលើដើមឈើនោះទៅ ។

- អ្ហ៎ា ! ចុះក៏ខ្លាចអីខ្លាចម្ល៉េះព្រះតេជព្រះគុណ ! ពាក់ស្បែកជើងឈើបែបនេះប្រហែលជាទៅមិនរួចទេ សូមព្រះតេជព្រះគុណពាក់ស្បែកជើងនេះវិញទៅអញ្ជឹង ! ណោះ ! សូមកុំចចេសណាំទាន !

រូបអាត្មានេះ តាំងពីមុននេះម្ល៉េះ អាត្មាហាក់ដូចជាមានចិត្តគោរពនាងនេះ បាត់ទៅហើយ មិនដឹងជាទឹកចិត្តនេះវាត្រឹមត្រូវ ឬក៏ខុសទេ ប៉ុន្តែអាត្មាបាន

គិតថាត្រូវតែធ្វើតាមបញ្ជារបស់នាងនេះ ដូច្នេះអាត្មាក៏ពាក់ស្បែកជើងសង្រែកទៅ ។ ស្ត្រីសិកជើងក្នុងស្បែកជើងឈើហើយកាន់កាន់អាត្មាអោយអាត្មាដើរ ។

ខ្លួនអាត្មាក៏បានស្រាល ហើយដើរតាមនាងពីក្រោយត្រុកៗ ទៅក៏បានចេញទៅដល់ក្រោយផ្ទះរបស់នាង ។

ពេលនោះ ស្រាប់តែឮសំលេងនិយាយមកកាន់អាត្មា :

- យីទៅបានយូរផង រួចព្រះតេជព្រះគុណហេតុអ្វីបានជាត្រលប់មកវិញដោយរូបរាងជាសង្ស័យដែលអញ្ជឹង?

- និយាយស្អីផ្តេសផ្តាសឥចឹង? ឯណាខ្ញុំអោយចាំផ្ទះ វាម៉េចទៅហើយពូ?

- បាទ យប់ពេកហើយ តែអាគ្រាត្រពេកទៅផ្លូវពិបាកណាស់ ដូច្នេះខ្ញុំគិតយកសេះចេញពីក្រោល ហើយរៀបចំខ្លួនចេញដំណើរ ហើយអ្នកស្រីម្ចាស់ ។

- ឱ សូមទោស ដោយបានអោយពូចាំយូរ ។

- ទេ មិនអីទេ សូមអ្នកស្រីទៅមើលមើល៍ លោកប្តីអ្នកស្រីអត់មានរលាក់រលាត់អ្វីទេ ។ ហ៊ឺស ខ្ញុំខំលួងលោមដែរ តែដូចជាអត់ប្រយោជន៍សោះ រកតែលួចក៏មិនបាន ហាសៗ ។

តាចាស់សើចឮខ្លាំងៗឥតន័យ ហើយដើរគ្រេងគ្រាងទៅក្រោលសេះបាត់ទៅ ។

កម្លោះមិនគ្រប់ទឹកនៅអង្គុយកន្លែងដដែល ដោយរូបរាង ដូចក្រមួនទទន់ពក្លក់ ជិតរលាយដោយកំដៅថ្ងៃ ។

## ជំពូកទី ១៨

ហេ ! ហេ !

គេឮសូរសម្លេងសេះកញ្ជ្រៀវ ព្រមទាំងសម្លេងក្រចកសេះលាន់ឮឡើង តាចាស់បានដឹកសេះមក ដល់រានហាល ពីខាងក្រោយចេញមកដល់មុខទ្វារ ។

គាត់ចាប់បង្ហៀវវាហើយដើរចេញមក ។

- អ្នកស្រីម្ចាស់ ខ្ញុំបាទលាទាំងអញ្ជឹងទៅហើយទានប្រោស ។ ឯព្រះតេជព្រះគុណវិញ សូមឆាន់អោយបានច្រើនណាំទានណាំ ។

ស្ត្រីបានយកចង្កៀងគោម ដើរទៅជិតជើងក្រាន ហើយឈ្ងោកផ្លុំភ្លើងពីក្រោមឆ្នាំង ។ ពេលឮតាចាស់និយាយ នាងក៏ងើបមុខឡើង ដាក់ដៃដែលកាន់ចង្កឹះវែងធ្វើពីដែកទៅលើភ្លៅ ។

- សូមអរគុណពូច្រើន ។

- មិនដឹងជាចាំគុណស្រាយអីទេ អ្នកស្រីម្ចាស់ អើយ !

តាក៏ចាប់ទាញខ្សែសេះ ។ សេះមានពពាលពណ៌ខៀវ-ខ្មៅ និង សូកូឡា នៅលើខ្លួនរបស់គេ ហើយមាំមួនល្អណាស់ទាស់តែសក់មុខដូចជាស្តើងពុំសូវមាន ។

អាត្មានេះថាទៅមិនមែនថា មិនដែលឃើញសេះ ឬក៏ថាសេះនោះវាល្អចំឡែកអ្វីទេ តែដោយអាត្មានៅអង្គុយពីក្រោយអ្នកកម្លោះមិនគ្រប់ទឹក អត់ធ្វើអ្វីក៏សួរលេងទៅថា :

- រួចចុះពូ ដឹកសេះនេះទៅណា?

- ឱ ខ្ញុំករុណាដឹកវាយកទៅម៉ុទន្លេ "ស៊ីវ៉ា " ទីនោះមានផ្សារសំរាប់លក់សេះ ខ្ញុំករុណាដើរទៅ មុនព្រះតេជព្រះគុណហើយទាន ព្រះតេជព្រះគុណនឹងនិមន្តតាមផ្លូវភ្នំដែលខ្ញុំព្រះករុណាទៅបន្តិចទៀតនេះ នៅវេលាស្អែក ។

- ឱព្រះតេជព្រះគុណគិតជិះសេះនេះរត់ទេដឹងទាន?

ស្ត្រីប្រញាប់និយាយកាត់សំដីរបស់តាចាស់ ។

- ទេ ញោម អាត្មាជាសង្ឃដែលកំពុងតែរៀនសូត្រ បើយើងរវល់ចង់តែស្រួលមិនដើរ មិនខិតខំហ្វឹកហ្វឺនខ្លួនប្រាណ ហើយទៅនេះសេះ ទៅនោះលាមិនបានទេ ។

- សេះនេះមិនមែនចេះតែថា អោយតែមនុស្សអោយឡើងជិះស្រួលៗទេ ។ ព្រះតេជព្រះគុណបានរួចព្រះជន្មហើយ ដូច្នេះយប់នេះសូមសឹងនៅក្នុងដៃរបស់អ្នកម្ចាស់ ហើយយល់សុបិន្តអោយល្អៗទៅទាន។ ខ្ញុំព្រះករុណាសូមថ្វាយបង្គំលាហើយ ។

- ពរ ។

- អាឆ្កួត !

តាចាស់បានជេរសេះ ប៉ុន្តែសេះមិនព្រមចេញទៅសោះ ។ វារមួលក្បាលឃើញច្រមុះដ៏ធំបែរមករកទីដែលយើងទាំងឡាយកំពុងអង្គុយ ។

- អារំបល់យក៏ ! ចុះម៉េចក៏រឹងម្ល៉េះអាសត្វនេះ !

តាចាស់បានទាញបង្ហៀរទៅស្ដាំទៅឆ្វេង ។ ជើងសេះប្រៀបដូចជាមានឫសចាក់ទៅក្នុងដី ធ្វើអោយវានៅទ្រឹងអត់កំរើក ។

តាចាស់ឡើងក្ដៅក្រហាយ ។ គាត់វ៉ាត់វាយវា ហើយដើរជុំវិញវា ២-៣ដង ។ តែសេះនៅតែមិនព្រមដើរ ។ គាត់បែរចំហៀងខ្លួនរបស់គាត់រកទៅផ្ទួលសេះ ។ វាក៏លោជើងមុខរបស់វាទៅលើតែបន្តិច ។ បន្ទាប់មកក៏ទម្លាក់មកក្រោមវិញ សន្ធឹងជើងទាំង ៤ របស់វា ស្ប៉ាបទៅលើដី ។

- អ្នកស្រីម្ចាស់ ! អ្នកស្រីម្ចាស់ !

ឮតាចាស់លាន់មាត់បែបនេះ ស្ត្រីក៏ជំទើតជើងឈរលើចុងជើងដ៏សក្បុសរបស់នាង ហើយដើរទៅពួនក្រោយសសរដ៏ធំមួយដែលឡើងខ្មៅ ដោយសារផ្សែងភ្លើងកុំអោយសេះមើលមកនាងឃើញ ។ រួចមកក៏ហូតកូនកន្សែងពោះគោដែលសៀតនៅនឹងខ្សែក្រវ៉ាត់ អូប៊ី ដែលទក់ទឹអស់ហើយមកជូតញើស ដែលនៅជាមជិតក្នុងចង្អែកស្នាមជ្រួញនៃថ្ពាសរបស់នាង ។

តាចាស់គិតថាប្រហែលជាអាចដឹកសេះទៅរួចហើយ ក៏ដើរទៅមុខសេះម្ដងទៀត ។ ប៉ុន្ដែដោយសេះមិនកំរើកបន្តិចសោះ ហើយនៅតែឈរទ្រឹងដដែលគាត់ក៏តម្រឹមជើង ប្រមូលកំលាំងចំកោងខ្នង យកដៃទាំងពីរទៅទាញសេះ អស់មួយកំលាំងកាយ និង កំលាំងចិត្តរបស់គាត់ ។ សេះបានលើកជើងមុខរបស់វាទាំងពីរឡើងលើក្នុងលំហអាកាស ហើយប្រែខ្លួនព្រឹប ។ ខ្លួនដ៏តូចរបស់តាចាស់បានដួលផ្ងារផាំង ហុយដីទ្រលោមនៅក្នុងរាត្រីខែភ្លឺដ៏ត្រចេះត្រចង់ ។

កម្លោះមិនគ្រប់ទឹក យើញបែបនេះប្រហែលជាគិតថាគួរអោយអស់សំណើចហើយមើលទៅ គេបញ្ឈរករបស់គេត្រង់ឆ្វក់ បើកបបូរមាត់ដ៏ក្រាស់ឃ្មឹកបញ្ចេញធ្មេញប៉ុន១ចបកាប់ បក់ដៃទាំងពីរយោលយោកទៅក្នុងលំហ ដូចជាប្រមោយដំរីពីរ ។

- យីពូ ! ធ្វើអ្វីមិនកើតសោះអញ្ជឹងពូឯង?

ស្ត្រីថាហើយក៏ដើរតាំង១ទៅសិកស្បែកជើងផ្ទាត់ខ្ទាច់ ហើយចេញមកដល់ជិតទ្វារចូលផ្ទះ ។

- អ្នកស្រីម្ចាស់ សូមកុំយល់ច្រឡំថាសេះនេះវារឹងរូសដោយសារវាមានការពាក់ព័ន្ធនឹងអ្នកស្រីទាន មើលអោយមែនទែនទៅវាដូចជាមានទំនាក់ទំនងអ្វីជាមួយនឹងកូនលោកឯនោះ ។ ខ្ញុំឃើញតាំងពីដំបូងទីម្ល៉េះ ហាក់ដូចជានិស្ស័យអ្វីរបស់វាជាសត្វធាតុទេនេះហ្ន៎ !

ឮតាចាស់គាត់ប្រើពាក្យ និស្ស័យជាសត្វធាតុ អាត្មាភ្ញាក់ព្រើត ។

ឮបែបនេះស្ត្រីក៏និយាយថា :

- ព្រះតេជព្រះគុណនៅពេលដែលព្រះអង្គនិមន្តមកតាមផ្លូវ តើទ្រង់មានបានជួបនឹងនរណាទេទាន?

## ជំពូកទី ១៩

- មុនពេលទៅដល់ " ស៊ីយី " បន្តិចអាត្មាបានជួបនឹងអ្នកលក់ថ្នាំ ម្នាក់មកពី "តូយ៉ាម៉ា " ។ គេនោះបានចូលមកផ្លូវនេះមុនអាត្មាមួយដង្ហើម ។

- ឱ អញ្ជឹង?

ស្ត្រីនិយាយដោយស្នាមញញឹម ដ៏ស្អាតបំផុតរបស់នាងហើយ បែរទៅទិសដែលមានសេះ ហើយទំនងដូចជាទ្រាំអស់សំណើចមិនបាន នាងក៏សើចហាស១ យ៉ាងអាក្រក់អាក្រី ។

ដោយអាត្មាមើលឃើញវាច្បាស់លើគោកពេក អាត្មាក៏សួរថា :

- តើគេមានបានមកដល់ផ្ទះនេះដែរឬទេ?

- ទេ ខ្ញុំព្រះករុណាមិនដឹងទេ ទាន ។

ដោយអាត្មាគិតថា មិនត្រូវប៉ះពាល់ អ្នកស្រីម្ចាស់នេះទេ អាត្មាក៏បិទមាត់។ ស្ត្រីក៏បែរទៅរកតាចាស់ដែលអស់តិរះនឹងដឹកសេះចេញ ហើយកំពុងបោសដីពីខោអាវនៅពីមុខជើងមុខរបស់សេះ ។

- យី អស់យ៉ាងតែម្តងពូកនេះ !

នាងថាហើយក៏ដោះអាវ គីម៉ូណូ ហើយទាញខ្សែក្រវាត់ អូប៊ី ដ៏តូចដែលធ្លាក់ចុងម្ខាងទៅលើដីផ្លូវហើយដូចជារួញរាបន្តិច ។

- អ្ហា ! អ្ហា !

កម្លោះមិនគ្រប់ទឹក បញ្ចេញសម្លេងដ៏ក្រងូរ ហើយដៃគេយោលយោកបក់ទៅមុខដូចជាប្រមោយដំរីដដែល ។ ស្ត្រីក៏ហុចខ្សែក្រវាត់ អូបីទៅ ។ អ្នកកម្លោះក៏លាវារួចមួរវាទុកលើភ្លៅរបស់គេក្រុងវា ប្រៀបបានដូចជាគេខំការពាររបស់ដ៏មានតំលៃ កុំអោយអ្នកដទៃដណ្តើម ។

ស្ត្រីកាន់តែមអាវ គីម៉ូណូ ទាំងសងខាងទប់ម្ពុំទ្រូងរបស់នាង ហើយដើរចេញតាមទ្វារមករកសេះ ។

អាត្មាឈរភ្លឹក គិតតែមើលថាតើនាងនឹងធ្វើអ្វី? ស្ត្រីឈរជំទើតលើចុងជើងរបស់នាង លោដៃទាំងពីរទៅលើស្កាំឆ្វេង រួចក៏អង្អែលសក់សេះ២-៣ដង ។

សេះក៏ងើយច្រមុះរបស់វា ហើយប្រុងប្រៀបនឹងក្រោកឈរ ។ គេឃើញកំពស់របស់សេះកាន់តែខ្ពស់ទៅៗ ។ ស្រីសំលឹងភ្នែកសេះត្មៃរ ខ្ទិបមាត់ ភ្នែកនាងកាន់តែឡើងស្លួតបន្តិចម្តងៗ អណ្តែតអណ្តូង ។ សម្ផស្សរបស់នាង ភាពថ្លៃថ្នូររបស់នាង ព្រមទាំងភាពរាក់ទាក់ដែលអាត្មាធ្លាប់បានឃើញ បានរសាត់បាត់បង់ទៅណាអស់ក្នុងមួយរំពេច នាំអោយមើលទៅឃើញនាងទៅជាព្រះជាម្ចាស់ ឬព្រាយបិសាច ។

ពេលនោះ ភ្នំងក្រោយ និង ខ្នងភ្នំដែលនៅពីមុខហាក់ដូចជានាំគ្នាបើកមាត់ចំហធ្លុង ងើយក្បាលឈរមើលពិភពចំឡែកនេះ ដែលមានរូបនារី ដ៏ល្អកំពុងឈរពីមុខសេះខាងឆ្វេងដៃតាចាស់ ក្រោមពន្លឺព្រះច័ន្ទ ។ វេលានោះគេទទួល

អារម្មណ៍ដូចជា ខ្យល់ព្រលឹងដែលសណ្ឋិតនៅក្នុងភ្នំហោះស្នេវមួយរឹប យ៉ាងធ្ងន់មកសង្កត់ ។

វេលាដែលកំពុងតែគិតថាមានខ្យល់ឧណ្ហៗបក់មកបែបនេះ ស្ត្រីស្រាប់តែលាត់អាវបញ្ចេញសាច់ស្មាខាងឆ្វេងរួចក្រលៀសដៃស្តាំចេញពីដៃអាវ ខាងស្តាំបង្វិលដៃនោះទៅមុខ ។ រួចនៅវេលាដែលអាវធ្លាក់បញ្ចេញដើមទ្រូងដ៏មូលក្លំរបស់នាងៗក៏ដោះអាវទាំងអស់ ឆ្លួលវាកាន់អោយឃើញសាច់រលើបរលោងរបស់នាងទាំងមូល ។

សេះយារសាច់ខ្នង សាច់ពោះស្បែបហៀវញើសស្រាក់ញ៉ូរជើង ហើយខ្លួនវាទាំងមូលឡើងញាក់ញ៉ូរ ទទ្រើកទទ្រើក ឈ្មុលច្រមុះទៅដី បញ្ចេញពពុះស្គុលមួយកំបង់ពីមាត់ រួចមកវាក៏បត់ជើងទាំងពីរ អង្គុយចុះឈរលែងរួច ។

ស្ត្រីក៏ដាក់ដៃទៅក្រោមចង្កាសេះ ។ ដៃម្ខាងទៀតដែលកាន់ គីម៉ូណូ បានត្រវែង គីម៉ូណូនោះបំរុងទៅគ្របក្បាលសេះ ។ វេលាដែលអាវ គីម៉ូណូ នោះមិនទាន់ទាំងបានទៅគ្របក្បាលសេះស្រួលបួលផង ស្ត្រីក៏ចាប់រវេរាំ ។ រូបរាងស្រមោលរបស់នាងបានក្លាយទៅជាទន្សាយសដែលចុះពីក្នុងព្រះច័ន្ទមក នាងប្រែខ្លួនផ្ងារពោះ ពោរពេញទៅដោយអច្ឆរិយភាព ។ នៅវេលាដែលគេកំពុងតែគិតថា សាច់របស់នាងកំពុងតែត្បៀតដោយជើងមុខរបស់សេះ ស្ត្រីក៏ឈ្ងោកដើរពីក្រោមពោះសេះ ទាំងរាងកាយស្រាតនទលចេញទៅខាងម្ខាងបាត់ ។

តាចាស់ឃើញឱកាសល្អមកដល់ហើយ ក៏ទាញបង្ហៀរសេះមកកាន់។ សេះស្រាប់តែមានកំលាំងព្រឺស ដើរព្រឹបៗឡើងលើផ្លូវភ្នំកុបៗ ។

ក្នុងមួយប៉ប្រិចសោះស្រមោលក៏វសាត់បាត់ពីមុខអាត្មាទៅ ។

ស្ត្រីក៏ប្រញិបប្រញាប់ស្លៀកពាក់ ហើយរត់មករានហាលរួចទាញខ្សែក្រវាត់ អូបី ពីដៃយុវជនមិនគ្រប់ទឹកភ្លឺប នាំអោយគេខំទប់ មិនព្រមលែងដៃអោយនាងវិញ ព្រមទាំងលោដៃទៅរកស្ទាបដោះរបស់ស្ត្រី ។

ស្ត្រីទះដៃនោះផ្លាប់ ព្រមទាំងត្រវែងវាទាំងទ្រគោះបោះបោក ។ រួចហើយនាងក៏សម្លក់យុវជននោះត្មែរ យុវជនឱនក្បាលចុះ ដាក់មុខជ្រប់ ។ ទិដ្ឋភាពទាំងឡាយ ព្រមទាំងពន្លឺគោមក្តី មើលទៅឃើញព្រិមៗ ព្រាលៗ ហាក់ដូចជាសុបិន្តនិមិត្ត ។ នៅឯជើងក្រានឯនោះ អុសដែលទើបនឹងថែមថ្មីឆេះឮសូរប្រើបៗចេញផ្កាភ្លើងព្រាត ។ ស្ត្រីនឹកឃើញ ក៏រត់ស្លេវចូលទៅ ។ នៅពីក្រោយព្រះច័ន្ទដែលតាចាស់ប្រហែលជាដើរទៅដល់ហើយ គេឮសូរសម្លេង " ចំរៀងសេះល្ហើយៗមក ។

## ជំពូកទី ២០

- មកដល់ពេលបាយហើយ ! នៅក្នុងថាសម្ហូបគេឃើញមានជ្រក់ខ្ទឹមទឹកស៊ុប សំឡសៀង ដែលមានដាក់សារាយស្ងោរ និង ផ្សិតដែលគេមិនស្គាល់ឈ្មោះ មើលទៅឃើញឆ្ងាយពីការ៉ុត និង សារាយក្រៀមណាស់ ។

គ្រឿងផ្សំមើលឃើញទៅ ឃើញដូចជាមិនមានអ្វីធំដុំចំឡែកទេ ប៉ុន្តែរសជាតិឆ្ងាញ់ចំឡែកណាស់ ត្រូវពេលនឹងអាត្មាឃ្លានស្រាប់ផង ការបំរើក៏ល្អអស់ពីចិត្តផង ...

ស្ត្រីដាក់ថាសនៅលើភ្លៅរបស់នាង យកដៃច្រត់ចង្កា ដាក់កែងដៃទៅក្នុងថាសហើយមើលអាត្មាឆាន់ ទាំងទឹកមុខសប្បាយរីករាយ ។

ឯកម្លោះមិនគ្រប់ទឹក ដែលនៅអង្គុយឯរានហាល ដោយពុំមាននរណារវីរវល់នឹងខ្លួន ក៏កើតក្តីអផ្សុក ហើយវារស្តេស្តាៗទៅជិតស្ត្រី កាន់ពោះដែលធ្លាក់ស្បៀចរបស់គេ ។ គេអង្គុយពែនភ្លែន ប៉ុន្តែហាក់ដូចជារកតែរលំ ភ្នែកសំឡឹងត្មៃរមករកថាសម្ហូបរបស់អាត្មា ហើយចង្អុលមក :

- អ៊ូ ! អ៊ូ ! អ៊ូ ! អ៊ូ ! អ៊ូ ! អ៊ី ! អ៊ី ! អ៊ី !

- វាយ៉ាងម៉េចអ្នកប្រុស? ចាំបន្តិចសិន ឥឡូវភ្ញៀវកំពុងពិសា ។ កម្លោះមិនគ្រប់ទឹក ធ្វើមុខគួរអោយអាណិតបង្ហៀចមាត់ ហើយគ្រវីក្បាល ។

- យ៉ាងម៉េចមិនសុខចិត្តទេឬ? យីកុំអោយតែដឹងអី អញ្ចឹងញ៉ាំជាមួយភ្ញៀវទៅអញ្ចឹង ! ព្រះតេជព្រះគុណសូមព្រះអង្គអភ័យទោសណាំទាន ! អាត្មាបានទុកចង្កឹះទៅវិញដោយមិនគិតវែងឆ្ងាយ :

- អញ្ជើញ សុំកុំគិតពីអាត្មាអី ពិសាជាមួយគ្នាទៅ ។

- ទេ ៗ ! មកអ្នកប្រុស អ្នកប្រុសឯងនេះគ្រាន់តែចាំមួយភ្លែត បន្តិចទៀតចាំទទួលទានជាមួយគ្នាទៅវាម៉េច នេះបានចំជានិយាយស្តាប់គ្នាមិនបានមែនតែម្តង ។ នាងនិយាយដោយគ្មានការខឹងសម្បារអ្វីទេ ហើយក៏រៀបចំស្លកអាហារមួយទៀតភ្លាម ដូចស្លកអាហារអាត្មាដែរ ។ របៀបដោះដូសបាយបំរើក៏ធ្វើដោយក្បៀវក្លា ដូចជាប្រពន្ធដ៏ល្អ ថែមពីលើនោះទៅទៀត យ៉ាងថ្លៃថ្នូរប្រកបដោយភាពសមរម្យ ជានារីដែលចេញពីគ្រួសារល្អ ។ កំលោះមិនគ្រប់ទឹក ងើយមុខមើលទៅលើថាសហើយថា :

- អានោះ អ៊ី អានោះៗ ។

គេមើលទៅនេះ ទៅនោះក្រឡិបក្រឡាប់ភ្នែក ។

ស្ត្រីមើលទៅគេហើយថា :

- ហ៊ឹស កុំអី របស់នោះអង្កាល់ក៏អាចញ៉ាំបានដែរ យប់នេះយើងមានភ្ញៀវ ។

- អ៊ី អត់ទេៗ ។

គេគ្រវីស្មានិងពោះរបស់គេប៉ប្លិកប៉ប្លុក់ហើយ ពេបមាត់ប្រុងនឹងយំ។ ស្ត្រីអល់អែក ។ អាត្មាមើលទៅឃើញពិបាកមើលពេក ក៏ថា :

- អ្នកស្រីម្ចាស់ អាត្មាមិនដឹងថាគេចង់បានអ្វីទេ សូមអ្នកស្រីម្ចាស់ធ្វើតាមអំពើចិត្តរបស់គេចុះ កុំបារម្ភពីចិត្តរបស់អាត្មាថ្វី ។ បើអ្នកស្រីម្ចាស់ខ្លាចចិត្តអាត្មាវានាំអោយលំបាកទេវិញទេ ។ អាត្មាបាននិយាយដោយគួរសម ។

ស្ត្រីក៏ថាម្តងទៀតថា :

- អត់សុខចិត្តទេឬ? ម្ហូបប៉ុណ្ណឹង ហើយនៅមិនសុខចិត្តទៀតឬ?

វេលានោះយុវជនមិនគ្រប់ទឹក ក៏រកកលនឹងយំ ។ ដោយពិបាកពេកស្ត្រីក៏សំឡក់វាហើយដើរសំដៅទៅទូមាសទ្វារដ៏ចាស់ទ្រុឌមួយ ។ នាងដករបស់អ្វីម្យ៉ាងពីថាសមករួចញាត់ផ្ទុកទៅក្នុងថាសអាហារ របស់បុរសមិនគ្រប់ទឹកយ៉ាងរហ័ស ។

- ហ៎ ! យកទៅ !

នាងនិយាយទាំងញញឹម ហើយដូចជាខឹងបន្តិចៗ ។ អាត្មាឯនេះវាពុំដឹងថារបស់នោះជាអ្វី លឿងៗមើលតែពស់ពណិលឿងខរមិនស្រួលៗ ជាសាច់ស្វាផើម អាំង ក៏មិនដឹង។ អោយតែយ៉ាងៗនេះច្បាស់ជាដាច់សីលអាត្មាទៀតហើយបើត្រឹមតែងៀតគីង្គក់ក្រហមអ្វីទៅវាគ្រាន់ខ្លះ ។ តើរបស់ដែលបុរសនេះយកមកកាន់អង្កៀមនោះជាអ្វី? អាត្មាខំលបគយគន់អោយសព្វទៅក៏បានដឹងថា នោះជា

នៃប៉ូវ ដែលធ្វើពីនៃថាវដ៏ធំមួយ ហើយកាត់ជាកង់ប្រហែលជាមួយភាគបីនៃនៃប៉ូវទាំងមូល ។

ស្ត្រីមិនកាត់តូចៗអោយគ្នាទេ ហុចទាំងមើមមកតែម្តង ។ អ្នកកំឡោះមិនគ្រប់ទឹកកាន់នៃប៉ូវដៃម្ខាងខាំពីចំហៀងមាត់ដូចជាគេខាំអំពៅស៊ីច្រុបៗ។ ស្ត្រីហាក់ដូចជាខ្មាសអៀន នាងលបចោលភ្នែកមើលមកអាត្មា។ មុខនាងឡើងក្រហមព្រឿងៗនាំអោយឃើញនាងហាក់ដូចជាកុមារីដ៏តូច ដែលមិនសមនឹងរូបនាងសោះ ។ រួចហើយនាងក៏ខាំជាយកូនកន្សែងដែលដាក់នៅលើភ្លៅ ដោយអៀនអន់ ។

ឱអញ្ជើងទេតើ បានជាអ្នកកម្លោះនេះឡើងធាត់លឿនឥចឹងនោះ? រួចហើយគេក៏ទទួលទានអាហារអស់មួយចាន ហើយមិនផឹកទឹកទេ ដកដង្ហើម ហ៊ឺហ៊ឺ ពីរបីដង ហើយបែរទៅឯណាឯណីហាក់ដូចជាហត់អស់យ៉ាង ។

- ឱខ្ញុំលែងឃ្លានបាយហើយ ដូចជាណែនអប់ដើមទ្រូង ចាំបន្តិចទៀតទើបទទួលទាន ។

រួចហើយស្ត្រី ក៏រៀបចំទុកដាក់ចានទាំងពីរ ហើយអត់ទទួលទានអ្វីទាំងអស់ ។

## ជំពូកទី ២១

អាត្មានៅស្លឹអស់មួយសន្ទុះ ។

- ព្រះតេជព្រះគុណប្រហែលជាអស់កំលាំងហើយ ។ ខ្ញុំព្រះករុណានឹងរៀបកន្លែងប្រគេនសឹង ។

- សូមអរគុណញោម ។ អាត្មាមិនទាន់ងងុយទាល់តែសោះ ។ អំបាញ់មិញបានលាងជំរះខ្លួនហើយ ដូច្នេះការហត់នឿយទាំងប៉ុន្មានបានរសាត់ទៅអស់ហើយ ។

- ស្ទឹងនោះសក្តិសិទ្ធិណាស់ ព្រះតេជព្រះគុណ ។ នៅវេលាដែលខ្ញុំព្រះករុណាហត់នឿយ ហើយរូបកាយ ស្ទើរតែស្លោកនៅតែស្បែកដណ្តប់ឆ្អឹងក្តី បើបានត្រាំទឹកនោះតែកន្លះថ្ងៃ ខ្ញុំព្រះករុណានឹងជា ហើយមានកំលាំងមកវិញ ។ ឯរូបរាងកាយក៏ឡើងស្រស់បស់មានទឹកដមមកវិញដែរ ។ ពីពេលឥឡូវរហូតទៅដល់វេលាដែលទឹកកកធ្លាក់ ភ្នំទាំងឡាយនឹងកក ស្ទឹងក្តី ជំរាលទាំងឡាយក្តីសុទ្ធសឹងតែនឹងទៅជាទឹកកកទាំងអស់ ចំឡែកអ្វីតែកន្លែងដែលព្រះតេជគុណស្រង់ទឹកអំបាញ់មិញនោះ ទឹកមិនរឹង មិនខះទេ ហើយហាក់ដូចជាមានជីវិតមានដង្ហើមបែបនោះឯង ។

មានសត្វគ្រប់យ៉ាងចុះមកងូតទឹកស្ទឹងនេះ តាំងពីស្វា ដែលមានដំបៅដោយសារត្រូវគ្រាប់កាំភ្លើងក្តី កុកបាក់ជើងក្តី ស្លាមជើងរបស់វាបានក្លាយទៅជាជំរាលមួយ ដោយសារតែទឹកនោះពូកែសក្តិសិទ្ធិ ។

ប្រសិនបើពុំមានមនុស្សមកទីនេះច្រើនបែបនេះទេ ឬក៏ពុំមាននរណានិយាយរឿងអោយខ្ញុំព្រះករុណាស្តាប់ទេ ខ្ញុំព្រះករុណាពុំដឹងជាឯកោ ត្រមង់ត្រមោចបែបណាទេ ។ គិតអោយសព្វៗទៅ និយាយទៅ ដូចជាគួរអោយខ្មាសគេណាស់ ។ នៅពេលដែលយើងរស់នៅក្នុងភ្នំក្នុងព្រៃបែបនេះ ឯកោអនាថាដាច់ពីគេពីឯងទៅ យើងភ្លេចទាំងពាក្យដែលមនុស្សនិយាយទៅទៀត ។

ឱព្រះតេជព្រះគុណ បើព្រះអង្គងងុយសឹងសូមនិមន្តសឹងចុះ កុំបីខ្វាចចិត្តខ្ញុំព្រះករុណាឡើយ ។ ទីនេះពុំមានបន្ទប់ទទួលទានដំណេកទេ ប៉ុន្តែមូសក៏ពុំមានដែរ ។

អ្នកដែលមកពីទីក្រុង ពេលមកសំណាក់នៅស្រុកស្រែ ហើយយើងចងមុងអោយគេសំរាក គេតែងតែឡកឡឺយអោយយើង ដូចជាទាររកបង្អោងសំរាប់ដាក់ឡើងលើមុង ព្រោះគេមិនដឹងថាត្រូវចូលតាមណា ។ ។

ទោះជាភ្លឺហើយក្តី សូមព្រះតេជព្រះគុណសឹងតាមសប្បាយទៅចុះ ពីព្រោះពុំមានមាន់ ឬជួងដែលរាំប្រាប់ពីពេលវេលាទេ ឆ្កែក៏គ្មាន ស្ងាត់ស្រួលណាស់ ។

ឯអ្នកប្រុសខាងនេះ កើតមកស្គាល់តែភ្នំ ស្គាល់តែព្រៃមិនដឹងពីអ្វីទេ។ ប៉ុន្តែគេជាមនុស្សបរិសុទ្ធ មិនមានមុខក្រោយក្នុងក្រៅទេ ។

វេលាឃើញអ្នកមកពីក្រៅមក គេតែងតែស្រលាញ់ ហើយយកចិត្តទុកដាក់ណាស់ ហើយបើត្រឹមតែធ្វើការកិច្ចដាក់ភ្នៀវ គឺគេអាចធ្វើបានល្អណាស់។

អ្នកប្រុសមិនទាន់ថ្វាយបង្គំព្រះសង្ឃទេ មែនទេ? ថ្មីៗនេះគេដូចជាល្ងើយប្រហែលជាចុករោយស្រពន់ខ្លួនណាស់ ។ អ្នកគេមិនដឹងថាខ្ជិលហើយ ។

ឱកុំថាគេល្ងង់ អ្វីក៏គេដឹងដែរ ព្រះតេជព្រះគុណ ។ តស់អ្នកប្រុសថ្វាយបង្គំព្រះតេជព្រះគុណទៅ ភ្លេចរបៀបថ្វាយបង្គំហើយទេដឹង?

ស្ត្រីនិយាយហើយក៏ខិតទៅជិតអ្នកកម្លោះមិនគ្រប់ទឹកយ៉ាងស្និទ្ធស្នាល ហើយឈ្ងោកមើលមុខរបស់គេព្រមទាំងនិយាយដដែលៗច្រើនដង។ អ្នកកំលោះមិនគ្រប់ទឹកលើកដៃខ្វេៗរួចហើយក៏តម្រឹមដៃនោះដាក់ពីមុខលើកន្ទេល ហើយងក់គោរពអាត្មាផ្ងក់ៗ នៅផ្ទាំងដូច្នេះបណ្ដោលដូចជារូបតុក្កតាដែលគេមួលខ្សៅអោយធ្វើចលនា ហើយត្រូវទុចងក់កណ្ដាលផ្លូវដោយខ្សៅនោះវាឈប់បែបនោះឯង ។

- ពរ ។

អាត្មាថាបានតែប៉ុណ្ណោះ នៅក្នុងដើមទ្រូងរបស់អាត្មា ហាក់ដូចជាមានអ្វីមកខ្ទាស់អោយឈឺចុកចាប់ អាត្មាក៏ឱនមុខចុះ ។ ឯអ្នកកំលោះក៏ឱនមុខចុះដែរហាក់ដូចជាត្រូវគេដកសរសៃសរសូងចេញអស់ នាំអោយគេទ្រេតទៅចំហៀងរកកលនឹងរលំ។ ស្ត្រីបានស្ទុះទៅត្រកងយ៉ាងសប្បុរស ទប់គេអោយគេអាចអង្គុយបាន ។

- អ្នកប្រុសធ្វើបានល្អណាស់ ។ ហើយនាងធ្វើមុខដូចជាសរសើរលើកទឹកចិត្តអ្នកកំលោះយ៉ាងខ្លាំង ។

- ព្រះតេជគុណមើលមើល៍ ទោះជាយើងអោយគេធ្វើអ្វីក៏គេអាចធ្វើបានដែរ ។ ទាស់តែម្យ៉ាង ជំងឺគេនេះទោះជាគ្រូពេទ្យក៏មើលមិនជា ចូលងូតទឹកស្ទឹងនេះក៏ពុំមានប្រសិទ្ធិភាព ។ ហើយដោយសារគេពុំអាចក្រោកឈរបាន ទោះជាបង្រៀនអ្វីក៏ពុំមានប្រយោជន៍ ។ ដូចព្រះតេជព្រះគុណឃើញហើយ សូម្បីតែធ្វើគារវកិច្ចដាក់ភ្ញៀវក៏ពិបាកម្ល៉េះទៅហើយ ។ ពេលបង្រៀនអ្វីមួយ គ្នាខំរៀននោះខំ តែនៅតែធ្វើមិនបាន ដល់អញ្ចឹងទៅអាណិតនឹកឃើញថានាំអោយតែពិបាកដល់ខ្លួនប្រាណរបស់គេឥតអំពើ ខ្ញុំព្រះករុណាក៏ចេះតែមិនអោយគេធ្វើអ្វី ។ ដូច្នេះគេក៏ទៅជាភ្លេចតាំងពីលើកដៃ លើកជើង ឬនិយាយស្តីអ្វីអស់រលីង ។ ប៉ុន្តែគេអាចច្រៀងបាន ២-៣បទ ។ មើលអ្នកប្រុសច្រៀងអោយភ្ញៀវស្តាប់មួយបទមើល !

អ្នកកំលោះមិនគ្រប់ទឹក មើលទៅស្ត្រី រួចហើយមើលមកអាត្មាភ្ញៀវក៏ដូចជាខ្លាចមនុស្ស ហើយគ្រវីក្បាល ។

## ជំពូកទី ២២

ស្ត្រីនោះបានលួងលោមព្រមទាំងបញ្ចើច អ្នកកំលោះអោយច្រៀង ។ អ្នកកំលោះក្រងៀកក្បាល យកដៃទៅឈ្មីផ្ចិត របស់គេបណ្តើរចាប់ផ្តើមច្រៀងបណ្តើរ ។

« វង្វើរក្តៅ " អូនអើយអ្នកអើយ " នៅឯកំពូលភ្នំ " គឺសូណូតាគេ " "អូនអើយអ្នកអើយ" វងាណាស់ រូបខ្ញុំបានចាក់អាវវងា " អូនអើយអ្នកអើយ" ព្រមទាំងស្រោមជើង ដើម្បីអោយអ្នកពាក់កុំអោយវងា ... »

ស្ត្រីអង្គុយស្ងៀមស្តាប់អ្នកកំលោះច្រៀង ។ រួចហើយនាងក៏ញញឹម :

- ព្រះតេជគុណឃើញពិរោះទេ?

ចំឡែកណាស់នៅពេលដែលអ្នកកំលោះច្រៀង សំលេងរបស់គេ សូម្បីតែអ្នកឯងដែលកំពុងតែស្តាប់ អាត្មានិយាយនេះក៏មិនជឿដែរ អាត្មាខ្លួនឯងក៏មិនជឿត្រចៀករបស់ខ្លួនឯងដែរ ។ អ្វីដែលអាត្មាបានគិត និងអ្វីដែលបានឮវាខុសគ្នាប្រៀបបានដូចជាព្រះច័ន្ទ និង អណ្តើក ពពក និង ភក់ជ្រាំ មេឃនិងដី ។ របៀបរលាក់សំលេង សំលេងលើក សំលេងដាក់ កន្លែងដែលត្រូវតែទប់ដង្ហើម ដើមច្រៀងអោយបានវែងជាដើម ។ ជាពិសេសសំលេងនោះ គឺជាសំលេងដ៏ថ្លាត្រជាក់ ដែលពុំអាចមាននរណាស្មានបានទាល់តែសោះ ថាជាសំលេងដែលចេញពីបំពង់ករបស់អ្នកកំលោះនោះ ។

នេះប្រហែលជាជាតិមុន អ្នកកំលោះនេះមានបំពង់កដែលមន្តពីស្ថានសួគ៌ តាមបំពង់មួយឆ្លងកាត់តាមពោះដ៏ធំរបស់គេនេះមិនខានឡើយ ។ បានជាអាចទៅជាសំលេងដ៏ល្អបែបនេះបាន ។

អាត្មាបានអង្គុយស្ងៀម ដាក់ដៃទាំងពីរលើភ្លៅ ខំស្តាប់គេងច្រៀង ។ ហើយទោះជាចំរៀងនោះចប់ហើយក្តី ក៏អាត្មាពុំមានដកដៃនោះពីលើភ្លៅ ហើយងើយមុខមើលបុរសស្ត្រីនោះបានឡើយ ។ ដើមទ្រូងអាត្មាឡើងអួលណែនស្ទើរតែប្រេះ ។ វេលានោះទឹកភ្នែកអាត្មាក៏ហូរធ្លាក់មកសន្សឹមៗ ។

ស្ត្រីបានឃើញហើយក៏សួរមកអាត្មា :

- ព្រះតេជព្រះគុណ យ៉ាងម៉េចទាន? ហេតុអ្វីបានជាព្រះតេជព្រះគុណយំ?

អាត្មាពុំអាចនិយាយអ្វីអោយចេញមកភ្លាមៗបានទេ ។ ចុងបញ្ចប់អាត្មាក៏អាចនិយាយថា :

- ពរអាត្មាពុំមានហេតុផលអ្វីទេញោម ។ អាត្មាពុំដែលចង់ដឹងអ្វីពីអ្នកស្រីម្ចាស់ទេ ហេតុដូច្នេះសូមអ្នកស្រីម្ចាស់ កុំសួរអ្វីពីអាត្មាអោយសោះ ។

អាត្មាពុំអាចនិយាយអ្វីអោយលើសពីនេះបានទេ ។ តាមពិតទៅ តាំងពីបានឃើញស្ត្រីដែលស្មៀតតំបៀតសក់មាស ស្លៀកពាក់ល្អពាក់ចិញ្ចៀន ព្រមទាំងគ្រឿងអលង្ការ មករស់នៅក្នុងព្រៃភ្នំដាច់ស្រយាលពីគេពីឯង ព្រមទាំងមានរូបឆោមលោមពណ៌ល្អ រាងកាយស្រឡូនស្រឡៅ គួរអោយចង់បីបមថ្នមថ្នាក់ ដូចស្ត្រីនេះ ហើយបែរជាមកនៅថែទាំបំរើបំរាស់មនុស្សប្រុស ដោយគ្មានលំអៀង

និង ប្រកបទៅដោយមេត្តាធម៌ ។ ទោះបីនេះជាទង្វើទៅលើអ្នកផ្សេងក៏ដោយ ក៏អាត្មាសប្បាយចិត្តរហូតដល់ស្រក់ទឹកភ្នែកទាំងមិនដឹងខ្លួន ។

លុះដូច្នេះទៅស្ត្រីក៏ដឹង ។ ពីព្រោះនាងមិនមែនជាមនុស្សដែលពុំអាចស្វែងយល់ពីជំរៅចិត្តរបស់មនុស្សនោះទេ។ នាងយល់ដល់ជំរៅចិត្តរបស់អាត្មាហើយថា :

- ព្រះតេជព្រះគុណ ព្រះអង្គពិតជាមនុស្សប្រកបដោយមេត្តាធម៌មែន។

អាត្មាឃើញភ្នែករបស់នាងដែលថ្លែងវាចាច្រើនលើសពីពាក្យសម្ដី ដែលនាងថ្លែងរាប់ម៉ឺនដង ក៏មើលពុំដាក់ភ្នែក ។ រួចមកអាត្មាក៏ឱនមុខចុះ ។ ឯស្ត្រីវិញក៏អៀនខ្មាសហើយបែរមុខចេញដែរ ។

វេលានោះចង្កៀងក៏ហាក់ដូចជាទៅជាងងឹត ។ នេះពុំមាននរណាក្រៅពីអ្នកកំលោះមិនគ្រប់ទឹកទេ ។

ដោយសារតែបរិយាកាសប្រែប្រួលភ្លាមៗបែបនេះ ទេវតាចម្រៀងក៏អផ្សុក ហើយស្ទាបយ៉ាងធំហាក់ដូចជាចង់ខាបចង្កៀងដែលនៅពីមុខគេនេះចូលទៅក្នុងមាត់របស់គេ ។ គេកំរើកខ្លួនហើយថា :

- តោះទៅអើង ! តោះទៅអើង !

រួចហើយយកខ្លួនរបស់គេទៅត្រដុសនឹងខ្លួនរបស់ស្ត្រី

- ងងុយគេងហើយឬ? មកទៅគេងអញ្ចឹង !

ថាហើយស្ត្រីក៏ប្ដូរជើងនាងដែលបត់ ហើយគន់មើលជុំវិញខ្លួនហាក់ដូចជាមនុស្សដែលទើបតែក្រោកពីដំណេកមីងមាំង។ ខាងក្រៅភ្លឺដូចជាពេលថ្ងៃ ។

រស្មីព្រះច័ន្ទឆ្លុះមកលើកន្ទេលតាតាមី សន្សឹម១ដោយស្ងៀមស្ងាត់ ។ ឯផ្កាកញ្ចុំក៏មើលទៅឃើញពណ៌ខៀវ ។

- ព្រះតេជព្រះគុណសឹងឬទាន?

- ពរអាត្មាសូមអភ័យទោសដោយធ្វើអោយញៀមពិបាកដោយសារ។

- ព្រះករុណាឥឡូវខ្ញុំព្រះករុណាក្រាលពូកប្រគេន។ សូមព្រះតេជព្រះគុណសឹងអោយបានសប្បាយទូលាយចិត្តនៅទីនេះតែមួយព្រះអង្គឯងចុះ ។ ខ្ញុំព្រះករុណាទាំងពីរចូលទៅសំរាកនៅក្នុងបន្ទប់ដាក់ឥវ៉ាន់។ សូមចាំមួយភ្លែតសិនទាន។

ថាហើយនាងក៏ក្រោកក្រេស ដើរញាប់១សំដៅទៅទ្វារ ។ ដោយដំណើរនោះវាលឿនពេក ភ្លួងសក់របស់នាងក៏របូតធ្លាក់មកលើកញ្ចឹងករបស់នាង។ ស្ត្រីទប់ជើងសក់របស់នាងរួចមើលទៅក្រៅហើយនិយាយតែម្នាក់ឯងថា :

- ហ៊ី ប្រហែលជារវល់តែរញ៉េរញ៉ៃ អំបាញ់មិញនេះហើយបានជាធ្លាក់ដង្កៀបសក់ទៅណាបាត់ ។

គឺវេលាដែលនាងត្បុលទៅក្រោមសេះនោះហើយ ដែលនាងបាត់ដង្កៀប។

# ជំពូកទី ២៣

ពេលនោះគេឮសូរស្នូរជើងមនុស្សដើរនៅថៃវខាងក្រោម ។ មាននរណាគេដើរលបៗដោយជំហានធំៗវែងៗ។ ប៉ុន្តែដោយទីនោះស្ងប់ស្ងាត់ សំលេងនោះក៏លាន់ឮយ៉ាងច្បាស់។ ប្រហែលជានរណាម្នាក់ចេញទៅបត់ជើងតូច ។ សំលេងទ្វារដែកដែលនៅពីក្រោយទ្វារធម្មតា បើកឮសូរក្រាក រួចហើយគេឮសំលេងផ្ដិលដែលគេដាក់ទៅលើមាត់ផើងទឹកវិញ ។

- ហ្អ៎ ព្រឹលធ្លាក់កាន់តែក្រាស់ទៅៗហើយតើ ។

- អ្នកដែលនិយាយនោះ គឺម្ចាស់ផ្ទះប្រុសនៃគេហដ្ឋាន " កាតូរីយ៉ា "

- អូនិយាយឥចឹង អ្នកជំនួយជាមិត្តរបស់អ្នកឯង ដែលមកពី " វ៉ាកាសា" ដែរនោះ ប្រហែលជាគេទៅសំណាក់ឯណាផ្សេង ហើយមើលទៅ ។ ហើយថ្មើរនេះ គេប្រហែលជាកំពុងតែយល់សុបិន្តល្អចំឡែកផងក៏មិនដឹង ។

- ព្រះតេជព្រះគុណសូមមានសង្ឃដីកាបន្តទៅទាន ។

ដោយខ្ញុំកំពុងតែជក់រឿង ហើយឮព្រះសង្ឃលោកបែរជាទៅមានសង្ឃដីការឿងផ្សេង ក៏បង្ខំលោកអោយ មានសង្ឃដីកាបន្ត :

- ឱយប់កាន់តែជ្រៅណាស់ហើយតើ !

ព្រះសង្ឃធម្មយាត្រា ក៏ចាប់ផ្ដើមមានសង្ឃដីកាបន្តរឿងទៅទៀតៈ

- អ្នកឯងច្បាស់ជាអាចស្មានបានហើយ ថាទោះជាអស់កំលាំងយ៉ាងណាក៏ដោយក៏អាត្មាពុំអាចសឹងលក់ភ្លាមៗ នៅផ្ទះមួយដាច់តែឯងក្នុងព្រៃជ្រៅបែប

នោះទេ។ ភ្នែកអាត្មាបើកក្រឡង់ៗ ជាដំបូងដោយអស់កំលាំងពេកភ្នែកចង់រលីវៗ បន្តិចដែរ។ អាត្មាចេះតែបន់អោយភ្លឺឆាប់។ ដំបូងបន់អោយជួងដែលគេរៃប្រាប់ពីពេលវេលាឆាប់លាន់ឡើង ។ តើអង្កាល់ទៅទើបវាលាន់? ឬមួយក៏វាលាន់រួចទៅហើយ? ពេលវេលាហាក់ដូចជាបានកន្លងទៅយ៉ាងច្រើនសន្ធឹកសន្ធាប់ហើយ។ រួចមកអាត្មាក៏ហាក់ដូចជាវិលត្រលប់វទៅរកការពិត គឺដឹងថាទីនេះពុំមែនជាវត្តទេ ហើយក៏ហាក់ដូចជាកាន់តែភ័យទៅ ។

វេលានោះ បើប្រៀបធៀបយប់នោះទៅអ្វីបាន អាត្មាច្បាស់ជាថាទៅនឹងបាតជ្រោះហើយ ។ ហើយនៅវេលាដែលអាត្មាលែងឮដង្ហើមធំ ដ៏គ្មានរបៀបរបស់យុវជនមិនគ្រប់ទឹកទៅអាត្មាក៏ទទួលអារម្មណ៍ថា នៅខាងក្រៅមាននរណាគេ ។

សំលេងនោះប្រៀបដូចជាសំលេងសត្វ ដែលដើរពីកន្លែងដែលនៅមិនឆ្ងាយប៉ុន្មានទេ។ អាត្មាគិតថាប្រហែលជាចេញពីកន្លែង ដែលស្វា និង គីង្គក់នៅ។ ក៏ប៉ុន្តែហេតុអ្វី បានជាអាត្មាគិតឃើញបែបនេះ?

ប្រហែលជាមួយសន្ទុះមកទៀត អាត្មាក៏បានឮសម្លេងសត្វអ្វីមួយចំពីទ្វារ គឺសម្លេងពពែ ។

អាត្មាបានដាក់ក្បាលអោយបែរទៅទិសនោះ ហើយសម្លេងនោះវាឮចំពីលើក្បាលអាត្មាពីខាងក្រៅទ្វារមក ។ បន្ទាប់មកពីខាងស្តាំដៃអាត្មា ពោលគឺពីកន្លែងដែលមានផ្កាកញ្ចុំ ប្រហែលជានៅពីក្រោមផ្កានោះ អាត្មាបានឮសូរសម្លេង

សត្វស្លាបទទះស្លាប ។ ប្រហែលជាសម្លេង សត្វម្យ៉ាងដូចកំប្រុក ដែលចេះហោះ ហើរមើលទៅ ។ អាត្មាឮវាហោះកាត់ដំបូលផ្ទះ គាក់ គាក់ ហើយខ្លួនវាមាន ទំហំមានតាមតែអារម្មណ៍ដែលអាត្មាទទួល គឺប្រហែលជាប៉ុនកូនភ្នំ។ សម្លេង នោះ បានសង្កត់ដើមទ្រូងអាត្មាយ៉ាងធ្ងន់ ហើយចេះតែខិតជិតមកៗ បន្ទាប់មកឮសំលេងគោរោទិ៍ ហើយពីចំងាយឯនោះ គេឮដូចជាសត្វអ៊ីរត់ដូចជា សត្វជើងពីរដែលពាក់ស្បែកជើងសំប្រែកធ្វើពីចំបើង។

ឱមិនដឹងជាស្អីខ្លះទេ នៅជុំវិញផ្ទះនោះ ។ ហាក់ដូចជាឮស្នូរដង្ហើម សត្វ មានជីវិត ២០ ឬ ៣០ សម្លេងដកដង្ហើមតាមច្រមុះ សម្លេងទទះស្លាបនៅក្នុង ចំណោមនោះមានឮទាំងសំលេង និង ខ្សឹបខ្សៀវគ្នាទៅទៀតផង ។ វាហាក់ដូច ជារូបភាពនៃឋាននរកអវិចី នៃស្រមោលដ៏គួរអោយសង្ស័យរបស់សត្វតិរច្ឆាន នៅក្នុងរាត្រីនៃពន្លឺចាំងពីជញ្ជាំងខ័ណ្ឌ ដូចជាសំលេងបិសាចដែលនៅលើទឹក ឬក៏ បិសាចដែលនៅក្នុងទឹក គេឮសំលេងស្លឹកឈើលាន់រ៉ាវៗ។

អាត្មាខំអត់ដង្ហើម ។ វេលានោះអាត្មាក៏ឮស្នូរសំលេងចេញពីបន្ទប់ដាក់ ឥវ៉ាន់មក :

- អ៊ឹស

ដូចជាសំលេងបង្ហួសដង្ហើម ឬជាសំលេងថ្ងូររបស់ស្ត្រី

- យប់នេះមានភ្ញៀវ ស្ត្រីស្រែក ។
- ឮយប់នេះមានភ្ញៀវទេ?

មួយស្របក់ក្រោយមកទៀត គេឮសូរសំលេងប្រែខ្លួន រួចហើយសំលេងប្រែខ្លួនម្តងទៀត ។

នៅខាងក្រៅផ្ទះ គេឮសូរសំលេងខ្សៀវខ្វារ ហើយបន្ទាប់ពីនោះមកផ្ទះក៏ចាប់យោលយោក ។

អាត្មាបានចាប់ផ្តើមសូត្រធម៌ កំចាត់សត្រូវ និង ខ្មោចអសុរកាយ ។

អាត្មាបានខំសូត្រធម៌យ៉ាងខ្ជាប់ខ្ជួន ។ ខ្យល់ដែលបក់ស្លឹកឈើបានបក់បង្ហួសទៅត្បូងបាត់ ។ អ្វីៗក៏ឡើងស្ងប់ស្ងាត់ ហើយបុរសស្រ្តីទាំងពីររូប ក៏ដេកលង់លក់យ៉ាងក្សេមក្សាន្តហើយ ។

# ជំពូកទី ២៤

នៅថ្ងៃបន្ទាប់ ប្រហែលជានៅពេលថ្ងៃត្រង់ នៅជិតភូមិអ្នកស្រុក កន្លែងទីដែលមានទឹកជ្រោះធ្លាក់ អាត្មាបានជួបនឹងតាចាស់ដែលយកសេះទៅលក់ពីម្សិល។ គាត់បានត្រលប់មកពីផ្សារលក់សេះ ។ ពេលនោះ គឺចំពេលដែលអាត្មាកំពុងតែគិតថា តើអាត្មាគួរតែឈប់ធ្វើធម្មយាត្រា ដើម្បីកសាងខ្លួនអោយទៅជាសង្ឃ ហើយត្រឡប់ទៅផ្ទះដែលស្ត្រីនៅដើម្បីរួមរស់ជាមួយនាងមួយជីវិត ។

និយាយអោយពិតទៅ នៅវេលាដើរតាមផ្លូវមកក្តី អាត្មាបានគិតតែពីរឿងនេះ ។ សំណាងល្អអាត្មាពុំបានជួបពស់ ឬ ស្ពាន ឬ ឈ្លើង ឬ ព្រៃឈើអីធំដុំឡើយ ។ តែទោះជាផ្លូវពិបាក ហួរហៀវញើសនាំអោយលំបាកវេទនា ក៏អាត្មាលែងគិតថា ធម្មយាត្រាដែលជាផ្លូវសំរាប់នាំអាត្មាអោយធ្វើដំណើរទៅកាន់ភាវៈជាសង្ឃពេញលក្ខណៈមួយរូបលែងមានន័យ ចំពោះអាត្មាតទៅទៀតហើយ ។ អោយអាត្មាស្លៀកស្បង់ចីពរទៅរស់នៅក្នុងព្រះវិហារដ៏ធំ ក៏លែងមានន័យទៀតដែរ ។ វេលាដែលមនុស្សម្នាទាំងឡាយ នាំគ្នាបញ្ចើចបញ្ចើអាត្មាថាជា "ព្រះរស់" ក៏វាជាពាក្យដែលគ្មានកំលាំងសំរាប់ធ្វើអោយអាត្មារីករាយចិត្តបានដែរ ។

អំបាញ់មិញអាត្មាពុំបាននិយាយប្រាប់អ្នកឯងទេ វេលាយប់នៅពេលដែលស្ត្រីបានផ្តេកយុវជនមិនគ្រប់ទឹក អោយដេកលក់ ហើយនាងក៏ចេញទៅជើងក្រានហើយនិយាយនឹងអាត្មាថា ជាជាងទៅទទួលការវេទនាគ្រប់យ៉ាងពីពិភពខាងក្រៅ

សូមអោយអាត្មានេះនៅជិតនាង នៅទីដែលត្រជាក់នាវដូវក្តៅ ហើយកក់ក្តៅនៅរដូវរងា ត្រាំទឹកស្ទឹងជាមួយនាង ។ អាត្មាបានដឹងថាខ្លួនឯងឯងនេះ បានធ្លាក់ទៅក្នុងទឹកន្លែងមួយនៅពេលវេលាដែលពុំបានគ្រោងទុក ។ អាត្មាបាននិយាយរកលេសមកការពារខ្លួនឯងថា អាត្មាអាណិតស្ត្រី ដែលរស់នៅក្នុងព្រៃភ្នំដ៏ជ្រៅក្នុងផ្ទះមួយដាច់តែឯង ជាមួយនឹងមនុស្សមិនគ្រប់ទឹកដែលនិយាយមិនត្រូវគ្នានិយាយស្តាប់គ្នាមិនបាន ហើយលំដាប់ដែលថ្ងៃខែកន្លងទៅ នាងកាន់តែភ្លេចរហូតដល់ទៅភាសានិយាយស្តីរបស់មនុស្សទៅទៀត ។ គួរអោយអនិច្ចាណាស់ ។

ជាពិសេសព្រឹកមិញ នៅពេលដែលអាត្មាលើកដៃគ្រវីសឹងតែអស់ដៃលានាង នាងបាននិយាយថា នាងស្តាយណាស់ ដោយយើងត្រូវបែកគ្នា ។ រូបនាងនឹងនៅបែបនេះរហូតដល់ចាស់ស្លាប់ បែកលើកនេះ ពុំដឹងជាវេលាណាទើបបានជួបវិញទេ ។ រួចមកនាងនិយាយទាំងស្រងេះស្រងោចថា :

- វេលាដែលព្រះតេជព្រះគុណបានឃើញស្ទឹងបែបនេះនៅទីណាមួយ ហើយបានឃើញផ្កា ម៉ូម៉ូ ដែលមានពណ៌ស អណ្តែតទឹកសូមគិតថានោះជារូបខ្ញុំព្រះករុណាដែលលិចស្រិមទៅក្នុងទឹក ហើយរសាត់ជាបំណែកតូចៗ ។

រួចហើយនាងក៏បានពន្យល់អាត្មាដោយក្តីស្មោះស្ម័គ្រថា ផ្លូវមានតែមួយនេះទេ នាងអោយអាត្មាដើរសៀវតាមមាត់ស្ទឹងនេះរហូតទៅមុខទៅ នឹងបានឃើញភូមិអ្នកស្រុកហើយ ។ ហើយនៅវេលាដែលដើរទៅប្រទះនឹងទីមួយដែលទឹករាំ ហើយមានជ្រោះជ្រៅធ្លាក់មក ទីនោះនឹងមានផ្ទះអ្នកស្រុក ហើយពុំមាន

ការចាំបាច់នឹងភ័យបារម្ភទៀតទេ ។ នាងបានផ្តាំអោយអាត្មាប្រយ័ត្នខ្លួន ព្រមទាំងបានដើរជូនផ្លូវអាត្មារហូតដល់ទីដែលយើងមើលផ្ទះនាងលែងឃើញ ។

ទោះបីជាយើងទាំងពីរពុំបានកាន់ដៃគ្នា ក៏ពិតមែន ហើយប៉ុន្តែនាងបាននៅជិតអាត្មាព្រឹកល្ងាច យើងបាននិយាយគ្នា នាងបានបំរើអាត្មា បានដាក់សម្លផ្សិតអោយអាត្មាឆាន់ អាត្មាបានជួយបង្កាត់ភ្លើងនាង នាងបានលើកឆ្នាំងដាក់លើជើងក្រាន ។ អាត្មាបានដើររើសផ្លែឈើ នាងបានបកសំបក យើងបាននិយាយគ្នាកាត់តាមទ្វារក្រដាស យើងបានសើចជាមួយគ្នា រួចមកយើងបានចូលងូតទឹកក្នុងស៊ីង នាងស្រាត ដង្ហើមនាងឆ្លងកាត់តាមខ្នងរបស់អាត្មា ទម្លុះខ្នងរបស់អាត្មា អាត្មាបានទទួលអារម្មណ៍ហាក់ដូចជាកំពុងតែត្រូវ ឱបក្រសោបដោយត្របកផ្កាដែលពោរពេញទៅដោយក្លិនដ៏ក្រអូប ឈ្ងុយឈ្ងប់ ព្រមទាំងបានគិតថាទោះជាស្លាប់ទាំងឥឡូវក៏អាត្មាមិនស្តាយដែរ ។

វេលាដែលអាត្មាមើលទឹកជ្រោះ អាត្មាបានរំលឹកឃើញរឿងនេះ ហើយអាត្មាពុំអាចទ្រាំទ្របានទេ អាត្មានឹកនាង ខ្លួនអាត្មាឡើងត្រជាក់ស្រេប ។

ទឹកចិត្តរបស់អាត្មាក្លាយទៅជាល្ហល្ហេវ គ្មានកោះត្រើយសរសៃសរសូងទាំងឡាយហាក់ដូចជាឡើងយារស្តោកអស់ ពុំមានកំលាំងនឹងដើរ ។ វេលាដែលបាន ឃើញផ្ទះអ្នកស្រុកចិត្តគួរតែឡើងសប្បាយតែផ្ទុយទៅវិញ ចិត្តអាត្មាទៅជាធុញថប់ ព្រោះនឹកថានៅពេលដែលចូលទៅផ្ទះឯណាមួយ ច្បាស់ជាមានជូនចាស់មាត់ស្អុយប៉ែរ ចេញមកដាក់តែដំចត់អោយអាត្មាពុំលែងឡើយ ។

នៅពេលដែលគិតបែបនេះហើយ អាត្មាក៏ដាក់គូថ អង្គុយប៉ុកទៅលើផ្ទាំងថ្ម។ នៅពីក្រោមនោះទឹកជ្រោះហូរ ។ អាត្មាបានដឹងនៅពេលក្រោយមកទៀតថាទឹកជ្រោះនោះឈ្មោះ ជ្រោះប្រុសជ្រោះស្រី ។

នៅចំកណ្ដាលនោះគេឃើញមានផ្ទាំងថ្មស្រួចមួយខ្មៅអែ ប្រៀបបាននឹងមាត់ក្រពើ ដែលបើកជង្រ្គាំង១លេចធ្លោចេញមក ហើយនៅពេលដែលទឹកជ្រលង និង ស្ទឹងហូរលឿនមកប៉ះជ្រុងទាំងពីរ បែកទៅជាដៃបូន ហើយធ្លាក់ក្លួង១មកលើជញ្ជាំងនៃអន្ទការ ហាក់ដូចជាគេបាញ់ព្រួញសំដៅទៅរកក្រណាត់សមួយផ្ទាំង ទៅឯភូមិអ្នកស្រុក ហើយទឹកដែលហូរលឿនស្មោ នោះមានទទឹងប្រហែលជា ១៨ម៉ែត្រ ហើយន្លួតទឹកនេះមិនបានធ្វើអោយទទឹងនៃស្ទឹងទៅជាចំណែក១ឥតសណ្ដាប់ធ្នាប់ទេ ។ មួយទៀតមានធ្មេញឈើចង្អៀតប្រហែលពាក់កណ្ដាលជ្រោះមុន ហើយនៅពីក្រោមផ្ទាំងថ្មដ៏រកេតរកូតដែលសឹងតែថា អាចចិញ្ច្រាំវាំងននដែលធ្វើពីអង្កាំអោយបែកបំណែកល្អិត១ រួចនាំទៅត្រដុសនឹងថ្មដែលមានរាងដូចមាត់ក្រពើនោះ ។

## ជំពូកទី ២៥

រូបរាងនៃសរសៃទឹកដែលហូរកាត់ផ្ទាំងថ្មហើយជ្រុះទៅក្រោម ហាក់ដូចជាធ្លាក់ទៅឱបជើងជ្រោះប្រុស ។ ទោះជាយ៉ាងនេះក្តីទឹកដែលធ្លាក់មកដល់ក្រោមប៉ះថ្ម ហើយសាចនោះវាច្រចាច់ វាញាប់ញ័រហាក់ដូចជាគេកំពុងតែលួងលោមបបោសអង្អែលសេចក្តីទុក្ខ ។ ជ្រោះខាងនេះ ហាក់បង្ហាញនូវរូបកាយដ៏ស្គមល្ងតល្ងៃ ហើយសំលេងសោតទៀត ក៏ខុសពីជ្រោះប្រុស ហាក់ដូចជាកំពុងតែទួញសោក ឬ ឡកលេង ហើយមានចិត្តរាបសា ស្លូត និង មេត្តាធមិគួរអោយអាណិតគឺជ្រោះស្រីនេះឯង ។

ផ្ទុយពីនេះ ជ្រោះប្រុសមានស្រមោល និង រូបរាងដូចជាស្ទុះទៅបុកទំលុះសិលា ទំលាយផ្ទៃដីប្រកបដោយកំលាំងខ្លាំងក្លា ។ ទឹកជ្រោះធ្លាក់ទៅលើផ្ទាំងសិលាពីរ បែកចេញជាឆ្វេងជាស្តាំ ហាក់ដូចជាសរសៃពីរ ធ្លាក់មកលើរូបរាងកាយ ហើយជ្រាបរមួតទៅក្នុងជ្រោះស្រី ដែលនាំអោយបេះដូងខ្ទេចខ្ទាំដូចជាស្ត្រីរូបស្អាតដែលកំពុងតែឱបជើងបុរសយំកន្ទក់កន្ទេញ ។ វេលាដែលអង្គុយនៅលើផ្ទាំងសិលាក្តី ខ្លួនអាត្មាញ័រ សាច់ឈាមសរសៃសងខាងញាក់កន្ត្រាក់ ហើយសមនឹងបាននៅលើទឹកបែបនេះទៀត ក៏នាំអោយរីតតែនឹកដល់វេលាម្សិលមិញដែរអាត្មានៅផ្ទះស្ត្រី ហើយបានចុះងូតទឹកជាមួយនាង ។ វេលានឹកដល់រឿងនេះ ភ្នែកអាត្មាក៏ស្រាប់តែមើលទៅឃើញថា នៅក្នុងជ្រោះស្រី រូបរាងស្រមោលរបស់ស្ត្រីនោះចេញឡើងជារូបភាពច្បាស់ រួចហើយក៏ត្រូវអ្វីស្រូបចូល

ទៅក្នុងបាត់ទៅ ហើយនៅវេលាដែលអារម្មណ៍គិតថា រូបនោះលិចបាត់ស្រមោល ហើយក៏ស្រាប់តែលេចធ្លោមកវិញ ។ រូបកាយនោះបានត្រូវសរសៃទឹករាប់ពាន់ បុកកំទេចអោយសុសទៅជាស្រទាប់ផ្កាដែលរុះរោយ ហើយជ្រុះរោភ១ចុះមក ។

នៅពេលដែលព្រលឹងអាត្មា កំពុងតែស្ដាយរូបស្ត្រីដែលរលុបបាត់នោះ ស្រាប់តែរូបនោះក្លាយទៅជាមុខពីមុន ជាដើមទ្រូង សុដន់ ដៃជើង គឺរូបរបស់ នាងទាំងមូលដែល លិចហើយងើប លិចហើយងើប រួចហើយត្រូវបានចញ្ច្រាំ អោយទៅជាកំទេច រួចហើយក៏ស្រាប់តែចេញមកដដែលជាថ្មីទៀត ។ អាត្មា ទ្រាំតទៅទៀតលែងបាន រហូតដល់គិតថាត្រូវតែលោតទៅក្នុងជ្រោះ ដើម្បីឱប នាងបីនាងត្រកងនាងជ្រោះស្រី ។

វេលាដែលអាត្មាត្រលប់មករកសភាពធម្មតាវិញ ជ្រោះប្រុសឯនោះកំពុង តែបោកបក់ទៅលើផែនពសុធា ស្រែកហៅសម្លេងខ្ទរពីភ្នំវិញ ហូរបណ្ដើរលាន់ ខ្ទរបណ្ដើរ ។

ឱកំលាំងដ៏ខ្លាំងក្លាអើយ ហេតុអ្វីក៏មិនអាចជួយបាន?

ព្រះជាម្ចាស់អើយ ហេតុអ្វីបានជាអ្វី១ប្រព្រឹត្តទៅផ្ទុយពីចិត្តរបស់អាត្មា ភាពបែបនេះ?

បើបានជាគិតថាត្រូវលោតសំលាប់ខ្លួនក្នុងជ្រោះនេះ អាត្មាត្រូវតែត្រឡប់ ទៅផ្ទះស្ត្រីវិញ ។ ដោយសារតែខ្លួនមានកិលេសដ៏ក្រខ្វក់បែបនេះ បានជាវាទៅ ជាអញ្ចឹង ។ ដូច្នេះគ្មានហេតុផលអ្វីនឹងរួញរាទៀតឡើយ ។ ទៅជួបគេ វេលា

ឃើញមុខគេ ស្តាប់សំលេងគេ អាត្មាច្បាស់ជាអាចសឹងក្បែរទាំងពីរបានគ្មានបញ្ហាទេ គ្រាន់បើជាដើរធ្វើធម្មយាត្រា បង្ហូរញើសរហាមរៀនធម៌បណ្តើរបែបនេះ ហើយនឹងនៅជាសង្ឃរហូតមួយជីវិត ។

វេលានោះស្រាប់តែមាននរណាម្នាក់គេមកគោះខ្នង អាត្មាប៉ុង

- សួស្តីកូនលោក !

លុះតែឮគេហៅបែបនេះ ចំពេលយ៉ាងហ្នឹង និង ទឹកចិត្តដែលកំពុងតែងងឹតបែបនេះ អាត្មាក៏ភ្ញាក់ព្រើត មើលទៅក្រោយគិតស្មានថាប្រហែលជាបំរើរបស់យមរាជហើយ ។ ក៏ប៉ុន្តែពុំដូច្នោះទេ នោះគឺតាចាស់ដឹកសេះ ។ គាត់ទំនងជាលក់សេះដាច់ហើយចូរខ្លួនច្រើន ។ គាត់ស្ពាយស្បោងមួយនៅស្មា ហើយដៃគាត់កាន់ត្រីរស់មួយធំវែងជិតមួយម៉ែត្រ ដែលចងខ្សែពីកតាមមាត់មានស្រកាពណ៌ផ្លេក១ ដូចមាស កំរើកកន្ទុយខ្ញើក១ អោយដឹងថាជាត្រីដែលស្រស់ថ្មី១ ។

ដោយអាត្មានៅស្ងៀមឥតស្រដីអ្វី ហើយតាចាស់ក៏អត់មាននិយាយអ្វីទៀតមកកាន់អាត្មា អាត្មាក៏នៅឈរទ្រឹង។ តាចាស់មើលមុខអាត្មាមិនដាក់ភ្នែក ហើយសើចវ៉ាស១។ គឺជាសំណើចដ៏គួរអោយខ្លាចដែលមិនធម្មតា ។

- ធ្វើស្អីហ្នឹងកូនលោក ? ក្រែងខ្លួនយើងជាអ្នកកំពុងសិក្សាធម៌អាថិខំប្រឹងធ្វើធម្មយាត្រា អប់រំចិត្ត អប់រំខ្លួនឬ? គ្រាន់តែក្តៅប៉ុន១ហ្នឹង ឈប់សំចតត្រែតត្រតលើផ្តាំងថ្មទៅហើយ តើអាចគិតធម៌អាថិ ឬធ្វើអ្វីធំដុំបានឬ? ទៅល្មមចេញដំណើរហ្វឹកហ្វឺនចិត្តនឹងកាយបន្តទៅមុខទៀតហើយ នៅដំអក់បែបនេះម៉េច

នឹងបាន? ពីកន្លែងម្សិលមិញមកដល់ទីនេះ មានចំងាយតែ ៩យោជន៍ នៅឡើយទេ ទៅប្រញាប់ដើរទៅភូមិអោយទាន់ពេល ថ្វាយបង្គំព្រះទៅ ។

ហ្អា ! ហ្អា ! អ្នកនេះកំពុងតែគិតពីអ្នកស្រីម្ចាស់ហើយតើ? មិនបាច់លាក់ទេ ទោះជាភ្នែកតាក្រហមប៉ែរបែបនេះក៏តាអាចដឹងខ្មៅ ស បានទៅហើយដែរ ។

អោយដឹងទៅកូនលោក ! អ្នកដែលបានប៉ះពាល់ដៃអ្នកស្រីម្ចាស់ហើយបានងូតទឹកស្ទឹងនោះ មិនអាចនៅមានរូបរាងជាមនុស្សដូចដើមទេ ។ ច្បាស់ជារូបរាងនោះ នឹងក្លាយទៅជាគោ ឬ សេះ ឬស្វា ឬ គីង្គក់ ឬជ្រើង លោតផ្លោះហោះហើរពេញទឹកពេញដីឥឡូវហ្នឹងហើយ ។

ពេលឃើញកូនលោកឯង ចេញពីទឹកមកវិញ ហើយមានរូបរាងជាមនុស្សដដែល តាសឹងតែលោះព្រលឹងអីឯនោះ នេះដោយសារតែកូនលោកឯងដែលក្មេងខ្ចីឥចឹងមែនតែមានការតាំងចិត្តមុតមាំ គួរអោយសរសើរនេះឯងតែម្តង ទើបបានជារស់រានមានជីវិត ។

តេជគុណបានឃើញសេះដែលតាដឹកទៅលក់ហើយមែនទេ? នោះហើយ អ្នកលក់ថ្នាំដែលមកពី "តូយ៉ាម៉ា" ហើយដែលជួបកូនលោកឯងតាមផ្លូវនោះ ។ អាប្រុសដ៏ជ្រួលជ្រើមកំហូចនោះវាបានក្លាយទៅជាសេះ ហើយតាបានលក់វាប្តូរជាលុយហើយជាមួយនឹងលុយនោះតាទិញបានត្រីរស់នេះ ហ្អេ! អ្នកស្រីម្ចាស់ចូលចិត្តត្រីរស់ណាស់ ។ យប់នេះនាងនឹងពិសាវាជាម្ហូបហើយ ។

នៃកូនលោក តើគេជគុណតិចថាអ្នកស្រីម្ចាស់ជាមនុស្សយ៉ាងម៉េចហ្នឹង ? គា សួរដូចជាឆោតទៅចុះ ។

ដោយសាររឿងនោះវាទៅជាបែបនេះ ខ្ញុំជាអ្នកស្តាប់ក៏លាន់មាត់កាត់សង្ឃដីកាព្រះសង្ឃ ។

- ព្រះតេជព្រះគុណ !

## ជំពូកទី ២៦

ព្រះសង្ឃបានងក់ព្រះកេសហើយ មានសង្ឃដីកាតិចៗថា :

- ស្តាប់អាត្មានិយាយសិន ស្ត្រីដែលនៅផ្ទះមួយខ្ទងនោះហាក់ដូចជាមាននិស្ស័យអ្វីនឹងអាត្មាទេ ។ នៅផ្លូវបំបែកដែលចូលទៅរកទីកន្លែងដ៏គួរអោយខ្លាចនោះមានថ្មកទីក ដក់ព្រៀបហើយកសិករបានប្រាប់អាត្មាថាទីនោះពីមុនជាផ្ទះរបស់គ្រូពេទ្យ ។ ស្ត្រីនោះគឺជាបុត្រីរបស់គ្រូពេទ្យនោះណា៎ !

ទីកន្លែងនោះពីមុនមិនមែនជាទីកន្លែងចំឡែក ឬក៏ជាកន្លែងល្បីឈ្មោះរបស់ ស្រុក "ហ៊ីដា" ទេ ។ ប៉ុន្តែតាំងពីបុត្រីដែលមានរូបស្អាតដូចគុជបែបនេះបានមក កើតនឹងបិតាមាតាដ៏ផ្តេសផ្តាសនោះមក ក៏ទៅជាកន្លែងចំឡែកហើយល្បីល្បាញតែម្តង ។

មាតាអ្នកស្រីម្ចាស់ មុខប៉ោង ភ្នែក ធ្លាក់ ច្រមុះទាលដោះនោះយារស្តោក ។ គេឆ្ងល់គ្រប់គ្នាថាហេតុអ្វីបានជាទារកដែលបៅទឹកដោះពុលនោះ ទៅជានារីដ៏មាន រូបល្អចំឡែករកអ្វីមកប្រៀបប្រដូចក៏មិនបានបែបនោះ ?

គេធ្លាប់និទានក្នុងរឿងព្រេងបុរាណ ពីមានព្រះឥន្ទដែលជ្រើសរើសទេវបុត្រ ឬ ទេពអប្សរល្អអោយចុះចាប់បដិសន្ធិ ឬក៏ក្រុមអ្នកប្រមាញ់ដែលរកឃើញនារីដ៏ល្អ ហើយនាំទៅព្រះរាជធានីព្រះបរមរាជវាំង អោយនាងនោះទៅជាក្សត្រីយ៍ជាដើម ។

មនុស្សម្នាទាំងឡាយបាននាំគ្នានិយាយបែបនេះពីមាត់មួយទៅមាត់មួយ ។

ឪពុករបស់អ្នកស្រីម្នាស់ជាមនុស្សមុខឆ្អឹង ដុះពុកមាត់មានអំណ្ហេតព្រមទាំងឫកពារធំណាស់ ។ តែទោះជាបែបនេះក្ដីនៅរដូវច្រូតកាត់នៅពេលដែលស្រូវចូលភ្អែក ហើយបណ្ដាលអោយទៅជាជម្ងឺភ្អែក ឡើងភ្អែកក្រហមភ្អែកពពីកភ្អែកស្រលៀងក្ដី គ្រូពេទ្យតែងពិនិត្យអោយខ្លះៗដែរ។ បើនិយាយពីរឿងពិនិត្យជម្ងឺទូទៅវិញស្រេចតែម្ដងហើយ គឺជាពេទ្យដាច់ថៃតែម្ដង ។ ហើយបើរឿងវះកាត់វិញគ្មានថ្នាំសណ្ដំថ្នាំសន្លប់ខ្មោចសេះអីទេ គ្រាន់តែអោយយកទឹកទៅបន្តក់ផ្សើមជើងសក់អោយត្រជាក់ៗប៉ុណ្ណោះ ។ នៅតំបន់ចុងកាត់មាត់ញកដែលអ្នកស្រុកគូសធ្យូងធ្វើមុខយក្ស ចងក្បាលត្រីពីមុខផ្ទះកំញើញខ្មោច អារក្សហើយគ្មានគ្រូពេទ្យវិទ្យាសាស្ត្របែបនេះ បានតែប៉ុនៗហ្នឹងក៏អ្នកស្រុកគ្នាអរហើយចុះឡើងជ្រូកជ្រាក់មិនដាច់ ។

ជាពិសេសនៅវេលាដែលអ្នកនាងជាបុត្រីបានអាយុ ១៦-១៧ គឺវេលាដែលនាងពេលល្អនៅក្នុងចំណោមបុរសស្ត្រីដែលល្ងង់ខ្លៅ គេនាំគ្នាជឿថានាងជាទេពធិតាដែលព្រះជាម្ចាស់ខាងជម្ងឺបញ្ជូនមកលោកយើងនេះ អោយមកជួយ

ព្យាបាលជម្ងឺប្រជាជននៅផ្ទះគ្រូពេទ្យ ហើយពាក្យចចាមអារាមនោះបានរាលដាលទៅគ្រប់ទិសទី ផ្អើលមនុស្សម្នា ជ្រួលច្រាលមកផ្ទះគ្រូពេទ្យដើម្បីអោយព្យាបាលជម្ងឺរបស់ខ្លួន។

រឿងនេះដំបូងវាអញ្ចេះ អ្នកនាងជាបុត្រីគ្រូពេទ្យនៅពេលនាងជួបអ្នកជម្ងឺ ដែលនាងចាំមុខ នាងតែងញញឹមដាក់គេសួរគេថា តើអ្នកឈឺទេ? ដៃអ្នកយ៉ាងម៉េចហើយ? ហើយនាងតែងតែដាក់បាតដៃដ៏ទន់ល្មើយរបស់នាងទៅលើខ្នងដៃអ្នកជម្ងឺ ។

មានវេលាមួយមានបុរសក្មេងម្នាក់ បានជាសះស្បើយជម្ងឺសន្លាក់របស់គេ ហើយមានអ្នកខ្លះទៀត ដែលនាងគ្រាន់តែយកដៃទៅស្ទាបពោះហើយថា: ឱពុំដឹងជាឈឺយ៉ាងណាទេ ខ្លះទៀតនាងគ្រាន់តែស្ទាបអង្អែលទ្រូងត្រង់ចុងដង្ហើមក៏ជម្ងឺស្ទះទ្រូងបានជា ។ ដើមដំបូងសក្តិសិទ្ធិតែចំពោះប្រុសកម្លោះៗទេ ក្រោយមកមនុស្សចាស់ក៏ជា រួចក្រោយមកទៀតជាដល់ទៅជម្ងឺរបស់នារីៗទៅទៀត ទោះជាថាមិនជាសះស្បើយមួយរយភាគរយ ក៏បានធូរស្រាល ។

និយាយពីគ្រូពេទ្យជាឪពុកនាងវិញ គ្រាន់តែវះបូសខ្ទុរមួយអ្នកជម្ងឺឈឺជិតស្លាប់ឯណោះ មានអីបើគាត់លេងសុទ្ធតែអាកាំបិតច្រេះចាប់កាត់មិនដាច់វះមិនមុតយកទៅវះអ្នកជម្ងឺ យ៉ាងហ្នឹងទ្រាំអ្វីមិនអោយ អ្នកជម្ងឺស្រែកឈឺត្រឡប់ត្រឡិនដួលក្រោកដួលក្រោកម្ដេចនិងបាន ។ ទោះជាឥចឹងក៏ដោយ

បើអោយតែបានអ្នកនាងជាបុត្រីចូលមកហើយត្រកងអ្នកនោះពីខាងក្រោយ ព្រមទាំង ទប់ស្មារបស់អ្នកជម្ងឺភ្លាមអ្នកនោះនឹងអាចទ្រាំទ្រនឹងការឈឺចាប់បាន ។

ដល់ដឹងឥចឹង មានវេលាមួយនោះនោគុម្ពោតព្រៃត្រង់ដើមម៉ាក់ប្រាង មានឃ្មុំ មកធ្វើសំបុកធំនោះធំ ។ ពេលនោះសិស្សគ្រូពេទ្យដែលទទួលបន្ទុកខាងចាត់ចែង រកថ្នាំសង្កូវផងបោស ជូតផងធ្វើចំការអោយគ្រូពេទ្យផង ជីកដំឡូងក៏ជីក ធ្វើតែកុង ក៏ធ្វើឈ្មោះ "គូម៉ា" ដែលមានអាយុប្រហែលជា ២៤ ឬ ២៥ឆ្នាំ បានលួចថ្នាំស៊ី រ៉ូ និង ថ្នាំជូរ១ទៅលាយគ្នាទុកផឹកមួយចប១ ។

ដោយគ្រូពេទ្យជាមនុស្សគិរិះ បើគាត់ដឹងគាត់នឹងជេរស្តី "គូម៉ា" បានយកដប "ភេសជ្ជៈ" នោះក្នុងខោអាវរបស់គាត់ ហើយនៅពេលដែលគេបោសសំអាតផ្ទះ ហើយមើលទៅឃើញថា គ្មាននរណាចាប់ភ្លឹកគេក៏តាំងដកដបនោះយកមកអក ។ ទទួលជាកំពុងតែងើយ ក៏ឃើញឃ្មុំគេក៏ដើរសសៀរ១មកជិតរានហាលហើយនិយាយទៅកាន់អ្នកនាងក្រមុំថា :

- អ្នកស្រីម្ចាស់ ខ្ញុំបាទនឹងបង្ហាញអ្នកស្រីអោយឃើញឆាកដ៏ល្អមើលមួយទាន ។ សូមអ្នកស្រីម្ចាស់អភ័យទោសបើខ្ញុំបាទព្រហើន ហ៊ានសុំអោយអ្នកនាងកាន់ដៃខ្ញុំបាទ ។ បើបានអ្នកនាងកាន់ដៃ ខ្ញុំបាទនឹងប្រើដៃនោះដាល់សំបុកឃ្មុំនោះ លូកយកក្បាលទឹកឃ្មុំមកជូនមើល ។ ទោះជាឃ្មុំទិចក៏កន្លែងដែលអ្នកនាងកាន់ច្បាស់ជាមិនឈឺឡើយ ។ ពេលនោះខ្ញុំបាទនឹងយកអំបោសវ៉ាត់វ៉ាយវា

អោយវាហើរចេញ តែភ័យខ្លាចតែឃ្មុំវាមករោមរាងកាយខ្ញុំបាទទេ វេលានោះច្បាស់ជាស្លាប់ហើយទាន ។

ថាហើយ "គួមា" បានលូកដៃទៅអោយអ្នកស្រីម្ចាស់កាន់ដៃខ្លួនទាំងនាងមិនចង់ ហើយដើរស្ដេស្ដាទៅសំបុកឃ្មុំ ។ ទីនោះឃ្មុំយំរ៉ូៗ ង៉ូងៗ គួរអោយញញើត ។ ស្រាប់តែដៃឆ្វេងដែលគេលូកទៅយកឃ្មុំនោះ ដកចេញមកវិញដោយទាំងឃ្មុំ ៧-៨ខ្លះ ទទះស្លាបទិចៗ ខ្លះញ័រជើងតតាក់ ឃ្មុំខ្លះលូចរត់តាមច្រវ៉ែកដៃ ដែលចាប់វានោះទៅទៀត ។

អោយតែបានដៃទិព្វនោះ ប៉ះពាល់ហើយទោះជាគ្រាប់កាំភ្លើងក៏ត្រូវតែរអិលផ្លាតចេញចូលមកក្នុងសាច់មិនចុះដែរ ហើយពាក្យចចាមអារាមនោះចេញពីមាត់ មនុស្សម្នាក់ចេញទៅ ម្នាក់ទៀតទាំង ៨ទិស ដូចសំបុកពីងពាងដែលព័ទ្ធសំបុកវាទៅគ្រប់ទិសបែបនោះឯង ។ តាំងពីពេលនោះមក ហាក់ដូចជាមានកំលាំងទិព្វអ្វី តាំងពីអ្នកស្រីម្ចាស់បានទៅរស់នៅក្នុងផ្ទះមួយខ្ទងដាច់ស្រយាលពីភូមិអ្នកស្រុកជាមួយនឹង អ្នកកំលោះមិនគ្រប់ទឹកនោះបានប៉ុន្មានឆ្នាំ នាងក៏អាចធ្វើអ្វីៗបានតាមចិត្តនាងប្រាថ្នា ។ ដំបូងធ្វើអោយអ្នកដែលមានខ្លួនប្រាណដៃជើងគ្រប់គ្រាន់ នៅសល់តែជើង សល់តែចុងដៃ ហើយចុងបញ្ចប់នៅពេលដែលពេលវេលាបានកន្លងទៅ បន្តិចទៅអ្នកដំណើរវង្វេងផ្លូវទាំងឡាយ បានប្រែខ្លួនប្រែរូបកាយទៅជាសត្វឬជាអីៗ ដែលអ្នកស្រីម្ចាស់ចង់អោយក្លាយដោយគ្រាន់តែនាងផ្លុំដង្ហើមមួយរឺបមកលើប៉ុណ្ណោះ ។

តាចាស់បាននិយាយរឿងទាំងនោះប្រាប់ព្រះសង្ឃហើយ និយាយទៀតថា : នៅម្តុំក្បែរៗផ្ទះនោះព្រះសង្ឃបានឃើញស្វា គង្កក់ ជ្រឹង មែនទេ ? ទន្សាយក្តី ពស់ក្តី សុទ្ធសឹងតែជាមនុស្សដែលអ្នកស្រីម្ចាស់នាំទៅងូតទឹកស្ទឹងរួចហើយក៏បំប្លែងអោយទៅជារូបរាងសត្វ ។

នៅពេលដែលអាត្មាវំឭកឃើញឡើងវិញពីស្ត្រីដែលអាត្មាអាណិត ដែលត្រូវ គង្កក់ ខាំជញ្ជក់ ត្រូវស្វាឪបរិត ពីក្រោយត្រូវជ្រឹងបឺត ហើយនៅវេលាយប់មាន ខ្មោចទឹក ខ្មោចដីមកលលេង លងបន្លាច ទ្រូងរបស់អាត្មាឡើងចុកចាប់ពើត ។

ចំណែកឯមនុស្សមិនគ្រប់ទឹកនោះ គឺជាអតីតអ្នកជម្ងឺដែលឪពុក និងបងប្រុសអៀវយកទៅអោយឪពុកអ្នកស្រីម្ចាស់ ព្យាបាលជម្ងឺនៅពេលដែលគាត់កំពុងតែ មានឈ្មោះល្បីល្បាញពេញបន្ទុកនោះ ។

វេលានោះអ្នកជម្ងឺនេះ នៅជាកុមារនៅឡើយ ឪពុកគេស្លូតត្រង់ដូចជាអ្នកស្រែបាននាំគេមក សក់គេវែងហើយបានបងប្រុសអៀវលើខ្នងពីភ្នំមក ។ គេមានបូសខ្ទុះដ៏ធំមួយនៅជើងរបស់គេ ហើយមកសុំអោយគ្រូពេទ្យព្យាបាលអោយ ។

គ្រួសារនោះបានបន្ទប់មួយនៅក្នុងផ្ទះគ្រូពេទ្យ ព្រោះគេបារម្ភដោយនៅវេលាវះកាត់នឹងមានឈាមចេញច្រើន ណាមួយអ្នកជម្ងឺជាកូនក្មេងតូចផងត្រូវការអោយមានសុខភាពល្អមាំទាំ ។ ជាដំបូងគេតម្រូវអោយកុមារហុតស៊ុតឆៅ

មួយថ្ងៃ ៣ រួចហើយបិទកៅអៀកជាប្រចាំពីលើមុខរបួស ដើម្បីកុំអោយមានការបារម្ភខ្លាចវាឡើងខ្លាំងទៅជាយឺតពេល ។

វេលាបកកៅអៀក ឪពុក ឬបងប្រុសគេ ឬអ្នកដែលនៅជិតៗនោះជួយទាញបកអោយ ។ ដោយកៅអៀកនោះស្អិតជាប់ស្បែកពិបាកទាញ កុមារតែងតែឈឺហើយចុកចាប់ស្រែកទ្រហោយំ ។ ប៉ុន្តែនៅពេលដែលអ្នកស្រីម្ចាស់មកជិត ហើយបកអោយវា វាខំទ្រាំខាំមាត់សង្កត់ធ្មេញនៅស្ងៀម ។

ឯគ្រូពេទ្យដែលសន្យាថានឹងវះបូសអោយនោះ ចេះតែរកលេសគេចវេះដោយយកហេតុផលថា ខ្លួនគាត់ចាស់កំលាំងខ្សោយហើយចេះតែលើកថ្ងៃមួយទៅថ្ងៃមួយថ្ងៃជាមួយថ្ងៃ ។

ឪពុកកុមារឆ្លាតដែរ ក៏ទុកតែកូនប្រុសច្បងអោយនៅមើលប្អូនឯខ្លួនគាត់ក៏ទៅភ្នំមុនក៏រលះរលាំងស្លៀកពាក់ខោអាវ ពាក់ស្បែកជើងហើយក្រាបសំពះព្រះធរណី អោយជួយស្រោចស្រង់ជីវិតកូនប្រុសគាត់ទី ២ អោយបានរស់រានមានជីវិតហើយចេញទៅបាត់ទៅ ។

ទោះជាឪពុកទៅបាត់ហើយក្តី ក៏ការវះកាត់ពុំឃើញប្រព្រឹត្តទៅសោះ ។ ៧ថ្ងៃក្រោយមក យុវជនបងដែលមានភារៈកិច្ចនៅកំដរប្អូន ក៏យកលេសថាដល់រដូវច្រូតកាត់ហើយ ហើយខ្លួនជាកូនច្បងត្រូវតែទៅជួយឪពុកម្តាយ ដែលរវល់ហើយត្រូវការជំនួយជាដៃជាជើង ដែលទោះជាមាន ៨-៩ ក៏មិនគ្រប់គ្រាន់ ។ ដូច្នេះគេមិនអាចទម្រេទម្រន់នៅទីនេះបាន ក៏លួងលោមប្អូនប្រុសថា ឯងត្រូវ

ចេះទ្រាំមិនត្រូវយំទេ ហើយគេក៏ចាកចេញពីផ្ទះគ្រូពេទ្យទៅទៀតទៅ ។ បន្ទាប់មកកុមារក៏នៅតែម្នាក់ឯង ។ វេលាដែលស្រាវជ្រាវមើលអាយុគេក្នុងបញ្ជីជាតិក៏ឃើញថាគេមានអាយុ៦ឆ្នាំ ។ វាមិនសមឪពុកអាយុ៦០ បើមានកូនអាយុ២០ គេនឹងតម្រូវអោយកូននោះទៅបំរើកងទ័ព ។ ប្រហែលជាគាត់គិតបែបនេះក៏ពុំដឹង ឬមួយច្រឡំក៏មិនដឹងអាយុកុមារនេះ ខុសពីអាយុមែនទែន ៥ឆ្នាំ តាមពិតគេមានអាយុ ១១ឆ្នាំហើយ ។

ដោយគេរស់នៅតែក្នុងព្រៃក្នុងភ្នំបែបនេះ គេក៏ភ្លេចភាសា ប៉ុន្តែដោយជាក្មេងមានបញ្ញា គេអាចដឹងបានថាស៊ុត ដែលគេហុតរាល់ថ្ងៃបានក្លាយទៅជាឈាមជាសាច់របស់គេ រង់ចាំទំរាំដល់ថ្ងៃវះកាត់ ។ គេដឹងថាការវះកាត់ឈឺ ហើយតែងតែពេប ប៉ុន្តែនឹកដល់សម្ដីបងប្រុស ដែលផ្ដាំកុំអោយយំអោយខំទ្រាំ គេបានខំទ្រាំអត់ ។

ដោយសេចក្ដីអាណិតមេត្តា អ្នកស្រីម្ចាស់តែងតែរៀបចាយរៀបទឹកអោយគេទទួលទានជាមួយនឹងគ្រួសារនាង ហើយគេតែងតែកាន់ឆៃប៉ូវអង្កៀមនៅកៀនជញ្ជាំងមើលទៅគួរអោយសង្វេគពន់ពេក ។

នៅយប់មុនថ្ងៃវះកាត់ ហើយមនុស្សម្នាទាំងឡាយនាំគ្នាដេកលង់លក់ស្ងប់ស្ងាត់ កុមារតូចបានលួចពួនយំស្ងាត់ៗតែម្នាក់ឯង ។ អ្នកស្រីម្ចាស់បានឃើញកុមារនៅពេលដែលនាងចេញទៅបត់ជើងតូច ក៏អាណិតខ្លោចចិត្តហើយឱបក្រសោបវារួចផ្ដេកវាអោយគេង ។

នៅថ្ងៃវះអ្នកស្រីម្ចាស់បានបីវា ហើយនៅពេលដែលពេទ្យវះវា កុមារនៅស្ងៀមអត់ទ្រាំខាំមាត់សង្កត់ចិត្តអត់យំមួយអ៊ឹះទេ ។

ប៉ុន្តែការវះកាត់នោះពុំដឹងជាប៉ះត្រូវអ្វី ច្រឡំត្រង់ណាឈាមបានហូរឥតឈប់ក្នុងមួយសន្ទុះសោះ មុខកុមារក៏ទៅជាស្វាយឥតឈាមដូចសាកសព ។

ឯគ្រូពេទ្យក៏ឡើងមុខខ្មៅប៉ែរដែរ ។ វេលានោះផ្ទះពេទ្យទាំងមូលមានការវឹកវរ ច្រួលច្របល់មួយរយៈ ។ តែជាសំណាងល្អ តើអោយថាជាមន្តអាគមរបស់ព្រះជាម្ចាស់ក៏មិនដឹង កុមារមិនបាត់បង់ជីវិតទេ ហើយក្នុងរយៈពេល ៣ថ្ងៃ ឈាមក៏ឈប់ហូរ តែតួថគេទៅជាធ្ងន់ គេបានក្លាយជាមនុស្សខ្វិន ។

កុមារដើរដោយអូសជើងរបស់គេ នៅពេលដែលគេមើលទៅជើងរបស់គេ គេធ្វើមុខគួរអោយអាណិត ហាក់ដូចជាកណ្តួបដែលត្រូវគេកាច់ជើង ហើយបៀមជើងនោះ នៅក្នុងមាត់របស់ខ្លួនយ៉ាងនោះមើលទៅគួរអោយអនិច្ចា ហើយសឹងតែថា មិនអាចយកភ្នែកទៅមើលបានឡើយ ។

ពេលធ្វើមុខដ៏គួរអោយអាណិតរួចហើយ ចុងបញ្ចប់កុមារដ៏ស្រែកយំ ។ ដោយខ្លាចពាក្យចចាមអារាមផង គ្រូពេទ្យទៅជាវង្វេងវង្វាន់គាត់សម្លក់កុមារដោយទឹកមុខគួរអោយខ្លាច ។ អ្នកស្រីម្ចាស់អាណិតកុមារលើកវាបីពរ វាក៏ជ្រប់មុខនៅក្នុងទ្រូងរបស់នាង ។

ឯគ្រូពេទ្យដែលតែងតែព្យាបាលអ្នកជម្ងឺដ៏ច្រើន បានគិតហើយបានទទួលស្គាល់ថាខ្លួនគាត់បរាជ័យក្នុងការព្យាបាលអ្នកជម្ងឺ ក៏ដកដង្ហើមធំ ។

លុះដល់វេលាដែលឪពុកកុមារមកទទួលកុមារយកទៅវិញ ហើយឃើញកូនខ្ញិនបែបនេះ គាត់បានគិតថាជាកម្មផលដែលបានសាងពីអតីតជាតិ ហើយគាត់ពុំមានថាអ្វីខ្លាំងក្លាអោយគ្រូពេទ្យទេ ហើយម្យ៉ាងទៀតដោយកូនប្រុសបន្ទាប់គាត់នេះតោងដៃអ្នកស្រីម្ចាស់ស្អិតមិនព្រមលែងផង គ្រូពេទ្យក៏បានលេសហើយលួងលោមគ្រួសារ កុមារថាគាត់នឹងអោយបុត្រីគាត់នាំកុមារទៅជូនដល់ផ្ទះកុមារ ។

ហើយផ្ទះដែលអ្នកស្រីម្ចាស់នាំកុមារទៅនោះគឺផ្ទះមួយខ្នងនោះឯង ។

នៅវេលានោះគឺជាភូមិមួយ ដែលមានផ្ទះប្រហែលជា ២០ខ្នង ។ ពេលដែលអ្នកនាងបានមកដល់មួយថ្ងៃពីរហើយនៅសំរាកទីនោះ ។ នៅប្រហែលជាថ្ងៃទី៥ក៏មានភ្លៀងធំមួយ បង្អុរមកដូចគេចាប់ជ្រោះផ្កាប់អត់ឈប់ឈរទាល់តែសោះ ។ អ្នកភូមិរកអាវភ្លៀង ពោង ទូក មូកដែក ហើយសម្ងំស្ងៀមមិនទាំងហ៊ានចេញទៅជួសជុលដំបូលស្បូវព្រមទាំងមិនហ៊ានទាំងបើកទ្វារផង ។ គេអើតពីក្នុងផ្ទះស្រែកសួរសុខទុក្ខអ្នកជិតខាង ហើយគិតថាអោយតែរស់រានមានជីវិតក៏គ្រប់គ្រាន់ហើយមិនចង់បានអ្វីអោយលើសនេះទេ ។

ភ្លៀង ៨ថ្ងៃប្រៀបបានដូចជា៨០០ឆ្នាំ ។ នៅពេលដែលអ្នកភូមិខំទ្រាំរស់នៅក្នុងទឹកភ្លៀងបែបនេះបាន ៨ថ្ងៃហើយ នៅថ្ងៃទី ៩ វេលាយប់កណ្ដាលអាធ្រាត្រមានខ្យល់ព្យុះដ៏ធំមួយ បានបក់បោកមកហើយខ្នងភ្នំទាំងមូល បានក្លាយទៅជាសមុទ្រភក់ ។

ដោយសារតែទឹកជំនន់នេះ មនុស្សសត្វជាច្រើនបានបាត់បង់ជីវិត ប៉ុន្តែអស្ចារ្យណាស់អ្នកស្រីម្ចាស់ និង កុមារពិការព្រមទាំង តាចាស់ដែលជូនដំណើរនាងពីភូមិមក បានគេចផុតពីមហន្តរាយនេះបាន ។

ហើយផ្ទះគ្រូពេទ្យឪពុកម្តាយនាង ក៏បានលិចលង់ហើយស្លាប់អស់មួយគ្រួសារនោះទៅ ។ អ្នកស្រុកបាននិយាយតៗគ្នាថា នារីរូបនេះបានចុះមកចាប់បដិសន្ធិដើម្បីកែប្រែសង្គមភូមិស្រុក និង សម័យកាល ។

ដោយអ្នកនាងម្ចាស់ពុំមានទីកន្លែងសំរាប់វិលត្រឡប់ទៅវិញ នាងក៏រស់នៅជាមួយ និង កុមារដែលត្រូវមាតាបិតាបងប្អូនស្លាប់ចោលអស់ ហើយរស់ក្បាលមកម៉ង់ៗ ដែលលោកសង្ឃបានឃើញនោះឯង ។ ហើយនាងតែងតែមើលថែទាំយុវជនមិនគ្រប់ទឹកនោះបែបនេះ ដរាបមកតាំងពីពេលមានទឹកជំនន់នោះមក គឺរយៈពេល ១៣ឆ្នាំ ហើយ ឥតមានកែប្រែ ប្រែប្រួលមួយថ្ងៃណាឡើយ ។

ថាហើយតាចាស់ក៏ចាប់សើចនូវសំណើចដ៏គួរអោយព្រឺក្បាល ។

- តិចលោកតែងពួតានិយាយបែបនេះ ហើយមានចិត្តអាណិតអ្នកស្រីម្ចាស់ សុំខ្លួនទៅកាប់អុស រែកទឹកជួយនាងតាមមេត្តាធម៌ចុះ ។ កូនលោកឯងយកពាក្យមេត្តាករុណានេះ ដើម្បីបំបិទបំបាំងទឹកចិត្តស្នេហាចំពោះស្ត្រីបែបនេះមិនបានទេ ។

អ្នកស្រីម្ចាស់បានទៅជាប្រពន្ធរបស់បុរសមិនគ្រប់ទឹកហើយ រស់នៅលាក់កំបាំងខ្លួនពីផុតពីភ្នែកពីច្រមុះរបស់មនុស្សម្នាទាំងឡាយមែន ប៉ុន្តែជាថ្នូរនាងអាចជ្រើសរើសបុរសភេទតាមចិត្តនាងចង់ ។ ហើយនាវេលាដែលនាងលែងត្រូវការបុរសនោះ នាងផ្តិតែមួយផែតទៅបុរសនោះ នឹងក្លាយទៅជាសត្វជាធាតុក្នុងមួយប៉ប្រិចនោះ ។

ទឹកជំនន់ប្រៀបបានដូចជាទទួលបញ្ជាពីមេឃ អោយទាញបុរសទាំងឡាយមកអោយជួបអ្នកនាង។ គឺជាទឹកដ៏គួរអោយខ្លាចមិនអាចជឿបាន ។ ហើយបើបានមកដល់ហើយ គ្មាននរណាម្នាក់បានរស់រានមានជីវិតត្រលប់ទៅ វិញទេ ។

ឯអ្នកនាងម្ចាស់វិញ នៅពេលដែលនាងមានទុក្ខទាំងបី គឺទុកសក់ខ្ចិចខ្ចីបាត់បង់សណ្តាប់ធ្នាប់ ពណ៌សម្បុរឡើងស្លេកស្លាំង ខ្លួនប្រាណដៃជើងដើមទ្រូងឡើងស្គមស្គាំង បើនាងបានចូលទៅងូតទឹកនោះ នាងនឹងវិលត្រលប់ទៅរកសភាពសុខសប្បាយដូចដើមវិញ មិនខានឡើយ ។

បើគ្រាន់តែធ្លាក់ ហើយនាងគ្រាន់តែបោយដៃហៅសូម្បីតែត្រីដែលកំពុងតែហែលទឹកក៏ហែលមកជិតនាង ហើយបើនាងសំឡក់វិញសូម្បីតែផ្លែផល្លាដែលស្រស់ថ្មីជាប់នឹងទងសោះ ក៏នឹងធ្លាក់មកក្រោមភ្លាម បើនាងទទះដៃអាវភ្លៀងនឹងធ្លាក់ ហើយបើនាងញោចចិញ្ចើមខ្យល់នឹងបក់ ។

លើសពីនេះទៅទៀត នាងដូចជាមានធម្មជាតិពីកំណើតអោយចូលចិត្តប្រុស១តែម្តង ជាពិសេសបុរសក្មេង១ដូចយ៉ាងកូនលោកឯងនេះ ។ ហើយដល់នាងឈប់ស្រលាញ់បុរសនឹងកំរើកត្រចៀក ដុះកន្ទុយ ជើងលូនវែង រូបរាងក៏ ប្រែប្រួល ។

ឱ ! តាចង់អោយតែកូនលោកឯងឃើញពេលនាងពែនភ្នែនពិសាត្រីរស់ក្លែមស្រាទេ រូបរាងនោះមិនខុសពីអ្នកតាញីធៀងខ្មៀងឡើយ ។

ចូរកូនលោកឈប់មានគំនិតរវើរវាយឥតបានការបែបនេះ ហើយឆាប់ចាកចេញពីទីនេះភ្លាមទៅ ។ អ្នកឯងបានរស់រានមានជីវិតនេះសូមគិតថាជាមហាសំណាងមួយក្នុងមហាចង្រៃមួយរយទៅ ។ នេះគឺជាការប្រោសប្រណីជាពិសេសនៃអ្នកស្រីម្ចាស់ហើយ ។ ជីវិតអ្នកថ្លៃណាស់ អ្នកនៅក្មេងមែនតែនេះគឺផលបុណ្យដែលអ្នកបានកសាងមកតាមមកជួយអ្នកហើយ ។

ថាហើយគាត់ក៏យកដៃគាត់មកគោះខ្នងអាត្មាម្តងទៀត រួចក៏ស្ពាយត្រីរស់ដើរចេញគ្មានងាកក្រោយឡើងភ្នំទៅបាត់ទៅ ។

វេលាដែលអាត្មាចាប់មើលគាត់ពីក្រោយ លុះត្រាតែស្រមោលគាត់ឡើងតូច ហើយកប់បាត់ទៅក្រោយជួរភ្នំបាត់ទៅ ពេលនោះផ្ទៃមេឃឡើងពណ៌រងើមដូចគេចាក់ប្រេងក្នុងទឹកហើយត្រូវកំសួលភ្លើង ។ ពីលើខ្នងភ្នំពពកបានចេញមកផុល១សម្លេងជ្រោះក៏ឡើងស្ងប់ស្ងាត់ ហើយផ្គរក៏លាន់ក្តុង១ ។

អាត្មាក្រោកឈរដោយគ្មានព្រលឹងនៅក្នុងខ្លួនមួយសន្ទុះ ។ ហើយនៅវេលាដែលព្រលឹងព្រលះនោះត្រឡប់មករកករូបរាងកាយអាត្មាវិញ អាត្មាបាន

លើកដៃសំពះទៅភ្នំយ៉ាងគោរព ហើយចាប់ឈើច្រត់ ផ្សៀងមូកឫស្សី បែរកែងជើងទៅភ្នំ ហើយប្រញាប់ដើរចុះទៅ ។

វេលាដែលអាត្មាបានទៅដល់ភូមិអ្នកស្រុក ភ្លៀងមួយមេបានបង្អុរចុះមក ។ ភ្លៀងនោះប្រៀបបានដូចជាធ្លាក់មកអោយដំណឹងអាត្មាថា តាចាស់បានធ្វើដំណើរទៅដល់ផ្ទះស្ត្រី ហើយបានជូនត្រីដ៏ស្រស់ទៅអ្នកស្រីម្ចាស់ហើយ ។

ព្រះសង្ឃនៃភ្នំ "កូយ៉ា" និទានរឿងអោយខ្ញុំស្តាប់តែប៉ុណ្ណោះ លោកពុំបានទូន្មានប្រៀនប្រដៅ ឬទាញជាគំនិតអ្វីមកអោយរូបខ្ញុំយកមកធ្វើជាមេរៀនឡើយ ។

ព្រឹកស្អែកឡើងលោកលាខ្ញុំទៅ ។ ខ្ញុំបានជូនដំណើរលោកទាំងសោកស្តាយ រហូតដល់ផ្លូវចោតនៃភ្នំ នៅពេលដែលមានព្រឹលធ្លាក់ចុះមកស្រិចៗ ។

ស្រមោលដ៏គួរអោយគោរពរបស់លោក បានរលាយចូលជាមួយនឹងពពក ទៅជារូបភាពដ៏វិចិត្រមួយ ៕

ករុណាខ្មែរ

CAMBODIAN • EDUCATION • EXCELLENCE

មូលនិធិខ្មែរសម្រាប់ការសិក្សា

FOUNDATION



អ៊ីស៊ីមី គ្យោកា

# ជីវប្រវត្តិអ្នកនិពន្ធ

កើតនៅថ្ងៃទី ១១ ខែ ៤ ឆ្នាំ ១៨៧៣ នៅខេត្តកាណាសាវ៉ា ។ មានបងប្អូន ៤ នាក់ ដែលលោកជាកូនច្បង ។

នៅកំណើតកូនទី៤ មាតាលោកក៏ទទួលអនិច្ចកម្មទៅ ដែលពេលនោះលោកទើបតែមានអាយុ៩ឆ្នាំ ។

អ៊ីស៊ីមី គ្យោការៀនបានត្រឹមថ្នាក់ទី ៩ ក៏ឈប់ ហើយទៅរៀនសរសេរប្រលោមលោកនៅសំណាក់លោក អូសាគីកូយោ ដែលជាអ្នកនិពន្ធដ៏ល្បីល្បាញនៅជំនាន់នោះ ។

គ្យោកា បានបន្សល់ទុកនូវស្នាដៃដ៏ច្រើនហើយបានទទួលមរណភាពនៅអាយុ៦៦ឆ្នាំ ។

ចេញផ្សាយដោយ សមាគមន៍ជំនួយវប្បធម៌អាស៊ីអាគ្នេយ៍

This book is printed by the assistance of **Soya**